ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ យុត្តិធម៌ដែលប្រជាជនកម្ពុជាសមនឹងទទួលបាន

◆ ខៀវ សំផន ចង់បានគណៈកម្មការស្វែងរកការពិត

លេខ៨៤ ខែ ធ្នូ ឆ្នាំ២០០៦

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៦ ខែធ្នូ ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រ៖ យុត្តិធម៌ដែលប្រជាជនកម្ពុជាសមនឹងទទួលបាន............១

**ផ្នែកឯកសារ**

◆ គម្រោងការសំខាន់ៗទាំងឡាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា....២

◆ វាសនាចុងក្រោយរបស់និស្សិតម្នាក់ ..................................១១

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស .......................................១៤

◆ ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម...........................................១៥

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ .......២១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ....................................២២

◆ ខែអកអំបុក ខ្ញុំព្រាត់ប្តី ..................................................៣២

◆ នឿន នាលៈ លោហិតព្រះយេស៊ូសម្អាតគ្រប់អំពើបាប...........៣៤

**ផ្នែកច្បាប់**

◆ រដ្ឋធម្មនុញ្ញទាំងឡាយ នៅកម្ពុជា .........................................៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ អតីតកាលមិនជ្រះស្រឡះប៉ះពាល់ដល់នីតិរដ្ឋ..........................៥២

◆ យុត្តិធម៌អន្តរកាលនៅកម្ពុជា ............................................៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ពាក្យបណ្តឹង ..................................................................៥៨

**សិល្បៈខ្មែរក្រហម**

◆ រូបថតខ្មែរក្រហម...............................................គ្របក្រោយ




ប្រជាជនឃុំព្រៃធំនាំគ្នាដឹកជញ្ជូនសាកសពយកទៅដាក់ក្នុងសារមន្ទីរ ឆ្នាំ១៩៨១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩
រូបថតគ្របមុខដោយៈ ចូសេហ្វ កុហ្វម៉ាន់
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះៈ** ហ៊ុយ វណ្ណៈ, យិន នាន, លឿង អ៊ឹង, គីម កែវកន្និដ្ឋា, វ៉ាអ៊ូល ដែន័រ, ស៊ូហ្សាណា លីនគុន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** សួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** ស៊ឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រ៖*

# យុត្តិធម៌ដែលប្រជាជនកម្ពុជាសមនឹងទទួលបាន

ការបង្កើតឲ្យមានតុលាការឯករាជ្យមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានការទទួលខុសត្រូវក្នុងការធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់ស្លាប់បាត់បង់ជីវិត គឺជាការស្ដាបនាគ្រឹះយុត្តិធម៌ លើកកម្ពស់សិទ្ធិមនុស្ស និងអភិវឌ្ឍកម្ពុជា ។ តុលាការនេះទៀតសោតនឹងជាវិធីតែម្យ៉ាងគត់ដែលអាចផ្សះផ្សាសង្គមកម្ពុជាទាំងមូលឲ្យបានពេញលេញ ។

ប្រសិនបើពុំមានការកាត់ទោសមេដឹកនាំខ្មែរក្រហមទេនោះ តើវានឹងមានប្រយោជន៍អ្វីក្នុងការវិនិច្ឆ័យបទឧក្រិដ្ឋតូចតាចក្នុងសង្គមកម្ពុជាបច្ចុប្បន្ន? បញ្ហានេះទៀតសោតនឹងបន្តឲ្យប្រជាជនគ្មានទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌សង្គមជារៀងរហូត ដែលជាគន្លឹះដ៏សំខាន់ដើម្បីអភិវឌ្ឍសង្គមកម្ពុជា ។

មេដឹកនាំខ្មែរក្រហមតែងតែពោលថា ខ្លួនមិនបានប្រព្រឹត្តអំពើទាំងឡាយដែលបានធ្វើឲ្យប្រជាជនកម្ពុជាទូទាំងប្រទេសលំបាកវេទនា ស្លាប់បងស្លាប់ប្អូន ព្រាត់ប្រាសប្រពន្ធប្ដី ហើយខ្លះទៀតធ្លាក់ខ្លួនពិការអស់មួយជីវិតនោះទេ ។ ប្រសិនបើពិតជាដូច្នេះមែន តើមានអ្វីគួរឲ្យខ្លាចរអាក្នុងការចូលខ្លួនមកក្នុងតុលាការឯករាជ្យមួយដើម្បីស្រាយបំភ្លឺបញ្ហានេះ? ប្រជាជនកម្ពុជាដែលជាសាក្សីរស់ និងឯកសារជាច្រើន បានត្រៀមរួចជាស្រេចដើម្បីឆ្លើយបំភ្លឺចំពោះមុខតុលាការ ។ ឯកសារដ៏សំខាន់មួយគឺទីតាំងរណ្ដៅសាកសពជនរងគ្រោះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្ដើមចុះស្រាវជ្រាវរកទីតាំងវាលពិឃាតចាប់តាំងពីឆ្នាំ១៩៩៥មកម្ល៉េះ យ៉ាងលំបាកលំបិន និងជាញឹកញយគួរឲ្យអស់សង្ឃឹមទៀតផង ។ យោងតាមកិច្ចសម្ភាសន៍និងការរុករកដល់ទីតាំង យើងបានរកឃើញរណ្ដៅសាកសពរួមមានចំនួនរហូតដល់ទៅជាង១ម៉ឺនរណ្ដៅ (១៩.៤៤០) គុកចំនួន១៦៧កន្លែង ដែលដំណើរការនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះចំនួន៧៧កន្លែង សាងសង់ឡើងដោយអ្នកដែលនៅរស់រានមានជីវិតចាកផុតអំពីរបបខ្មែរក្រហម ។ ទីតាំងជាច្រើនក្នុងចំណោមទីតាំងទាំងអស់នេះមានផ្ទុក (ឬធ្លាប់ផ្ទុក) នូវសាកសពជនរងគ្រោះរាប់ម៉ឺននាក់ ហើយមាននៅទូទាំងស្រុកទាំង១៧០ និងស្ទើរតែគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងខណៈដែលអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជានៅតែមិនទាន់មានលទ្ធភាពនិងសុឆន្ទៈយល់ព្រមលើនីតិវិធីក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម រណ្ដៅសាកសពរួមជាច្រើនពាន់ ព្រមទាំងគុកជាច្រើនដែលភាគច្រើននៅសេសសល់ឧបករណ៍ធ្វើទារុណកម្មនៅឡើយនោះ ធ្វើឲ្យយើងនឹកដល់ការចាំបាច់ក្នុងការបង្កើតឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់ ។ ទម្រង់គុកនិងរណ្ដៅសាកសពរួមដែលមានលក្ខណៈដូចៗគ្នា ព្រមទាំងដំណើររឿងផ្ទាល់របស់សាក្សីដែលនិយាយចេញមកប្រហាក់ប្រហែលគ្នានៅទូទាំងប្រទេស ជាភស្តុតាងបញ្ជាក់នូវការអនុវត្តជាលក្ខណៈប្រព័ន្ធនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏គួរឲ្យរន្ធត់ ដែលរួមមាន ទារុណកម្ម មនុស្សឃាត និងការចាប់ចងឃុំឃាំងស្រេចតែអំពើចិត្ត ប្រព្រឹត្តឡើងក្រោមការដឹកនាំរបស់មេដឹកនាំខ្មែរក្រហម ។

ក្រៅពីរណ្ដៅសាកសពរួមនិងគុកដែលបានបញ្ជាក់ឲ្យឃើញនូវទំហំឧក្រិដ្ឋកម្មដែលមិនអាចនឹកស្មានដល់ ប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមនោះ មានសក្ខីភាពបញ្ជាក់ពីសេចក្ដីក្លាហាននិងការក្រោកឡើងវិញរបស់អ្នកដែលរស់រានមានជីវិតផុតពីរបបខ្មែរក្រហម ។ ក្រៅពីទីតាំងជាច្រើនដែលកើតមានអំពើឃោរឃៅជនរងគ្រោះដែលមានជីវិតបានសាងសង់ជាបូជនីយដ្ឋាន ដើម្បីឧទ្ទិសបូជាដល់ក្រុមគ្រួសារបងប្អូនញាតិមិត្តជាទីស្រលាញ់របស់ខ្លួនដែលបានលាចាកលោកនេះទៅ និងជាការរំឭកដល់សេចក្ដីលំបាកវេទនារបស់ខ្លួនកាលពីរបបខ្មែរក្រហម ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នឹងជួយឲ្យប្រជាជនកម្ពុជាដឹងច្បាស់អំពីយុត្តិធម៌និងការផ្សះផ្សាជាតិដែលខ្លួនសមនឹងទទួលបាន ។

**ឆាំង យុ**

# គម្រោងការសំខាន់ៗទាំងឡាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ឆ្នាំ២០០៣

អត្ថបទនេះបកស្រាយអំពីគម្រោងការនិងសកម្មភាពចម្បងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានគ្រោងទុកសម្រាប់ឆ្នាំ២០០៣ ។ ការងារគ្រោងទុកជាមុនទាំងនេះបង្ហាញពីការចម្រើនលូតលាស់នៃការងារបច្ចុប្បន្នរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងអភិវឌ្ឍបន្ថែមនិងបង្ហាញឲ្យកាន់តែច្បាស់នូវប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ផ្សព្វផ្សាយពត៌មានទាំងនេះទៅឲ្យសាធារណជនបានដឹង និងជំរុញឲ្យមានការទទួលខុសត្រូវនិងការផ្សះផ្សាជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការងារគ្រោងទុករបស់យើងសម្រាប់ឆ្នាំ២០០៣ មានសារសំខាន់ខ្លាំងណាស់ ប្រសិនបើយើងសម្រេចឲ្យបាននូវគោលដៅនេះ យើងនឹងអាចបំពេញនូវតម្រូវការដែលចេះតែកើនឡើង ដែលទាមទារដោយបញ្ញាជន រដ្ឋាភិបាលជាតិនិងអន្តរជាតិ អង្គការនានា និង សាធារណជនទូទៅ ។

## គម្រោងការចងក្រងឯកសារ

នៅក្នុងឆ្នាំ២០០៣ គម្រោងការចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តផ្តោតការយកចិត្តទុកដាក់ទៅលើការប្រមែប្រមូលនូវឯកសារថ្មីៗបន្ថែមទាំងនៅក្នុងប្រទេសកម្ពុជានិងនៅឯបរទេស ហើយពង្រីកបន្ថែមនូវគន្ថនិទ្ទេសនិងទិន្នន័យប្រវត្តិរូប ដោយបន្ថែមល្បឿនទៅលើការបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ ។ ទិន្នន័យប្រវត្តិរូបផ្ទុកនូវពត៌មានពិស្តារដែលទាក់ទងទៅនឹងមេដឹកនាំនិងកម្មាភិបាលខ្មែរក្រហម ។ នៅក្នុងអំឡុងឆ្នាំ២០០១និង២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចប់នូវការបង្កើនកម្រិតដ៏ធំមួយទៅលើទិន្នន័យប្រវត្តិរូប ដោយមានបញ្ចូលប្រវត្តិរូបចំនួន១០៨១២ ជាភាសាខ្មែរនិងអង់គ្លេស ។ សម្រាប់គន្ថនិទ្ទេសឯកសារ ការយកចិត្តទុកដាក់ជាចម្បងរបស់យើងកាលពីឆ្នាំមុន គឺទៅលើឯកសារកងឈ្លបខ្មែរក្រហម ។ ឯកសារគន្ថនិទ្ទេសចំនួន១០៦១២ នៃឯកសារសរុបមានចំនួន ២៨៦៩១ ត្រូវបានចងក្រងនិងកែសម្រួលរួចរាល់ក្នុងខែកញ្ញា ឆ្នាំ២០០២ ។ យើងនឹងចាប់ផ្តើមបញ្ចូលទិន្នន័យសម្រាប់ការបង្កើនកម្រិតនៃគន្ថនិទ្ទេសឯកសារក្នុងខែធ្នូ ឆ្នាំ២០០៥ បន្ទាប់ពីការងារបង្កើនកម្រិតគន្ថនិទ្ទេសប្រវត្តិរូបត្រូវបានបញ្ចប់ ។

ដៃគូរបស់យើងតាំងពីយូរណាស់មកហើយ គឺកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃសាកលវិទ្យាល័យយែល ដែលបានបញ្ឈប់ដំណើរការរបស់ខ្លួននៅខែវិច្ឆិកា ឆ្នាំ ២០០១ ប៉ុន្តែយើងនៅតែបន្តចរចាជាមួយសកលវិទ្យាល័យនេះ ដើម្បីស្នើសុំសិទ្ធិរួមបញ្ចូលពត៌មាននៅក្នុងទិន្នន័យដែលមានស្រាប់ទៅក្នុងគម្រោងការមួយឲ្យកាន់តែធំនិងយូរអង្វែងជាងមុន ។ គម្រោងការនេះមានគោលដៅចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យកាន់តែពិស្តារថែមទៀត ។ បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់ដែលមិនទាន់បានរៀបចំចងក្រង រួមមានដូចជារូបថត៤១៨៣សន្លឹក (រៀបចំហើយចំនួន៦៣៧៦) និងឯកសារចំនួនជាង៩៥០០០ទំព័រ ។

## គម្រោងការបង្កើតផែនទី ទីតាំងរណ្តៅសាកសពជនរងគ្រោះ

រហូតមកដល់បច្ចុប្បន្ន យើងបានស្រាវជ្រាវរកឃើញរណ្តៅសាកសព អតីតគុកខ្មែរក្រហម និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុស្ថិតនៅក្នុងស្រុកទាំង១៧០និងនៅស្ទើរគ្រប់ខេត្តទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ទីតាំងភាគច្រើនមាន(ឬធ្លាប់មាន) ផ្ទុកសាកសពរបស់ជនរងគ្រោះរាប់ពាន់នាក់ ។ នៅក្នុងឆ្នាំ២០០៣ យើងមានគម្រោងនឹងបន្តស្រាវជ្រាវរកទីតាំងថ្មីៗបន្ថែមទៀតនៅក្នុងតំបន់ដែលពីមុនមកមិនទាន់បានចុះទៅស្រាវជ្រាវនៅឡើយ រួចហើយ បញ្ចូលទីតាំងថ្មីៗទាំងនោះទៅក្នុងទិន្នន័យកុំព្យូទ័ររបស់យើង ។ ទិន្នន័យនេះមិនមានដាក់ផ្សាយនៅក្នុងប្រព័ន្ធអ៊ីនធឺនែតនៅឡើយទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងខិតខំបន្តធ្វើការងារនេះដោយពឹងផ្អែកទៅលើការស្វែងរកដោយខ្លួនឯងនិងការសម្ភាសន៍ជាមួយអ្នកស្រុកអ្នកភូមិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែរៀបចំគម្រោងសម្រាប់ចុះស្រាវជ្រាវ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តគម្រោងការធ្វើកោសល្យវិច័យសាកសពជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម

ដោយមានកិច្ចសហការជាមួយបណ្ឌិត ម៉ៃឃើល ប៉ូលានិន (អ្នកជំនាញការផ្នែករោគសាស្ត្រកោសល្យវិច័យ) បណ្ឌិត ខាសារិន ហ្វ្រុសស្ពៀរ (អ្នកជំនាញការខាងផ្នែកនរវិទ្យា) និងបណ្ឌិត ក្រេក អេចឆេសាន់ (អ្នកជំនាញការខាងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ) ។ គម្រោងការនេះទាក់ទិនទៅនឹងការធ្វើកោសល្យវិច័យទៅលើសាកសពជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ហើយមានគោលដៅប្រមែប្រមូលទិន្នន័យសម្រាប់ធ្វើកោសល្យវិច័យពីលក្ខណៈនៃការសម្លាប់ជាទ្រង់ទ្រាយធំនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ ដំណាក់កាលទី១នៃគម្រោងការនេះត្រូវបានបញ្ចប់នៅខែមីនានិងខែមេសា ឆ្នាំ២០០២ ។ នៅក្នុងដំណាក់កាលនេះបានរួមបញ្ចូលទាំងការវាយតម្លៃ ភាពដែលអាចធ្វើទៅបាននៃការវិភាគទៅលើឆ្អឹងដែលនៅសេសសល់ក្នុងរណ្តៅសាកសព និងអដ្ឋិធាតុតម្កល់ទុកក្នុងបូជនីយដ្ឋាន ។ ដំណាក់កាលទីពីរ គឺជាការពិនិត្យយ៉ាងប្រុងប្រយ័ត្នទៅលើរណ្តៅសាកសព ដើម្បីស្វែងរកទីតាំងថ្មីៗសម្រាប់ការវិភាគពេញលក្ខណៈ និងការប្រមែប្រមូលនិងអភិរក្សនូវគំរូនៃសំណល់ឆ្អឹងដែលមានបង្ហាញពីស្លាកស្នាមរបួស ។ ដំណាក់កាលទីបី គឺវិភាគទៅលើគំរូឆ្អឹងឲ្យបានក្បោះក្បាយ ដោយប្រើប្រាស់វិធាននៃការវិភាគច្រើនបែប ។

នៅពេលដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាមិនចុះសម្រុងគ្នាទៅលើរបៀបរបបបង្កើតតុលាការខ្មែរក្រហម រណ្តៅសាកសពរាប់ពាន់ និងគុកកម្ពុជាប្រជាធិបតេយ្យដ៏ច្រើនសន្ធឹកសន្ធាប់ (ភាគច្រើននៅសេសសល់ឧបករណ៍សម្រាប់ធ្វើទារុណកម្មដ៏ឃោរឃៅ) ដែលបានរកឃើញ ដាស់អារម្មណ៍ដល់យើងទាំងអស់គ្នាថា ការដាក់ឲ្យមានការទទួលខុសត្រូវ ត្រូវតែធ្វើឲ្យបាន ។ រណ្តៅសាកសពធំៗ និងទីតាំងផ្សេងទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញ ជាភស្តុតាងយ៉ាងសំខាន់សម្រាប់បង្ហាញនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយបក្សកុម្មុយនិស្តកម្ពុជា ។ ទីតាំងកប់សាកសពនិងអគារឃុំឃាំងជាច្រើនបង្ហាញថាវាមិនគួរឲ្យជឿ ហើយជាការមិនសមហេតុផលទាល់តែសោះ ដែលថាគ្មានមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យណាម្នាក់បានដឹងពុថាសមាជិកបក្សមួយចំនួនកំពុងតែប្រព្រឹត្តនូវអំពើឃាតកម្មក្នុងទ្រង់ទ្រាយធំ និងអំពើឧក្រិដ្ឋផ្សេងទៀតនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឬក៏ចាត់វិធានការដើម្បីទប់ស្កាត់នូវអំពើទាំងនោះ ។ ធ្ងន់ធ្ងរជាងនេះទៅទៀត ទីតាំងរណ្តៅសាកសពនិងគុកទាំងឡាយ បង្ហាញយ៉ាងច្បាស់ថាអំពើឃោរឃៅរបស់បក្សកុម្មុយនិស្តកម្ពុជា ជាផ្នែកនៃគម្រោងដែលបានបង្កើតឡើងដោយចេតនាបញ្ជាឲ្យអនុវត្ត គាំទ្រ និងជំរុញដោយថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះគម្រោងការបង្កើតផែនទីទីតាំងរណ្តៅសាកសពនៃជនរងគ្រោះផ្តល់នូវហេតុផលខាងសីលធម៌និងពេញលេញសម្រាប់ជំរុញឲ្យមានការវិលត្រឡប់ទៅកាន់តុបរចាវិញ យល់ស្របគ្នាទៅលើយន្តការដែលនឹងនាំមកនូវយុត្តិធម៌គួរឲ្យទុកចិត្តបាន ទៅឲ្យជនរងគ្រោះដែលនៅរស់ពីសម័យខ្មែរក្រហម ហើយរួមចំណែកជួយកសាងប្រព័ន្ធច្បាប់ដ៏ពិសិដ្ឋនៅប្រទេសកម្ពុជា ។

## គម្រោងការថតឯកសារជាមីក្រូហ្វីល

នៅឆ្នាំ២០០៣ខាងមុខ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងបង្កើនល្បឿនថតមីក្រូហ្វីល ដែលអាចរក្សាឯកសារទុកបានយូរសម្រាប់ការប្រើប្រាស់នាពេលអនាគត ។ នៅឆ្នាំ២០០១ យើងថតមីក្រូហ្វីលបានចំនួន២៣៦ដុំ ហើយនៅក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ២០០២ យើងថតបន្ថែមបានចំនួន៧០ដុំ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយក៏យើងនៅតែមានឯកសារច្រើនទៀត ដែលត្រូវអភិរក្សជាចាំបាច់ ។ រយៈពេលកាន់តែយូរ គម្រោងការថតមីក្រូហ្វីលកាន់តែមានសារសំខាន់ ដោយហេតុថា ឯកសារខ្មែរក្រហមមួយចំនួនបានចាប់ផ្តើមទទួលរងការពុកផុយ ដោយសារអាយុកាល ។ ការហ្វឹកហ្វឺនបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០១និង២០០២ គួរតែធ្វើឲ្យយើងអាចថតមីក្រូហ្វីលក្នុងល្បឿនមួយកាន់តែលឿននៅក្នុងឆ្នាំ២០០៣ ហើយការងារនេះអាចប្រព្រឹត្តទៅបានលុះត្រាតែមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននូវការផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ ។ នៅឆ្នាំ២០០៣ យើងមានគម្រោងនឹងថតមីក្រូហ្វីលឲ្យបាន១២០ដុំ ដែលគិតជាចំនួនឯកសារមានចំនួន១៣១៨៤ សរុបទាំងអស់ស្មើនឹង៩៥០០០ទំព័រ ។

## គម្រោងការស្រាវជ្រាវ

នៅក្នុងឆ្នាំ២០០៣ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោង

បោះពុម្ពផ្សាយសៀវភៅមួយចំនួន និងអនុវត្តការចុះស្រាវជ្រាវថ្មីៗទៀត ដោយមានកិច្ចសហការរបស់អ្នកជំនាញការអន្តរជាតិ ។ សៀវភៅដែលកំពុងតែត្រូវបានសរសេរបញ្ចប់ ហើយនឹងត្រូវបោះពុម្ពផ្សាយនៅឆ្នាំ២០០៣រួមមានៈ សៀវភៅ «កងទ័ពខ្មែរក្រហមក្នុងកងពល៧០៣» របស់ ហ៊ុយ វណ្ណៈ, សៀវភៅ «ការបះបោររបស់ជនជាតិចាម» របស់ អ៊ីសា ឧស្មាន និងសៀវភៅ «ភាពភ័យរន្ធត់ចេញមកពីភូមិភាគនិរតី» របស់ អៀ ម៉េងទ្រី ។ ការសរសេរសៀវភៅផ្សេងទៀតទៅលើប្រធានបទ «កម្មាភិបាលកុមារនិងការអប់រំរបស់ខ្មែរក្រហមនៅស្រុកត្រាំកក់» «គិលានុបដ្ឋាយិកាខ្មែរក្រហម»«ជនជាតិភាគតិចក្នុងរបបខ្មែរក្រហម» និង «គ្រួសារជនជាតិវៀតណាមនៅភូមិពោធិចិនដាំ» ក៏កំពុងតែសរសេរបញ្ចប់ ហើយក៏ជាប្រធានបទសម្រាប់ការចុះស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវនៅឆ្នាំ២០០៣ ។ ប្រធានបទថ្មីៗបីគឺ «ខ្មែរកម្ពុជាក្រោមក្នុងរបបខ្មែរក្រហម» «ស្ត្រីដែលជាជនដៃដល់នៅក្នុងរបបខ្មែរក្រហម» និង «ការផ្សះផ្សាជាតិកម្ពុជា» ក៏កំពុងត្រូវចាប់ផ្តើមដំណើរការស្រាវជ្រាវដែរ ។ សំណើថ្មីមួយទៅលើការសិក្សាស៊ីជម្រៅអំពីព្រះពុទ្ធសាសនាក្នុងរបបខ្មែរក្រហមក៏កំពុងត្រូវរៀបចំឡើងឲ្យបានទូលំទូលាយជាមួយបណ្ឌិត អៀន ហារីស មកពីសាកលវិទ្យាល័យ អ័កហ្វឺត ប្រទេសអង់គ្លេស ។ លទ្ធផលនៃការចុះស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានផ្សព្វផ្សាយដល់សាធារណជន និងមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវស្វែងយល់ ហើយការផ្សព្វផ្សាយនេះជាមធ្យោបាយសម្រាប់ប្តូរយោបល់ជាមួយអ្នកទាំងនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានគម្រោងបន្តស្វាគមន៍បញ្ញាជននៅក្នុងនិងក្រៅប្រទេសមកកាន់មជ្ឈមណ្ឌលនៅឆ្នាំ២០០៣ ដើម្បីផ្តល់ជាយោបល់និងជួបពិភាក្សាជាមួយបុគ្គលិករបស់យើង ។ ការពិភាក្សានេះនឹងផ្តល់នូវលំហូរចូលនៃគំនិតថ្មីៗនិងជំនាញឯកទេសជាច្រើនដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយលទ្ធផលការងាររបស់បញ្ញាជនអន្តរជាតិទាំងនេះ ជាវិធីសាស្ត្រដោយប្រយោលមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនូវគំហើញរបស់ខ្លួនជាមួយមជ្ឈដ្ឋានអ្នកចេះដឹងនិងសាធារណជន ។ កាលពីឆ្នាំមុនៗ លទ្ធភាពរបស់យើងសម្រាប់ទទួលបញ្ញាជនទាំងនោះមានកំណត់ ។ ប៉ុន្តែក្នុងពេលនេះ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងបានផ្តល់បន្ទប់មួយឲ្យយើងសម្រាប់ផ្ទុកនិងអានឯកសារ ។ នេះជាជំនួយមួយសំខាន់ខ្លាំងណាស់ ។ លើសពីនេះ ដើម្បីធ្វើឲ្យការទទួលស្វាគមន៍បញ្ញាជនបរទេសអាចប្រព្រឹត្តទៅបានយូរអង្វែង យើងកំពុងតែពិចារណាអំពីការអនុវត្តផ្តល់ប្រាក់កម្រៃសមរម្យមួយចំនួនដល់អ្នកទាំងនោះទៀតផង ។

## គម្រោងការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត

មកដល់ខែធ្នូ ឆ្នាំ២០០២ យើងបានបោះពុម្ពផ្សាយទស្សនាវដ្តី ស្វែងរកការពិត បានចំនួន៣៦លេខ ។ ទស្សនាវដ្តីនេះមានសរសេរអត្ថបទទាក់ទងនឹងប្រធានបទខុសៗគ្នាជាច្រើន ។ លេខនីមួយៗមានប្រាំផ្នែកគឺ ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិ-សាស្ត្រនិងការស្រាវជ្រាវ ៣) ផ្នែកច្បាប់ ៤) វេទិកាពិភាក្សាសាធារណៈ និង ៥) ទំព័រស្រាវជ្រាវរកគ្រួសារ ។ ផ្នែកចុងក្រោយបង្ហាញអំពីកិច្ចខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការស្រាវជ្រាវរកពត៌មានអំពីសមាជិកគ្រួសារដែលបានបាត់ខ្លួនក្នុងសម័យខ្មែរក្រហម ។

ការបោះពុម្ពផ្សាយរបស់យើងបានកើនឡើងដល់ ៨៤០០០ច្បាប់ក្នុងមួយឆ្នាំ ប៉ុន្តែយើងនៅតែព្យាយាមសម្រេចឲ្យបាននូវគោលបំណងដើមរបស់យើង ដែលគ្រោងនឹងបោះពុម្ពឲ្យបានមួយលេខចំនួន៤០០០០ច្បាប់ក្នុងមួយខែជារៀងរាល់ខែ ។ ដោយមានជំនួយសប្បុរសធម៌មកពីប្រទេសស៊ុយអែដ យើងក៏បានបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិតជាភាសាអង់គ្លេសចំនួន១០០០ច្បាប់ក្នុងមួយខែ ។ ក្នុងខែតុលា ឆ្នាំ២០០១ ទស្សនាវដ្តីជាភាសាអង់គ្លេសត្រូវបានដាក់លក់ក្នុងតម្លៃ៣,៥ដុល្លារក្នុងមួយច្បាប់ ។ ក្នុងឆ្នាំ២០០៣ យើងមានគម្រោងរកចំណូលបន្ថែមទៀត តាមរយៈការបង្កើនបរិមាណលក់ទស្សនាវដ្តីជាភាសាអង់គ្លេស ដើម្បីសម្រួលដល់ការចំណាយក្នុងការបោះពុម្ពទស្សនាវដ្តីជាភាសាខ្មែរ ។ លើសពីនេះ ទស្សនាវដ្តីស្វែងរកការពិតត្រូវបានចេញផ្សាយតាមអ៊ិនធឺនែតដើម្បីឲ្យប្រជាជនកម្ពុជានិងអ្នកអាននៅក្រៅប្រទេសកាន់តែមានភាពងាយស្រួលក្នុងការរកអានទស្សនាវដ្តីនេះ ។ តាមការសន្និដ្ឋាន មានប្រជាជនកម្ពុជាចំនួន

ប្រហែលមួយលាននាក់រស់នៅឯបរទេស ។

នៅឆ្នាំ២០០៣ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរនិងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។ បច្ចុប្បន្ន ដោយការយឺតយ៉ាវក្នុងការបកប្រែភាសា យើងមិនអាចបោះពុម្ពផ្សាយជាពីរភាសាក្នុងពេលជាមួយគ្នាបានទេ ។ យើងកំពុងតែស្វែងរកអ្នកកែសម្រួលទស្សនាវដ្ដីមួយរូបដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីជាជំនួយបន្ថែមដល់បុគ្គលិកដែលមានស្រាប់ ដែលការទទួលខុសត្រូវខ្ពស់របស់បុគ្គលិកទាំងនោះគឺតម្រូវឲ្យមានការយកចិត្តទុកដាក់ជាចម្បងក្នុងការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ ។ ក្នុងពេលជាមួយគ្នានេះ យើងក៏កំពុងតែពិចារណាទៅលើមធ្យោបាយដើម្បីឲ្យនិស្សិតមហាវិទ្យាល័យនិងអ្នកស្ម័គ្រចិត្តដែលមានសមត្ថភាពគ្រប់គ្រាន់ មកធ្វើការងារនេះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាការពិតណាស់ គោលបំណងដ៏សំខាន់របស់យើងគឺត្រូវរក្សាឲ្យបាននូវកម្រិតបទដ្ឋានខ្ពស់នៃការបោះពុម្ពផ្សាយដែលយើងបានប្រកាន់ខ្ជាប់ក្នុងរយៈពេល៣៥ ខែដំបូងនៃការបោះពុម្ពផ្សាយ ។

គោលបំណងមួយទៀត គឺយើងបន្តបង្កើនប្រសិទ្ធភាពនៃការចែកចាយក្នុងស្រុក ដែលយើងបានជួបប្រទះនូវការលំបាកមួយចំនួនកន្លងមក ។ ការចែកចាយអស់រយៈពេលពីរឆ្នាំកន្លងទៅនេះ យើងបានកត់សម្គាល់ឃើញថា ទំនាក់ទំនងជាមួយភ្នាក់ងារក្នុងតំបន់ ពុំមានប្រសិទ្ធភាពនៃការចំណាយប៉ុន្មានទេ ហើយក៏ពុំបានធានាឲ្យមានការចែកផ្សាយឲ្យដល់គោលដៅដែរ ។ តាំងពីពេលនោះយើងបានដឹងថា ការចែកផ្សាយដោយខ្លួនឯងមានការសំចៃនិងគួរឲ្យទុកចិត្តជាង ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានជួយដល់យើងក្នុងការចែកចាយទស្សនាវដ្ដីនៅតាមខេត្ត ដែលរួមមានៈ សម្ព័ន្ធកម្ពុជាសម្រាប់ការជំរុញនិងការការពារសិទ្ធិមនុស្ស, មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម, ដៃគូរអភិវឌ្ឍន៍ និងអង្គការដទៃទៀត ។ ជារៀងរាល់ខែ ៨៥ភាគរយនៃទស្សនាវដ្ដីស្វែងរកការពិត ត្រូវបានចែកចាយដោយឥតគិតថ្លៃនៅក្នុងក្រុងចំនួន៤ ខេត្តចំនួន២០ ស្រុក១៧៣ និងឃុំ១៥៦០ នៅទូទាំងប្រទេស ។ ទស្សនាវដ្ដីស្វែងរកការពិតត្រូវបានចែកចាយដោយឥតគិតថ្លៃទៅឲ្យក្រុមប្រឹក្សាព្រះមហាក្សត្រ សមាជិកសភា ព្រឹទ្ធសភា ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួង គណបក្សនយោបាយ បណ្ដាស្ថានទូតដែលតាំងនៅប្រទេសកម្ពុជា អង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំ បណ្ណាល័យ វិទ្យាល័យ អនុវិទ្យាល័យនៅខេត្តក្រុង បណ្ណសាររដ្ឋានជាតិ និងឯកអគ្គរដ្ឋទូតកម្ពុជាទាំងអស់នៅបរទេស ។

នៅឆ្នាំ២០០៣ យើងមានគម្រោងពង្រីកការចែកផ្សាយទស្សនាវដ្ដីស្វែងរកការពិតជាអន្តរជាតិ ដោយស្វែងរកអតិថិជនជាស្ថាប័ននិងបុគ្គល ។ យើងក៏បានចាប់ផ្ដើមបង្កើតឲ្យមានការសហការរវាងបុគ្គលិកផ្នែកទស្សនាវដ្ដីរបស់យើងនិងទីប្រឹក្សាអន្តរជាតិ ដើម្បីស្វែងរកមធ្យោបាយពង្រីកបរិមាណលក់នៅលើទីផ្សារអន្តរជាតិ ។ ការបង្កើនចំណូលតាមរយៈការលក់នៅលើទីផ្សារអន្តរជាតិ ជាជំនួយមួយយ៉ាងសំខាន់ធ្វើឲ្យគម្រោងការបោះពុម្ពផ្សាយរបស់យើងកាន់តែមានភាពយូរអង្វែង និងកាត់បន្ថយការពឹងផ្អែកទៅលើជំនួយពីខាងក្រៅ ។ មធ្យោបាយមួយទៀត ដើម្បីផ្សព្វផ្សាយទស្សនាវដ្ដីស្វែងរកការពិត និងសៀវភៅដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺការនាំយកសៀវភៅទាំងនេះទៅកាន់សន្និសីទនិងសិក្ខាសាលាអន្តរជាតិដែលចូលរួមដោយតំណាងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ កន្លងមក ការឆ្លើយតបមិនដូវការ មានលក្ខណៈជាវិជ្ជមាននិងពោរពេញទៅដោយការលើកសរសើរ ជាពិសេសពីបុគ្គលដែលធ្វើការក្នុងស្ថាប័នទាក់ទិននឹងយុត្តិធម៌ក្នុងសម័យអន្តរកាល ។ ដោយទទួលបានលទ្ធផលជាវិជ្ជមានបែបនេះ បុគ្គលិករបស់យើងបច្ចុប្បន្នកំពុងតែចាត់វិធានការដើម្បីរក្សាឲ្យបាន និងពង្រីកចំនួនមិត្តអ្នកអានទស្សនាវដ្ដីស្វែងរកការពិត ។

## គម្រោងការជំរុញឲ្យមានការទទួលខុសត្រូវ

ចាប់តាំងពីខែមេសា ឆ្នាំ២០០១ នៃការកកើតដំបូងនៃគម្រោងការដាក់ឲ្យមានការទទួលខុសត្រូវ គឺមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ សំដៅទៅរកគោលដៅធំៗទាំងពីររបស់គម្រោង ។ ដោយមានសំណុំរឿងដែលបានបន្សល់ទុកពីបក្សកុម្មុយនិស្តកម្ពុជាជាឯកសារយោង បុគ្គលិកយើងបានប្រមូលនិងរៀបចំឯកសារបានមួយចំនួនធំ ។ សំណុំរឿងទាំងនេះមានឯកសារចំនួន២៥០០ ទំព័រ ដែលបានសង្ខេបជាសៀវភៅមួយក្បាលកម្រាស់៣០០

ទំព័រ ។ ជារួមសៀវភៅទាំង១១ក្បាល ជាភស្តុតាងបញ្ជាក់អំពីការរីកចម្រើនគួរឲ្យចាប់អារម្មណ៍ ។ សេចក្តីសង្ខេបបកស្រាយអំពីសម្តីមួយចំនួនដែលបានដកស្រង់ចេញពីសៀវភៅដើម ហើយត្រូវបានផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពៅដារ៉ា ដែលជាប្រធានគម្រោងការនេះ ។ សេចក្តីសង្ខេបនេះមិនទាន់ត្រូវបានប្រែសម្រួលជាភាសាអង់គ្លេសនៅឡើយទេ ។ កង្វះខាតនេះធ្វើឲ្យខ្ញុំមិនអាចវាយតម្លៃមាតិកាដ៏សំខាន់និងប្រព័ន្ធនៃការប្រមូលផ្តុំគំនិតរបស់សៀវភៅបានឡើយ ។ ដើម្បីបង្កើននិងអភិវឌ្ឍបន្ថែមទៅក្នុងគម្រោងការទាំងមូល វិធានការពីរត្រូវបានរៀបចំជាស្រេចសម្រាប់ឆ្នាំ២០០៣ៈ

១) ប្រែសម្រួលឯកសារបន្ថែមទៀត ហើយបង្កើនទំនាក់ទំនងជាមួយក្រុមប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការត្រួតពិនិត្យនិងវិភាគឯកសារ ។




២) បង្កើតទិន្នន័យកុំព្យូទ័រដើម្បីបញ្ចូលភស្តុតាងមួយចំនួនដែលបុគ្គលិករបស់យើងបានប្រមូលទាក់ទិនទៅនឹងវ៉ាន់នានុក្រមនយោបាយកម្ពុជាប្រជាធិបតេយ្យ និងខ្សែសង្វាក់នៃការដាក់បញ្ជារបស់បក្សកុម្មុយនិស្តកម្ពុជា ។

វិធានការថ្មីទាំងពីរចំពោះគម្រោងការនេះ គួរតែអាចជួយបង្កើតនូវភស្តុតាងទាំងឡាយ ដែលកាន់តែមានសារប្រយោជន៍ក្នុងការលាតត្រដាងនូវបទឧក្រិដ្ឋរបស់មេដឹកនាំខ្មែរក្រហមនិងជនដៃដល់ចំពោះការរំលោភបំពានដ៏ធ្ងន់ធ្ងរ ។

ក្រុមការងារនៃគម្រោងការនេះ ក៏មានការរីកចម្រើនយ៉ាងខ្លាំងក្នុងការធ្វើសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម ឬញាតិសន្តានដែលនៅរស់រានមានជីវិតរបស់កម្មាភិបាលទាំងនោះ ។ សមាជិកក្រុមនៃគម្រោងការបានរៀបចំការចេញដំណើរទៅធ្វើសម្ភាសនៅតាមស្រុក ។ មកទល់ខែមិថុនា ឆ្នាំ២០០២ ក្រុមការងារបានស្រាវជ្រាវរកឃើញ១២៤ប្រវត្តិរូបនៃអតីតសន្តិសុខខ្មែរក្រហម ក្នុងនោះកម្មាភិបាលចំនួន៣៥រូប ត្រូវបានរកឃើញថានៅមានជីវិតនៅឡើយ ហើយកំពុងតែរស់នៅក្នុងប្រទេសកម្ពុជា ។ បុគ្គល៨៩នាក់ទៀតត្រូវបានសន្និដ្ឋានថា បាត់ខ្លួន ឬស្លាប់បាត់បង់ជីវិត បន្ទាប់ពីមានការស្រាវជ្រាវដ៏ទូលំទូលាយនិងការជួបសន្ទនាជាមួយញាតិសន្តាននិងអ្នកដែលធ្លាប់ស្គាល់ ។ ក្រុមការងារនៃគម្រោងការនេះបានសម្រេចដោយជោគជ័យក្នុងការស្វែងរកលំនៅដ្ឋាន និងជួបសម្ភាសអតីតកម្មាភិបាលចំនួន២០រូបដែលនៅរស់ និងញាតិសន្តានចំនួន១៣៦នាក់នៃកម្មាភិបាលដែលត្រូវបានសន្និដ្ឋានថាបាត់ខ្លួនឬស្លាប់ ។ បទសម្ភាសន៍ត្រូវបានថតចម្លងជាខ្សែអាត់ទាំងស្រុង ហើយវាយចេញជាអត្ថបទនៅពេលក្រោយ ដើម្បីបង្កើតជាភស្តុតាងប្រវត្តិសាស្ត្រនិងផ្នែកច្បាប់ ដែលទាក់ទិនទៅនឹងអត្តសញ្ញាណនិងសកម្មភាពនៃជនដៃដល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មកដល់បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជាសន្សំបានអត្ថបទសម្ភាសចំនួន១៦៥២ទំព័រ ដែលបានមកពីសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងញាតិសន្តានរបស់អ្នកទាំងនោះ ។

ច្បាស់ណាស់ វាមានការពិបាកខ្លះៗក្នុងការស្វែងរកអតីតកម្មាភិបាលមួយចំនួន និងពន្យល់ឲ្យកម្មាភិបាលទាំងនោះសហការដោយសកម្មក្នុងការធ្វើសម្ភាសដែលថតជាខ្សែអាត់ ។ ដូចបានរៀបរាប់ខាងលើ ក្នុងចំណោមប្រវត្តិរូប១២៦ដែលបានស៊ើបអង្កេត តិចជាងមួយភាគបីត្រូវបានរកឃើញ ហើយមិនទាន់បានធ្វើសម្ភាសទាំងអស់ទេ ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតនូវវិធីសាស្ត្រមួយចំនួនទៀត សម្រាប់គម្រោងការនៃការដាក់ឲ្យមានការទទួលខុសត្រូវ ដែលចំណុចទាំងនេះនឹងត្រូវកែប្រែបន្ថែមទៀតនៅឆ្នាំ២០០៣ៈ

១) រក្សាឲ្យបាននូវនិយោជិកបណ្តោះអាសន្ននៅតាមខេត្តនានា ដើម្បីស្វែងរកលំនៅដ្ឋានអ្នកដែលត្រូវសម្ភាសនិងរក្សានូវ

ការសម្ភាសន៍មិនបានព្រាងទុកសម្រាប់ក្រុមការងារនៃគម្រោងការនេះ ។

២) ប្រើប្រាស់ប្រវត្តិរូបនៃបក្សកុម្មុយនិស្តកម្ពុជា ដែលមានលក្ខណៈទូលំទូលាយជាងប្រវត្តិរូប៥៥៥ ទាក់ទងទៅនឹងអតីតសន្តិសុខខ្មែរក្រហមដែលអនុញ្ញាតឲ្យយើងអាចសម្ភាសបានច្រើន (ប្រវត្តិរូបនៅក្នុងតំបន់ណាមួយជាក់លាក់) ។

៣) បង្កើតការិយាល័យនៅតាមខេត្តមួយចំនួនដើម្បីកាត់បន្ថយការចំណាយ និងធ្វើឲ្យមានភាពងាយស្រួលក្នុងការចុះខេត្ត (ពិសេសសម្រាប់គម្រោងការនេះនិងសកម្មភាពដទៃទៀត) ។

ក្រុមការងារនៃគម្រោងការនេះ បច្ចុប្បន្នកំពុងតែប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើខេត្តចំនួនបួន ហើយបានពង្រីកសំណាញ់នៃការស្រាវជ្រាវអតីតកម្មាភិបាលខ្មែរក្រហមរហូតដល់ប្រមាណ ៥០០០នាក់ ។

គម្រោងការនៃការដាក់ឲ្យមានការទទួលខុសត្រូវកាន់តែមានសារប្រយោជន៍ពីមួយខែទៅមួយខែ ។ ប្រសិនបើតុលាការខ្មែរក្រហម ឬវេទិកាដាក់ឲ្យមានការទទួលខុសត្រូវស្រដៀងគ្នាត្រូវបានបង្កើតឡើង ពត៌មានទាំងឡាយដែលបានបង្កើតឡើងដោយគម្រោងការនេះ នឹងក្លាយជាទ្រព្យដ៏មានតម្លៃសម្រាប់អ្នកស៊ើបអង្កេតផ្នែកច្បាប់ទាំងឡាយ ។ ឥឡូវនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទុកនូវឯកសារដែលអាចក្លាយជាភស្តុតាងច្រើនជាងគេបំផុត សម្រាប់ប្រឆាំងនឹងមេដឹកខ្មែរក្រហម ។ ដើម្បីជាជំនួយដល់ប្រតិបត្តិការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានដាក់ស្នើមជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងនឹងបង្កើតបុគ្គលិកផ្នែកច្បាប់មួយក្រុមតូច ដែលជាអតីតឬបច្ចុប្បន្នជាទីប្រឹក្សាច្បាប់ស្ម័គ្រចិត្តរបស់យើង ។ ការងាររបស់ក្រុមនេះ គឺទាក់ទងទៅនឹងការរៀបចំឯកសារភស្តុតាងសំខាន់ៗ និងការអប់រំសាធារណជនអំពីដំណើរការនៃការសម្រេចឲ្យបានយុត្តិធម៌ ។

## គម្រោងការបកប្រែនិងបោះពុម្ពផ្សាយ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលនូវការគាំទ្រពីសំណាក់អ្នកនិពន្ធល្បីល្បាញជាច្រើន ក្នុងការប្រែសម្រួលសៀវភៅមួយចំនួនដែលសរសេរជាភាសាអង់គ្លេសទៅជាភាសាខ្មែរដើម្បីបោះពុម្ព ។ សៀវភៅទាំងនោះរួមមានៈ "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ដោយ លឿង អ៊ឹង, "សំឡេងពីមន្ទីរស-២១" ដោយ សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ, "សត្រូវបងប្អូនឯង" (សង្គ្រាមដែលឆាបឆេះបន្ទាប់ពីសង្គ្រាម) ដោយលោក ណាយ៉ាន់ ចាន់ដា និង "កំណត់ហេតុរបស់ អាន់ ហ្វ្រែង" ។ ក្នុងអំឡុងខែមេសា និងខែមិថុនា ក្រុមបកប្រែភាសារបស់យើងបានបញ្ចប់ការបកប្រែសៀវភៅទាំងនេះជាស្ថាពរ ។ អត្ថបទដែលបានបកប្រែរួចរាល់ហើយ ឥឡូវនេះកំពុងតែរៀបចំដើម្បីបោះពុម្ព ។ នៅក្នុងឆ្នាំ ២០០៣ ខ្ញុំមានគម្រោងនឹងបញ្ចប់ការបកប្រែ "ឯកសារទូរលេខខ្មែរក្រហម" ទៅជាភាសាអង់គ្លេស ដែលជាឯកសារដ៏សំខាន់ទាក់ទងទៅនឹងសេចក្តីប្រកាសផ្ទៃក្នុង លិខិត និងរបាយការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា ។

## សកម្មភាពដាក់ស្នើបន្ទាប់បន្សំផ្សេងទៀតសម្រាប់ឆ្នាំ២០០៣

រាល់គម្រោងការទាំងអស់ដែលបានរៀបរាប់ខាងលើ ជាសក្ខីភាពបញ្ជាក់ពីការពង្រីកការងារបច្ចុប្បន្នរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានជំនួយថវិកាគ្រប់គ្រាន់ គម្រោងការខាងក្រោមនឹងធ្វើឲ្យមានដំណើរការនៅឆ្នាំ២០០៣ៈ

***ក)*** *គម្រោងការបង្កើតសៀវភៅប្រវត្តិសាស្ត្រៈ* ប្រជាជនកម្ពុជាអាចធ្វើដំណើរឆ្ពោះទៅមុខបានលុះត្រាតែប្រជាជនកម្ពុជាត្រូវតែយល់អំពីអតីតកាលរបស់ខ្លួន ។ បញ្ហាមិនយល់អំពីអតីតកាលរបស់ខ្លួននេះ ចាប់ផ្តើមនៅក្នុងសាលារៀន ដែលសិស្សានុសិស្សអានសៀវភៅពុម្ពដែលជារឿយៗមិនបានលាតត្រដាងអំពីប្រវត្តិខ្មែរក្រហមឲ្យបានពេញលេញនិងត្រឹមត្រូវ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថានឹងអាចកែប្រែចំណុចនេះ ដោយពិនិត្យសាឡើងវិញនូវសៀវភៅពុម្ពបច្ចុប្បន្ន នូវចំណុចខ្វះខាត ហើយបង្កើតសេចក្តីព្រាងនិងកម្មវិធីសិក្សាប្រវត្តិខ្មែរក្រហមគំរូថ្មីមួយសម្រាប់សិស្សានុសិស្សវិទ្យាល័យនិងអនុវិទ្យាល័យ ដើម្បីជាជំនួយឬជំនួសឯកសារបង្រៀនដែលមានស្រាប់ ។

***ខ)*** *ប្រវត្តិសាស្ត្រផ្ទាល់មាត់សម្រាប់បណ្ណសារវីដេអូៈ* មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថានឹងអាចដំណើរការគម្រោងការមួយដើម្បីប្រមែប្រមូលប្រវត្តិសាស្ត្រដែលចេញអំពីការនិយាយផ្ទាល់មាត់ពីកម្មាភិបាលខ្មែរក្រហមគ្រប់ជាន់ថ្នាក់ និង

អ្នកដែលនៅរស់រានមានជីវិតចំនួន២៨០០នាក់ ។ លើសពីនេះ យើងមានបំណងស្វែងរកអ្នកនៅរស់ ដែលមានបទពិសោធន៍ជាក់លាក់ក្នុងរបបខ្មែរក្រហម រួចហើយប្រៀបធៀបទស្សនៈរបស់អ្នកទាំងនោះទៅនឹងយោបល់របស់កម្មាភិបាលដែលប្រចាំការនៅតំបន់ជាមួយគ្នាក្នុងសម័យខ្មែរក្រហម ។ ការបរិយាយដោយផ្ទាល់មាត់របស់ជនរងគ្រោះនិងជនដៃដល់នេះ នឹងត្រូវបូកបញ្ចូលគ្នាដើម្បីបង្កើតជាបណ្ណសារវីដេអូ ហើយរក្សាទុកសម្រាប់ការស្រាវជ្រាវទៅថ្ងៃអនាគតរបស់បញ្ញាជន ។ បណ្ណសារនេះនឹងក្លាយជាវត្ថុធាតុដើមសម្រាប់ភាពយន្តឯកសារមួយឬច្រើននៅពេលខាងមុខ ។ គម្រោងការនេះអាចជួយបំពេញតម្រូវការសម្រាប់ប្រវត្តិសាស្ត្រផ្ទាល់មាត់ពិស្តារអំពីសម័យខ្មែរក្រហម ។

**ក)** *បណ្ណសាររូបថតឌីជីថលៈ* យើងសង្ឃឹមថានឹងអាចចូលរួមក្នុងគម្រោងការរួមមួយជាមួយកម្ពុជាការចងចាំឌីជីថល ដើម្បីបញ្ចូលរូបថតចំនួន៣០០០០រូប ដែលកំពុងរក្សាទុកយ៉ាងប្រយ័ត្នប្រយែងនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការធ្វើដូចនេះនឹងអនុញ្ញាតឲ្យមានការប្រើប្រាស់រូបថតកាន់តែច្រើន និងអាចអភិរក្សរូបថតដើមបានទៀតផង ។

**ឃ)** *ប្រមូលផ្តុំនិងពិនិត្យឯកសារពាក្យបណ្តឹង (ញត្តិ)ៈ*

មជ្ឈមណ្ឌលឯកសារកម្ពុជាតម្កល់នូវឯកសារពាក្យបណ្តឹងជាច្រើនច្បាប់របស់អ្នកដែលនៅរស់រានមានជីវិតពីសម័យ ប៉ុល ពត ដែលជាទូទៅហៅថា “ឯកសាររណសិរ្ស” ។ ក្នុងអំឡុងពីរឬបីឆ្នាំខាងមុខ យើងសង្ឃឹមថា អាចបរិច្ចាគធនធានមនុស្សដែលយើងមានមួយក្រុម ដើម្បីប្រមូលផ្តុំនិងពិនិត្យមើលឯកសារពាក្យបណ្តឹងទាំងនោះ ។ បន្ទាប់មក ប្រសិនបើមានការអនុញ្ញាតពីម្ចាស់ឯកសារពាក្យបណ្តឹង យើងនឹងផ្សព្វផ្សាយឯកសារទាំងនេះទៅឲ្យសាធារណជនបានយល់ដឹង ។ គម្រោងការនេះនឹងផ្តល់នូវពត៌មានមានតម្លៃដល់ប្រជាជនខ្មែរឲ្យបានដឹង ហើយក្នុងពេលដំណាលគ្នា ផ្តល់ដល់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម នូវសំឡេងក្នុងការពិពណ៌នាអំពីបទពិសោធន៍របស់ខ្លួន ។

**ង)** *គំណាងនៅតាមតំបន់ៈ* មិនមែនប្រជាជនកម្ពុជាទាំងអស់ទេ ដែលអាចអាននូវលទ្ធផលការងាររបស់ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ដូចជា ការសរសេរដៃនិងការបោះពុម្ពផ្សាយតាមរយៈទស្សនាវដ្តីស្វែងរកការពិត ។ គម្រោងការមួយដែលយើងមានបំណងនឹងធ្វើឲ្យមានដំណើរការ (ដែលត្រូវចំណាយថវិកាអស់តែមួយកម្រិតតូចប៉ុណ្ណោះ) គឺការបញ្ជូនអ្នកស្រាវជ្រាវមួយចំនួនរបស់យើងទៅតាមជនបទ ដើម្បីពន្យល់អំពីការងារដែលខ្លួនសម្រេចបានឲ្យប្រជាជនក្នុងតំបន់យល់ ។ ប្រជាជនកម្ពុជាជាច្រើននាក់បានបញ្ចេញនូវចំណាប់អារម្មណ៍ចំពោះគំហើញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការពន្យល់ផ្ទាល់មាត់មួងម្កាលនេះ នឹងផ្តល់ជាជំនួយដល់ការខំប្រឹងប្រែងស្វែងរកមនុស្សរបស់យើង ដោយមិនចាំបាច់ចំណាយអស់ថវិកាឬកម្លាំងច្រើន ។

រាល់គម្រោងការទាំងនេះ អាចដំណើរការទៅបានលុះត្រាតែមានជំនួយថវិកានិងធនធានមនុស្សគ្រប់គ្រាន់នៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងមានបំណងនឹងអនុវត្តគម្រោងការនីមួយៗភ្លាម នៅពេលដែលកត្តាហិរញ្ញវត្ថុនិងកត្តាផ្សេងទៀតត្រូវបានបំពេញ ។ យើងមានជំនឿយ៉ាងមុតមាំថា គម្រោងការមួយចំនួនអាចដំណើរការបាននៅដើមឆ្នាំ២០០៣ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានសុទិដ្ឋិនិយមថា គម្រោងការទាំងអស់នេះនឹងត្រូវបានយកទៅអនុវត្តនៅប៉ុន្មានឆ្នាំខាងមុខ ។ ដោយឯកឯងនិងដោយរួមគ្នា គម្រោងការនីមួយៗនឹងក្លាយទៅជាវិភាគទានដ៏ធំធេងដល់គោលបំណងថែរក្សាប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ជំរុញឲ្យមានការទទួលខុសត្រូវ និងចែកចាយការសម្រេចបានរបស់យើងទៅឲ្យសាធារណជនកម្ពុជាបានដឹងឮ ។

## មជ្ឈមណ្ឌលឯកសារកម្ពុជាករណីមានឬគ្មានតុលាការខ្មែរក្រហម

នៅពេលដែលគម្រោងការទាំងនេះកំពុងតែសរសេរឡើង តុលាការខ្មែរក្រហមមិនទាន់ប្រាកដថានឹងអាចកើតមានទេ ទោះបីជាអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាខិតកាន់តែខិតជិតដល់ការចរចាជាថ្មីម្តងទៀតនៅពេលខាងមុខនេះក៏ដោយ ។ ថ្មីៗនេះ គណៈកម្មាធិការទីបីរបស់អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចចិត្តលើសេចក្តីព្រាងមួយ ដែលគាំទ្រដោយប្រទេសបារាំងនិងជប៉ុន ។ សេចក្តីសម្រេចចិត្តនេះនឹងជួយជំរុញឲ្យលោកអគ្គលេខាធិការនិងអាជ្ញាធរកម្ពុជាសម្រេចបាននូវកិច្ចព្រមព្រៀងមួយទៅលើតុលាការខ្មែរក្រហមនៅក្នុងអនាគតដ៏ខ្លី

ខាងមុខ ។ ប្រទេសមួយចំនួនបានបោះឆ្នោតអនុបវាទចំពោះសេចក្តីសម្រេចចិត្តលើសេចក្តីព្រាង ទោះជាខ្លួនជឿជាក់ថា ការសម្រេចចិត្តនេះនឹងមិនធានាឲ្យបានគ្រប់គ្រាន់ថាតុលាការដែលត្រូវបង្កើតនឹងបំពេញនូវបទដ្ឋានអន្តរជាតិ ។ ប្រទេសចិននៅតែបន្តប្រឆាំងនឹងតុលាការនេះយ៉ាងដាច់អហង្ការ ។ ដូច្នេះ វានៅតែមិនច្បាស់លាស់ថាតើតុលាការមួយគួរឲ្យទុកចិត្តបាននិងយុត្តិធម៌ នឹងអាចកើតមាននៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនោះទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងរៀបចំកិច្ចការរបស់យើងឲ្យមានទំនាក់ទំនង (ហើយតាមពិតជាការចាំបាច់) សម្រាប់តុលាការខ្មែរក្រហម ទោះបីជាតុលាការនេះនឹងកើតមានឬអត់យ៉ាងណាក៏ដោយ ។

ប្រសិនបើតុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងពិតមែននោះ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រាកដជានឹងមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ភ័ស្តុតាងប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម និងជាប្រភពព័ត៌មានដ៏ចម្បងទាក់ទងទៅនឹងតុលាការនេះ ។ ជាការពិតណាស់ នៅពេលមានតុលាការ ការងារទាក់ទងនឹងប្រវត្តិសាស្ត្រ ការជួបជាមួយសាធារណជន និងគម្រោងការផ្សេងទៀត នៅតែមានដំណើរការដដែល ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការខ្មែរក្រហមមិនបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៣ ឬក៏ក្រោយពីនោះ ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអាចនឹងមានតម្លៃកាន់តែខ្ពស់ ។ បញ្ញាជននិងមន្ត្រីផ្លូវការមួយចំនួនបានសង្កេតឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានតួនាទីច្រើនយ៉ាង ។ នៅប្រទេសដទៃ អង្គភាពដែលមានលក្ខណៈស្រដៀងគ្នានឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ជួនកាលត្រូវដាក់ឲ្យដើរតួជា "គណៈកម្មការស្វែងរកការពិត" (សូមអានគ្របក្រោយទំនាក់ទំនងនិងទស្សនៈគណៈកម្មការស្វែងរកការពិតនៅកម្ពុជា) ។ ដោយគ្មានដំណើរការជាផ្លូវការណាមួយ ជាការពិតណាស់ កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងក្លាយជាគណៈកម្មការស្វែងរកការពិតមួយ ។ ដូច្នេះ ការងារប្រមូលផ្តុំនិងផ្សព្វផ្សាយការពិតនឹងមានសារប្រយោជន៍កាន់តែខ្លាំងជាងមុន ។




នៅក្នុងឆ្នាំ២០០៣ ក៏ដូចជានៅឆ្នាំមុនៗដែរ យើងនឹងបន្តបង្កើតជាលទ្ធផលដោយយកចិត្តទុកដាក់បំផុតដែលមានសារ-ប្រយោជន៍ដូចគ្នា ទោះបីជាមានតុលាការខ្មែរក្រហមឬគ្មាន ។ ទីប្រឹក្សាផ្នែកច្បាប់មួយចំនួនរបស់យើងកំពុងតែជួយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការកំណត់ព័ត៌មានដែលមានសារប្រយោជន៍បំផុតសម្រាប់ដំណើរការដាក់ឲ្យមានការទទួលខុសត្រូវ ឬសម្រាប់គោលបំណងបង្កើតនូវ"ការពិត"ផ្នែកច្បាប់ សម្រាប់កត់ត្រាទុកក្នុងប្រវត្តិសាស្ត្រ ។ ក្នុងករណីគ្មានតុលាការខ្មែរក្រហម យើងនឹងព្យាយាមធ្វើដោយខ្លួនឯង ក្នុងការផ្សព្វផ្សាយការពិតអំពីសម័យខ្មែរក្រហម តាមរយៈការបោះពុម្ព ការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាន និងសន្និសីទសាធារណៈ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែស្វែងរកយ៉ាងសកម្ម នូវមធ្យោបាយផ្សេងទៀត ដែលតាមរយៈមធ្យោបាយនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបំពេញនូវចន្លោះប្រហោងដោយសារកង្វះតុលាការខ្មែរក្រហម ។ នៅក្នុងករណីនោះ យើងនឹងខិតខំបង្កើនសកម្មភាពចុះជួបជាមួយប្រជាជនដើម្បីធានាឲ្យបានថា ការពិតត្រូវបានផ្សព្វផ្សាយទៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាគ្មានការផ្សព្វផ្សាយជាសាធារណៈដោយតុលាការខ្មែរក្រហមក៏ដោយ ។ តាមរយៈការចុះតាមស្រុកជាជំនួយបង្កើនការបោះពុម្ពផ្សាយទស្សនាវដ្តីរបស់យើង និងការដឹកនាំដែលអាចកើតមានក្នុងទម្រង់ជាការស៊ើបអង្កេតជាសាធារណៈ យើងនឹងព្យាយាមបំពេញចន្លោះប្រហោងដែលបណ្តាលពីអវត្តមានរបស់តុលាការខ្មែរក្រហម ។ ជាការពិតណាស់ ដោយសារមានការចរចាគ្នារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាសាឡើងវិញនៅពេលខាងមុខនេះគម្រោងការទាំងនេះចាំបាច់ត្រូវស្ថិតក្នុងការព្យួរទុកសិន ។ **ឆាំង យុ**



អៀង សារី

# ចាសនាចុងក្រោយរបស់និស្សិតម្នាក់មកពីយូហ្គោស្លាវី

សោម សីលា គឺជានិស្សិតខ្មែរម្នាក់ក្នុងចំណោមនិស្សិតខ្មែរដទៃៗទៀត ដែលមានឱកាសទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេស ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាននិស្សិតមកពីបរទេសមិនតិចជាងមួយពាន់នាក់ទេ ដែលត្រូវបានបញ្ជូនទៅអប់រំនៅបឹងត្របែក (មន្ទីរក-១៧) បន្ទាប់ពីខ្លួនបានវិលត្រឡប់ពីបរទេសតាមការអំពាវនាវរបស់ អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យោងតាមបញ្ជីឈ្មោះអ្នកទោសដែលដកស្រង់ចេញពីបញ្ជីអ្នកទោសកម្មេចនៅមន្ទីរស-២១ នៅផ្នែក «និស្សិតនិងអ្នករដ្ឋការមកពីបរទេស» មានចំនួន១៨៤នាក់ ក្នុងនោះពុំមានឃើញឈ្មោះ សោម សីលា ទេ ឃើញតែឈ្មោះ ហួត សម្បត្តិ ជាទូតប្រចាំនៅប្រទេសយូហ្គោស្លាវី និង ថាច់ សួង លេខាទីពីរ ដែល សីលា អះអាងថាធ្លាប់មានទំនាក់ទំនងជាមួយនៅពេលខ្លួនកំពុងសិក្សានៅប្រទេសយូហ្គោស្លាវី ។ ក្រោយពីត្រូវអង្គការចាប់ខ្លួន សោម សីលា បានបាត់ដំណឹងរហូតមកដល់បច្ចុប្បន្ននេះ ។ ខាងក្រោមនេះគឺជាការដកស្រង់ចម្លើយសារភាពរបស់ សោម សីលា ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ សួរដោយក្រុមសួរចម្លើយពួក១០ ឈ្មោះ ហុង ។

## ជីវិតយុវវ័យ

គិតត្រឹមឆ្នាំ១៩៧៧ សោម សីលា មានអាយុ៣៥ឆ្នាំ ។ សោម សីលា មានស្រុកកំណើតនៅភូមិរមិញ ឃុំរមិញ ស្រុករមិញ ខេត្តតាកែវ ។ នៅឆ្នាំ១៩៤៩ សីលា ចូលរៀនថ្នាក់ដំបូងនៅសាលារៀនក្រុងបាត់ដំបង ។ ឆ្នាំ១៩៥០ ដោយសារឪពុករបស់ សោម សីលា ត្រូវផ្លាស់ទៅបង្រៀនខេត្តបាត់ដំបង សីលា ក៏ផ្លាស់ទៅរៀននៅសាលារៀនស្រុកស្វាយស៊ីសុផុន ក្នុងខេត្តបាត់ដំបងដែរ ។ ឆ្នាំ១៩៥៥ ឪពុករបស់ សីលា បានមកធ្វើគ្រូវិន័យនៅក្រុងភ្នំពេញ ។ សីលា ក៏មកចូលរៀននៅសាលាបឹងកេងកង ។

នៅឆ្នាំ១៩៥៦ សីលា ក៏ផ្លាស់មករៀននៅក្រុងកំពត (បានជិតពាក់កណ្តាលឆ្នាំ) ។ កាលនោះមានការបោះឆ្នោតជ្រើសរើសគណបក្សមួយចំនួន ។ ឪពុករបស់ សីលា ឈ្មោះ ឡាំ សោម ជាសមាជិកគណបក្សប្រជាធិបតេយ្យ ប៉ុន្តែដោយសារគណបក្សនេះចាញ់ឆ្នោត ឪពុករបស់ សីលា ក៏ត្រូវផ្លាស់ឲ្យទៅធ្វើជាអធិការបឋមសិក្សារងក្រុងកំពង់ធំវិញ ។ ពេលនោះ សីលា បានទៅរៀននៅក្រុងកំពង់ធំ ។

## ការទទួលឥទ្ធិពលពីលោកខាងលិច

នៅឆ្នាំ១៩៥៧ ម្តាយ សីលា ឈ្មោះ ម៉េង គីមស៊ិន បានទៅលេងផ្ទះជីតាសីលានៅទីក្រុងកែប ឈ្មោះ គង់ ធុច ។ កាលណោះជីតារបស់ សីលា ក៏បានលើកឡើងពីស្ថានភាពស្រុកទេសនៅប្រទេសអាមេរិកដែលមានការសម្បូរសប្បាយក្នុងការរស់នៅនិងមានរដ្ឋអំណាចគ្រប់គ្រងលើសកលលោក ហើយថាជនជាតិអាមេរិកាំងម្នាក់ៗសុទ្ធតែមានរថយន្តពីរបុបី ហើយជាទូទៅពលរដ្ឋអាមេរិកកាំងប្រើសុទ្ធតែឧបករណ៍ស័យប្រវត្តិទាំងអស់ ។ ឆ្នាំ១៩៥៩ សីលា រៀននៅថ្នាក់ទី៤នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ជារៀងរាល់ល្ងាច សីលា តែងតែដើរលេងតាមផ្លូវមុនីវង្ស ។ មានថ្ងៃមួយ សីលា ជួបនិងស្គាល់មិត្តម្នាក់ឈ្មោះ ជ័យ វុធ សិស្សសាលាដូចគ្នា ។ ក្រោយពីបានចងចំណងមិត្តភាពជាមួយ វុធ រួចមក ជាញឹកញយអ្នកទាំងពីរតែងតែដើរលេងជាមួយគ្នា ។ វុធ បានអប់រំឲ្យ សីលា ចូលចិត្តដើរលេងហ៊ឺហា និងខិលខូចស្រីញីនិងឲ្យចេះស្រលាញ់បុណ្យស័ក្តិ ។ មិនតែប៉ុណ្ណោះ វុធ ក៏បានអួតសរសើរពីជីវិតដ៏មានជាសុកភាពនៅសហរដ្ឋអាមេរិក ដោយពន្យល់ថា មិនថាតែសេចក្តីសុខទេ សូម្បីតែស្រីៗនៅអាមេរិកក៏ល្អជាងគេទាំងអស់ដែរ ។

## ទំនាក់ទំនងសេ.អ៊ី.អា

ឆ្នាំ១៩៦០ ក្រុមគ្រួសាររបស់ សីលា បានមករស់នៅទីក្រុងភ្នំពេញ ។ ឪពុករបស់ សីលា ធ្វើការនៅក្រសួងអប់រំជាតិ ។ ឆ្នាំនោះ សីលា រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិដដែល ។ ឆ្នាំ១៩៦០ គឺជាឆ្នាំដំបូងបំផុតដែល សីលា ដាក់ចិត្តចូលបម្រើ

សេ.អ៊ី.អា ។ ជ័យ វុធ បាននាំ សីលា ចូលសេ.អ៊ី.អា នៅមុំផ្សារថ្មី ។ អ្នកដែលទទួលស្គាល់ សីលា ចូលក្នុងអង្គការនេះគឺជាជីតារបស់ សីលា តែម្តង ។ នៅពេល សីលា ចូលជា សេ.អ៊ី.អា សីលា ត្រូវបានទទួលស្វាគមន៍ដោយពិធីជប់លៀងមួយ ។ នៅក្នុងពិធីជប់លៀងនោះមានម្នាក់ឈ្មោះ គង់ ធុច បានក្រោកឡើងនិយាយអំពីគោលបំណងនៃសេ.អ៊ី.អា ។ គង់ ធុច និយាយថា សេ.អ៊ី.អា អាចជួយឲ្យប្រទេសកម្ពុជារួចផុតពីក្រញ៉ាំចក្រពត្តិសូវៀតនិងចិនបាន ។ បន្ទាប់មកម្នាក់ៗបានឡើងមកបង្ហាញខ្លួនម្តងម្នាក់ៗ ព្រមទាំងសច្ចាស្បថស្បែរឲ្យស្មោះត្រង់នឹងគ្នាទៅវិញទៅមក ។ នៅពេលចូលនោះ សីលា ទទួលបានប្រាក់ខែ ១០០ដុល្លារ ។ អ្នកដែលចូលសេ.អ៊ី.អាជាមួយគ្នា មានចំនួន ៥នាក់ រួមទាំងសីលា ផង ។ ក្នុងនោះមាន ហួត ជាអ្នកជំនួញ កេង ធ្វើការនៅឃ្លាំងប្រាក់ ផេង ធ្វើការនៅឃ្លាំងប្រាក់ និង ស្រេង ជាអ្នកចម្ការ ។

## ការពង្រីកកម្លាំងនៅក្នុងប្រទេសកម្ពុជា

ជ័យ វុធ បានប្រាប់ សីលា ឲ្យទាក់ទងជាមួយឈ្មោះ ឈាន និង ឆុង ជាកូនសិស្សដូចគ្នា ដើម្បីធ្វើសហប្រតិបត្តិការជាមួយគ្នា ពីព្រោះអ្នកទាំងពីរនេះចូលសេ.អ៊ី.អាមុន សីលា ទៅទៀតនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ អ្នកទាំងពីរនេះធ្វើការតាមរយៈ ជ័យ វុធ ដែរ ។

ឆ្នាំ១៩៦០ ឈាន, ឆុង និង សីលា បានមកប្រជុំគ្នានៅទួលទំពូងអំពីលទ្ធផលនៃការតាមដានខ្មែរក្រហមម្នាក់ឈ្មោះ រី ដែលជាសិស្សរួមសាលាជាមួយគ្នា ។ អ្នកទាំងបីបានដឹងថា ឈ្មោះ រី ជាខ្មែរក្រហម ដោយសារ រី ចេះតែនិយាយសរសើរពីរបបសង្គមនិយម ។ ក្រោយពីរាយការណ៍ទៅ វុធ ហើយ វុធ ក៏ចាប់ រី ដាក់គុកនៅការិយាល័យទី២ ។ ជ័យ វុធ បានចាត់តាំងឲ្យ សីលា ទាក់ទងជាមួយឈ្មោះ ច័ន្ទ ដើម្បីរៀបចំបង្កបង្កើនកម្លាំងសេ.អ៊ី.អាឲ្យកាន់តែខ្លាំងឡើង ។ មានពេលមួយ សីលា បានទៅប្រជុំនៅក្នុងថ្នាក់រៀនទំនេរមួយនៃវិទ្យាល័យព្រះស៊ីសុវត្ថិ ។ អ្នកដែលចូលប្រជុំនោះមានគ្នា៨នាក់រួមទាំង សីលា ផង ។ កិច្ចប្រជុំនេះបានរៀបចំឡើងដើម្បីលើកឡើងអំពីកម្មវិធីកសាងកម្លាំងសេ.អ៊ី.អា ឲ្យកាន់តែខ្លាំងឡើង ដោយប្រើលុយ ការអប់រំផ្ទាល់ និងការបង្ខិតបង្ខំ ។

ជ័យ វុធ បានចាត់តាំងឲ្យ សីលា ទាក់ទងជាមួយកូនសិស្សដូចគ្នាឈ្មោះ មែន ដើម្បីឲ្យ មែន ទទួលបន្ទុកអប់រំសិស្សឯទៀតឲ្យចូលសេ.អ៊ី.អា ។ ក្រោយមក ជ័យ វុធ បានចាត់តាំងឲ្យ សីលា ទៅទាក់ទង ម៉ម ឲ្យចូលធ្វើជាប៉ូលិសទៀត ដើម្បីឲ្យ ម៉ម ទាក់ទាញប៉ូលិសដូចគ្នាឲ្យធ្វើជាសេ.អ៊ី.អា ។ នៅឆ្នាំ១៩៦១ មានជនជាតិវៀតណាមម្នាក់ឈ្មោះ ធៀវ ដែលជាភ្នាក់ងារសេ.អ៊ី.អានៅប្រទេសវៀតណាមបានមកទាក់ទង សីលា នៅទឹកល្អក់តាមរយៈ ហួត ។ ធៀវ បានប្រាប់ សីលា ថា “ត្រូវជួយតាមដានឃើញយួនណាម្នាក់បម្រើឲ្យយៀកកុងត្រូវរាយការណ៍ទៅឲ្យឈ្មោះ ហួត រួច ហួត ក៏ទៅរាយការណ៍ឲ្យខ្ញុំនៅស្រុកយួនទៀត” ។

នៅឆ្នាំ១៩៦៣ សីលា បានទៅទាក់ទងឈ្មោះ ជា នៅខេត្តកំពង់ធំ ក្នុងគោលបំណងបង្កើតសេ.អ៊ី.អា នៅតាមខេត្តនានា និងចាត់តាំង ជា ឲ្យធ្វើជាមេក្រុមសេ.អ៊ី.អា ដើម្បីតាមដានខ្មែរក្រហមនៅខេត្តកំពង់ធំ ហើយរាយការណ៍មកឲ្យខ្លួន ។

សីលា បានសរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ ថា “សមណា បានមកប្រាប់ខ្ញុំនៅមុំវិទ្យាល័យព្រះស៊ីសុវត្ថិថា យើងទាំងអស់គ្នាត្រូវត្រៀមខ្លួនរៀបចំធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ និងយករបបលោកសេរីមកកាន់កាប់នៅកម្ពុជាវិញ” ។ ជ្រាបពត៌មាននេះហើយ សីលា កាន់តែខិតខំប្រមូលកម្លាំងនៅគ្រប់កន្លែង ហើយបានចាត់តាំងឈ្មោះ យៀន ឲ្យចូលធ្វើជាប៉ូលិសដើម្បីទាក់ទាញប៉ូលិសដែលធ្វើការជាមួយគ្នាឲ្យចូលសេ.អ៊ី.អាកាន់តែច្រើន ។ ប៉ុន្តែនៅពេលនោះ កម្លាំងធ្វើរដ្ឋប្រហារមិនទាន់មានគ្រប់គ្រាន់ ពិសេសកម្លាំងនៅបង្កប់ក្នុងរដ្ឋការ សីលា ក៏បានប្រលងជាប់អាហារូបករណ៍ទៅសិក្សានៅបរទេស ។ នៅឆ្នាំ១៩៦៤ សីលា បានចេញទៅសិក្សាខាងសេដ្ឋកិច្ចនៅប្រទេសយូហ្គោស្លាវី ហើយស្នាក់នៅក្រុងសាក្រិប ។

## ការកសាងខ្សែបណ្តាញនៅបរទេស

សីលា សរសេរថា ក្រោយពេលខ្លួនបានមកសិក្សានៅប្រទេសយូហ្គោស្លាវី តែងតែឮជនជាតិអាល់ហ្សេរីនិយាយអំពីអង្គការមួយសម្រាប់ទាក់ទងជាមួយសេ.អ៊ី.អានៅក្នុងប្រទេស ។

ចម្លើយសារភាពរបស់ សីលា ក៏បានលើកឡើងដែរ អំពីសកម្ម-ភាពរបស់ទូតរណសិរ្សកម្ពុជាប្រចាំនៅទីក្រុងប៉ែលក្រាត ក្នុងនោះមានឈ្មោះ ថាច់ សួង ជាលេខាទីពីរទូតនៅយូហ្គោស្លាវីនិង ហួត សម្បត្តិ ដែលជាទូតប្រចាំនៅយូហ្គោស្លាវី ព្រមទាំងក្រុមគ្រួសារ ។ ឆ្នាំ១៩៧១ និស្សិតខ្មែររណសិរ្សទាំងអស់ បានចូលរួមប្រជុំមួយនៅទីក្រុងប៉ែលក្រាត ដើម្បីធ្វើលក្ខន្តិកៈតាមលក្ខខណ្ឌរបស់សមាគមនិស្សិតខ្មែរប្រចាំប្រទេសយូហ្គោស្លាវី ។ បន្ទាប់មកសមាគមនិស្សិតខ្មែរ ផ្ញើលក្ខន្តិកៈទាំងនេះទៅសមាគមនិស្សិតខ្មែររណសិរ្សនៅប្រទេសផ្សេងៗទៀត ។ នៅឆ្នាំ១៩៧៦ ក្នុងអំឡុងពេលនៃការស្នាក់នៅនិងសិក្សានៅប្រទេសយូហ្គោស្លាវី សីលា បានទទួលការអប់រំ និងឲ្យកសាងកម្លាំងនៅក្នុងប្រទេសកម្ពុជាឲ្យបានច្រើន ក្នុងគោលបំណងផ្តួលរំលំឯករាជ្យនៃប្រទេសកម្ពុជាតាមរយៈការបង្អាក់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ ចាប់ពីវិស័យកសិកម្ម ឧស្សាហកម្ម វប្បធម៌ អារ្យធម៌ រហូតដល់ការរស់នៅក្នុងសមូហភាពនៃសង្គមខ្មែរទាំងមូល ។

ផ្អែកតាមចម្លើយសារភាពរបស់ សីលា កម្លាំងនិងបណ្តាញទាំងក្នុងនិងក្រៅប្រទេសដែល សីលា ធ្វើការជាមួយមានចំនួនរហូតដល់១៨១នាក់ ក្នុងនោះមានថ្នាក់ដឹកនាំការិយាល័យនគរបាល ទាហាន សាស្ត្រាចារ្យ គ្រូបង្រៀន អ្នកជំនួញ អ្នកចម្ការ សិស្ស និស្សិតខ្មែរនៅបរទេស បុគ្គលិកទូតខ្មែរប្រចាំនៅយូហ្គោស្លាវីរួមមាន ថាច់ សួង, ហួត សម្បត្តិ ព្រមទាំងប្រពន្ធកូន និស្សិតជនជាតិយូហ្គោស្លាវី ពេទ្យ ជនជាតិអ៊ីរ៉ាក់ ស៊ូដង់ ឥណ្ឌា លាវ តង់ហ្សានី និងប្រទេសមួយចំនួនទៀត ។

**វាសនាចុងក្រោយ**

សីលា បានត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៧ ហើយបានមកនៅក្នុងក្រសួងការបរទេស ។ មកដល់ទីក្រុងភ្នំពេញភ្លាម សីលា ក៏បានចាប់ផ្តើមអនុវត្តផែនការដែលខ្លួនបានគ្រោងទុកកាលពីនៅប្រទេសយូហ្គោស្លាវី ។ សីលា បានចូលរួមប្រជុំជាមួយឈ្មោះ ចាន់ ឈឿវ អំពីកម្លាំងសេ.អ៊ី.អា ដែលនឹងត្រូវកសាងនិងប្រមូលកម្លាំងឲ្យបានគ្រប់គ្រាន់ដើម្បីនឹងផ្តួលរំលំឯករាជ្យនៃប្រទេសកម្ពុជា ។

សីលា មានវាសនាមិនខុសពីបុគ្គលិកទូតកម្ពុជាប្រជា-ធិបតេយ្យប្រចាំនៅបរទេសនិងនិស្សិតដែលសិក្សានៅបរទេសប៉ុន្មានទេ នៅពេលត្រឡប់មកប្រទេសកម្ពុជាមិនបានប៉ុន្មានផងសីលា ក៏ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៧ ហើយបាត់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ **សូ ប៊ុនស៊ូ**

## ពាក្យស្លោកខ្មែរក្រហម

◆ **កម្ចាត់គោលជំហរអនុធន នាយទុន សក្តិភូមិ ព្រមទាំងកសិករនិងសិប្បករ ហើយបំពាក់និងពង្រឹងគោលជំហរអធនរបស់បក្សជាចំខាត។** *(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆ **វាយកម្ចាត់នយោបាយឈ្លានពានរុករាន វាយនយោបាយជិះជាន់គ្រប់ផ្នែក វាយនយោបាយអាណានិគមរបៀបថ្មី។**

◆ **ត្រូវប្រមូលកម្លាំងប្រជាជាតិទាំងអស់ ជាពិសេសប្រមូលផ្នែកកម្មករ កសិករ នៅក្រោមការដឹកនាំរបស់បក្ស ដើម្បីវាយខ្មាំងចក្រពត្តិនិងពួកបរិវារ។ល។**

*(ឯកសារD២១៥០៩)*

◆ **សត្រូវមិនអាចបរាជ័យខ្លួនឯងបានទេ ទោះពួកប្រតិកិរិយានៅក្នុងប្រទេសចិន ឬប្រតិកិរិយាចក្រពត្តិនិយមអាមេរិកាំងនៅក្នុងឥណ្ឌូចិនក៏មិនអាចចែកចេញពីធាតុប្រវត្តិសាស្ត្រដែរ។**

*(សៀវភៅកំណត់ហេតុ ញូក)*

◆ **ពង្រឹងពង្រីករបបសមូហភាពសង្គមនិយមឱ្យបានកាន់តែណែន កាន់តែល្អ ទៅតាមសហករណ៍ រោងចក្រ ការដ្ឋាន មន្ទីរទាំងអស់ ទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំង ជាប់ជានិច្ច។**

◆ **ផ្អែកឱ្យរឹងមាំលើវណ្ណៈអធន តាមសម្ព័ន្ធភាពកម្មករ កសិករ សាមគ្គីយ៉ាងជិតស្និទ្ធជាមួយកម្លាំងទាំងអស់ ធ្វើបដិវត្តសង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស។**

◆ **ឈរលើជំហរវណ្ណៈអធន ខិតខំកសាងលោកទស្សនៈអធន ជីវទស្សនៈអធន ការរស់នៅប្រចាំថ្ងៃ សីលធម៌ប្រចាំថ្ងៃ តាមបែបអធនឱ្យបានល្អជាប់ជានិច្ច។**

*(កំណត់ហេតុលេខ ០៧៦)*

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ២០៨ | ង្វៀង អ៊ុត | យួន | ចារកិច្ចយួន | កំពង់សោម | ១២-១១-៧៨ | ២០-១១-៧៨ |
| ២០៩ | ដៀង វ៉ាំងខាង | យួន | ចារកិច្ចយួន | កំពង់សោម | ១២-១១-៧៨ | ២-១២-៧៨ |
| ២១០ | ង្វៀង យ៉ាំងយ | យួន | ចារកិច្ចយួន | កំពង់សោម | ១២-១១-៧៨ | ២-១២-៧៨ |
| ២១១ | ឌិញ ថាញ់លៀម | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១៥-១១-៧៨ |
| ២១២ | ង្វៀង យ៉ាំងតា | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១៥-១១-៧៨ |
| ២១៣ | ង្វៀង ធីង៉ា (ស) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១៥-១១-៧៨ |
| ២១៤ | ត្រឹង យ៉ាំងឌុក | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១៥-១១-៧៨ |
| ២១៥ | ឡេ យ៉ាំងសឺន | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២០-១១-៧៨ |
| ២១៦ | ឡេ យ៉ាំងមិញ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២០-១១-៧៨ |
| ២១៧ | វិញ យ៉ាំងប៉ែ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២-១២-៧៨ |
| ២១៨ | ឡេ យ៉ាំងវ៉ាច់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១១-១២-៧៨ |
| ២១៩ | ង្វៀង យ៉ាំងឌឿ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ៣-១២-៧៨ |
| ២២០ | ឌិញ យ៉ាំងសូវ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២-១២-៧៨ |
| ២២១ | ឌិញ យ៉ាំងត្រាង | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២-១២-៧៨ |
| ២២២ | ត្រឹង យ៉ាំងខា | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ១៥-១១-៧៨ |
| ២២៣ | ត្រឹង យ៉ាំងវ៉ាង | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ៣-១២-៧៨ |
| ២២៤ | ឡេ យ៉ាំងថាញ់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-១១-៧៨ | ២-១២-៧៨ |
| ២២៥ | លូវ ប៊ុងទីន | យួន | ប៊ិញញី | ស្វាយរៀង | ១៤-១១-៧៨ | |
| ២២៦ | យ៉ី យ៉ាំងដុង | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២-១២-៧៨ |
| ២២៧ | ផាម យ៉ាំងយ៉ឺ | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២-១២-៧៨ |
| ២២៨ | យ៉ី យ៉ាំងម៉ុង | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២០-១១-៧៨ |
| ២២៩ | ផាម យ៉ាំងយុង | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២០-១១-៧៨ |
| ២៣០ | ត្រឹង យ៉ាំងស៊ិន | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២០-១១-៧៨ |
| ២៣១ | ត្រឹង យ៉ាំងឡូម | យួន | ចារកិច្ចយួន | និរតី | ១៤-១១-៧៨ | ២០-១១-៧៨ |
| ២៣២ | ដៀង ធីង្វៀងស) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៤-១១-៧៨ | ២០-១១-៧៨ |
| ២៣៣ | ឡេ យ៉ាំងវ៉ឹក | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៧-១១-៧៨ | ១១-១២-៧៨ |
| ២៣៤ | ត្រឹង សាំងលៀម | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១៨-១១-៧៨ | ២-១២-៧៨ |

(នៅមានត)

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

***(តពីលេខមុន)***

*នៅថ្ងៃ២២ ឧសភា យើងបានជួបពិភាក្សាជាមួយលោក ធុច រិន ហៅ គ្រិន អតីតសាស្ត្រាចារ្យមធ្យមសិក្សា ជាប្រធានមន្ទីរវប្បធម៌នៅភូមិភាគនិរតីទិស ដែលមានទីតាំងនៅក្បែរទីរួមស្រុកអមលាំង ។ ដោយសារម្ហូបចំណីពុំគ្រប់គ្រាន់ និងដោយសារយើងរស់នៅក្រោមដើមឈើសឹប់ទ្រុបទាំងយប់ទាំងថ្ងៃ សុខភាពរបស់ខ្ញុំកាន់តែទ្រុឌទ្រោមបន្តិចម្តងៗ ។ ភាពទំនេរគ្មានការងារអ្វីធ្វើ រឹតតែធ្វើឲ្យយើងអផ្សុកខ្លាំងឡើងៗ ។ ម្យ៉ាងទៀត និន្នាការនយោបាយតាមគន្លងចិនក្រហម និងផ្នត់គំនិតនិយមហួសហេតុរបស់ស្ហួលខ្មែរក្រហមភាគច្រើនរឹតតែធ្វើឲ្យយើងស្រងាកចិត្តយ៉ាងខ្លាំង ។ ការជួបពិភាក្សាជាហូរហែជាមួយ“ស្ហួលខ្មែរក្រហម” រឹតតែធ្វើឲ្យយើងអស់សង្ឃឹមថា ខ្មែរខាងណោះនិងខ្មែរខាងណេះប្រហែលពុំអាចធ្វើការចរចាសម្រុះសម្រួលគ្នាកើតទេ ។ បន្តិចម្តងៗយើងកាន់តែយល់នូវឥរិយាបថពិតប្រាកដរបស់ខ្មែរក្រហម ។*

*សំណួរទាំងអម្បាលម៉ានដែលយើងរកចម្លើយពុំឃើញ មិនសមហេតុផល ឥឡូវយើងចូលមកប្រឡូកក្នុងចម្លើយទាំងនោះហើយ ។ ចំពោះយើងៗប្រកាន់ជំហរតែមួយរបស់យើង គឺៈ “សង្គមខ្មែរ និង លទ្ធិកុម្មុយនិស្ត” មិនស៊ីចង្វាក់គ្នាទេ ។ យើងធ្លាប់ល្បងធ្វើការត្រិះរិះខ្លះៗមកហើយ ទៅលើទំនាស់ធំៗរវាងសង្គមជាតិខ្មែរនិងលទ្ធិក្រហមនេះ ។*

*ថ្ងៃ២៦ ឧសភា ដល់ថ្ងៃ៣ ខែមិថុនា ១៩៧២*

*នៅល្ងាចថ្ងៃ២៦ ឧសភា មិត្តនាគ បានប្រាប់ឲ្យយើងរៀបចំអីវ៉ាន់ដើម្បីទៅចូលរួមក្នុងមហាសន្និបាតបញ្ញវន្តនឹងគេ ។ យើងបានទទួលមុងមួយ ខោអាវខ្មៅ១សម្រាប់ និងស្បោង* **(sac à dos)** *ខ្មៅមួយពីមិត្តនាគ ។ នៅវេលាម៉ោង៥ល្ងាច លោក រស់ ជាខ្មៅ មកនាំយើងទៅចូលរួមក្នុងមហាសន្និបាតដែលនឹងធ្វើឡើងនៅក្នុងសាលារៀន “នយោបាយ”នៅខាងជើងភូមិតាំងខ្មៅ ។ នៅទីនោះ យើងបានជួបសន្ទនាជាមួយវរជនសំខាន់ៗជាច្រើនដែលបានបាត់ខ្លួនពីក្រុងភ្នំពេញ ។ ទ្រង់ នរោត្តម ភូរិស្សរា ដែលកំពុងឈរនិយាយជាមួយលោក ហ៊ូ យន់ បានស្ទុះមកចាប់ដៃយើងមុនគេ ។ បន្ទាប់មកយើងក៏សម្តែងការគួរសមចំពោះ “សមមិត្ត”ឯទៀតៗមានជាអាទិ៍ លោកវេជ្ជបណ្ឌិត ជួន ជឿន និងភរិយា លោកវេជ្ជបណ្ឌិត ឌី ផុន ហៅ ធុក, លោក ឃៀង ការុន លោក ភោគ ឆាយ ហៅ ណាង, លោក ធុច រិន ហៅ គ្រិន, លោក ម៉ែន នីថូ ហៅ ដន, លោក ងួន អេង ហៅ នី, លោក ចន្ទ បុប្ផា ហៅ ខុម (អតីតចៅក្រម), លោក យូ ថាន ហៅ ផល (អតីតសាស្ត្រាចារ្យ), លោក សៀក តឹកឆាយ ហៅ ថន, លោក ស្រី ដួង ហៅ ខែ (វិស្វករ), លោក ឌៀន ភីកាន ហៅ រិន (អតីតគ្រូបង្រៀន) និងពួកបញ្ញាជនដទៃទៀតដែលមានទាំងអស់ប្រហែល៥០ ឬ ៦០នាក់ ។*

*នៅជុំវិញសាលារៀននយោបាយ គេមានសង់រោងប្រាំបុ ប្រាំមួយ សម្រាប់ធ្វើជាកន្លែងដំណេក និងរោងបាយធំមួយ ។ មិត្តនារីមួយក្រុមទទួលភារៈរៀបចំម្ហូបចំណីនិងថ្នាំសង្កូវសម្រាប់ពួកបញ្ញាជនទាំងអស់ ។ គេបានរៀបចំកម្មវិធីដូចតទៅគឺៈ រាល់ព្រឹក*

- *ម៉ោង៦និង៣០នាទីៈ ស្រស់ស្រូបបបរបុបាយ*
- *ម៉ោង៧ដល់ម៉ោង១១ៈ ប្រជុំពិភាក្សាក្នុងសាលារៀន*
- *ម៉ោង១១និង៣០នាទីៈ បាយថ្ងៃត្រង់*
- *ម៉ោង១៤ដល់ម៉ោង១៧ៈ ប្រជុំពិភាក្សាក្នុងសាលារៀន*
- *ម៉ោង១៧និង៣០នាទីៈ បាយល្ងាច*
- *ម៉ោង២០ដល់ម៉ោង២១ឬ២២ៈ ប្រជុំធ្វើការទិតៀននិងស្វ័យទិតៀនតាមពួកនីមួយៗ ដែលគេនិយមហៅថា ប្រជុំជីវភាព ។*

*កិច្ចការសន្និបាតនេះ រៀបចំឡើងដោយគណៈកម្មាការរណសិរ្សក្រុងភ្នំពេញ ដែលមានសមាសភាពដូចតទៅៈ*

*១) នរោត្តម ភូរិស្សរា ហៅ កែនៈ ប្រធាន*

*២) លោកវេជ្ជបណ្ឌិត ជួន ជឿន ហៅ ប៉ែនៈ អនុប្រធាន*

*៣) លោក រស់ ជាខ្មៅ ហៅ ជាតិៈ សមាជិកទទួលបន្ទុក*

ខាងសារពត៌មាន ។

៤) លោក ងួន អេង: សមាជិកតំណាងសហជីពកម្មករ និង ពលករ ។

៥) លោក ភោគ ឆាយៈ សមាជិក តំណាងនិស្សិត និង បញ្ញាជន ។

៦) អ្នកស្រី ខៀវ ប៉ុណ្ណារីៈ សមាជិក តំណាងនារីប្រជាធិបតេយ្យ

ភូមិភាគពិសេសរបស់ខ្មែរក្រហមនេះមានភារៈទទួលត្រួតត្រាកាន់កាប់ទឹកដីជុំវិញភ្នំពេញនិងក្រុងភ្នំពេញ ដូចយោធាភូមិភាគរបស់យើងដែរ (RMS) ។

នៅថ្ងៃ២៧ ឧសភា វេលាម៉ោង៧ព្រឹក លោក រស់ ជាទ្វោ បានឡើងប្រកាសកម្មវិធីដូនអង្គប្រជុំស្តាប់ និងចាត់ចែងរៀបចំសមាជិកទាំងអស់ជាពួកៗ រួចក៏ផ្ទេរសម្តីជូនទៅទ្រង់ ភូរិស្សរា ។ ទ្រង់ ភូរិស្សរា ក្រោយពីបានឡើងថ្លែងសុន្ទរកថា ស្វាគមន៍និងជូនពរដល់ជោគជ័យនៃមហាសន្និបាតមក ក៏ជូនសម្តីទៅលោក ហ៊ូ យន់ តទៅទៀត ។

នៅក្នុងមហាសន្និបាតបញ្ញវន្តនេះ គេពុំបានប្រាប់ឲ្យដឹងជាមុននូវរបៀបវារៈទេ ។ ដំបូងលោក ហ៊ូ យន់ បានធ្វើវិភាគទៅលើសភាពការណ៍នៅក្នុងសាកលលោក ដែលអាចជះឥទ្ធិពលមកលើ "បដិវត្តន៍" របស់គេ ។ ការធ្វើវិភាគនេះ តាមរបៀបបដិវត្តន៍ម៉ាក្សនិស្ត ឡេនីននិស្ត (*Méthode marxiste léniniste d'analysedes événements sociaux*) ដែលពួកគេឲ្យតម្លៃថាមានលក្ខណៈវិទ្យាសាស្ត្រ ។

បន្ទាប់មកលោក ហ៊ូ យន់ បកមកធ្វើវិភាគទៅលើសភាពការណ៍ក្នុងស្រុក ទៅលើសម្ព័ន្ធភាព និងយុទ្ធសាមគ្គីរវាងប្រជាជនលាវ-ខ្មែរ-វៀតណាម ជាពិសេសនៅលើសម្ព័ន្ធភាពរវាងយៀកកុង យៀកណាមខាងជើង និងខ្មែរក្រហម ។ លោក ហ៊ូ យន់ បានបំភ្លឺអង្គប្រជុំពីជំហរបដិវត្តន៍របស់គេ (ខ្មែរក្រហម) នៅក្នុងស្រុកនិងលើឆាកអន្តរជាតិ ។

នៅក្នុងស្រុកលោក ហ៊ូ យន់ បានសារភាពថា នៅឆ្នាំ ១៩៧០-៧១ ពួកយៀកកុង យៀកណាមខាងជើង(ខ្មែរក្រហមនិយមហៅមិត្តទី៧ តាមជំហរកុម្មុយនិស្តអន្តរជាតិ ។ ចំណែកពួកគេវិញ គេអួតអាងថា គេមានជំហរទី៣ បន្ទាប់ពីចិនប្រជាមានិតនិងអាល់បានី) បានលួចប្លន់ទ្រព្យសម្បត្តិអ្នកស្រុក ជិះជាន់លួចកាប់សម្លាប់ខ្មែរក្រហម ហើយគ្របសង្កត់ទៅលើកម្មាភិបាលខ្មែរក្រហមមែន ព្រោះពេលនោះ កម្លាំងពួកខ្មែរក្រហមនៅខ្សោយខ្វះអាវុធ គ្មានកងទ័ពមាំមួន ។ ពួកយៀកកុង-យៀកណាមខាងជើងបានរឹបអូសសង្កត់សង្កិនយកមាសប្រាក់ប្រជាពលរដ្ឋជាច្រើនយកទៅចិញ្ចឹមពួកវា ដូចជានៅតាមតំបន់ស្អាងកោះធំជាដើម ។ ទាល់តែមកដល់ចុងឆ្នាំ១៩៧១ ទើបពួកខ្មែរក្រហម ឬខ្មែររំដោះបានរើបម្រះខ្លួនមកវិញបាន មិននៅក្រោមឥទ្ធិពលយៀកកុង-យៀកណាមខាងជើងទេ ។ ឥឡូវនេះ យើងប្រកាន់ជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនជាធំ ។ យៀកកុង-យៀកណាមខាងជើងត្រូវគោរពប្រជាជនខ្មែរជាដាច់ខាត គោរពអង្គការខ្មែរ ហើយជួយច្បាំងដេញចក្រពត្តិអាមេរិកាំងនិងបរិវាររវា ។ នេះជាសម្តីរបស់លោក ហ៊ូ យន់ ។

ចំពោះសំណួររបស់ខ្ញុំមួយ ថាតើអង្គការមានការព្រួយបារម្ភខ្លះទេ ហើយបានរៀបចំវិធានការយ៉ាងណាដែរ ចំពោះទ័ពបរទេសយៀកកុង-យៀកណាមខាងជើងនៅក្នុងស្រុកខ្មែរ លោក ហ៊ូ យន់ បានឆ្លើយថា អង្គការមានការព្រួយបារម្ភខ្លះដែរក្នុងរឿងនេះ តែអង្គការបានប្រុងប្រៀបជើងព្រួលស្រេចបាច់អស់ហើយ ។ លោក ហ៊ូ យន់ បានលើកសរសើរជំហររបស់អង្គការបដិវត្តន៍របស់គេលើឆាកអន្តរជាតិ ហើយមានការពោលថា បក្សកុម្មុយនិស្តនិងកូរ៉េ គេសុំរៀនសូត្រពីយើង (ខ្មែរក្រហម) ទៀតផង ។

ចម្លើយនិងសេចក្តីសន្និដ្ឋានរបស់លោក ហ៊ូ យន់ នៅតែធ្វើឲ្យយើងមិនអស់សង្ស័យ និងគ្មានជំនឿដដែល ។

នៅថ្ងៃបន្តបន្ទាប់មកទៀត អង្គប្រជុំបានបើកឲ្យមានការពិភាក្សាប្តូរយោបល់គ្នាទៅវិញទៅមក និងលើកសំណួរផ្សេងៗមកចោទ ។ លោក ភោគ ឆាយ បានធ្វើសេចក្តីរាយការណ៍មួយស្តីអំពីជោគជ័យនៃកងទ័ពគេ ។ នៅល្ងាចថ្ងៃ២ មិថុនា ១៩៧២ លោក រស់ ជាទ្វោ បានរៀបចំនិងថ្លែងសេចក្តីប្រកាសរួមមួយក្រោមចំណងជើងថា "សេចក្តីសម្រេចចិត្តនៃមហាសន្និបាតបញ្ញាជនក្រុងភ្នំពេញ" ។ នៅថ្ងៃដដែលវេលាម៉ោង៦ល្ងាច គេបាន

រៀបចំពិធីជប់លៀងបិទមហាសន្និបាត។

ខ្ញុំភ្លេចជម្រាបថា នៅថ្ងៃ២៩ ឧសភា លោក ជ័យ ជុំ (វរមន្ត្រី) ដែលទើបនឹងចេញពីភ្នំពេញ នៅថ្ងៃ២៨ ឧសភា បានចូលរួមក្នុងមហាសន្និបាតនេះដែរ។

នៅរាត្រីថ្ងៃទី២ មិថុនា គេបានរៀបចំរាត្រីសិល្បៈមួយ សម្តែងដោយក្រុមសិល្បៈភូមិភាគពិសេសមាន របាំ អាយ៉ៃ ចម្រៀង រឿងល្ខោនតូចៗ។ នៅក្នុងរបាំ អាយ៉ៃ ឬរឿងកំប្លែង យើងពិនិត្យឃើញនូវលក្ខណៈប្រាំដែលនូវខ្លឹមសារដដែលៗគ្មានផ្លាស់ប្តូរដូចជា ចម្រៀង "ពួកកងឈ្លបយើង" របាំ "បង្កើតផល" "កុមារឈានមុខ"។ល។ អាយ៉ៃត្រូវច្រៀងតាមពាក្យពេចន៍ដែលគេតែងនិងចងក្រងឲ្យគ្មានការបំភ្លៃក្រៅទេ។ ជាខ្លឹមសារគឺការបញ្ចើចបញ្ចើវណ្ណៈអធន វណ្ណៈកសិករ ពលករ ឲ្យក្រោកឈរតស៊ូកម្ទេចវណ្ណៈជិះជាន់ មានពួកសក្តិភូមិ នាយទុន ប្រតិកិរិយា ចក្រពត្តិអាមេរិកាំង ឲ្យវណ្ណៈដែលត្រូវគេជិះជាន់ (Les exploités) មាន "កំហឹងឆាបឆេះ" ជានិច្ច។ លក្ខណៈទន់ភ្លន់ សន្តិភាព មនុស្សធម៌ ដែលមាននៅក្នុងខ្លឹមសារសិល្បៈបុរាណខ្មែរ បានប្រែក្លាយទៅជាឃោរឃៅ ញាក់កន្ត្រាក់។ ស្នូលខ្មែរក្រហម ប្រហែលជាមានចេតនាបញ្ចូលផ្នត់ "ម៉ាក្សិស្ត" ទៅក្នុងលំនាំបុរាណខ្មែរទេដឹង! យើងចាប់អារម្មណ៍ហាក់ដូចកំពុងទស្សនារបាំចិនកុម្មុយនិស្ត ឬរបាំយួនយៀកណាមខាងជើង! គួរឲ្យសង្វេគដល់ព្រលឹងខ្មែរ!!

## ជីវភាពនៅតាមមន្ទីរ "ការិយាល័យ" ខ្មែរក្រហម

(ថ្ងៃ៣ មិថុនា ១៩៧២ ដល់ថ្ងៃ ១៥ មករា ១៩៧៣)។

នៅថ្ងៃ៣ មិថុនា ១៩៧២ យើងត្រូវ "អង្គការ" ចាត់ឲ្យទៅធ្វើការនៅមន្ទីរឃោសនាការនិងវប្បធម៌នៅភូមិភាគពិសេស។ មិត្ត ឈុន សុកងួន អតីតវិស្វករ ជាប្រធានមន្ទីរឃោសនាការភូមិភាគពិសេសជំនួសលោក ជី គឹមអាន ដែលបានចងកសម្លាប់ខ្លួននៅដើមខែមេសា បាននាំយើងទៅកាន់ភូមិស្រែអណ្តូង។ មន្ទីររបស់យើងសង់នៅលើទួលមួយខ្ពស់ ជាភូមិចាស់ដែលគេបោះបង់ចោលនៅខាងលិចវត្តស្រែអណ្តូង ចម្ងាយប្រមាណ៥០០ម៉ែត្រ ជាប់និងបរិវេណគោកខ្មោចស្រែអណ្តូង។ ពេលយើងចូលទៅដល់ សមាជិកដទៃទៀតមានការចាប់អារម្មណ៍យកចិត្តទុកដាក់នឹងយើងជាខ្លាំង។ ក្រុមរបស់យើងមានសមាជិកទាំងអស់១៣នាក់ ភាគច្រើនជាវិស្វករនិងជាបុគ្គលិកសិក្សាដែលនៅក្រោមឱវាទរបស់លោក រស់ ជាត្ទោ ផ្ទាល់។ លោក រស់ ជាត្ទោ ជាវរជនទី៣ នៅភូមិភាគពិសេស បន្ទាប់ពីមិត្ត សុក ធួក និងមិត្តហង់ មក។ ប្រធានមន្ទីរបានណែនាំពន្យល់យើង ពីវិន័យរបស់អង្គការពីរបបរស់នៅក្នុងសមូហភាពពីភារកិច្ចប្រចាំថ្ងៃដែលយើងត្រូវបំពេញ។ សមាជិកទាំង១៣នាក់ត្រូវចែកជា១៣ពួក។ ប្រធានមន្ទីរចាត់តាំងសហការីណាដែលមានទឹកចិត្តស្មោះត្រង់នឹងអង្គការជាងគេ មានជំហរនយោបាយរឹងប៉ឹងជាងគេ ឲ្យធ្វើជាប្រធានពួក។ ពួកនីមួយៗត្រូវរួមប្រជុំមួយសប្តាហ៍ម្តងដើម្បីតាមដានពិនិត្យជំហរគ្នាទៅវិញទៅមកគេហៅថា "ប្រជុំជីវភាព" ឬប្រជុំធ្វើការរិះគន់និងស្វ័យរិះគន់។ គេនាំគ្នាសន្មតយកល្ងាចថ្ងៃព្រហស្បតិ៍ សម្រាប់ "ប្រជុំពួក" និងល្ងាចថ្ងៃអាទិត្យសម្រាប់ "ប្រជុំក្រុម" គឺប្រជុំសមាជិកគ្រប់ពួកទាំងអស់។

## ទីកន្លែង-ទីតាំង

មន្ទីរនីមួយៗត្រូវសង់ដាច់ឆ្ងាយពីភូមិអ្នកស្រុក ក្បែរប្រភពទឹកមាន ស្ទឹងអូរ ត្រពាំងអណ្តូង ជាដើម នៅក្នុងព្រៃឈើស៊ុបទ្រុប និងនៅក្បែរវាលស្រះណាមួយ។ គេសង់ជាខ្ទមស្លឹកទាបនឹងដីនៅក្រោមដើមឈើធំៗ មានខ្ទមសម្រាប់ធ្វើជាកន្លែងសម្រាក-ដំណេក ខ្ទមសម្រាប់ជាផ្ទះបាយនិងខ្ទមផ្សេងទៀតសម្រាប់ជាកន្លែងធ្វើការ។ នៅក្នុងមន្ទីរឃោសនាភូមិភាគពិសេសមានពុម្ពអក្សរ អង្គុលីលេខ ម៉ាស៊ីនទាញរ៉ូណេអូ ស្តង់ស៊ីលទឹកខ្មៅរ៉ូណេអូ ឯកសារផ្សេង។ល។ នៅក្បែររោងធ្វើការគេមានជីកប៊ុងគ័រ (Bunker) និងលេណដ្ឋានតូចៗជាច្រើនសម្រាប់ជ្រកនៅពេលយន្តហោះទម្លាក់គ្រាប់បែក។ សមាជិកទាំងអស់ព្រមទាំងប្រជាជនចាស់ក្មេង សុទ្ធតែចេះស្តាប់សូរ-សំឡេងយន្តហោះសឹងតែគ្រប់ធុនដែលមានហោះហើរនៅក្នុងទឹកដីខ្មែរ។ គ្រាន់តែឮសូរពីចម្ងាយក្មេងៗអាយុប្រមាណ១០ឆ្នាំអាចដឹងបានភ្លាមថាជាយន្តហោះសង្កេតការណ៍ ឬជាយន្តហោះទម្លាក់គ្រាប់បែកតេ-២៨។

មន្ទីរសម្រាប់កម្មាភិបាល (ក្របខ័ណ្ឌ) សំខាន់ៗច្រើនសង់នៅក្នុងព្រៃស្ងាត់ពីភូមិតូចៗ ដែលជាភូមិបង្អែក ឬភូមិមូលដ្ឋានរបស់គេប្រមាណពី៥០០ម៉ែត្រ។ តាមការសង្កេតទីតាំងរបស់គេ ច្រើននៅក្នុងព្រៃឈើក្រាស់ផង នៅក្បែរវាលស្រែតូចៗផង

ដើម្បីលាក់កំបាំងកុំឲ្យយន្តហោះមើលឃើញ និងដើម្បីឲ្យមានខ្យល់អាកាសចេញចូលបរិបូណ៌ ។

បក្សកុម្មុយនិស្តកម្ពុជា បានបែងចែកតំបន់ដែលគេកាន់កាប់ជាភូមិភាគធំៗដូចតទៅៈ

១) ភូមិភាគនិរតីទិស រួមបញ្ចូលខេត្តកំពត កោះកុង ក្រុងព្រះសីហនុ កំពង់សីលា តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ ឧដុង្គ និងខេត្តកណ្តាល១ភាគ ។

២) ភូមិភាគបូព៌ាទិស រួមបញ្ចូលខេត្តក្រចេះ ស្វាយរៀង ព្រៃវែង កំពង់ចាម ។

៣) ភូមិភាគពាយ័ព្យទិស មានខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ បន្ទាយឆ្មារ ។

៤) ភូមិភាគពោធិ៍សាត់-បាត់ដំបង-ប៉ៃលិន ។

៥) ភូមិភាគពិសេស ទើបបង្កើតថ្មីនៅចុងឆ្នាំ(១៩៧១) សម្រាប់ត្រួតត្រាតំបន់ជុំវិញភ្នំពេញ ។ សព្វថ្ងៃនេះ ភូមិភាគពិសេស តាំងទីបញ្ជាការ និងទីចាត់ការរបស់ខ្លួននៅក្នុងភូមិភាគនិរតីទិស ត្រង់ព្រំប្រទល់ខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំងក្នុងសង្កាត់ពាមប្រាំបីមុម ប៉ែកខាងត្បូងក្នុងស្រុកកំពង់ត្រឡាច និងចាត់តាំងបុគ្គលិករដ្ឋាភិបាលរបស់គេខ្លះទៀត នៅក្នុងខេត្តកំពង់ស្ពឺ (ស្រុកបរសេត) ក្នុងខេត្តកណ្តាល ស្រុកកណ្តាលស្ទឹង-ស្រុកស្អាង (កោះធំ) ។

៦) ខេត្តព្រះវិហារ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តរតនគិរី ត្រូវបានគណៈមជ្ឈិម គណៈកម្មាធិការ (កណ្តាល) នៃបក្សកុម្មុយនិស្តខ្មែរគេបានកាន់កាប់ផ្ទាល់ ។ តាមដែនទីភូមិសាស្ត្រនិងយុទ្ធសាស្ត្រ យើងអាចយល់បានថា ហេតុដូចម្តេចបានជា «គណៈមជ្ឈិម» គេសុខចិត្តកាន់កាប់ភូមិភាគទាំងអស់នេះផ្ទាល់? ខេត្តទាំងអស់នេះជាមូលដ្ឋានយុទ្ធសាស្ត្រយ៉ាងមាំមានព្រំប្រទល់ជាប់ទៅនិងយួន លាវ និង ថៃ ។

ភូមិភាគនីមួយៗមានចែកទៅជាតំបន់ ជាស្រុក ជាឃុំ ភូមិតទៅទៀត ។ លេខាធិការ ឬ ប្រធានភូមិភាគនីមួយៗមានឥទ្ធិពលខ្លាំងណាស់ទៅលើភូមិភាគរបស់ខ្លួន ។ គឺជាអ្នកទទួលខុសត្រូវទាំងស្រុងទៅលើអំណាចនយោបាយ រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច និងយោធា «លេខាភាគ» «ប្រធានភាគ» នេះ សុទ្ធតែជាសមាជិកនៅក្នុង «គណៈមជ្ឈិម» ផង និងជាសមាជិកនៅក្នុង «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (Le GRUNK) ផង ។ គឺជាបញ្ញវន្ត «ស្នូលខ្មែរក្រហម» ដើមចាស់ដែលធ្លាប់ «ជាប់នឹងចលនាកុម្មុយនិស្តខ្មែរ» ពីយូរមកហើយៗជា «បក្សជនពេញលេញ» នៅក្នុងបក្សរបស់គេ ។

នៅភូមិភាគនិរតីទិស វរជនខ្មែរក្រហមសំខាន់ៗមានលោក



កងទ័ពរំដោះ

ជូ ជេត ជាប្រធានភាគ និងជាអនុរដ្ឋមន្ត្រីនៃក្រសួងសុខាភិបាល លោក កោត ឆាយ ហៅ ណាង ជាស្នងការនយោបាយនៅក្នុងកងទ័ពនិរតីទិស លោក ធុច រិន ហៅ គ្រីន (អតីតសាស្ត្រាចារ្យមធ្យមសិក្សា) ជាប្រធានមន្ទីរវប្បធម៌និងឃោសនាការ តាម៉ុក (ឈ្មោះបដិវត្តន៍) ជាមេបញ្ជាការកងទ័ពភូមិភាគនិរតីទិស ។ ទីបាត់ការធំរបស់គេនៅក្នុងតំបន់អមលាំង ។ នៅទីនោះមានរោងពុម្ពផ្សាយកាសែតមួយឈ្មោះ «ប្រជាជនបដិវត្តន៍» ដឹកនាំដោយលោក ធុច រិន ផ្ទាល់ ។ តំបន់ភូមិភាគនិរតីនេះមានទំហំធំជាងគេទាំងអស់ មានកម្លាំងទ័ពខ្លាំងជាងគេ និងមាន«ក្របខ័ណ្ឌ» ដឹកនាំសំខាន់ៗជាងគេ ។

តាមសេចក្តីរាយការណ៍របស់លោក កោត ឆាយ ផ្ញើជូនមហាសន្និបាតនៅចុងខែឧសភា ១៩៧២ ថា ចំណោយក្នុងមួយ



ខែ១ សម្រាប់ភូមិភាគនិរតីទិសឡើងដល់ជាងពីរលានរៀលសម្រាប់បុគ្គលិករដ្ឋបាលនិងយោធាខ្មែរក្រហមដែលត្រូវបានក្នុងមួយខែ ១៣៥រៀល ក្នុងបុគ្គលិកម្នាក់ៗ ។

ភូមិភាគពិសេស នៅក្រោមការត្រួតត្រារបស់លោក សុក ធូក ហៅ វន មានងារជាប្រធានភាគផង ជាអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិផង ។ បន្ទាប់មកទៀតមានមិត្ត ហង់ (ឈ្មោះបដិវត្តន៍) មិត្ត រស់ ជាទ្វោ ហៅ ជាតិ ។

វរជនខ្មែរក្រហមសំខាន់ៗនៅក្នុង "គណៈមជ្ឈិម" ច្រើនជាបញ្ញវន្តដែលបាត់ខ្លួនពីភ្នំពេញនៅចន្លោះឆ្នាំ១៩៦២ និង ១៩៦៨ មានជាអាទិ៍:

លោក ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានិងជាអគ្គបញ្ជាការនៃ "កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា" ។ លោក ខៀវ សំផន ជាវរជនទីបីនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។

លោក សាឡុត ស (វរជនទី១) ជាអគ្គលេខាធិការនៃបក្សកុម្មុយនិស្តកម្ពុជា ។

លោក អៀង សារី ជាវរជនទី២ នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។

លោក សុន សេន ជាវរជនទី៤ ។

លោក កុយ ធួន ជាអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។

លោក ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ ។

លោក ទីវ អុល ជាអនុរដ្ឋមន្ត្រីក្រសួងឃោសនាការ ។

លោក ហ៊ូ យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកខាងរៀបចំជនបទនិងសហករណ៍ ។

អ្នកស្រី ខៀវ ប៉ុណ្ណារី អនុរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងយុវជន ។

លោក ជូ ជេត អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

លោក សុក ធួក អនុរដ្ឋមន្ត្រីសន្តិសុខជាតិ ។

លោក ប៉ុក ឌើសកុមារ អនុរដ្ឋមន្ត្រីក្រសួងការបរទេស ។

លោក សុន សេន និងលោក ប៉ុក ឌើសកុមារ

ក្រោយពេលដែលអាជ្ញាធរយើងនៅភ្នំពេញផ្សាយថាបាត់ខ្លួនហើយបានលាក់ខ្លួនសម្ងំនៅក្នុងក្រុងភ្នំពេញអស់រយៈពេលមួយឆ្នាំទៀត ។ នេះជាពត៌មានដែលយើងបានទទួលពីវរជនខ្មែរក្រហមនៅក្នុងព្រៃ ។

ចំពោះក្របខ័ណ្ឌខ្មែរក្រហមសំខាន់ៗដែលបានបាត់បង់ជីវិតនៅក្នុងព្រៃវិញ មានលោក អ៊ុច វ៉ែន (សាស្ត្រាចារ្យ) ស្លាប់ដោយជំងឺគ្រុនពោះវៀននិងលោក ជី គឹមអាន (វិស្វករ) ស្លាប់ដោយធ្វើអត្តឃាតខ្លួនឯងនៅភូមិស្រែអណ្តូង ។

មន្ទីរឃោសនាការនិងវប្បធម៌ភូមិភាគពិសេស តាំងនៅភូមិស្រែអណ្តូងរហូតមកដល់ថ្ងៃ៧ សីហា ១៩៧២ ហើយបានរុះរើទៅធ្វើនៅខាងកើតភូមិស្រែឫស្សីក្នុងតំបន់ដាច់ស្រយាល ។ នៅដើមខែកក្កដា យន្តហោះបានទៅទម្លាក់គ្រាប់បែកជាញឹកញាប់ នៅត្រង់ភូមិតាំងខ្មៅនិងភូមិស្រែអណ្តូង ។

នៅក្នុងមន្ទីរឃោសនាការ យើងបានរស់នៅក្នុងរង្វង់សមមិត្តដែលមានទស្សនៈបដិវត្តន៍សង្គមនិយមចង្អៀតចង្អល់និងឆេវឆាវហួសប្រមាណ ។ សមាជិកទាំងនោះច្រើនជាយុវជនក្មេងៗធ្លាប់ជាប់នឹងចលនាយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) សម្ងាត់នៅភ្នំពេញ ធ្លាប់ជាសមាជិកនៅក្នុងសមាគមនិស្សិតខ្មែរ (AGEK) បំប៉នដោយប៉េកាំង ។

មន្ទីរសិល្បៈភូមិភាគពិសេស ស្ថិតនៅប៉ែកខាងនិរតីភូមិស្រែឫស្សីចម្ងាយប្រហែល៦០០ម៉ែត្រ ។ មានយុវជនតូចៗនិងអ្នកដឹកនាំ សិល្បៈទាំងអស់ជាង៧០នាក់នៅទីនោះ ភាគច្រើនជាកូនកសិករ មានខ្លះជាកូនវរជនស្នូលខ្មែរក្រហម មានកូនលោក អៀង សារី និងកូនលោក សៀង ប៉ោសែ ជាដើម ។

នៅខាងកើតមន្ទីរឃោសនាការប្រមាណ៣គ.ម គឺនៅខាងលិចភូមិហុងត្នោតប្រមាណ៨០០ម៉ែត្រ មានមន្ទីរពេទ្យធំរបស់ភូមិភាគពិសេស សង់នៅប្របមាត់អូរត្រង់ភូមិចាស់ដែលគេបោះបង់ចោល ។ មន្ទីរពេទ្យនេះអាចឲ្យអ្នកជំងឺ អ្នករបួសមកដេកព្យាបាលបានរាប់រយនាក់ ។ គឺនៅក្នុងមន្ទីរពេទ្យនេះហើយ ដែលលោកវេជ្ជបណ្ឌិត ជួន ជឿន លោកវេជ្ជបណ្ឌិត ឌី ផុន លោកសាស្ត្រាចារ្យ យៀង ការុន និងលោកវិស្វករ ផួន អេង នៅធ្វើការអមដោយគ្រូពេទ្យខ្មែរក្រហមខ្លះទៀតដែលទើបមកពីហាណូយ ។

**(នៅមានត)**

**អ៊ិត សារិន**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៥៧៨ | វង់ សុខា | កម្មករ | តម្បាញត-៥ | ១១-៤-៧៦ | ២៧-៥-៧៦ |
| ៥៧៩ | ឆាយ បួយ | កម្មករ | តម្បាញត-៥ | ?? | ២៧-៥-៧៦ |
| ៥៨០ | គីម សុធានី ហៅ យន | កម្មករ | រោងចក្រកង់ឡាន | ?? | ២៧-៥-៧៦ |
| ៥៨១ | ពេញ ស៊ីង ហៅ ឈឹម គីមលី | កម្មករ | រោងចក្រកង់ឡាន | ?? | ២៧-៥-៧៦ |
| ៥៨២ | នេត សុផល | កម្មករ | តម្បាញត-៤ | ?? | ២៧-៥-៧៦ |
| ៥៨៣ | កូ គីមឈុន | កម្មករ | ព្រៃនប់ | ?? | ២៧-៥-៧៦ |
| ៥៨៤ | ហ៊ុល ហ៊ាញ ហៅ វៃ | កងហា | ៩៩ | ?? | ២៧-៥-៧៦ |
| ៥៨៥ | សួន ស្រេង | កងហា | ៩៩ | ?? | ២៧-៥-៧៦ |
| ៥៨៦ | នួន ស្រី | យុទ្ធជន | ០៤ | ?? | ២៧-៥-៧៦ |
| ៥៨៧ | ខៀវ ម៉ុង ហៅ សារី | សេដ្ឋកិច្ច | ២៦០ | ?? | ២៧-៥-៧៦ |
| ៥៨៨ | ស៊ុម តួ ហៅ គក | សេដ្ឋកិច្ច | ១៣៨ | ?? | ២៧-៥-៧៦ |
| ៥៨៩ | ញ៉ិល ហ៊ុម ហៅ ធី | យុទ្ធជន | ១៣៨ | ?? | ២៧-៥-៧៦ |
| ៥៩០ | ឯក ង៉ែត | យុទ្ធជន | ១២៧ | ?? | ២៧-៥-៧៦ |
| ៥៩១ | ជា រិន | យុទ្ធជន | ២៦៥ | ?? | ២៧-៥-៧៦ |
| ៥៩២ | ស៊ឹម យុយ | យុទ្ធជន | ២៦៥ | ?? | ២៧-៥-៧៦ |
| ៥៩៣ | ហ៊ឹម ហាក់លី | យុទ្ធជន | ១១២ | ?? | ២៧-៥-៧៦ |
| ៥៩៤ | ថៃ ស្រេង | យុទ្ធជន | ១១២ | ?? | ២៧-៥-៧៦ |
| ៥៩៥ | អ៊ុក មុត | យុទ្ធជន | ១២៧ | ?? | ២៧-៥-៧៦ |
| ៥៩៦ | ខៀវ ស៊ុន ហៅ សារ៉ាត | មេពួក | ១៤៣ | ?? | ២៧-៥-៧៦ |
| ៥៩៧ | សៅ សុក | យុទ្ធជន | ១២៧ | ?? | ២៧-៥-៧៦ |
| ៥៩៨ | ម៉ៅ ឈុំ | កងរយ | ១៣៨ | ?? | ២៧-៥-៧៦ |
| ៥៩៩ | ដេង ឈឿន | ចោរព្រៃ | តំបន់៣៥ | ៥-៤-៧៦ | ២៧-៥-៧៦ |
| ៦០០ | សៅ ដេត | ចោរព្រៃ | តំបន់៣៥ | ៥-៤-៧៦ | ២៧-៥-៧៦ |
| ៦០១ | អ៊ុម ធឹម | ចោរព្រៃ | តំបន់៣៧ | ៥-៤-៧៦ | ២៧-៥-៧៦ |
| ៦០២ | កុល សឿន | ចោរព្រៃ | ព្រៃនប់ | ៥-៤-៧៦ | ២៧-៥-៧៦ |
| ៦០៣ | បួយ ស្រេង ហៅ ប៉េង ស្រួយ | ចាងហ្វាងកាសែត | តំបន់២៥ | ២២-២-៧៦ | ២៧-៥-៧៦ |

(នៅមានត)



# មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ

## ការចងចាំរបស់កុមារីកម្ពុជាម្នាក់

**លឿង អ៊ឹង**

***(តពីលេខមុន)***

«នៅខាងស្តាំដៃ មានតុមួយដែលសមមិត្តម្នាក់អង្គុយរង់ចាំជួយបងប្អូន ។ អ្នកទាំងឡាយណាដែលធ្លាប់ធ្វើការឲ្យរដ្ឋាភិបាលរបបសាធារណរដ្ឋខ្មែរនិងធ្លាប់ធ្វើទាហាន ឬអ្នកនយោបាយកាលពីមុន សូមដើរចេញមកក្រៅជួរ ដើម្បីចុះឈ្មោះចូលធ្វើការ ។ អង្គការត្រូវការអ្នកទាំងអស់នេះឲ្យចូលធ្វើការតែម្តង» ។ ពេលមើលទៅកងទ័ពខ្មែរក្រហមទាំងអស់នោះ ភាពរសាប់រសល់បានរីករាលដាលពេញខ្លួនប្រាណរបស់ខ្ញុំ ហើយធ្វើឲ្យខ្ញុំមានអារម្មណ៍ដូចចង់ក្អួត ។ ភ្លាមៗនោះ ប៉ាបានប្រមែប្រមូលគ្រួសារយើងឲ្យឈរក្នុងជួរជាមួយគ្រួសារអ្នកស្រែដទៃទៀត ។ ប៉ាបង្គាប់យ៉ាងម៉ឺងម៉ាត់ថា «ចាំណាំ យើងគឺជាគ្រួសារអ្នកស្រែ ហើយចូរកូនឲ្យអ្វីៗទាំងអស់ទៅពួកគេទាំងនោះចុះ បើគេចង់បាន កុំតវ៉ាជាមួយគេពុទេ ។ កុំនិយាយអ្វីទាំងអស់ទុកឲ្យប៉ាជាអ្នកនិយាយ ហើយកុំដើរទៅមុខ លុះត្រាតែប៉ាប្រាប់ឯងទាំងអស់គ្នាឲ្យដើរ» ។ ពេលឈរប្រជ្រៀតគ្នាក្នុងជួរជាមួយប្រជាជនជាច្រើនទៀត ច្រមុះខ្ញុំធុំក្លិនខ្លួនខ្មោះៗរបស់មនុស្សដែលមិនបានមុជទឹកតាំងពីច្រើនថ្ងៃមកហើយ ។ ដើម្បីកុំឲ្យធុំក្លិនទៀត ខ្ញុំក៏ទាញក្រមាមករុំជុំវិញច្រមុះនិងមាត់របស់ខ្ញុំ ។ នៅខាងមុខយើង ជួរប្រជាជនត្រូវបានបែកចេញជាពីរ ពេលដែលក្រុមទាហានចាស់ៗបុគ្គលិករដ្ឋាភិបាលអ្នកនយោបាយរបស់របបមុន ដើរទៅរកតុមួយដើម្បីចុះឈ្មោះចូលធ្វើការ ។ បេះដូងរបស់ខ្ញុំលោតគុកកក្កាក់ៗ ប៉ុន្តែខ្ញុំមិននិយាយអ្វីទាំងអស់ ហើយខ្ញុំផ្អែកខ្លួនរបស់ខ្ញុំទៅលើជើងប៉ា ប៉ាយកដៃរបស់គាត់មកដាក់លើក្បាលខ្ញុំ ហើយដៃនេះមានតួនាទីដូចជាជួយបាំងកម្តៅថ្ងៃឲ្យខ្ញុំនិងការពារខ្ញុំអ៊ីចឹង ។ ប៉ុន្មាននាទីក្រោយមក ខ្ញុំមានអារម្មណ៍ថា ខ្លួនខ្ញុំបានទទួលភាពកក់ក្តៅ ហើយចង្វាក់បេះដូងខ្ញុំចាប់ផ្តើមលោតមួយៗឡើងវិញ ។

កងទ័ពខ្មែរក្រហមដើរមកឈរពីមុខយើងហើយស្រែកដាក់ហ្វូងមនុស្ស ប៉ុន្តែខ្ញុំមិនយល់នូវអ្វីដែលពួកគេនិយាយទេ ។ ភ្លាមនោះ កងទ័ពខ្មែរក្រហមម្នាក់បានកន្ត្រាក់ថង់មួយចេញពីស្មារបស់បុរសម្នាក់ ដែលកំពុងឈរនៅក្នុងជួរជាមួយយើង ហើយរលាក់របស់របរក្នុងស្បោងនោះទម្លាក់ទៅលើដី ។ ពីគំនរអីវ៉ាន់ដែលខ្ចាត់ខ្ចាយនៅលើដី កងទ័ពខ្មែរក្រហមបានរើសឯកសណ្ឋានទាហាន លន់ ណុល ឡើង ។ ឃើញឯកសណ្ឋាននេះ កងទ័ពខ្មែរក្រហមក៏ចាប់ផ្តើមនិយាយទិះតៀនបុរសនោះ ហើយរុញគាត់ឲ្យទៅកងទ័ពម្នាក់ទៀត ដែលឈរនៅក្បែរនោះដែរ ។ បន្ទាប់មក កងទ័ពខ្មែរក្រហមបានដើរសំដៅទៅគ្រួសារបន្ទាប់ដែលឈរក្នុងជួរតែមួយ ។

ដោយខ្លួនប្រាណល្ងិតល្ងៃ បុរសដែលមានឯកសណ្ឋានទាហាន លន់ ណុល នៅក្នុងថង់របស់ខ្លួននោះ មិនបានប្រឆាំងតបតនឹងកងទ័ពខ្មែរក្រហមវិញទេ ពេលដែលគេភ្ជង់គាត់នឹងកាំភ្លើងឲ្យដើរចេញទៅ ។

បន្ទាប់ពីឈរជាច្រើនម៉ោងរួចមក ដល់វេនដែលយើងត្រូវគេសួរសំណួរម្តង ។ ខ្ញុំអាចនិយាយថា យើងបានឈរនៅទីនេះជាច្រើនម៉ោង ពីព្រោះពន្លឺថ្ងៃបានចាំងចុះមកក្រោយខ្នងរបស់ខ្ញុំ ហើយពុំមែនចាំងពីលើក្បាលខ្ញុំទៀតទេ ។ នៅពេលដែលខ្មែរក្រហមដើរសំដៅមករកយើង ខ្ញុំនឹកភ័យបុកពោះដួចៗ ។ ខ្ញុំក៏

បង្អិតខ្លួនទៅជិតជើងប៉ា ហើយយកដៃឈោងចាប់ដៃគាត់ ។ ដៃរបស់ប៉ាធំណាស់សម្រាប់ដៃខ្ញុំ ដូច្នេះខ្ញុំអាចចាប់ច្បាមបានតែចង្អុលដៃរបស់គាត់ប៉ុណ្ណោះ ។

កងទ័ពម្នាក់សួរមកប៉ាយ៉ាងសោះកក្រោះថា “មិត្តឯងធ្វើការអ្វី?” ។

“ខ្ញុំធ្វើការជាអ្នកវេចខ្ចប់អីវ៉ាន់នៅក្នុងផែកប៉ាល់” ។

កងទ័ពចង្អុលទៅ ម៉ា ហើយសួរថា “ចុះមិត្តឯងធ្វើអីដែរ?” ។

ម៉ាទម្លាក់ភ្នែកចុះក្រោមបណ្តើរ លើក ហ៊ុច ប្តូរទៅត្រគាកម្ខាងទៀតរបស់គាត់បណ្តើរ ហើយឆ្លើយក្នុងសំឡេងខ្សាវៗទៅកាន់កងទ័ពនោះថា “ខ្ញុំលក់ខោអាវចាស់ៗ នៅក្នុងផ្សារ” ។

កងទ័ពនោះចាប់ផ្តើមរើកកាយថង់អីវ៉ាន់របស់យើងពីមួយទៅមួយ ។ បន្ទាប់មកក៏ឱនក្បាលចុះ ហើយយកដៃបើកគម្របឆ្នាំងបាយដែលនៅជិតជើងរបស់ប៉ា ។ ដោយឃើញកងទ័ពឆែកឆេរឆ្នាំងរបស់យើង ខ្ញុំក៏ក្តាប់ដៃប៉ារបស់ខ្ញុំកាន់តែខ្លាំងឡើងៗ ហើយបេះដូងរបស់ខ្ញុំលោតលឿនខុសពីធម្មតា ។ មុខរបស់កងទ័ពឱនមកជិតមុខខ្ញុំ ដោយមូលហេតុនេះ ខ្ញុំក៏ទម្លាក់ភ្នែកសម្លឹងទៅចុងជើងដ៏គគ្រិចរបស់ខ្ញុំ ។ ខ្ញុំមិនហ៊ានសម្លឹងភ្នែកកងទ័ពនោះទេ ពីព្រោះប៉ាប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំសម្លឹងមើលភ្នែករបស់កងទ័ពទាំងនោះ ខ្ញុំនឹងឃើញបិសាច ។

“មិនអីទេ មិត្តឯងត្រូវបោសសម្អាតហើយ ដូច្នេះមិត្តឯងអាចទៅបាន” ។

“អរគុណសមមិត្ត” ប៉ានិយាយទាំងកាយវិការញ័រៗ ដោយងក់ក្បាលដក់ៗដាក់កងទ័ពនោះ ។ កងទ័ពគ្រាន់តែលើកដៃជាសញ្ញាឲ្យប៉ាប្រញាប់ដើរចេញទៅ ហើយគេក៏សម្លឹងទៅរកអ្នកដែលឈរបន្ទាប់ពីប៉ាបន្តទៀត ។ បន្ទាប់ពីឆ្លងកាត់ចំណុចឆែកឆេរដោយសុវត្ថិភាព យើងបានបន្តដំណើរទៅមុខទៀតជាច្រើនម៉ោង រហូតដល់ថ្ងៃលិចក្រោយភ្នំ ។ ពេលថ្មើរណេះពិភពលោកបានប្រែជាកន្លែងនៃស្រមោលអន្ធការម្តងទៀត ។ នៅក្នុងចំណោមហ្វូងមនុស្សដ៏ច្រើនកុះករ ប៉ាក្រឡេកឃើញមានវាលស្មៅទំនេរមួយនៅក្បែរផ្លូវ ។ ចំណែកឯ ម៉ា ដាក់ ហ៊ុច ចុះក្បែរខ្ញុំ ហើយប្រាប់ខ្ញុំឲ្យមើលនាង ។ ពេល ហ៊ុច អង្គុយជិតខ្ញុំ ខ្ញុំមានការរន្ធត់ចិត្តជាខ្លាំង ដោយឃើញផ្ទៃមុខរបស់នាងឡើងស្លេកស្លាំង ។ ប្អូន ហ៊ុច ដកដង្ហើមមួយៗ ហើយខំប្រឹងបើកភ្នែក ប៉ុន្តែចុងបញ្ចប់នាងក៏ចុះចាញ់ភាពងងុយ ហើយគេងលក់ទៅ ។ ពោះរបស់នាងកូរឮសូរគ្រុកៗដូចជាពោះរបស់ខ្ញុំដែរ ។ ដោយដឹងថា ខ្ញុំនឹងគ្មានអ្វីញ៉ាំនោះ ខ្ញុំក៏ទម្រេតក្បាលទៅលើបង្វិចខោអាវតូចមួយដែលដាក់ជិត ហ៊ុច ហើយមួយរំពេចក្រោយមក ខ្ញុំក៏គេងលង់លក់ដែរ ។ នៅពេលដែលខ្ញុំភ្ញាក់ពីដេក ខ្ញុំក្រោកអង្គុយឆក់នៅលើកន្ទេលកក់ បងតារា កំពុងរុញម្ហូបមកដាក់មាត់ខ្ញុំ គាត់និយាយមករកខ្ញុំថា “ញ៉ាំអានេះទៅដុំបាយជាមួយផ្សិតដែល បងឃួយ និង បងម៉េង បេះពីព្រៃមក” ។

ទោះបីជាខ្ញុំបើកភ្នែកមិនទាន់ស្រួលបួលក៏ដោយ ក៏ដុំបាយរមៀលចុះយឺតៗតាមបំពង់កខ្ញុំ ហើយធ្វើឲ្យពោះរបស់ខ្ញុំកំពុងកូរខ្ញុំស្រាកចុះ ។ បន្ទាប់ពីខ្ញុំញ៉ាំចំណែកតូចរបស់ខ្ញុំរួចហើយ ខ្ញុំក៏ទម្រេតខ្លួនគេងទៀត បន្សល់ទុកឲ្យពិភពលោកដែលពោរពេញដោយកងទ័ពខ្មែរក្រហមនៅពីក្រោយភាពលង់លក់របស់ខ្ញុំ ។

នៅពាក់កណ្តាលអធ្រាត្រនោះ ខ្ញុំសុបិនឃើញខ្ញុំបានចូលរួមការដើរហែក្បួនក្នុងពិធីចូលឆ្នាំខ្មែរ ។ បើគិតតាមចន្ទគតិ ពិធីចូលឆ្នាំខ្មែរឆ្នាំនេះគឺត្រូវនឹងថ្ងៃទី១៣ ខែមេសា ។ តាមប្រពៃណីខ្មែរយើងប្រារព្ធពិធីចូលឆ្នាំក្នុងរយៈពេលបីថ្ងៃបីយប់ ដោយមានការដើរហែក្បួន ការជប់លៀង និង ការប្រគុំតន្ត្រីអឺងកង ស្ទើរតែគ្រប់ទិសទី ។ ខ្ញុំសុបិនលាន់ឮសំឡេងប្រសៗនៃស្នូរគាំជ្រូច និងសម្រែកសប្បាយរីករាយដើម្បីអបអរសាទរពិធីចូលឆ្នាំថ្មី ។ មានចំណីអាហារគ្រប់ប្រភេទដាក់នៅលើតុ ដូចជា នំពងទាដុត ស្ករគ្រាប់ពណ៌ក្រហម ជ្រូកខ្វៃ ហើយនិងមីឆា ។ អ្វីៗទាំងអស់សុទ្ធតែមានពណ៌ក្រហម សូម្បីតែខ្ញុំក៏ស្លៀកសម្លៀកបំពាក់ពណ៌ក្រហម ដែលម៉ាកាត់ឲ្យក្នុងឱកាសដ៏ពិសេសនេះដែរ ។ ក្នុងវប្បធម៌ជនជាតិចិន វាមិនមែនជាការសមរម្យទេដែលមនុស្សស្រីស្លៀកពាក់សំពត់អាវពណ៌ក្រហម ពីព្រោះពណ៌នោះវាទាក់ទាញអារម្មណ៍របស់អ្នកដទៃខ្លាំងពេក ។ មនុស្សស្រីដែលចង់បានការចាប់អារម្មណ៍ខ្លាំងពីអ្នកដទៃដោយស្លៀកពាក់សំពត់អាវពណ៌ក្រហម ជាទូទៅត្រូវបានគេចាត់ទុកថាជា “ស្រីមិនល្អ” ហើយ “មិនសូវសមរម្យ” ។ ជាងនេះទៅទៀត គេអាចនិយាយបានថា ស្រីទាំងនោះមានប្រភពមកពីគ្រួសារមិនល្អណាមួយដង ។ ប៉ុន្តែក្នុងពិធីចូលឆ្នាំថ្មី ដែលជាពិធីដ៏

ពិសេសមួយនរណាៗក៏អាចស្លៀកពាក់សំពត់អាវពណ៌ក្រហមបានដែរនៅក្នុងឱកាសនេះ ។ នៅក្នុងសុបិន ខ្ញុំឃើញ ជួ កំពុងតែឈរទះដៃក្បែរខ្ញុំ ចំណែកឯ ហ៊ុច កំពុងសើចក្អឹកៗ ហើយព្យាយាមដេញចាប់ខ្ញុំនៅពេលដែលខ្ញុំរត់ចុះរត់ឡើងក្នុងផ្ទះ ។ យើងទាំងអស់គ្នាស្លៀកសម្លៀកបំពាក់ដូចៗគ្នា មើលទៅយើងទាំងអស់គ្នាស្អាតមែនទែន ។ យើងមានចងបូក្រហមនៅលើក្បាលផង យើងលាបថ្ពាល់និងបបូរមាត់ឡើងក្រហមទុំ ។ បងប្អូនស្រីៗរបស់ខ្ញុំហើយនិងខ្ញុំកាន់ដៃគ្នាសើចសប្បាយក្អាកក្អាយនៅក្រោមស្នូរកាំជ្រួចផ្ទុះ ។ នៅពេលព្រឹកថ្ងៃបន្ទាប់ ខ្ញុំត្រូវដាស់ឲ្យភ្ញាក់ដោយសារសំឡេងបងប្រុសនិងប៉ារបស់ខ្ញុំដែលកំពុងខ្សឹបខ្សៀវគ្នាទៅវិញទៅមកពីរឿងហេតុដែលកើតឡើងកាលពីពេលយប់មិញ ។

ម៉េង និយាយទៅកាន់ប៉ាដោយសំឡេងភ័យញ័រថា "ប៉ាប៉ា បុរសម្នាក់បានប្រាប់ខ្ញុំថា សំឡេងយប់មិញជាសំឡេងកាំភ្លើងរបស់កងទ័ពខ្មែរក្រហមបាញ់សម្លាប់មនុស្សដែលចុះឈ្មោះធ្វើការកាលពីម្សិលមិញ ។ ពួកវាបានសម្លាប់អ្នកដែលចុះឈ្មោះទាំងអស់គ្មានសល់ម្នាក់" ។ សម្តីរបស់ បងម៉េង បានរត់មកផ្ទប់សៀតដួងរបស់ខ្ញុំ ធ្វើឲ្យក្បាលខ្ញុំឈឺខ្មោកៗ ដោយភាពភ័យខ្លាច ។

"កុំនិយាយអ្វីទាំងអស់ ប្រសិនបើកងទ័ពឮយើងនិយាយច្បាស់ជាមានគ្រោះថ្នាក់ជាមិនខាន" ។ ឮដូច្នេះ ធ្វើឲ្យខ្ញុំកាន់តែភ័យខ្លាចខ្លាំងឡើងៗ ខ្ញុំក៏ដើរទៅរកលោកប៉ា ។ "តើនៅពេលណាបានយើងត្រឡប់ទៅផ្ទះរបស់យើងវិញប៉ា? យើងដើរអស់រយៈពេលប្រាំថ្ងៃមកហើយ" ។

"កុំនិយាយពីរឿងទៅផ្ទះវិញតទៅទៀត" ប៉ាខ្សឹបដាក់ត្រចៀកខ្ញុំ ហើយដាក់ខ្ញុំចុះឲ្យទៅ គាវ ។ គាវ កាន់ដៃរបស់ខ្ញុំហើយនាំខ្ញុំចូលក្នុងព្រៃមួយកន្លែង ដើម្បីឲ្យខ្ញុំបត់ជើង ។ យើងដើរទៅមុខបានពីរបីជំហាន ស្រាប់តែ បងឃួយ ស្រែកបង្អាក់ដំណើរមិនឲ្យយើងដើរទៅមុខទៀត ។

គាត់ស្រែកថា "ត្រឡប់ថយក្រោយវិញ! កុំដើរទៅមុខទៀត!" ។

បងគាវ ឆ្លើយតបទៅ បងឃួយ វិញថា "លឿង ត្រូវទៅបត់ជើង" ។

"នៅប្រមាណពីរបីម៉ែត្រពីឯង មានសាកសពមួយនៅក្នុងស្មៅខ្ពស់ៗនោះ ។ មកពីអីចឹងហើយ បានជាកន្លែងនេះវានៅ"

ភ្លាមនោះខ្ញុំក្តាប់ដៃ គាវ យ៉ាងណែន ហើយខ្ញុំមានអារម្មណ៍ថាធុំក្លិនអ្វីម្យ៉ាងឡើងឆួលច្រមុះ ។ វាមិនមែនជាក្លិនស្អុយរលួយរបស់ស្មៅ ហើយក៏មិនមែនជាក្លិនខ្លួនដ៏ស្អុយរបស់ខ្ញុំដែរ ក្លិននោះវាស្អុយមែនទែនរហូតដល់ធ្វើឲ្យខ្ញុំរមួលពោះរកកលចង់ក្អួត ។ ក្លិនហ្នឹងវាស្រដៀងនឹងក្លិនស្អុយអសោចរបស់គ្រឿងក្នុងមាន់ដែលរលួយក្រោមកម្តៅថ្ងៃយូរមកហើយ ។ អ្វីៗទាំងអស់ដែលព័ទ្ធជុំវិញខ្ញុំក្លាយជាព្រឹលៗ ហើយខ្ញុំមិនបានឮសំឡេង គាវ ប្រាប់ខ្ញុំឲ្យថយក្រោយវិញទេ ។ ខ្ញុំឮតែសំឡេងសត្វរុយហើរឆ្វែងៗមករោមសាកសពដ៏ស្អុយរលួយនោះ ។ ខ្ញុំមានអារម្មណ៍ថា គាវ កំពុងទាញដៃខ្ញុំ ហើយជើងរបស់ខ្ញុំក៏កម្រើកតាមគាត់ជាស្វ័យប្រវត្តិ ។ ដោយដៃខ្ញុំឋិតនៅក្នុងដៃ បងគាវ យើងក៏ដើរទៅទាន់សមាជិកគ្រួសាររបស់យើង ដើម្បីចាប់ផ្តើមធ្វើដំណើរថ្ងៃទីប្រាំមួយតទៅមុខទៀត ។ នៅតាមផ្លូវធ្វើដំណើរ យើងឃើញកងទ័ពនៅគ្រប់ទីកន្លែងដែលចាំបង្ខំឲ្យយើងដើរទៅមុខទៀត ។ កងទ័ពទាំងនោះភ្ជង់កាំភ្លើងដាក់ យើងបណ្តើរ ចង្អុលទិសប្រាប់យើងដោយសម្រែកខ្លាំងៗបណ្តើរ ។ នៅក្នុងខែមេសា ដ៏ក្តៅហែងនេះ មានប្រជាជនចាស់ៗជាច្រើនធ្លាក់ខ្លួនឈឺដោយសារខ្វះជាតិទឹកនិងចាញ់កម្តៅថ្ងៃ ប៉ុន្តែអ្នកទាំងអស់នោះមិនហ៊ានឈប់សម្រាកទេ ។ នៅពេលនរណាម្នាក់ធ្លាក់ខ្លួនឈឺ គ្រួសាររបស់គេក៏បោះចោលរបស់របរខ្លះដើម្បីអៀវអ្នកជំងឺព្រនាក់លើខ្នង ឬក៏ដាក់នៅលើរទេះរុញ ប្រសិនបើគ្រួសារនោះមានរទេះ រួចបន្តដំណើរទៅមុខទៀត ។ យើងដើរតាំងពីព្រឹករហូតដល់រសៀល ហើយឈប់សម្រាកដើម្បីញ៉ាំអាហារនិងដេកតែនៅពេលថ្ងៃលិចប៉ុណ្ណោះ ។

នៅជុំវិញគ្រួសារយើង យើងឃើញមានគ្រួសារដទៃទៀតជាច្រើនឈប់សម្រាកពេលយប់នៅត្រង់នេះដែរ ។ អ្នកខ្លះដើរត្រេតត្រត នៅក្នុងវាលស្រែដើម្បីរកអុសមកចម្អិនអាហារ ។ អ្នកខ្លះទៀតញ៉ាំអ្វីៗដែលបានចម្អិនទុកជាស្រេច ហើយគេងលង់លក់ភ្លាមបន្ទាប់ពីដាក់ខ្លួនដល់កន្ទេល ។ យើងដើរក្រឡឹងជុំវិញអ្នកគេងក្រវៀនៗដើម្បីរកកន្លែងទំនេរ ។ ម៉ា និង គាវ ចាប់ផ្តើមរៀបចំកន្លែងសម្រាក ហើយចាប់ផ្តើមបង្កាត់ភ្លើង ទោះបីជា

គាត់អស់កម្លាំងយ៉ាងណាក៏ដោយ ។ គាវ ដកកម្រាលពូកចេញពីថង់ប្លាស្ទិកដាក់អីវ៉ាន់ ហើយយកមកក្រាលលើដី ។ ម៉ា យកកន្ទេលកក់មួយមកក្រាលនៅក្បែរកម្រាលពូកដែល គាវ ក្រាលដែរ ។ ពេលដែលខ្ញុំអង្គុយជាមួយ ហ្គិច នៅលើបង្ហេចតូចមួយ ខ្ញុំយកដៃមកត្រដុសកជើងរលាកនិងរមាស់ឈឺរបស់ខ្ញុំ ចំណែក ជូ និង គីម នាំគ្នារំកិលស្បោងដទៃទៀតរបស់យើងមកដាក់លើក្រណាត់កម្រាលពូកវិញ ។ ខ្ញុំដឹកដៃ ហ្គិច ដើម្បីឲ្យនាងទៅអង្គុយនៅលើកម្រាលពូក ប៉ុន្តែ ហ្គិច មិនព្រមតាមខ្ញុំទេ មិនតែប៉ុណ្ណោះ នាងថែមទាំងរលាស់ដៃខ្ញុំចេញ ហើយដើរតេតះតតះទៅរកប៉ាវិញ ។ ប៉ា លើកនាងឡើងយកមកបីលើទ្រូងរបស់គាត់ ។ មុខរបស់ ហ្គិច ត្រូវកម្តៅថ្ងៃឡើងពណ៌ក្រហមក្រម៉ៅនិងមានពងបែក ។ ដោយការបំពេរបស់ប៉ា មិនយូរប៉ុន្មាន ហ្គិច ក៏គេងលក់បាត់ទៅ ។

ស្បៀងអាហាររបស់យើងបានចុះថយបន្តិចម្តងៗ រហូតនៅសល់អង្ករតែបីទៅបួនគីឡូក្រាមទៀតប៉ុណ្ណោះ ដូច្នេះ បងម៉េង បងឃួយ និង គីម ត្រូវចេញទៅស្វែងរកម្ហូបអាហារនិងអង្ករបន្ថែមទៀត ។ គាត់ទាំងបីនាក់ដើរទៅរកអាហារនៅជិតភូមិអង្គស្នួល ដែលមានចម្ងាយប្រមាណពីរគីឡូម៉ែត្រកន្លះ ហើយត្រឡប់មកវិញក្នុងរយៈពេលមួយម៉ោងក្រោយ ។ គាត់ដើរឆ្ពោះមករកយើងយឺតៗ ហើយយើងមើលឃើញ គីម កំពុងតែត្រកងអុសមួយកងនៅក្នុងដៃ បងម៉េង មានចង្កាក់ឈើដោតត្រីពីរនិងមានបន្លែព្រៃខ្លះទៀត ។ ឃួយ ដើរមករកយើងដោយទឹកមុខញញឹម ព្រមទាំងកាន់កូនឆ្នាំងមួយផង ។

បងឃួយ ស្រែកហៅម៉ាឲ្យមើលទាំងទឹកមុខរីករាយថា "ម៉ាមើលនែ៎! ស្ករណ៎ាម៉ា" ។

"ស្ករត្នោត!" ម៉ាលាន់មាត់ដោយទទួលឆ្នាំងនោះពីដៃបងឃួយ ។ ទោះបីជាខ្ញុំអស់កម្លាំងយ៉ាងណាក៏ដោយ ក៏ពាក្យពីរម៉ាត់ថា "ស្ករត្នោត" បានធ្វើឲ្យខ្ញុំរត់យ៉ាងលឿនទៅរកឆ្នាំងស្ករ ។

"ស្ករត្នោត!" ខ្ញុំនិយាយពាក្យដដែលនេះតិចៗ ។ ខ្ញុំមិនស្មានថា ពាក្យពីរម៉ាត់នោះបានផ្តល់សេចក្តីរីករាយឲ្យខ្ញុំដល់ម្លឹងសោះ ។

"ម៉ាឲ្យខ្ញុំសូមភ្លក្សបន្តិចមកម៉ា! យើងមានស្ករត្នោតជិតពាក់កណ្តាលនៃឆ្នាំងឯណោះ!" ។

គាវ ព្រមានខ្ញុំថា "ស៊ូត!! កុំនិយាយឮៗពេក បើមិនដូច្នេះទេ មនុស្សខ្លះនឹងមកសុំញ៉ាំដែរជាមិនខាន" ពេលដែល បងគាវ និយាយដូច្នេះ ខ្ញុំឃើញអ្នកជិតខាងយើងពីរឬបីនាក់សម្លឹងមករកយើង ។

ម៉ាមានប្រសាសន៍ពេលដែលយើងទាំងអស់ឈរជុំវិញគាត់ថា "កូនៗអាចភ្លក្សបន្តិចម្នាក់ៗបាន ហើយយើងត្រូវទុកវាខ្លះសម្រាប់ថ្ងៃក្រោយ" ។ បងប្អូនរបស់ខ្ញុំយកម្រាមដៃជ្រលក់ចូលទៅក្នុងស្ករ ហើយលិឍស្ករទាំងប៉ុន្មានដែលគៀរបានជាប់នឹងដៃ ។

"ខ្ញុំ ម៉ា...ខ្ញុំ...ខ្ញុំ..." ខ្ញុំអង្វរម៉ាឲ្យគាត់ឲ្យស្ករខ្ញុំញ៉ាំខ្លះក្នុងខណៈដែលគាត់ទប់ឆ្នាំងឲ្យខ្ញុំ ។ ខ្ញុំដឹងថា នេះគឺជាឱកាសតែមួយគត់របស់ខ្ញុំដើម្បីយកស្ករ ដូច្នេះខ្ញុំត្រូវរកវិធីយ៉ាងណាដែលអាចឲ្យខ្ញុំគៀរយកស្ករបានច្រើនតាមតែខ្ញុំអាចយកបាន ។ ខ្ញុំក៏ដាក់ម្រាមដៃរបស់ខ្ញុំចូលទៅក្នុងមាត់ ហើយយកអណ្តាតលិទ្ធគ្រប់ម្រាមដៃរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំប្រាកដថា ម្រាមដៃរបស់ខ្ញុំសើមគ្រប់ម្រាមហើយ ខ្ញុំក៏ដកវាចេញពីមាត់ ហើយលូកបន្តិចម្តងៗចូលទៅក្នុងឆ្នាំងស្ករ ខ្ញុំមានអារម្មណ៍ថាដុំស្ករវាល្អិតចូលគ្នា ហើយខ្ញុំក៏ចាប់ផ្តើមដកដៃចេញពីឆ្នាំងស្ករមកវិញ ខ្ញុំសប្បាយចិត្តជាខ្លាំងចំពោះអ្វីដែលខ្ញុំចង់បានហើយខ្ញុំអាចធ្វើបានសម្រេចមែន ។ ខ្ញុំអាចយកស្ករបានយ៉ាងច្រើនតាមរយៈម្រាមដៃរបស់ខ្ញុំជាងអ្នកដទៃទៀត! ដោយប្រយ័ត្នមិនឲ្យស្ករហៀរធ្លាក់ទៅក្រោមមួយតំណក់ណានោះ ខ្ញុំក៏យកដៃម្ខាងទៀតរបស់ខ្ញុំមកទ្រតំណក់ស្ករ ។ ខ្ញុំដើរយឺតៗជាមួយដៃជាប់ស្កររបស់ខ្ញុំ ទៅកាន់កន្ទេលដែលខ្ញុំអង្គុយដដែល ហើយចាប់ផ្តើមញ៉ាំស្ករដែលយកបានមក ។

បន្ទាប់ពីញ៉ាំអាហារពេលល្ងាចរួចរាល់ ម៉ាបាននាំយើងទាំងអស់គ្នាទៅកាន់ត្រពាំងមួយជិតកន្លែងគេងរបស់យើង ។ ពេលយើងទៅដល់ត្រពាំងនោះ យើងឃើញមានមនុស្សកកកុញនៅទីនោះរួចជាស្រេចដើម្បីបោកគក់សម្លៀកបំពាក់ ។ ក្មេងៗស្រាតនលកកបានជ្រមុជក្បាលទៅក្នុងទឹកដ៏ល្អក់ដោយញញើតញញើម ។ ក្មេងទាំងអស់មើលទៅហាក់ដូចជាអស់កម្លាំងខ្លាំងណាស់ ។ ពួកគេមិនលោតប្រឡែង សើចសប្បាយនិងបាចទឹកដាក់គ្នាទេ ។ ម៉ា បង្គាប់ឲ្យពួកយើងដោះខោអាវចេញ ។ ខ្ញុំដោះអាវ

ពណ៌ត្នោត តាមពិតវាមានពណ៌លឿង ពេលដែលខ្ញុំពាក់វា(ពីដំបូង) ដែលខ្ញុំពាក់ទាំងប្រញាប់ប្រញាល់ពេលចេញដំណើរកាលពីប្រាំមួយថ្ងៃកន្លងទៅនេះ ។

ជូ ហ៊្គិច និង ខ្ញុំ ឈរចាំ ម៉ា ទាំងខ្លួនទទេ នៅពេលដែលម៉ាកំពុងផ្លាស់ខោអាវគាត់ចេញដាក់ក្នុងសារុង ដែលគាត់កំពុងមូរ ហើយហុចខោអាវគាត់ដែលផ្លាស់ចេញនោះឲ្យទៅ គាវ បោក ។ ដោយសារយើងគ្មានសាប៊ូ គាវ ក៏យកខោអាវប្រឡាក់ទៅមាត់ត្រពាំងហើយបោកវាជាមួយនឹងថ្ម ។ ម៉ា ព ហ៊្គិច ជាប់នឹងត្រគាក ហើយគាត់យកដៃម្ខាងទៀតទាញដៃខ្ញុំ និង ជូ ឲ្យដើរចុះទៅក្នុងត្រពាំង ដើម្បីសម្អាតខ្លួនពីភាពកខ្វក់ដែលមានតាំងពីរយៈពេលប្រាំមួយថ្ងៃមកហើយ ។ យើងដើរកាន់ដៃគ្នាពីមួយទៅមួយចុះទៅក្នុងត្រពាំង យើងនាំគ្នាដើរទៅមុខរហូតដល់ទឹកត្រឹមចង្កេះខ្ញុំ ។ ក្នុងខណៈនោះ ខ្ញុំមានអារម្មណ៍ថា ទឹកត្រជាក់បានមកប៉ះនឹងស្បែករបស់ខ្ញុំ ហើយខ្ញុំយកដៃដុះក្អែលដែលកកលើស្បែកខ្ញុំជាច្រើនថ្ងៃចេញ ។ ស្មៅដ៏រអិលនៅក្នុងទឹកបានយោលយោកមកប៉ះជើងរបស់ខ្ញុំ មានស្មៅខ្លះមករុំកជើងខ្ញុំដូចសត្វពស់ ធ្វើឲ្យខ្ញុំព្រឺឆ្អឹងខ្នងខ្លាកៗដោយភាពរអើល ។ ខ្ញុំលោតឡើងហើយធ្លាក់ចូលក្នុងទឹកវិញ ព្រមទាំងទាញដៃ ជូ ឲ្យទៅជាមួយផង ពេលដែល ជូ កំពុងកាន់ដៃម៉ានៅឡើយ ។ ពេលខ្ញុំងើបក្បាលផុតពីទឹក អ្នកទាំងអស់បាននាំគ្នាសើចដាក់ខ្ញុំ ។ ខ្ញុំសប្បាយរីករាយជាខ្លាំងពេលដែលខ្ញុំធ្វើឲ្យគ្រួសារយើងសើចសប្បាយជាថ្មីម្តងទៀត ។ នៅព្រឹកព្រលឹមថ្ងៃបន្ទាប់ ម៉ា បានដាស់យើងគ្រប់គ្នាឲ្យភ្ញាក់ឡើង ហើយយើងប្រុងប្រៀបខ្លួនជាស្រេចដើម្បីធ្វើដំណើរក្នុងថ្ងៃទីប្រាំពីរតទៅទៀត ។ ផ្លូវនៅខាងមុខយើងមានពន្លឺថ្ងៃចាំងព្រាកៗ និងមានដីហុយឡើងទ្រលោមគ្រប់កន្លែងទាំងអស់ ។ កម្តៅថ្ងៃបានធ្វើឲ្យភ្នែកខ្ញុំក្តៅផ្សា ។ ភ្នែករបស់ខ្ញុំផ្តោតទៅលើបុរសម្នាក់ដែលកំពុងជិះកង់នៅឆ្ងាយពីយើង ខ្ញុំមិនអាចដឹងថា បុរសម្នាក់នោះមានកម្ពស់ប៉ុន្មានទេ ខ្ញុំគ្រាន់តែអាចប្រាប់អ្នកថា គាត់នោះមានរូបរាងស្គមស្វែនទែន ។ ចម្លែកណាស់ដែលបុរសម្នាក់នោះ ខំប្រឹងជិះកង់បញ្ច្រាសទិសដៅអ្នកដំណើរ ប៉ុន្តែមួយរំពេចក្រោយមកខ្ញុំភ្ញាក់ព្រើត ពេលខ្ញុំឮសម្រែករបស់ម៉ា ។ គាត់ព្យាយាមស្រែកទាំងដង្ហក់ថា «នោះគឺលោកពូ លាង របស់ឯង» ។ ដោយការរំភើបខ្លាំងពេក យើងទាំងអស់គ្នាក៏លោតចុះលោតឡើងនៅលើដី ហើយគ្រវីដៃទៅរកគាត់ ។ លោកពូ លាង ក៏លើកដៃម្ខាងគ្រវីមករកយើងវិញ ហើយធាក់កង់កាន់តែលឿនសំដៅមករកយើង ។ គាត់ឈប់កង់ចម្ងាយប្រហែលមួយម៉ែត្រពីយើង ភ្លាមនោះយើងទាំងអស់គ្នាក៏រត់ទៅរកគាត់ ។ ដោយធ្មើភ្នែកព្រិចៗ គាត់ទាញម៉ាទៅឱបនៅក្នុងរង្វង់ដៃ ដោយទុកឲ្យប៉ាំនៅឈរធ្មឹងយ៉ាងស្ងៀមស្ងាត់ក្បែរនោះ ។ ការភ័យខ្លាចនិងការព្រួយបារម្ភទាំងប៉ុន្មានដែលមានក្នុងរយៈពេលបួនប្រាំថ្ងៃមុន បានរសាត់ផុតទៅអស់រលីង ។ ទីបំផុត លោកពូ លាង អាចរកឃើញបងស្រីរបស់គាត់ដោយជោគជ័យ ។ លោកពូ លាង បានយកអីវ៉ាន់មួយកញ្ចប់ពីដៃកង់របស់គាត់ហុចទៅឲ្យម៉ា ។ ក្នុងខណៈដែលម៉ាបើកគ្រឿងកំប៉ុងនិងម្ហូបដទៃទៀត លោកពូ លាង បានប្រាប់លោកប៉ាថា កាលពីព្រឹកមិញមានប្រជាជនមកពីភ្នំពេញទៅដល់ភូមិគាត់ អ្នកមកដល់ថ្មីនៅភូមិគាត់បានប្រាប់គាត់ ពីរឿងខ្មែរក្រហមបង្ខំឲ្យប្រជាជនចេញពីទីក្រុងទាំងអស់ទូទាំងប្រទេស ដែលរួមមានទីក្រុងភ្នំពេញ បាត់ដំបង និងសៀមរាបផង ។ ពេលឮដូច្នេះ ពូលាង ក៏ប្រញាប់ប្រញាល់ជិះកង់មករកពួកយើងពេញមួយព្រឹក ។ បន្ទាប់មក គាត់បានប្រាប់ដំណឹងដ៏ល្អបំផុតមួយដល់យើងថា បងប្រុសច្បងរបស់ម៉ា គឺ អ៊ំហ៊ាង កំពុងបររទេះ នៅតាមផ្លូវដើម្បីមកទទួលយើងដែរ ។ ស្នាមញញឹមដែលបញ្ជាក់ឲ្យឃើញភាពរីករាយបានលេចឡើងពេញផ្ទៃមុខរបស់ខ្ញុំ នៅពេលដឹងថា ខ្ញុំមិនចាំបាច់ដើរទៅមុខទៀត ហើយគិតថា ក្នុងរយៈពេលពីរបីថ្ងៃទៀត យើងនឹងជិះរទេះរបស់ពួកគាត់ទៅផ្ទះយើងនៅភ្នំពេញវិញហើយ ។

ឈរនៅជិតលោកពូ លាង ខ្ញុំត្រូវតែប្រឹងងើយក្បាលរបស់ខ្ញុំទៅលើដើម្បីមើលមុខគាត់ ពីព្រោះគាត់ខ្ពស់ណាស់ ។ ទោះបីជាខ្ញុំខំងើយមើលគាត់ក៏ដោយ ក៏អ្វីដែលខ្ញុំអាចមើលឃើញគឺបបូរមាត់ស្តើងនិងរន្ធច្រមុះធំដែលមានរោមខ្មៅៗញាក់ចុះញាក់ឡើងនៅពេលណាគាត់និយាយទៅកាន់ម៉ាប៉ុណ្ណោះ ។ ក្នុងកម្ពស់ប្រហែលជាជិតមួយម៉ែត្រប្រាំបីតឹក ប្អូនប្រុសទីពីររបស់ម៉ា គឺមលាង មានកម្ពស់ខ្ពស់ជាងគេជាងឯងក្នុងចំណោមយើងទាំងអស់គ្នា ។ ដៃជើងវែងៗនិងស្គមៗរបស់គាត់ មើលទៅដូចជា ឈើចាក់

ធ្មេញដែលខ្ញុំធ្លាប់គូរនៅក្នុងសៀវភៅរបស់ខ្ញុំ ។ លោក ពូលាង និងលោកអ៊ីហ៊ាង គាត់រស់នៅជនបទតាំងពីមុនថ្ងៃបដិវត្តន៍ម្ល៉េះ ហើយគាត់ទាំងពីរនាក់មិនដែលទៅរស់នៅក្នុងទីក្រុងទេ ។ ពួកខ្មែរក្រហមចាត់ទុកប្រជាជនបែបនេះជាជនគំរូសម្រាប់សង្គមថ្មីរបស់គេ ។ លោកប៉ាមានប្រសាសន៍ថា យើងនឹងទៅស្នាក់នៅក្នុងភូមិរបស់លោកអ៊ីនិងលោកពូ ។ រទេះដែលអូសដោយគោសម្បុរលឿងពីរក្បាលបានមកដល់ នៅពេលយប់ណាស់ទៅហើយ ។ នៅពេលលោកប៉ានិងម៉ាជជែកគ្នាជាមួយលោកអ៊ីនិងលោកពូ ខ្ញុំក៏ប្រញាប់ប្រញាល់ឡើងអង្គុយលើរទេះគោនោះ ជាមួយ ជូ និង ហ្គិច ។ រទេះគោរបស់យើងបានដឹកយើងទៅតាមផ្លូវគ្រួសលេខ១២៦ ឆ្ពោះទៅកាន់ទិសខាងលិច រហូតដល់ភូមិបាត់ដឹងដែលគ្រប់គ្រងដោយពួកខ្មែរក្រហម ។ មិនថាកន្លែងណាដែលយើងទៅដល់ ឬធ្វើដំណើរបត់ទៅទីណាទេ យើងឃើញហ្វូងប្រជាជននៅខាងមុខនិងក្រោយយើងគ្រប់ទិសទីទាំងអស់ ។ នៅកណ្តាលហ្វូងមនុស្សរទេះគោរបស់យើងបានបរកាត់ភូមិខ្មែរក្រហមដោយគ្មានឈប់ឡើយ ។ បន្ទាប់មកយើងបត់រទេះ ទៅទិសខាងលិច ដោយទុកអ្នករួមដំណើរតាមផ្លូវជាមួយយើងនៅយ៉ាងឆ្ងាយពីក្រោយយើង ។ នៅតាមផ្លូវពីភូមិបាត់ដឹងទៅក្រាំងត្រប់ ខ្ញុំគេងលង់លក់បាត់ទៅហើយ ។

## ក្រាំងត្រប់

**ខែមេសា ឆ្នាំ១៩៧៥**

នៅព្រឹកថ្ងៃទី២៥ ខែមេសា គឺប្រាំបីថ្ងៃក្រោយការចាកចេញពីផ្ទះដ៏ស្អាតរបស់យើងនៅទីក្រុងភ្នំពេញ យើងទាំងអស់បានមកដល់ទីតាំងថ្មីមួយ ។ ក្រាំងត្រប់ ជាភូមិតូចមួយដែលមានវាលស្រែឆ្ងាយដាច់កន្ទុយភ្នែកព័ទ្ធជុំវិញ ។ នៅទីនោះ យើងឃើញមានសុទ្ធតែផ្លូវដីក្រហមតូចៗបត់បែនដូចពស់លូនក្នុងទឹក ។ នៅតាមវាលស្រែ យើងឃើញគោពណ៌ប្រផេះនិងពណ៌ត្នោតកំពុងតែស៊ីស្មៅយ៉ាងប្រអូស ។ ភាគច្រើន គោ ទាំងនោះសុទ្ធតែមានកណ្តឹងចងព័ទ្ធករបស់វាដែលបន្លឺសូរសំឡេងណិងណុងៗឬរ៉ឹងៗមិនចេះដាច់នៅពេលវាដើរទៅមុខ ។ ពេលគោរត់ទៅមុខ វាធ្វើឲ្យខ្ញុំនឹកឃើញដល់សំឡេងកណ្តឹងអ្នកលក់ការ៉េមគីនៅទីក្រុងភ្នំពេញដែរ ។ ប្រជាជននៅទីនេះរស់នៅក្នុងផ្ទះខ្ទមធ្វើពីស្បូវដែលសង់ខ្ពស់ជាងស្មៅដីរីចំកណ្តាលវាលស្រែ ។

"កូនក្មេងនៅទីនេះស្មោកគ្រោកជាងខ្ញុំពេលនេះទៅទៀត!" ខ្ញុំលាន់មាត់នៅពេលដែលឃើញកូនក្មេងម្នាក់រត់កាត់ផ្លូវពីមុខយើង ដោយមិនបានកត់សម្គាល់រូបខ្លួនឯងដ៏រយីករយាកផងទេ ។

ម៉ាតែងតែស្តីបន្ទោសឲ្យខ្ញុំជានិច្ច គាត់ប្រាប់ឲ្យខ្ញុំគ្រាន់តែមើលគេបានហើយ ។ កូនក្មេងទាំងនោះប្រឡាក់ដីក្រហមស្រមកពាសពេញខោអាវ ស្បែក និងសក់ក្បាលរបស់វា ។

បងជូ ជ្រួញចិញ្ចើមហើយគ្រវីក្បាលដាក់ខ្ញុំ ។ ទោះបីជាបងជូ មានអាយុច្រើនជាងខ្ញុំតែបីឆ្នាំក៏ដោយ ក៏គាត់តែងតែធ្វើដូចជាខ្លួនឯងដឹងរឿងច្រើនជាងខ្ញុំណាស់អីចឹង ។ តែខ្ញុំមានមាឌធំជាងគាត់ ហើយខ្ញុំអាចវាយគាត់ឲ្យដួលយ៉ាងស្រួល ទោះបីជាខ្ញុំកម្រធ្វើដូច្នេះក៏ដោយ ។ ដោយសារតែ បងជូ ជាមនុស្សអៀនខ្មាស ស្ងាត់ស្ងៀម ហើយជាកូនស្តាប់បង្គាប់ បងប្អូនទាំងអស់របស់ខ្ញុំតែងតែសន្មតថាអ្វីដែល បងជូ ជ្រើសរើសមកនិយាយគឺភាគច្រើនជារឿងសំខាន់ ហើយជាទូទៅ បងៗតែងតែកាន់ជើង បងជូ ជានិច្ចរាល់ពេលដែលខ្ញុំឈ្លោះជាមួយគាត់ម្តងៗ ។ ដោយសារតែខ្ញុំជាមនុស្សនិយាយប៉ប៉ាច់ប៉ប៉ោចច្រើន បងប្អូនខ្ញុំតែងតែចាត់ទុកពាក្យសម្តីខ្ញុំដែលនិយាយចេញមក ជាសម្តីរាក់កំផែលគ្មានបានការ ។

បងជូ ក្រឡេកមើលខ្ញុំដោយជ្រួញចិញ្ចើមចូលគ្នាធ្វើហាក់ដូចជាព្យាយាមចង់ដឹងថាខ្ញុំកំពុងគិតអ្វី ។ ខ្ញុំលៀនអណ្តាតដាក់គាត់ ខ្ញុំមិនខ្វល់អ្វីទាំងអស់ ព្រោះខ្ញុំរំភើបចិត្តដែលបានមកដល់ទីនេះ ហើយអាចត្រឡប់ទៅផ្ទះវិញនៅពីរបីថ្ងៃក្រោយ ។

បន្ទាប់ការជួបជុំគ្នាយ៉ាងសប្បាយរីករាយជាមួយអ៊ំស្រី អ៊ំប្រុសក្នុងផ្ទះរួចមក ប៉ាក៏ដើរចេញទៅខាងក្រៅជាមួយ ពូលាង ជួបប្រធានភូមិ ដើម្បីសុំការអនុញ្ញាតស្នាក់នៅក្នុងភូមិនេះ ។ ពូលាង និង អ៊ំហ៊ាង មានប្រសាសន៍ថា ចាប់តាំងពីខ្មែរក្រហមឈ្នះសង្គ្រាម ពួកគេបានដកប្រធានភូមិចាស់ចេញដោយដាក់កម្មាភិបាលខ្មែរក្រហមថ្មីម្នាក់ជំនួសវិញ ។ ឥឡូវនេះ អ្នកភូមិគ្រប់គ្នាត្រូវតែស្នើសុំការអនុញ្ញាតទាំងអស់ ទោះបីវាជាបំណាងធម្មតារបស់មនុស្សក៏ដោយ ក៏ប្រជាជនត្រូវតែសុំការអនុញ្ញាតពីកម្មាភិបាលខ្មែរក្រហមដែរ នៅពេលដែលនរណាម្នាក់ចង់ឲ្យ

សាច់ញាតិរបស់ខ្លួនស្នាក់ជាមួយ ឬពេលដែលមានបំណងទៅសួរសុខទុក្ខនរណាម្នាក់នៅភូមិមួយទៀត ។

មិនយូរប៉ុន្មាន ប៉ានិងអ៊ំបានត្រឡប់មកវិញ ដោយនាំពាក្យមកប្រាប់ថា យើងត្រូវបានអនុញ្ញាតឲ្យរស់នៅទីនេះហើយ ។ អារម្មណ៍របស់ខ្ញុំដែលចង់រស់នៅក្នុងទីក្រុង ក៏រលត់បាត់ភ្លាមនៅពេល ប៉ា ប្រាប់យើងថា យើងទាំងអស់នឹងរស់នៅជាមួយលោកពូ លាង និងគ្រួសាររបស់គាត់ក្នុងផ្ទះដ៏តូចនេះ ។ លោកពូលាង ហើយនិងប្រពន្ធគាត់មានកូនប្រាំមួយនាក់ ដូច្នេះបូករួមទាំងសមាជិកគ្រួសារយើងប្រាំបួននាក់ទៀត មនុស្សទាំងអស់នឹងត្រូវឡើងដល់ទៅចំនួនដប់ប្រាំពីរនាក់ដែលត្រូវរស់នៅក្នុងផ្ទះប្រក់ស្បូវមួយនេះ ។ បើគិតតាមស្តង់ដាររបស់ប្រជាជនទីក្រុង គេមិនហៅផ្ទះនេះថាជាផ្ទះទេ ។ ផ្ទះនេះមើលទៅហាក់ដូចជាខ្ទមមួយក្នុងចំណោមផ្ទះខ្ទមជាច្រើនដែលប្រជាជនក្រីក្ររស់នៅអ៊ីចឹង ។ ផ្ទះនេះក្រាលដោយដីបុកបង្ហាប់ ហើយដំបូលនិងជញ្ជាំងរបស់វាធ្វើពីស្បូវ ។ ផ្ទះនេះគ្រាន់តែជាបន្ទប់ដ៏ធំទូលាយមួយដែលគ្មានជញ្ជាំងខណ្ឌចែកជាបន្ទប់ឡើយ ។ នៅក្នុងផ្ទះគ្មានបន្ទប់ចង្ក្រានបាយទេ ដូច្នេះការចម្អិនអាហារត្រូវតែធ្វើនៅក្រៅផ្ទះក្រោមញ៉ាបស្បូវមួយ ។ នៅអធ្រាត្រថ្ងៃដដែល បងគីម ទាញខ្ញុំទៅក្បែរ ហើយស្តីបន្ទោសឲ្យខ្ញុំពីរឿងដែលខ្ញុំនិយាយមាក់ងាយផ្ទះថ្មីរបស់យើងនេះ ។ ទោះបីជា បងគីម មានអាយុទើបតែដប់ឆ្នាំក៏ដោយ ក៏គាត់អាចយល់ថា លោកពូគាត់ក្លាហានប៉ុនណា ដែលហ៊ានទៅសុំការអនុញ្ញាតពីប្រធានភូមិខ្មែរក្រហមដើម្បីឲ្យយើងស្នាក់នៅជាមួយគាត់ ។

«ភូមិនេះក្រណាស់ប៉ា» ខ្ញុំនិយាយទៅកាន់ប៉ានៅពេលដែលគ្រួសារខ្ញុំទាំងអស់ជុំគ្នា ក្រោមដំបូលផ្ទះលោកពូលាង ។ នៅពេលជុំគ្នា សមាជិកគ្រួសារយើងខ្លះអង្គុយលើកន្ទេលកក់ ខ្លះទៀតអង្គុយលើកៅអីឬដុំឈើ ដើម្បីស្តាប់ការណែនាំរបស់ប៉ា ។

«ភូមិនេះក្រដូចជាយើងអ៊ីចឹងដែរ» ។ សំឡេងដ៏ម៉ឺងម៉ាត់របស់ប៉ាធ្វើឲ្យមុខខ្ញុំឡើងក្រហមដោយសារអៀនខ្មាស ។ «ចាប់ពីពេលនេះទៅយើងទាំងអស់គ្នាក៏ក្រដូចជាអ្នកភូមិនេះដែរ យើងត្រូវតែរស់នៅឲ្យឆ្ងាយពីទីក្រុងដែលមានមនុស្សខ្លះអាចស្គាល់ប៉ា ហើយដឹងថាប៉ាជានរណា ។ ប្រសិនបើនរណាម្នាក់ក្រៅពីគ្រួសាររបស់យើងសួរថា យើងមកពីណា យើងត្រូវប្រាប់គេថាយើងជាប្រជាជនជនបទដូចលោកអ៊ំរបស់ឯង ទាំងអស់គ្នាដែរព្រុទេ!» ។

«ហេតុអ្វីបានជាយើងមិនចង់ឲ្យគេដឹងថាយើងជានរណា ប៉ា? ហេតុអ្វីបានជាយើងមិនអាចទៅផ្ទះរបស់យើង? កងទ័ពបានសន្យាថា យើងអាចទៅផ្ទះរបស់យើងវិញបានក្នុងរយៈពេលបីថ្ងៃ» ។

«កងទ័ពខ្មែរក្រហមកុហកពួកយើងទេ គេឈ្នះសង្គ្រាមហើយ ដូច្នេះយើងមិនអាចត្រឡប់ទៅផ្ទះវិញបានទេ ។ ឯងត្រូវតែឈប់គិតពីរឿងទៅផ្ទះ ឈប់គិតពីទីក្រុងភ្នំពេញតទៅទៀតទៅ» ។ ប៉ាមិនដែលនិយាយពាក្យធំៗដាក់ខ្ញុំទេ តាំងពីមុនមក ហើយពាក្យសម្តីម៉ាត់ៗរបស់គាត់បានធ្វើឲ្យខ្ញុំអស់សង្ឃឹមបន្តិចម្តងៗ ។ ខ្លួនរបស់ខ្ញុំឡើងញ័រដោយការភ័យខ្លាចចំពោះហេតុការណ៍មិនគួរឲ្យជឿនិងដែលមិនអាចទទួលយកបាន ។ ខ្ញុំនឹងមិនអាចត្រឡប់ទៅផ្ទះវិញរហូត ខ្ញុំនឹងមិនអាចឃើញទីក្រុងភ្នំពេញទៀតទេ ខ្ញុំនឹងមិនអាចជិះឡានរបស់យើង ខ្ញុំនឹងមិនអាចជិះស៊ីក្លូជាមួយ ម៉ាទៅផ្សារ ហើយខ្ញុំនឹងមិនអាចទិញចំណីចំណុកពីរទេះរុញមុខផ្ទះខ្ញុំបានទៀតឡើយ ។ អ្វីៗទាំងអស់ដែលខ្ញុំធ្លាប់មាន បានរលត់ផុតអស់ហើយនៅពេលនេះ ។ លោកប៉ាបានលើកខ្ញុំបីក្នុងរង្វង់ដៃគាត់ពេលបបូរមាត់ខ្ញុំពេបរកយំ ហើយទឹកភ្នែកខ្ញុំស្រក់ចុះមកតក់ៗ ។

ក្នុងពេលដែលប៉ាមានប្រសាសន៍បន្តទៀត ខ្ញុំក៏សម្រូតខ្លួនចុះពីដៃគាត់ហើយដើរទៅរក គាវ វិញ ។ ប៉ា ព្យាយាមពន្យល់បងប្រុសរបស់ខ្ញុំឲ្យយល់ពីប្រវត្តិនយោបាយ នៅក្នុងប្រទេសកម្ពុជា ។ ក្រោមការដឹកនាំរបស់សម្តេច សីហនុ ប្រទេសកម្ពុជាបានទាមទារឯករាជ្យពីប្រទេសបារាំងនៅក្នុងឆ្នាំ១៩៥៣ ។ ចាប់តាំងពីឆ្នាំ ១៩៥០ ដល់ឆ្នាំ១៩៦០ ប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង ហើយអាចចិញ្ចឹមខ្លួនឯងរស់បានដោយខ្លួនឯង ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ប្រជាជនជាច្រើនមិនសប្បាយចិត្តនឹងរដ្ឋាភិបាលរបស់សម្តេច សីហនុ ដែរ ។ ប្រជាជនជាច្រើនចាត់ទុករដ្ឋាភិបាលសម្តេចថា ជារដ្ឋាភិបាលពុករលួយនិងបក្សពួកនិយម ព្រោះគេយល់ថា រដ្ឋាភិបាលនេះធ្វើឲ្យប្រជាជនក្រីក្រកាន់តែក្រទៅៗ ហើយអ្នកមានកាន់តែមានឡើងៗ ។ ក្រុមអ្នកជាតិនិយមផ្សេងៗបានក្រោកឡើង ហើយទាមទារឲ្យមានការកែទម្រង់ ។ ក្រុមមួយក្នុងចំណោមនោះ គឺក្រុមកុម្មុយនិស្តសម្ងាត់មួយហៅ

ថា“ខ្មែរក្រហម” បានផ្តើមធ្វើការប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យសង្គមរាស្ត្រនិយម ។ សង្គ្រាមនៅក្នុងប្រទេសវៀតណាមបានរាលដាលមកដល់ប្រទេសកម្ពុជា ក្នុងខណៈដែលសហរដ្ឋអាមេរិកចាប់ទម្លាក់គ្រាប់បែកតាមតំបន់ព្រំដែនរបស់ប្រទេសយើង ដើម្បីកម្ទេចមូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ។ ការទម្លាក់គ្រាប់បែកនេះបានធ្វើឲ្យភូមិជាច្រើនវិនាសអន្តរាយនិងធ្វើឲ្យមនុស្សមួយចំនួនធំរងគ្រោះ ។ សង្គ្រាមនៅក្នុងប្រទេសវៀតណាមបានរីករាលដាលដល់ប្រទេសកម្ពុជា ក្នុងខណៈដែលសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកមកលើព្រំប្រទល់ប្រទេសយើងដើម្បីកម្ចាត់មូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ។ ការទម្លាក់គ្រាប់បែកនេះបានបំផ្លិចបំផ្លាញនិងសម្លាប់មនុស្សអស់ជាច្រើននាក់ ។ ភាពខ្ទេចខ្ទាំនេះបានអនុញ្ញាតឲ្យខ្មែរក្រហមទទួលការគាំទ្រកាន់តែច្រើនឡើងៗពីសំណាក់អ្នកស្រែចម្ការ ។ នៅក្នុងឆ្នាំ១៩៧០ សម្តេចព្រះនរោត្តម សីហនុ បានត្រូវឧត្តមសេនីយ៍ លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់ពីអំណាច ។ រដ្ឋាភិបាល លន់ ណុល ដែលគាំទ្រដោយសហរដ្ឋអាមេរិកជារដ្ឋាភិបាលពុករលួយ ហើយទន់ខ្សោយបណ្តាលឲ្យខ្មែរក្រហមផ្តួលរំលំបានដោយងាយស្រួល ។ ប៉ានិយាយរឿងនយោបាយជាច្រើនទៀត ប្រាប់បងប្រុសទាំងអស់របស់ខ្ញុំ តែខ្ញុំមិនយល់ប៉ុន្មានទេពីរឿងនយោបាយ ។ អ្វីដែលខ្ញុំត្រូវដឹងហើយត្រូវចាំគឺខ្ញុំត្រូវធ្វើខ្លួនជាមនុស្សគរ គឺមិននិយាយពីរឿងជីវិតនៅទីក្រុងរបស់យើងប្រាប់នរណាម្នាក់ឡើយ ។ ខ្ញុំមិនអាចនិយាយប្រាប់មនុស្សដទៃទៀតថា ខ្ញុំនឹកផ្ទះណាស់ ឬក៏ថាខ្ញុំចង់ត្រឡប់ទៅយកអ្វីដែលខ្ញុំធ្លាប់មានពីមុនមកវិញទេ ។ ខ្ញុំទ្រោបក្បាលរបស់ខ្ញុំលើស្មារបស់ គាវ ហើយបិទភ្នែកដោយសង្កៀតធ្មេញផង ។ បងគាវ យកដៃមកអង្អែលសក់និងថ្ពាល់ខ្ញុំបន្តើៗ ហើយនិយាយខ្សឹបតិចៗដាក់ត្រចៀកខ្ញុំបណ្តើរថា “កុំបារម្ភអីបងស្រីធំរបស់ប្អូននឹងមើលថែទាំប្អូនរហូត” ។ នៅក្បែរ បងគាវ ម៉ាអង្គុយលើកន្ទេលដោយយកដៃឱបហ៊ុិចដែលកំពុងគេងលក់នៅនឹងដៃរបស់គាត់ ។ ជូ អង្គុយជិតម៉ាកំពុងសម្លឹងមើលទៅក្រមាឆ្នូតពណ៌សនិងខ្មៅហាក់ដូចជាចង់បត់វាបន្តិច ចង់លាវាវិញបន្តិច ។

អគ្រាត្រយប់នោះ យើងយកក្តារបន្ទះធ្វើជាគ្រែ ។ គេងលើក្តារបន្ទះធ្វើឲ្យ បងជូ ភ្ញាក់ដោយសារការប្រែខ្លួនចុះឡើងៗរបស់ខ្ញុំ ។

ខ្ញុំរអ៊ូដាក់ បងជូ ដែលកំពុងគេងនៅជិតខ្ញុំថា “ខ្ញុំស្អប់ក្តារបន្ទះនេះណាស់ ។ វាធ្វើឲ្យខ្ញុំពិបាកគេងមែនទែន!” ។ នៅទីក្រុង បងគាវ បងជូ ហើយនិងខ្ញុំ គេងលើគ្រែពូករួមគ្នា ។ ហើយនៅទីនេះ កូនប្រុសទាំងអស់គេងនៅលើអង្រឹង ចំណែកឯកូនស្រីបែរជាគេងយ៉ាងស្រងូតស្រងាត់ជាជួរនៅលើរនាបឫស្សីដ៏កំពឹកកំពកមួយបន្ទះទៅវិញ ។ ខ្ញុំគួរតែគេងនៅលើអង្រឹងទើបត្រូវ ។

“ស្ងាត់ ឈប់និយាយតទៅទៀត ហើយសំងំគេង”

“បងជូ ខ្ញុំត្រូវទៅបន្ទប់ទឹក”

“ទៅ! ម្តេចក៏មិនទៅ!”

“ខ្ញុំខ្លាច ។ បងទៅជាមួយខ្ញុំទៅ!”

បងជូ បែរខ្នងដាក់ខ្ញុំដោយមិនឆ្លើយតបនឹងសំណួរខ្ញុំឡើយ ។ រៀងរាល់ពេលដែលខ្ញុំត្រូវទៅបត់ជើង ខ្ញុំត្រូវតែដើរកាត់ព្រៃដោយខ្លួនឯង ព្រោះខ្ញុំត្រូវដើរទៅបន្ទប់ទឹកដែលនៅក្រៅផ្ទះ ។ យើងបានប្រើលុយរបស់យើងអស់ទៅហើយ ហើយឥឡូវនេះយើងគ្មានលុយសេសសល់ដើម្បីធ្វើជាក្រដាសបង្គន់ទៀតទេ ។ បងជូ បានបង្រៀនខ្ញុំឲ្យចេះប្រើស្លឹកឈើ ប៉ុន្តែនៅពេលយប់ដែលខ្ញុំមិនអាចមើលឃើញអ្វីសោះនោះ ខ្ញុំខ្លាចមានសត្វល្អិតជាប់នៅលើស្លឹកឈើនោះ ។

ម្យ៉ាងវិញទៀតពេលដើរចូលទៅក្នុងព្រៃនៅពេលយប់ វាមានអារម្មណ៍ដូចជាត្រូវគេបន្លាចអ៊ីចឹង ជាពិសេសអារម្មណ៍នេះនឹងឃើញកាន់តែច្បាស់ចំពោះអ្នកណាដែលពូកែស្រមើស្រមៃ ។ នៅពេលងងឹត ខ្ញុំស្រមៃឃើញខ្មោចអង្រួនដើមឈើរង្គើៗ ដោយធ្វើឲ្យខ្ញុំដឹងថាវានោះកំពុងរង់ចាំខ្ញុំ ។ ខ្មោចនោះសូត្រមន្តអាគមគាថាខ្សឹបៗដាក់ត្រចៀកខ្ញុំ ហើយខ្យល់បក់ស្លឹកឈើលាន់មកប៉ះត្រចៀកខ្ញុំព្រូប្រាវៗ ។ ខ្មោចនោះហៅខ្ញុំឲ្យចុះទៅក្រោមជួបវា ដូច្នេះវាអាចដកហូតព្រលឹងពីខ្ញុំបាន ខ្ញុំមានអារម្មណ៍ភ័យខ្លាចជាខ្លាំង ពេលខ្ញុំគិតចង់ទៅបន្ទប់ទឹកតែម្នាក់ឯងក្នុងពេលអធ្រាត្រ ដូច្នេះខ្ញុំត្រូវតែបង្ខំចិត្តមិនទៅវិញ ហើយរង់ចាំដល់ព្រឹកព្រលឹម ទើបខ្ញុំស្ទុះរត់យ៉ាងលឿនសំដៅទៅរកព្រៃ ។

ពេលខ្ញុំត្រឡប់ពីបត់ជើងមកវិញ ស្រាប់តែខ្ញុំដឹងថា អ្នកផ្ទះរបស់ខ្ញុំគ្រប់គ្នាបានក្រោកពីដំណេកតាំងពីព្រលឹមម៉្លេះ ហើយ

ពេលដែលខ្ញុំភ្ញាក់នៅព្រឹកថ្ងៃបន្ទាប់ គេទាំងអស់គ្នាបានត្រៀមខ្លួនជាស្រេចដើម្បីចេញទៅធ្វើស្រែឲ្យបានមុនថ្ងៃរះ ។ ជីវិតនៅក្នុងវាលស្រែធ្វើឲ្យខ្ញុំធុញថប់យ៉ាងខ្លាំង ប៉ុន្តែយ៉ាងហោចណាស់ក៏យើងមានអ្វីគ្រប់គ្រាន់សម្រាប់ញុំាដែរ ។ មិនដូចជាជីវិតនៅក្នុងទីក្រុងភ្នំពេញទេ នៅទីនេះក្រៅពីបងប្អូនរបស់ខ្ញុំ ខ្ញុំគ្មានមិត្តភក្តិផ្សេងទៀតឡើយ ។ ជាការពិបាកណាស់ក្នុងការបង្កើតមិត្តជាមួយអ្នកដទៃ ពីព្រោះខ្ញុំមិនហ៊ាននិយាយ ខ្ញុំខ្លាចខ្ញុំរអិលមាត់និយាយរឿងសម្ងាត់របស់គ្រួសារយើងទៅប្រាប់គេឯង ។ ប៉ាមានប្រសាសន៍ថា អង្គការបានបិទមិនឲ្យមានផ្សារ សាលា ហើយនិងមហាវិទ្យា-ល័យទាំងអស់និងហាមមិនឲ្យនរណាម្នាក់ប្រើលុយ នាឡិកាដៃនាឡិកាព្យួរលើជញ្ជាំង និងទូរទស្សន៍ឡើយ ។ ដោយហេតុថាពេលនេះគ្រួសារយើងបានក្លាយទៅជាគ្រួសារអ្នកស្រែមួយដែរ ខ្ញុំត្រូវតែរៀនមើលម៉ោងតាមដំណើរព្រះអាទិត្យ និងព្រះច័ន្ទវិញ ។

ប្រសិនបើខ្ញុំរត់ទៅនិយាយលេងជាមួយក្មេងដទៃ ខ្ញុំត្រូវតែប្រយ័ត្នពាក្យសម្តីនិងភាសាដែលខ្ញុំប្រើជាមួយពួកគេ ។ ខ្ញុំមិនអាចលើកយកមុខម្ហូបដែលខ្ញុំប៉ងចង់ញុំាមកនិយាយ ខ្ញុំមិនអាចនិយាយពីកុនដែលខ្ញុំបានមើល ឬមិនអាចនិយាយពីស៊ីក្លូដែលខ្ញុំធ្លាប់ជិះប្រាប់អ្នកដទៃទៀតបានឡើយ ប្រសិនជាខ្ញុំនិយាយពីរឿងទាំងនេះចេញមកក្មេងៗដទៃទៀតនឹងដឹងថាគ្រួសារយើងមកពីទីក្រុងជាមិនខាន ។ ខ្ញុំសុំាលេងជាមួយក្មេងៗ នៅទីក្រុងដែលតែងតែបង្ហាញការយកចិត្តទុកដាក់មករកខ្ញុំទៅហើយ នៅទីនេះក្មេងៗទាំងនេះមើលមកខ្ញុំទាំងការសង្ស័យ ហើយដើរចៀសពីខ្ញុំនៅពេលខ្ញុំដើរសំដៅទៅរកគេ ។ ទោះបីជាខ្ញុំមានបងប្អូនជីដូនមួយជាច្រើនដើម្បីលេងជាមួយក៏ដោយ ក៏នៅពេលថ្ងៃ ខ្ញុំតែងតែទៅជួយដឹកគោជាមួយបងជីដូនមួយរបស់ខ្ញុំនៅឯវាលស្រែជានិច្ច ព្រោះខ្ញុំមិនចង់ឲ្យអ្នកដទៃចំណាយពេលសម្លឹងមករកគ្រួសារយើងខ្លាំងពេក ។ ជាបណ្តើរៗ ខ្ញុំចាប់ស៊ាំនឹងជីវិតនៅតាមវាលស្រែ ហើយបោះបង់ចោលក្តីស្រមៃទាំងប៉ុន្មានដែលចង់ត្រឡប់ទៅផ្ទះវិញអស់រលីង ។

ជាលើកដំបូង ពេលបងស្រីជីដូនមួយ លី ជឿន របស់ខ្ញុំលើកដាក់ខ្ញុំនៅលើខ្នងគោ ខ្ញុំមានការភិតភ័យជាខ្លាំងព្រោះខ្លាចធ្លាក់ពីលើគោមកក្រោម ។ គោមានមាឌខ្ពស់ជាងខ្ញុំឆ្ងាយណាស់ ចំណែកបង លី ជឿន មានអាយុ១៦ឆ្នាំហើយ ដូច្នេះគាត់មានកម្ពស់ខ្ពស់ជាងគោ ។ គាត់លើកខ្ញុំដាក់លើខ្នងគោដោយមិនបាច់ប្រឹងអង្គុយលើខ្នងគោ ជើងរបស់ខ្ញុំយោលទៅយោលមកចំពាក់កណ្តាលពោះរបស់វា ។ ដៃរបស់ខ្ញុំកាន់ខ្សែគោដែលគេខ្ទុះតាមរន្ធច្រមុះវាយ៉ាងណែន ហើយជើងទាំងពីររបស់ខ្ញុំខំប្រឹងឱបខ្លួនវាយ៉ាងជាប់ ។ រៀងរាល់ពេលដែលគោដើរទៅមុខទ្រនុងឆ្អឹងជំនីរបស់វា ធ្វើឲ្យជើងខ្ញុំរង្កៀកចុះឡើងៗ ឯកែងជើងរបស់ខ្ញុំក៏រលាស់ទៅមកៗដូចជាដាក់ម្រាមដៃលើព្យាណូអ៊ីចឹង ។

បង លី ជឿន សើចបណ្តើរនិយាយប្រាប់ខ្ញុំបណ្តើរថា "ខ្លួននៅឲ្យនឹង កុំប្រឹងពេក សត្វគោវាខ្ជិល ដូច្នេះវាដើរទៅមុខយឺតៗ ប្អូននឹងធ្លាក់ពីខ្នងគោប្រសិនបើប្អូនប្រឹងអង្គុយយ៉ាងនេះ" ។ ដោយស្តាប់តាមដំបូន្មានរបស់បង លី ជឿន ខ្ញុំក៏បណ្តោយដងខ្លួនរបស់ខ្ញុំឲ្យយោលយោកទៅតាមចលនារបស់គោ មិនយូរប៉ុន្មានភាពភ័យខ្លាចធ្លាក់ពីលើខ្នងគោរបស់ខ្ញុំក៏រសាយបាត់អស់ទៅ ។

ខ្ញុំត្អូញដាក់គាត់ថា "តើចម្ងាយប៉ុន្មានទៀតបានយើងឈប់? ថ្ងៃនេះធាតុអាកាសក្តៅខ្លាំងណាស់ ហើយខ្ញុំក៏ឈឺគូទដែរ" ។

បង លី ជឿន យកដៃចង្អុលទៅកាន់ក្មេងស្រីមួយក្រុមដែលកំពុងដើរនៅក្នុងវាលដ៏សែនឆ្ងាយពីយើងបណ្តើរនិយាយមករកខ្ញុំបណ្តើរថា "យើងគ្រាន់តែដើរទៅឲ្យហួសកូនភ្នំនោះបន្តិច នៅកន្លែងនោះមានស្មៅខ្ចីជាងនេះសម្រាប់ឲ្យគោស៊ី ។ ឯងគឺជាអ្នកបង់មក ដូច្នេះត្រូវឈប់រអ៊ូរទាំតទៅទៀត" ។ គាត់ពោលទៀតថា "មើលហ្ន៎ មើលពួកគេហ្ន៎ យ៉ាងហោចណាស់ឯងមិនចាំបាច់ធ្វើការដូចគេទេ" ។

គេទាំងនោះគឺជាកូនស្រីអ្នកស្រែ គេមិនមានអាយុច្រើនជាងខ្ញុំប៉ុន្មានទេ ប៉ុន្តែគេកំពុងដើរត្រេតត្រតនៅក្នុងវាលស្រែ ដោយស្ពាយស្បោងសំប៉ែតនៅលើខ្នងជាមួយផង ។ ភ្នែករបស់គេសម្លឹងមើលក្រោម ហើយជារឿយៗក្មេងស្រីម្នាក់នោះឱនចុះរើសយកដុំអ្វីម្យ៉ាងពណ៌បៃតងលាយខ្មៅរួចហើយដាក់ប្រកវាចូលក្នុងស្បោង ។

"គេកំពុងធ្វើអ្វីហ្នឹង?" ។

"គេកំពុងរើសអាចម៍គោក្រៀម" ។

"គគ្រិចណាស់" ។

"ជាទូទៅអ្នកស្រែជិះរទេះគោ ហើយដឹកជញ្ជូនអាចម៍សត្វ

ទុកធ្វើជាជី ។ ក្មេងស្រីនេះកំពុងរើសអាចម៍សត្វស្វូត ពីព្រោះគេជឿថាគេអាចយកវាធ្វើជាថ្នាំបាន ។ គេនឹងយកអាចម៍សត្វក្រៀមនេះ ទៅស្ងោរក្នុងទឹក ហើយផឹកវាដូចជាតែអ៊ីចឹង ។»

ខ្ញុំលាន់មាត់ម្តងទៀតថា «ខ្ពើមណាស់!» ។

ទោះបីជាវាក្លាយទៅជាបទពិសោធន៍ថ្មីសម្រាប់ខ្ញុំក៏ដោយ ក៏វានៅតែធ្វើឲ្យខ្ញុំធុញដដែល ព្រោះខ្ញុំជិះវារាល់ថ្ងៃពេក ។ យើងរស់នៅក្នុងភាពដដែលៗនៃជីវិតចម្ការរបស់យើង នៅពេលយើងរស់នៅក្នុងភូមិក្រាំងត្រប់ យូរៗទៅភាពភ័យខ្លាចក៏កាន់តែកើនឡើងៗ ។ នៅគ្រប់ទីកន្លែងទាំងអស់ដែលខ្ញុំបានធ្វើដំណើរ ខ្ញុំមិនអាចគេចចេញពីអារម្មណ៍ដែលថា មានមនុស្សចាំឃ្លាំមើលខ្ញុំបានទេ ។ ហេតុដូច្នេះហើយ ទោះបីជាខ្ញុំមិនមានកន្លែងណាដែលត្រូវទៅនៅពេលព្រឹកៗក៏ដោយ ក៏ខ្ញុំប្រញាប់ក្រោកពីដំណេកហើយស្លៀកពាក់ដើម្បីខ្ញុំអាចឃើញប៉ាមួយភ្លែតមុននឹងគាត់ចេញទៅធ្វើការ ។ ភាគច្រើននៅពេលព្រឹក ពេលដែលខ្ញុំក្រោកឡើងប៉ាហើយនិងបងប្រុសរបស់ខ្ញុំបានចេញដំណើរទៅធ្វើការបាត់អស់ទៅហើយ ចំណែកម៉ាកំពុងតែរវល់ដេរខោអាវសម្រាប់គ្រួសារយើង ឬកំពុងរវល់ធ្វើការនៅក្នុងសួនដំណាំ ។ បន្ទាប់ពីស្លៀកពាក់ហើយខ្ញុំចាប់ផ្តើមធ្វើអ្វីៗដែលខ្ញុំអាចធ្វើដូចជាសម្អាតខ្លួនរបស់ខ្ញុំដោយខ្លួនឯង ។ ប៉ាប្រាប់យើងថាអនាម័យខ្លួនប្រាណគឺជាការសំខាន់ ដូច្នេះខ្ញុំព្យាយាមសម្អាតខ្លួនដើម្បីឲ្យគាត់សប្បាយចិត្ត ។ ដោយហេតុថា យើងគ្មានថ្នាំដុសធ្មេញ និងច្រាសដុសធ្មេញខ្ញុំយកស្មៅស្ងួតមួយដៃមកដុសធ្មេញជំនួសច្រាសដុសធ្មេញវិញ ។ ដើម្បីដុសធ្មេញឲ្យដល់ធ្មេញក្រោយខ្ញុំត្រូវតែរុញចង្អុលដៃរបស់ខ្ញុំចូលទៅក្នុងមាត់ ហើយយកដៃនោះកៀរកម្ទេចកម្ទីដែលជាប់នឹងធ្មេញចេញ ។

ពេលខ្ញុំងូតទឹកម្តងៗ ខ្ញុំត្រូវទៅងូតនៅរានតូចមួយដែលស្រដៀងនឹងបន្ទប់ទឹកក្រោយផ្ទះ ។ នៅលើរានងូតទឹកនោះមានធុងទឹកធំមួយដែលមើលទៅដូចជាថូផ្កា ធ្វើពីដីឥដ្ឋកម្ពស់០.៩១៥ម៉ែត្រ ។ ទឹកនោះ បងគីម និងបងប្អូនជីដូនមួយខ្ញុំបានយួរមកចាក់បំពេញវាជារៀងរាល់ល្ងាច ។ ខ្ញុំដោះសម្លៀកបំពាក់ចេញ ហើយព្យួរវាទៅនឹងមែកឈើតាមផ្លូវចូលរានងូតទឹកនោះ ។ បន្ទាប់មកខ្ញុំក៏លូកដៃដងទឹកមួយផ្តិលចេញពីធុង ហើយយកវាមកស្រោចលើខ្លួនខ្ញុំ ។ នៅទីនេះគ្មានសាប៊ូដុសខ្លួននិងសាប៊ូកក់សក់ទេ មកពីមូលហេតុនេះហើយទើបបានជាសក់ខ្ញុំស្អិតជំពាក់ជាប់គ្នាធ្វើឲ្យខ្ញុំឈឺណាស់ ពេលខ្ញុំសិតសក់ម្តងៗ ។

ប៉ាត្រឡប់មកវិញនៅពេលអគ្រាត្រទាំងខ្លួនគគ្រិចនិងអស់កម្លាំង ។ ជួនកាល បន្ទាប់ពីពិសាអាហារយ៉ាងរហ័សរួចមក ប៉ាអង្គុយសម្លឹងមើលមេឃតែម្នាក់ឯងយ៉ាងស្ងៀមស្ងាត់នៅក្រៅផ្ទះ ហើយពេលគាត់ត្រឡប់ចូលមកក្នុងខ្ទមរបស់យើងវិញ គាត់ក៏គេងលក់បាត់ក្នុងមួយពព្រិចភ្នែក ។ ខ្ញុំកម្របានអង្គុយលើភ្លៅប៉ា ដូចកាលពីមុនទៀតណាស់ ។ ខ្ញុំនឹកដល់ការឱបថើបរបស់គាត់ ហើយនឹកដល់ពេលដែលគាត់ធ្វើឲ្យខ្ញុំសើច ពេលខ្ញុំស្តាប់រឿងនិទាននិងរឿងចិនបុរាណរបស់គាត់ ។ រឿងនិទានរបស់ប៉ា គឺជារឿងនិយាយអំពីទេវតា ព្រះពុទ្ធនិងនាគដែលចុះមកផែនដីដើម្បីកម្ចាត់ពួកបិសាចនិងដើម្បីមកជួយប្រជាជន ។ ខ្ញុំឆ្ងល់ណាស់ថា តើទេវតានិងនាគនឹងចុះមកផែនដីជួយយើងដែរឬទេនៅពេលនេះ? ។

**(ចប់ដោយសង្ខេប)**


## សេចក្តីជូនដំណឹង

ប្រសិនបើមិត្តអ្នកអានចាប់អារម្មណ៍ក្នុងការអានសៀវភៅនេះទាំងស្រុង សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានដូចខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

**Email: dccam@bigpond.com.kh**
**Home page: http://welcome.to/dccam**

ឬអាចរកបាននៅតាមបណ្តាតូបលក់សៀវភៅ និងហាងលក់សៀវភៅ *Monument Book Store* ។

សូមអរគុណ ។

# ខែអកអំបុក ខ្ញុំព្រាត់ប្តី




ជារៀងរាល់ឆ្នាំ នៅពេលដែលស្រូវវស្សាចាប់ផ្តើមទុំស្គាបសេក ប្រជាជនកម្ពុជានៅតាមស្រុកស្រែចម្ការតែងតែនាំគ្នាដាល់អំបុក ហើយនៅថ្ងៃទី១៥កើត ខែកត្តិក (ខែវិច្ឆិកា) ប្រជាជនកម្ពុជាទាំងអស់តែងប្រារព្ធពិធីបុណ្យអកអំបុកនិងសំពះព្រះខែយ៉ាងអធឹកអធម ។ ប៉ុន្តែ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានការដាល់អំបុកនិងគ្មានពិធីបុណ្យអកអំបុកទេ ។ នៅរដូវអកអំបុកនាឆ្នាំ១៩៧៧ គឺជាពេលដែលខ្មែរក្រហមប្រមូលខ្មែរក្រោមទាំងអស់នៅក្នុងឃុំខ្វារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ យកទៅសម្លាប់ ។

ចាយ គឹម អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ បានក្លាយទៅជាស្ត្រីមេម៉ាយក្នុងឆ្នាំ១៩៧៧ ដោយសារខ្មែរក្រហមបានយកប្តីរបស់គាត់ទៅសម្លាប់ ។ ចាយ គឹម បាននិយាយទាំងទឹកភ្នែករលីងរលោងថាៈ «ខ្ញុំដឹងច្បាស់ថាខ្មែរក្រហមស្រាវជ្រាវរកខ្មែរក្រោមទៅសម្លាប់ ។ ប៉ុន្តែខ្ញុំនៅតែប្រាប់កម្មាភិបាលខ្មែរក្រហមទាំងនោះថាខ្ញុំជាខ្មែរក្រោម ពីព្រោះខ្ញុំចង់ស្លាប់ជាមួយប្តីនិងកូនទាំង៧នាក់របស់ខ្ញុំ» ។

កាលពីជាង៤០ឆ្នាំមុន ចាយ គឹម ជាប្រជាជនរស់នៅក្នុងខេត្តកណ្តាល ហើយបានរៀបការជាមួយបុរសខ្មែរក្រោមម្នាក់ឈ្មោះ សារ៉ែន ។ ក្រោយពេលរៀបការ ចាយ គឹម បានផ្លាស់មករស់នៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ។

ក្រោយពេលដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរកាន់អំណាចនៅឆ្នាំ១៩៧០ ប្រជាជនជាច្រើនត្រូវបានកេណ្ឌឲ្យចូលធ្វើទាហានដើម្បីប្រយុទ្ធជាមួយខ្មែរក្រហម ។ ប្រជាជនមួយចំនួននៅក្នុងឃុំរំលេចមានការភ័យខ្លាច ហើយបានរត់ចោលផ្ទះសម្បែង ភូមិដ្ឋានទៅលាក់ខ្លួននៅតាមព្រៃ ។ ទន្ទឹមនឹងនោះ កម្មាភិបាលខ្មែរក្រហមបានមកដល់ឃុំរំលេច ហើយបានឃោសនាអូសទាញប្រជាជនឲ្យចូលបម្រើបដិវត្តន៍របស់ខ្លួន ។ ក្នុងចំណោមកម្មាភិបាលខ្មែរក្រហមដែលមកឃោសនា ក៏មានខ្មែរក្រោមដែលនៅក្នុងឃុំរំលេចដែរ ។ ក្នុងចំណោមខ្មែរក្រោមទាំងនោះ មានម្នាក់ឈ្មោះ តាផាន់ ត្រូវបានចាត់តាំងឲ្យធ្វើជាមេឃុំរំលេច និងជំនួយការបីនាក់ទៀតគឺ តាខែវ, តាយ៉ាន និង តាធឹម ។ ក្រោមការឃោសនាអូសទាញនេះ មានខ្មែរក្រោមជាច្រើនបានចូលបម្រើបដិវត្តន៍ ។ បន្ទាប់មកភាគច្រើននៃអ្នកទាំងនោះត្រូវបានចាត់តាំងឲ្យធ្វើជាឈ្លបនិងកងទ័ព ។

នៅពេលដែលមានការប្រយុទ្ធគ្នារវាងកងកម្លាំងរបស់សាធារណរដ្ឋខ្មែរនិងខ្មែរក្រហម ភាគីទាំងសងខាងតែងតែកៀរប្រជាជនឲ្យមករស់នៅក្នុងតំបន់ដែលខ្លួនកាន់កាប់ ។ ថ្ងៃមួយ ទាហាននៃរបបសាធារណរដ្ឋខ្មែរបានវាយលុកទៅដល់ភូមិរបស់ ចាយ គឹម ហើយកៀរគាត់ឲ្យមករស់នៅក្នុងឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នៅឆ្នាំ១៩៧៤ ចាយ គឹម ត្រូវបានអ្នកនាំពាក្យម្នាក់នៅតំបន់រំដោះប្រាប់ថា ប្រសិនបើគាត់ត្រឡប់ទៅរស់នៅក្នុងភូមិវិញ ប្រធានភូមិនឹងប្រគល់គោក្របីដែលគាត់បានរត់ចោលនោះឲ្យទៅគាត់វិញ ។ ប៉ុន្តែនៅពេលទៅដល់ភូមិប្រឡាយរំដេងដែលជាភូមិចាស់ ចាយ គឹម ត្រូវបានខ្មែរក្រហមចាត់ទុកជាឈ្លញនាយទុនប្រតិកិរិយាទៅវិញ ។

ចាយ គឹម បានរៀបរាប់ថា ក្នុងអំឡុងដើមឆ្នាំ១៩៧៧ ប្រធានឃុំឈ្មោះ តាផាន់ បានកោះហៅប្រជាជនទាំងអស់ទៅប្រជុំ ហើយប្រកាសប្រាប់ថានឹងមានការស្រង់ប្រវត្តិរូប ។ បន្ទាប់ពីការប្រជុំ ចាយ គឹម ត្រូវមេកងឈ្មោះ តាមៀន សួរប្រវត្តិរូបចំនួន២ទៅ៣ដង ។ តាមៀន សួរសំណួរដដែលៗថា "ជាខ្មែរឬខ្មែរក្រោម? មានកូនប៉ុន្មាននាក់?" ។ តាមៀន បានប្រាប់ ចាយ គឹម ថា គាត់ស្រង់ប្រវត្តិរូបនេះដើម្បីយកខ្មែរក្រោមទៅរស់នៅកន្លែងផ្សេងពីអ្នកដទៃ ។ ការសាកសួរប្រវត្តិរូបនេះ គឺប្រធានកងដើរសួរសមាជិកក្នុងកងគ្រប់គ្នា មិនថានរណាជានរណាឡើយ ។ ចំពោះប្រជាជនណាដែលប្រធានកងស្គាល់ច្បាស់

ថាជាខ្មែរក្រោម ប្រធានកងបានចុះឈ្មោះនៅក្នុងបញ្ជីខ្មែរក្រោមតែម្តង ។

ក្រោយពីការសាកសួរអស់មួយរយៈមក នៅដើមរដូវវស្សាឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្មែរក្រោមទាំងអស់ចេញពីឃុំរំលេចឲ្យទៅរស់នៅក្នុងឃុំខ្នារទទឹង ។ សារ៉ន ដែលជាប្តីរបស់ ចាយ គីម ត្រូវបានចាត់តាំងឲ្យទៅកាប់ឈើនៅលើភ្នំ ។ ចំណែក ចាយ គីម ត្រូវបានចាត់តាំងឲ្យទៅកិនស្រូវនិងធ្វើជាចុងភៅ ។ ការរស់នៅក្នុងឃុំខ្នារទទឹង ចាយ គីម ត្រូវមេកងឈ្មោះ យាយពុម សួរប្រវត្តិរូបជាច្រើនដងបន្ថែមទៀត ។

អស់រយៈពេល៤-៥ខែក្រោយមក គឺជាពេលដែលស្រូវចាប់ផ្តើមទុំស្វាបសេក កម្មាភិបាលខ្មែរក្រហមបានប្រមូលខ្មែរក្រោមទាំងអស់យកទៅសម្លាប់ ដោយប្រាប់ថាទៅធ្វើការនៅព្រៃធំ ។

សារ៉ន ត្រូវមិត្តភក្តិម្នាក់ដែលជាកម្មាភិបាលខ្មែរក្រហមប្រាប់ឲ្យដឹងជាមុនថា ការហៅទៅធ្វើការនៅព្រៃធំគ្រាន់តែជាលេស ដើម្បីយកខ្មែរក្រោមទៅសម្លាប់ចោលប៉ុណ្ណោះ ។ សារ៉ន បានគិតទុកជាស្រេចថានឹងតដៃ ហើយរត់គេចនៅពេលដែលដល់វេនខ្លួនត្រូវយកទៅ"ព្រៃធំ" ។ សារ៉ន ក៏ធ្លាប់បាននិយាយរឿងនេះប្រាប់ ចាយ គីម ជាប្រពន្ធដែរ ។ នៅពេលដែលអង្គការចាត់តាំងឲ្យទៅធ្វើការនៅព្រៃធំ សារ៉ន បានត្រូវមេកងអនុញ្ញាតឲ្យចុះពីលើភ្នំត្រឡប់មកផ្ទះវិញ ហើយនៅវេលាម៉ោង៥ល្ងាចថ្ងៃដដែល មេកងបានមកប្រាប់ឲ្យ សារ៉ន រៀបចំអីវ៉ាន់ ដើម្បីជួបប្រជុំគ្នានៅវេលាម៉ោង៩ថ្ងៃស្អែក អំពីផែនការផ្លាស់ប្តូរការងារពីកាប់ពោតទៅកាប់ឈើនៅព្រៃធំវិញ ។

ចាយ គីម បានដឹងថា ខ្មែរក្រោមទាំងអស់ដែលមកប្រជុំនេះនឹងត្រូវយកទៅសម្លាប់ ប៉ុន្តែគាត់បែរជាប្រាប់កម្មាភិបាលខ្មែរក្រហមដែលមកប្រជុំនោះថា គាត់ជាខ្មែរក្រោម ។ ចាយ គីម មិនចង់ឲ្យខ្មែរក្រហមយកសេចក្តីស្លាប់មកបំបែកក្រុមគ្រួសាររបស់គាត់ឡើយ ។ ចាយ គីម បានតាំងចិត្តស្លាប់ជាមួយប្តីនិងកូន៧នាក់របស់គាត់ ទោះបីជាប្តីរបស់គាត់អង្វរករឲ្យគាត់ប្រាប់ការពិតដល់មេកងថា ខ្លួនមិនមែនជាខ្មែរក្រោមយ៉ាងណាក៏ដោយ ។

ចាយ គីម នៅតែមិនបោះបង់ការតាំងចិត្តរបស់ខ្លួនដដែល ។ សារ៉ន មិនព្រមបណ្តោយឲ្យប្រពន្ធនិងកូនរបស់ខ្លួនត្រូវស្លាប់ដោយអយុត្តិធម៌ដូច្នេះឡើយ ។ សារ៉ន បានក្រោកឈរឡើង ហើយនិយាយថា "ប្រពន្ធខ្ញុំមិនមែនជាខ្មែរក្រោមទេ ខ្ញុំសូមផ្ញើគាត់នឹងមិត្តបងផង បើសិនជាគាត់មានជីវិតរស់នៅ សូមជួយមើលគាត់ផង" ។ សាក្សីជាច្រើននាក់បានបញ្ជាក់ថា ចាយ គីម មិនមែនជាខ្មែរក្រោមទេ ។

ការប្រជុំបានបញ្ចប់នៅម៉ោង១០ព្រឹក ។ សារ៉ន និងខ្មែរក្រោមដទៃទៀត ត្រូវបានឈ្លបបញ្ជាឲ្យចេញដំណើរ ។ កងឈ្លបបានប្រមូលអីវ៉ាន់ដាក់នៅលើរទេះ ដោយប្រាប់ថានឹងយកទៅតាមក្រោយ ។ ប៉ុន្តែនៅពេលដែលប្រមូលមនុស្សទៅបាត់អស់ហើយ អីវ៉ាន់ទាំងនោះត្រូវបញ្ជូនចូលឃ្លាំងក្នុងភូមិវិញ ។

សារ៉ន បានព្យាយាមការពារក្រុមគ្រួសាររហូតដល់នាទីចុងក្រោយនៃជីវិតរបស់គាត់ ។ ខ្មែរក្រហមបានសម្លាប់ សារ៉ន ទៅហើយ ប៉ុន្តែ សារ៉ន នៅតែរស់ក្នុងអារម្មណ៍របស់ប្រពន្ធគាត់ជានិច្ច ។ សារ៉ន បានស្លាប់ទៅដោយបន្សល់ទុកនូវបណ្តាំចុងក្រោយឲ្យ ចាយ គីម "ខិតខំថែរក្សាកូនៗ និងខំតស៊ូរស់នៅតទៅទៀត" ។

បច្ចុប្បន្ន ចាយ គីម រស់នៅភូមិប្រឡាយរំដេង ក្នុងខេត្តពោធិ៍សាត់ ។ ភូមិប្រឡាយរំដេងគឺជាអតីតព្រៃឈើទាល ។ នៅក្នុងរជ្ជកាលព្រះមហាក្សត្រ សម្តេចព្រះ មុនីវង្ស មានខ្មែរក្រោមមួយចំនួនបានរត់ចេញពីស្រុកកំណើតមកកាប់ឆ្ការព្រៃឈើទាលនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ បង្កបង្កើតជាភូមិឋានជាច្រើន ។ ក្នុងចំណោមភូមិទាំងនោះ មានភូមិចំនួនបីស្ថិតនៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ គឺភូមិរំលេច ភូមិប្រឡាយរំដេង និងភូមិរូងតាកុក ដែលមានខ្មែរក្រោមរស់នៅច្រើន ។ មុនឆ្នាំ១៩៧៥ នៅក្នុងឃុំរំលេចមានខ្មែរក្រោមរស់នៅប្រមាណ៤០០០នាក់ ប៉ុន្តែក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងរយៈកាលជាង៣ឆ្នាំ ខ្មែរក្រោមទាំងនោះត្រូវបានសម្លាប់ស្ទើរតែទាំងអស់ ។ អ្នកដែលមានជីវិតរស់សេសសល់មកដល់បច្ចុប្បន្នមានប្រមាណជាង៤០នាក់ប៉ុណ្ណោះ ដោយសារអ្នកទាំងនោះ ១) ជាខ្មែរក្រោមដែលរត់ទៅរស់នៅតំបន់ផ្សេង ក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច ២) កូនដែលមានឪពុកឬម្តាយដែលជាខ្មែរក្រោម ។

**គីម កែវកន្និដ្ឋា**

# ឡឿន នាលៈ លោហិតព្រះយេស៊ូសម្អាតគ្រប់អំពើបាប

ឡឿន នាល ត្រូវបានប្រជាជនភាគច្រើននៅក្នុងភូមិជាមួយស្គាល់ថា ជាគ្រូគង្វាលនៃសាសនាព្រះយេស៊ូគ្រិស្ត ។ នាល បាននិយាយថា បើគាត់មានឱកាសគាត់នឹងជួយដល់ប្រជាជននៅក្នុងភូមិរបស់គាត់ និងប្រជាជនដទៃទៀតឲ្យបានរួចផុតពីអំពើបាប និងអាចទៅកាន់ឋានសួគ៌ ។ ក៏ប៉ុន្តែកាលពី២៥ឆ្នាំមុន នាល ធ្លាប់បានធ្វើការជាកងឈ្លបរបស់ខ្មែរក្រហម ។

នាល មានអាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងលំនៅដ្ឋានមួយដែលសង់អំពីឈើប្រក់ស័ង្កសី និងជញ្ជាំងធ្វើអំពីស្លឹកត្នោតដែលហ៊ុំព័ទ្ធជុំវិញដោយវាលស្រែធំល្វឹងល្វើយ ។ នាល បាននិយាយថា “សព្វថ្ងៃនេះ ខ្ញុំធ្វើស្រែនិងបម្រើព្រះ” ។ ប្រពន្ធនិងកូនរបស់គាត់ទាំងអស់សុទ្ធតែបានជឿ និងគោរពប្រតិបត្តិព្រះយេស៊ូ ។




នៅខាងលើនិងសងខាងទ្វារផ្ទះរបស់គាត់ផ្នែកខាងមុខគាត់បានដាក់ព្យួរយ៉ាងមានរបៀបរៀបរយ នូវពាក្យស្លោកដែលមានខ្លឹមសារថា “លោហិតព្រះយេស៊ូសម្អាតគ្រប់អំពើបាប” “ជឿព្រះយេស៊ូមានជីវិតអស់កល្បជានិច្ច” និង “ព្រះសង្គ្រោះបាប គឺព្រះយេស៊ូ” ។

នៅឆ្នាំ១៩៧០ នាល បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែលមានឋានៈជាសមាជិកឈ្លបឃុំ ។ នាល បានធ្វើការងារនេះអស់រយៈពេលជាងប្រាំឆ្នាំ ។ ថ្ងៃ១៧ មេសា ១៩៧៥ នាល ត្រូវបានជ្រើសតាំងជាប្រធានសហករណ៍ឃុំរំលេច ស្ថិតនៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ ។ ប្រមាណបីខែក្រោយ នាល ត្រូវបានចាត់តាំងឲ្យបម្រើការជាកងឈ្លបវិញរហូតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម ។

រំលេចជាឃុំមួយក្នុងចំណោមឃុំទាំងអស់របស់ស្រុកបាកាន ដែលមានប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅច្រើន ។ នៅមុនឆ្នាំ១៩៧៥ ឃុំនេះមានប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅប្រមាណប្រាំរយគ្រួសារ ដែលមានសមាជិកប្រមាណបួនពាន់នាក់ ។ នៅក្នុងរយៈកាលនៃការកាន់អំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ប្រជាជនខ្មែរកម្ពុជាក្រោមនៅទីនោះត្រូវបានចាប់បញ្ជូនយកទៅសម្លាប់នៅក្នុងឃុំខ្នារទទឹងស្ទើរតែទាំងអស់ ។

ឃុំខ្នារទទឹងមានព្រំប្រទល់ជាប់ឃុំរំលេច និងជាកន្ទ្រៃសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃ ។ តាមការអះអាងរបស់ប្រជាជននៅទីនោះថា នៅក្នុងឆ្នាំ១៩៧៨ ប្រជាជនភូមិភាគបូព៌ារាប់ពាន់នាក់ត្រូវបានបញ្ជូនយកមកបាញ់សម្លាប់ចោលនៅទីនេះ ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម នៅឆ្នាំ១៩៧៩ ប្រជាជនខ្មែរកម្ពុជាក្រោមប្រមាណ៤០នាក់ប៉ុណ្ណោះ ដែលបានរួចផុតពីការសម្លាប់រង្គាល ។ អ្នកទាំងនោះនៅរស់រានមានជីវិតដោយសារតែបានលួចរត់គេចចេញពីការគ្រប់គ្រងរបស់ខ្មែរក្រហមនៅតំបន់នោះ ។

ប្រជាជនខ្មែរកម្ពុជាក្រោមរាប់ពាន់នាក់ បានត្រូវចាប់ខ្លួនយកទៅសម្លាប់ ។ នៅក្នុងចំណោមអ្នកទាំងអស់នោះ ក៏មាន

បងថ្លៃប្រុសម្នាក់និងក្មួយប្រុសម្នាក់របស់ នាល ដែរ ។ នាល បាននិយាយថា *"នៅពេលដែលនឹកដល់អ្នកទាំងពីរ ធ្វើឲ្យខ្ញុំរំជួលចិត្ត ហើយជួនកាលស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ កាលណោះ សូម្បីតែខ្ញុំធ្វើការឲ្យខ្មែរក្រហម ក៏ពិបាកនឹងរក្សាជីវិតខ្លួនឯងឲ្យគង់ដែរ"* ។

នាល បាននិយាយដោយមានកាន់ព្រះគម្ពីរនៅក្នុងដៃថា ទោះបីជាគាត់បម្រើការងារជាកងឈ្លបក៏ពិតមែន តែគាត់មិនដែលបានធ្វើបាបអ្នកណាម្នាក់នៅក្នុងភូមិស្រុករបស់គាត់ទេ ។ នាល បានអះអាងថា គាត់ធ្លាប់បានដឹងនិងឃើញកងឈ្លបនៅក្នុងក្រុមរបស់គាត់ចាប់មនុស្សយកទៅសម្លាប់ចោល ។

ឆ្នាំ១៩៧៩ នាល បានរត់ភៀសខ្លួនទៅដល់ព្រំប្រទល់កម្ពុជា-ថៃ ហើយបានរស់នៅក្នុងជំរំភៀសខ្លួនមួយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ៍ សាក់ ស៊ុតសាខន ។ នៅក្នុងឆ្នាំ១៩៩២ នាល បានធ្វើមាតុភូមិនិវត្តន៍ជាមួយប្រជាជនកម្ពុជាជាច្រើននាក់ទៀត មកនៅរស់នៅក្នុងភូមិកំណើតវិញ ។

នាល ចាប់ផ្តើមគោរពប្រណិតបត្តិសាសនាព្រះយេស៊ូគ្រិស្ត នៅក្នុងឆ្នាំ១៩៩៦ ។ នាល បានប្រាប់ឲ្យដឹងថា មូលហេតុដែលនាំឲ្យគាត់គោរពប្រណិបត្តិព្រះយេស៊ូ គឺដោយសារគាត់យល់ថា "ជឿព្រះយេស៊ូរួចពីអំពើបាប" ។ គាត់បានពន្យល់ទៀតថា "ព្រះយេស៊ូបានបង្កើតអ្វីៗទាំងអស់នៅលើផែនដីនេះ ហើយមនុស្សគ្រប់គ្នាសុទ្ធតែមានបាប ។ ដូច្នេះមានតែព្រះយេស៊ូមួយអង្គគត់ដែលអាចសង្គ្រោះមនុស្សឲ្យរួចផុតពីអំពើបាប" ។

នៅក្នុងព្រះគម្ពីរបរិសុទ្ធសញ្ញាចាស់និងសញ្ញាថ្មីនៃគ្រិស្តសាសនាបានកត់ត្រានូវព្រះបន្ទូលរបស់ព្រះនៅក្នុងសារបានលោកុប្បតិត្រង់ទំព័រ១៣ជំពូក៩:៥ថា "រីឯជីវិតមនុស្សវិញ បើអ្នកណាយកជីវិតគេ នោះអញនឹងទាមទារឈាមដែលជាជីវិតរបស់អ្នកនោះជាមិនខាន អញនឹងទារឈាមអ្នកនោះ ដោយសារអស់ទាំងសត្វ ហើយដោយសារដៃរបស់មនុស្ស គឺដោយសារដៃរបស់បងប្អូននៃអ្នកដែលស្លាប់នោះផង ។ អ្នកណាដែលបានកម្ចាយឈាមរបស់មនុស្សនោះឈាមអ្នកនោះឯង នឹងត្រូវខ្ចាយដោយសារមនុស្សដែរ ដ្បិតទ្រង់បានបង្កើតមនុស្សដូចជារូបរបស់ទ្រង់" ។

**ហ៊ុយ ខណ្ឌៈ**

# សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

***ការសរសេរអត្ថបទនេះមានសារសំខាន់៥យ៉ាងគឺ***

◆ ចូលរួមជាចំណែកមួយនៃប្រវត្តិសាស្ត្រ ទុកសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជួយដល់ក្នុងការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យនោះ ។

◆ ជាវិធីមួយដើម្បីរំសាប់អារម្មណ៍ ដោយយកសេចក្តីទុក្ខការឈឺចាប់ មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រ ដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពីប្រល័យពូជសាសន៍កើតឡើងបានជាថ្មីម្តងទៀតក្នុងសង្គមមនុស្ស ។

◆ ជួយលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស (សិទ្ធិរស់រានមានជីវិត) នៅក្នុងពេលបច្ចុប្បន្ននិងថ្ងៃអនាគត ។

មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចុះផ្សាយអត្ថបទទាំងនោះនៅលើទំព័រទស្សនាវដ្តី ឬបោះពុម្ពជាសៀវភៅ ក្នុងករណីបានទទួលការអនុញ្ញាតពីសាមីខ្លួន ។

សូមអរគុណ ។



នួន ជា

# រដ្ឋធម្មនុញ្ញទាំងឡាយនៅកម្ពុជា

## មហិច្ឆតា ការបន្ត និង ការលុបចោល

**(តចប់)**

ជំពូកទី៣ និយាយអំពីសិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋ ។ ការគោរពសិទ្ធិផ្សេងៗរបស់មនុស្ស ភាពស្មើគ្នារបស់ពលរដ្ឋចំពោះមុខច្បាប់ សិទ្ធិបោះឆ្នោតនិងឈរឈ្មោះឲ្យគេបោះឆ្នោត សិទ្ធិទទួលប្រាក់បំណាច់សមស្របតាមបរិមាណនិងគុណភាពនៃការងារ សិទ្ធិក្នុងការឈប់សម្រាក លម្ហែ ភាពមិនអាចរំលោភលើរូបកាយពលរដ្ឋគ្រប់រូប សេរីភាពក្នុងការសម្តែងមតិ ការប្រជុំនិងការបង្កើតសហគមន៍ត្រូវបានទទួលស្គាល់ (មាត្រា៣០ដល់៣៨) ។ ពលរដ្ឋត្រូវគោរពគោលការណ៍នៃការរស់នៅក្នុងសង្គម អនុវត្តន៍គោលនយោបាយរបស់រដ្ឋនិងគោរពទ្រព្យសម្បត្តិរួម (មាត្រា៣៩) ។ ពលរដ្ឋត្រូវគោរពយ៉ាងខ្ជាប់ខ្ជួនតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ និងមានករណីយកិច្ចបម្រើកិច្ចការរបស់រដ្ឋព្រមទាំងបម្រើក្នុងកងទ័ពតាមបញ្ញត្តិច្បាប់ (មាត្រា៤០និង៤១) ។ ពលរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលកំពុងរស់នៅបរទេស ត្រូវបានគាំពារដោយច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា (មាត្រា៤២) ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាផ្តល់សិទ្ធិជ្រកកោនដល់ជនបរទេសទាំងឡាយណាដែលត្រូវចោទពីបទបានធ្វើសកម្មភាពតស៊ូជាគុណប្រយោជន៍ដល់លទ្ធិប្រជាធិប-តេយ្យនិងសង្គមនិយម (មាត្រា៤៣) ។ អាណិកជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជាត្រូវគោរពច្បាប់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា (មាត្រា៤៤) ។

គេដឹងថា ក្នុងនាទីដ៏ជាក់លាក់នៃសេរីភាពសំខាន់ៗនេះ រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមិនសូវធ្វើតាមការសន្យារបស់ខ្លួនប៉ុន្មានទេ ។ ការចាប់ខ្លួនដែលធ្វើដោយអំណាចចិត្ត ការដាក់គុកដោយគ្មានការវិនិច្ឆ័យទោស ភាពគ្មានសេរីភាពក្នុងការបញ្ចេញមតិនិងការបង្កើតសហគមន៍ ការកម្រិតព្រំដែនក្នុងការធ្វើដំណើរ ការដាក់ប្រជាជនឲ្យនៅក្នុងក្របខ័ណ្ឌនយោបាយ-នគរបាល បានធ្វើឲ្យគេកត់សម្គាល់ក្នុងបណ្តាឆ្នាំនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ជំពូកទី៤ រៀបរាប់ពីអាណត្តិ សមាសភាព និងការប្រព្រឹត្តិទៅរបស់រដ្ឋសភាជាតិ (មាត្រា៤៥ដល់៥៨) ។ ក្នុងជំពូកនេះ យើងបានជួបជាថ្មីនូវបញ្ញត្តិផ្សេងៗដូចធ្លាប់មានមកហើយ ដែលទាក់ទងទៅនឹងសភាតំណាងមួយ ។ យើងដឹងថា សភាដែលជ្រើសតាំងនៅឆ្នាំ១៩៨១ មានអាណត្តិមួយសម្រាប់រយៈពេល៥ឆ្នាំ (មាត្រា៤៧ ជំពូក១) ។ ពុំមានការបោះឆ្នោតនៅឆ្នាំ១៩៨៦ទេ ទាំងក្នុងបណ្តាឆ្នាំដែលមានជាបន្តបន្ទាប់ ពីព្រោះគេប្រាប់ឲ្យដឹងថា “រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនបានក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត” (មាត្រា៤៧ ជំពូក២) ។ ដូចគ្នាដែររដ្ឋសភាបានប្រើសិទ្ធិរបស់ខ្លួនតិចតួចក្នុងការត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋ និងក្រុមប្រឹក្សារដ្ឋមន្ត្រីដែលផ្តល់ឲ្យដោយមាត្រា៤៨ ជំពូក៧ ។ ទីបំផុត គឺភាពមិនប្រែប្រួលដែលអាចសង្កេតបានអំពីរបបកុម្មុយនិស្ត ប៉ុន្តែក៏មានក្នុងការអនុវត្តត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាដែរ រដ្ឋសភាពុំបានបង្ហាញឲ្យឃើញស្វ័យភាពរបស់ខ្លួនទេ បើប្រៀបធៀបនឹងអង្គការនីតិប្រតិបត្តិ ។

ជំពូកទី៥ និយាយអំពីក្រុមប្រឹក្សារដ្ឋ (មាត្រា៥៩ដល់៦៣) ។ រីឯជំពូកទី៦ និយាយអំពីក្រុមប្រឹក្សារដ្ឋមន្ត្រី (មាត្រា៦៤ដល់៧០) ។ គ្មានលក្ខណៈពិសេសអ្វីដែលត្រូវលើកយកមកនិយាយអំពីជំពូកទាំងពីរនេះ ដែលស្របទៅតាមច្បាប់រដ្ឋធម្មនុញ្ញដូចធ្លាប់មានមកហើយរបស់បណ្តារបបកុម្មុយនិស្តទេ ។

ជំពូកទី៧ និយាយអំពីរចនាសម្ព័ន្ធខេត្តនិងមូលដ្ឋាន (មាត្រា៧១ដល់៧៨) ។ ស្ថាប័នផ្សេងៗ គណៈកម្មាធិការប្រជាជនបដិវត្តន៍ត្រូវមាននៅគ្រប់ក្រុង ខេត្ត ស្រុក និងឃុំ ។ ទីក្រុងនានាដែលចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ (ក្រុងភ្នំពេញ កំពង់សោម) ត្រូវបែងចែកជាសង្កាត់ដែលគ្រប់គ្រងដោយប្រភេទគណៈកម្មាធិការប្រជាជនមួយដូចគ្នា ។ គណៈកម្មាធិការ សង្កាត់ឬឃុំទាំងនេះ ត្រូវបានប្រជាជននៅឃុំនិងសង្កាត់ជ្រើសរើសតាមគោលការណ៍បោះឆ្នោតជាសកល ។ ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រជាជនបដិវត្តន៍នៅថ្នាក់ក្រុង ខេត្ត ឬ ស្រុក ត្រូវបានធ្វើឡើងដោយអ្នកតំណាងថ្នាក់ក្រុង ខេត្ត ស្រុក និងដោយអ្នកតំណាងបក្សនិងអង្គការមហាជននៅតាមថ្នាក់នីមួយៗនោះ ។ គណៈកម្មាធិការប្រជាជនបដិវត្តន៍ទាំងនេះ បំពេញភារកិច្ចព្រមគ្នាក្នុងឋានៈជាអង្គការវិមជ្ឈការរបស់រដ្ឋាភិបាលផង ជារដ្ឋអំណាចគ្រប់គ្រងការងាររដ្ឋបាលថ្នាក់ក្រោមឱវាទផង និងជាអង្គការមួយអនុវត្តសេចក្តីសម្រេចព្រមទាំងសារាចររបស់អង្គការរដ្ឋថ្នាក់លើផង ។

ជំពូកទី៨ និយាយអំពីសាលាជម្រះក្តីនិងអយ្យការ (មាត្រា៧៩ដល់៨៦) ។ មានតុលាការ២ប្រភេទគឺ តុលាការប្រជាជននិងតុលាការយោធា ។ ក្រុមប្រឹក្សារដ្ឋអាចបង្កើតតុលាការពិសេស ។ ការជំនុំជម្រះត្រូវបានធ្វើឡើងដោយចៅក្រមម្នាក់និងទីប្រឹក្សាប្រជាជន ។ ការជំនុំជម្រះត្រូវធ្វើជាសាធារណៈ ។ ពលរដ្ឋដែលជាជនជាតិភាគតិច អាចប្រើភាសានិងអក្សររបស់ខ្លួនបាន ។ ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងមេធាវីម្នាក់ឲ្យជួយការពារ ។

ការប្រព្រឹត្តិទៅនៃប្រព័ន្ធយុត្តិធម៌ គឺជាចំណុចខ្សោយមួយក្នុងចំណោមចំណុចខ្សោយជាច្រើនរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ឯករាជ្យភាពរបស់វា បើប្រៀបធៀបនឹងអង្គការនីតិប្រតិបត្តិ ហើយជាពិសេស បើប្រៀបធៀបនឹងបក្ស គឺគ្មានសោះ ។ កម្រិតនៃការធ្វើម្ចាស់លើច្បាប់គឺខ្សោយមែនទែន ។ គេគួរតែពិនិត្យមើលថា ការសម្រេចបង្កើតមហាវិទ្យាល័យច្បាប់ឡើងវិញ ដែលមានលក្ខណៈនយោបាយខ្ពស់បំផុត មិនដែលត្រូវបានយល់ព្រមឡើយ ក្នុងរយៈពេលនៃអត្ថិភាពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

ជំពូកទី៩ និយាយអំពីសញ្ញាជាតិ ទង់ជាតិ ភ្លេងជាតិ បុណ្យជាតិ និងរដ្ឋធានី (មាត្រា៨៧ដល់៩០) ។ យើងគ្រាន់តែប្រាប់ឲ្យដឹងថា ទង់ជាតិគឺជាទង់របស់ចលនាខ្មែរឥស្សរៈ ផ្ទៃពណ៌ក្រហមចំកណ្តាល មានប្រាសាទអង្គរវត្តកំពូលប្រាំពណ៌លឿង ។ ថ្ងៃបុណ្យជាតិ ៧មករា គឺជាថ្ងៃនៃការដណ្តើមបានទីក្រុងភ្នំពេញ និងការដួលរលំនៃរបប ប៉ុល ពត ។

ជំពូកទី១០ (មាត្រាទី៩១ ដល់៩៣) និយាយពីអានុភាពនៃរដ្ឋធម្មនុញ្ញទៅលើច្បាប់ផ្សេងៗទៀតទាំងអស់ និងកំណត់នូវយន្តការនៃការកែប្រែរដ្ឋធម្មនុញ្ញ ។

ពួកអ្នកដៀលបន្ទាប់សាធារណរដ្ឋប្រជាមានិតកម្ពុជាមិនភ្លេចសង្កត់បញ្ជាក់ពីភាពដូចគ្នារវាងរដ្ឋធម្មនុញ្ញនេះ និងរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមឡើយ ។ ដោយដកឃ្លាឆ្ងាយពីពួកអ្នកទាំងឡាយដែលចូលចិត្តបន្តជម្លោះនយោបាយរបស់ពួកគេតាមរយៈការបញ្ចូលកម្ពុជាជាអ្នកកណ្តាល ការពិនិត្យមើលច្បាប់និងនីតិវិធីដ៏ហ្មត់ចត់មួយដែលនាំមុខការប្រកាន់យករបស់ខ្លួន អាចបញ្ចេញឲ្យឃើញការវិភាគដូចតទៅៈ

១) ទោះបីជាវាក្យស័ព្ទនៃរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រាប់តាមតិចតួចជាងសព្វដង នូវភាសាមិនត្រឹមត្រូវដោយឡែកសម្រាប់ប្រភេទនៃរដ្ឋធម្មនុញ្ញនេះក៏ដោយ ក៏គំរូនៃអំណាចគឺជាគំរូនៃរបៀបគ្រប់គ្រងកុម្មុយនិស្តដូចធ្លាប់មានមកហើយ ដែលត្រូវបានស្គាល់យ៉ាងច្បាស់ថា "ប្រជាធិបតេយ្យប្រជាមានិត" ។ ដូច្នេះ គ្មានការងឿងឆ្ងល់អ្វីឡើយក្នុងការបង្កើតក្រុមប្រឹក្សារដ្ឋមួយ គឺស្ថាប័នដែលបំពេញព្រមគ្នានូវមុខងារផ្សេងៗដែលត្រូវបានទទួលសិទ្ធិក្នុងប្រព័ន្ធគ្រប់គ្រងតាមលទ្ធិប្រជាធិបតេយ្យ ជាប្រមុខរដ្ឋផង ជាអង្គការនីតិបញ្ញត្តិផង និងជាអង្គការនីតិប្រតិបត្តិផង ។

២) កិច្ចការតាក់តែងរដ្ឋធម្មនុញ្ញនិងនីតិក្រមនៃការសុំយោបល់ គឺមានរយៈពេល២ឆ្នាំ និងបង្កឲ្យមានការពិភាក្សាពិតប្រាកដមួយ នេះបើតាមមតិរបស់ពួកអ្នកសង្កេតការណ៍ដែលជំទើតហួសបន្តិចចំពោះសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រដ្ឋសភាដែលជ្រើសតាំងនៅថ្ងៃទី១ ខែឧសភា បានជជែកពិភាក្សារដ្ឋធម្មនុញ្ញក្នុងរយៈពេល៣ថ្ងៃ និងបំពេញវិសោធនកម្មជាច្រើន

ដែលគ្មានទម្រង់ត្រឹមត្រូវឡើយ ។

៣) ការពិនិត្យមើលដែលធ្វើឡើងជាក្បួន នូវលក្ខណៈផ្សេងៗគ្នានៃសេចក្តីព្រាង ការកែប្រែដែលបំពេញជាបន្តបន្ទាប់ ការប្រៀបធៀបរវាងរដ្ឋធម្មនុញ្ញវៀតណាម ដែលមាន១៤៧មាត្រា និងរដ្ឋធម្មនុញ្ញកម្ពុជាដែលមាន៩៣មាត្រា បានបញ្ចេញឲ្យឃើញភាពប្រាកដក្នុងចិត្តថា របបបានប្រើប្រែងអះអាងចរិតលក្ខណៈជាកម្ពុជារបស់ខ្លួនប្រកបដោយជោគជ័យ ទោះបីជានៅទីតំនិតទន់ខ្សោយ និងពឹងផ្អែកយ៉ាងខ្លាំងទៅលើផ្នែកការទូត យោធានិងសេដ្ឋកិច្ចក៏ដោយ ។

ថ្វីបើមានភាពតិចតួចស្តួចស្តើងរបស់ខ្លួនក៏ដោយ ក៏រដ្ឋធម្មនុញ្ញនេះបានសម្តែងឲ្យឃើញពីមហិច្ឆតាដ៏សម្បើមមួយបន្ទាប់ពីការដួលរំលំរបប ប៉ុល ពត ២ឆ្នាំៈ បង្កើតរដ្ឋមួយ សង្គមដែលមានរបនាសម្ព័ន្ធមួយ ជីវភាពឯកជនមួយ ឡើងវិញដែរ ។

## រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩

ចាប់តាំងពីឆ្នាំ១៩៨៦ គឺជាការជាក់ច្បាស់ណាស់ ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនដែលត្រូវបានទទួលស្គាល់នៅអង្គការសហប្រជាជាតិ ហើយក៏មិនដែលត្រូវទទួលស្គាល់ដោយប្រទេសចិន ដោយសហរដ្ឋអាមេរិក និងដោយបណ្តាសម្ព័ន្ធមិត្តរបស់អាមេរិកដែរ ។ វាជាការជាក់ស្តែងដែរ ដែលថាមានតែដំណោះស្រាយដោយការចរចាមួយប៉ុណ្ណោះ ដែលនឹងបញ្ចប់ភាពឯកោតាំងពីឆ្នាំ១៩៧៩មក របស់ប្រទេសនេះ ។ នៅទីបំផុតប្រព័ន្ធនយោបាយ ដែលរៀបចំឲ្យមានជាលើកដំបូងកាលពី៥ឆ្នាំមុន ការផ្លាស់ប្តូរបានកើតមានឡើង ។ ការផ្លាស់ប្តូរសំខាន់បំផុត គឺការឈានឡើងទៅរកភាពខ្លាំងនៃស្ថាប័នមួយដែលក្នុងរបបកុម្មុយនិស្តដូចធ្លាប់មានពីមុនៗមក គឺជាអំណាចប្រតិបត្តិមួយក៏ដូចអំណាចសម្រេចមួយគឺ រដ្ឋាភិបាល ។ ក្រោមការជំរុញរបស់លោក ហ៊ុន សែន ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋាភិបាលបានក្លាយទៅជាចលករពិតប្រាកដរបស់ស្ថាប័នគ្រប់គ្រងដឹកនាំប្រទេសដែលត្រូតត្រាយ៉ាងតឹងរ៉ឹងថែមទៀត ដោយការិយាល័យនយោបាយរបស់បក្ស ។ ប្រទេសមួយដែលទើបចេញពីភាពគ្មានអ្វីទាំងអស់ដោយសន្សឹមៗ ហើយដែលប្រជាពលរដ្ឋនៃប្រទេសនោះនៅមិនទាន់បាត់ភ័យខ្លាចនៅឡើយ បានបណ្តោយឲ្យជ្រាបចូលនូវបំណងប្រាថ្នាទៅរកការផ្លាស់ប្តូរមួយចំនួន ។

មូលហេតុទាំងអស់នេះហើយ គឺជាដើមហេតុនៃការកែប្រែផ្សេងៗដែលផ្តល់ដល់រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ ។ ថ្ងៃទី២៩ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ នៅក្នុងឱកាសនៃសម័យប្រជុំពិសេសមួយ រដ្ឋសភាជាតិបានអនុម័តវិសោធនកម្មមាត្រាច្បាប់រដ្ឋធម្មនុញ្ញមួយ ជាវិសោធនកម្មដែលរៀបចំដោយគណៈកម្មាធិការពិសេសមួយសម្រាប់ការងារនេះ ដោយមានការចូលរួម ឬបញ្ចូលឥស្សរជនជាច្រើនដែលកាលពីដើមធ្លាប់បម្រើចលនាសង្គមរាស្ត្រនិយម ឬសាធារណរដ្ឋខ្មែរ រួមទាំងពួកអ្នកជំនាញការបស្ចិមប្រទេសផង ។ តើអាចនិយាយអំពីរដ្ឋធម្មនុញ្ញថ្មីនេះទេ? ។ យើងអាចត្រឹមតែនិយាយពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ ដោយប្រៀបធៀបនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ប៉ុណ្ណោះ ។ ក្នុងករណីរដ្ឋធម្មនុញ្ញទាំងពីរ អ្នកខ្លះបានសម្តែងឲ្យឃើញពីការយកចិត្តទុកដាក់អំពីភាពត្រឹមត្រូវនិងភាពបរិសុទ្ធនៃភាសាដែលប្រើ ជាងអ្នកឯទៀតៗនឹងសង្កត់បញ្ជាក់ពីរបបគ្រប់គ្រង (តាមរដ្ឋធម្មនុញ្ញ) ដោយសម្គាល់ថា រដ្ឋធម្មនុញ្ញខាងដើមបានធ្វើវិសោធនកម្មតែមួយចំនួនប៉ុណ្ណោះ ។ ដោយជ្រើសរើសរដ្ឋធម្មនុញ្ញទីពីរ យើងនឹងចាត់ចែងតាមរបៀបដ៏ជាក់លាក់មួយសម្រាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ដូចដែលយើងធ្លាប់បានធ្វើសម្រាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ដែរ ។

រដ្ឋធម្មនុញ្ញថ្មីក៏ដូចរដ្ឋធម្មនុញ្ញចាស់ រួមមានដោយដាក់លាក់៩៣មាត្រា (មាត្រា៨៣និង៨៤ត្រូវលុបចោល) ចែកជា១០ជំពូក ។

ការកែប្រែមាត្រាផ្សេងៗដែលផ្តល់ឲ្យរដ្ឋធម្មនុញ្ញមានពីរបែបគឺ ការផ្តោតទៅលើនិមិត្តរូបទាំងឡាយរបស់រដ្ឋ និងការផ្តោតទៅលើលក្ខណៈឬការប្រព្រឹត្តិទៅនៃរបប ។

ជាដំបូង ឈ្មោះរបស់ប្រទេសនិងទង់ជាតិត្រូវបានកែប្រែ ។ អំណឹះតទៅ ប្រទេសកម្ពុជាមាននាមជាផ្លូវការថា "រដ្ឋកម្ពុជា" (មាត្រា១) ហើយទង់ជាតិមានពណ៌ពីរឡើងវិញ ដូចទង់ជាតិមុនឆ្នាំ១៩៧៥ដែរ គឺពណ៌ខៀវនិងពណ៌ក្រហម ។ ប៉ុន្តែពណ៌សជាពណ៌តំណាងរាជាធិបតេយ្យ ពុំត្រូវបានប្រើប្រាស់សម្រាប់តំណាងប្រាសាទអង្គរវត្តកំពូលប្រាំឡើយ ។ ពណ៌លឿងគឺជាពណ៌ដែលចូលចិត្តប្រើជាងគេ ព្រោះតាមរដ្ឋធម្មនុញ្ញអះអាងថា ជាពណ៌

"តំណាងអារម្មណ៍ដ៏យូរលង់របស់ប្រជាជនកម្ពុជានិងសាសនា" (មាត្រា៨៨) ។

មាត្រា១ស្ទួន បានបញ្ចូលសញ្ញាណថា រដ្ឋកម្ពុជាជារដ្ឋមួយមិនអាចបំបែកបាន ហើយស្ថាប័នរដ្ឋនានាត្រូវចាត់តាំងនិងប្រព្រឹត្តឲ្យសមស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់នៃរដ្ឋកម្ពុជា ។

កំណែទម្រង់ដ៏សំខាន់លើកដំបូងគឺ ការលើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋឡើងវិញ (មាត្រា៦) ។ មិនត្រូវឲ្យមានការពិភាក្សាណាមួយតាមបែបអ៊ីវ៉ែបចំពោះលក្ខន្តិកៈនេះទេ ។ វាពុំបណ្តាលឲ្យមានការច្រឡំបល់ណាមួយរវាងសាសនានិងរដ្ឋ ហើយក៏ពុំអនុញ្ញាតឲ្យមានការបង្ខិតបង្ខំណាមួយដែរ ។ នេះជាការទទួលស្គាល់មួយអំពីនាទីដ៏សំខាន់នៃចរន្តគំនិតក្នុងសង្គមនិងមុខងារសង្គមដ៏ច្រើនសន្ធឹកដែលត្រូវបំពេញ ។ ការទទួលស្គាល់នេះជាមូលដ្ឋាននៃការផ្លាស់ប្តូរដ៏ធំមួយដោយខ្លួនឯង ។ រហូតមកដល់ពេលនេះព្រះពុទ្ធសាសនា គឺត្រូវបានយោគយល់ ។ លក្ខខណ្ឌដ៏តឹងរ៉ឹងត្រូវបានបំពេញក្នុងរដ្ឋធម្មនុញ្ញសម្រាប់បួសជាព្រះសង្ឃ ។ វត្តអារាមមួយចំនួនធំ ភាគច្រើនបានត្រូវវិផុតបំផ្លាញដោយពួកខ្មែរក្រហម ក៏នៅតែគ្មាននរណាយកចិត្តទុកដាក់ថែទាំដែរ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ តាមរយៈការផ្លាស់ប្តូរតែមួយនេះ នឹងបើកទ្វារឆ្ពោះទៅរកការធ្វើឲ្យប្រែប្រួលដ៏សម្បើម ក្នុងសកម្មភាពរបស់សង្គម ដូចជាការកសាងវត្តអារាមនានាឡើងវិញ ដែលប្រកបទៅដោយភាពស្វាហាប់មួយនឹងមានជាប់រហូត ចំនួនព្រះសង្ឃនឹងកើនឡើង ។ ព្រះសង្ឃទាំងឡាយនឹងរកឃើញជាលំដាប់នូវឋានៈនិងតួនាទីរបស់ព្រះអង្គក្នុងសង្គម ។ គេនិយាយថា កាលដែលព្រះសង្ឃធ្វើសកម្មភាពខ្លាំងក្លានៅឆ្នាំ១៩៩៣ ដើម្បីផ្តើមចលនាសន្តិភាព ទាមទាររដ្ឋធម្មនុញ្ញមួយដែលប្រកបដោយលទ្ធិប្រជាធិបតេយ្យ សង្កត់ទៅលើសិទ្ធិជាមូលដ្ឋានរបស់បុគ្គលម្នាក់ៗ គឺដោយសារការកែរដ្ឋធម្មនុញ្ញឡើងវិញ ដែលផ្តើមប្រើនៅឆ្នាំ១៩៨៩នោះឯង ។

កំណែទម្រង់ដ៏សំខាន់ទី២ គឺការទទួលស្គាល់កម្មសិទ្ធិឯកជនក្នុងសេដ្ឋកិច្ចជាតិ (មាត្រា១២) ។ ផលវិបាកផ្សេងៗនៃការបញ្ចូលដ៏គំហុកនេះ ដោយគ្មានការរៀបចំ គ្មានការដាក់ឲ្យមានក្របខ័ណ្ឌជាមួយវត្តមានដែលឡើងស្រឹតៗនៃពួកអ្នករកស៊ីបរទេសគ្រប់ប្រភេទទាំងអស់ នឹងបង្ខិតបង្ខោចដល់សេដ្ឋកិច្ចដ៏ផុយស្រួយរបស់ប្រទេស ។ ប្រទេសជាតិនឹងក្លាយទៅជាគំរូសេដ្ឋកិច្ចសេរីនិយមមួយដែលមានលក្ខណៈពុះពោរបំផុត ។

កំណែទម្រង់ទី៣ គឺការទទួលស្គាល់និងការការពារកម្មសិទ្ធិឯកជន (មាត្រា១៥,១៧,១៨និង១៨ស្ទួន) ជាមួយការបោះបង់ចោលក្រុមសាមគ្គី ហើយខ្ញុំសន្និដ្ឋានថា គេប្រហែលជាសោកស្តាយ ។ ការរលាយបាត់ក្រុមសាមគ្គីបានធ្វើឲ្យមានភាពងាយស្រួលដល់ការត្រឡប់មកវិញនៃជនដ៏គួរឲ្យព្រឺខ្លាចម្នាក់ទៅតាមជនបទនៃប្រទេស គឺអ្នកយកការប្រាក់ហួសកំណត់ ។

នៅជំពូកស្តីអំពីសិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋ (មាត្រា៣៥) ដែលនិយាយទាក់ទងនឹងការការពារ ការរំលោភបំពានលើរូបរាង កាយពលរដ្ឋ បានត្រូវបន្ថែមសេចក្តីមួយចំនួនធំដោយការហាមឃាត់មិនឲ្យមានការចាប់ខ្លួន និងការឃុំឃាំងស្រេចតែនឹងចិត្ត ព្រមទាំងការហាមមិនឲ្យធ្វើបាបលើរាងកាយ ដោយការបញ្ចូលឃ្លាថា បើបទល្មើសគ្រាន់តែមានវិមតិសង្ស័យ ជនជាប់ចោទត្រូវបានឲ្យរួចខ្លួននិងការលុបបំបាត់ទោសប្រហារជីវិត ។ ប៉ុន្តែការកែប្រែថ្មីនេះនឹងមិនបង្ហាញឲ្យឃើញក្នុងហេតុការណ៍ផ្សេងៗឡើយ ។

មាត្រា៤៩(ស្ទួន១) និងមាត្រា៤៩(ស្ទួន២) និយាយអំពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ដែលកិច្ចការផ្សេងៗមានលក្ខណៈដូចគ្នានឹងកិច្ចការដែលធ្វើតាមទម្លាប់នៅការិយាល័យក្នុងរបបអាស្រ័យរដ្ឋសភាពីមុនមកដែរ ។ មាត្រា៥៨ស្ទួន និយាយអំពីការផ្តល់ប្រាក់បំណាច់មួយឲ្យសមាជិករដ្ឋសភាគ្រប់រូប ។

ការកែប្រែមាត្រា៤៨ (អំណាចរបស់រដ្ឋសភាជាតិ) និងមាត្រា៦០ (អំណាចរបស់ក្រុមប្រឹក្សារដ្ឋ) បានអនុញ្ញាតឲ្យបង្កើតតុលាការកំពូលមួយ និងមហាអយ្យការអមតុលាការកំពូលនេះ ។ ប៉ុន្តែគ្មានការបញ្ជាក់ច្បាស់លាស់ណាមួយអំពីអំណាចដែលផ្តល់ឲ្យស្ថាប័នថ្មីទាំងពីរនេះទេ ដោយត្រូវរង់ចាំការបង្កើតច្បាប់មួយបន្ថែមទៀត ។ ប្រធានតុលាការកំពូលនិងអគ្គរដ្ឋអាជ្ញាអមតុលាការកំពូល ត្រូវបានជ្រើសតាំងដោយរដ្ឋសភាជាតិ ។ រដ្ឋសភាជាតិជាអ្នកត្រួតពិនិត្យសកម្មភាពរបស់តុលាការកំពូលនិងមហា

អយ្យការអមតុលាការកំពូល (មាត្រា៨៨និង៩៧) ដែលនេះគឺជាការដណ្ដើមឯករាជ្យទាំងស្រុងពីស្ថាប័នតុលាការ ។ ចំណែកក្រុមប្រឹក្សារដ្ឋបានកត់សម្គាល់ថា អំណាចនីតិបញ្ញត្តិរបស់ខ្លួនត្រូវកាត់បន្ថយ ជាពិសេសដោយសារការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិ(មាត្រា៦០) ។

នៅទីបំផុត រចនាសម្ព័ន្ធថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋានបានទទួលស្គាល់នូវការផ្លាស់ប្ដូរទម្រង់មួយដែរៈ គណៈកម្មាធិការទាំងអស់លែងត្រូវឲ្យឈ្មោះថា "បដិវត្តន៍" ទៀតហើយ ។ ការកែប្រែមួយទៀតចំពោះច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ បានឆ្លុះបញ្ចាំងឲ្យឃើញការពង្រីកទីក្រុងធំៗជាថ្មី ពោលគឺក្រុងត្រូវបែងចែកជាខណ្ឌ សង្កាត់ ស្រុក និងជាយក្រុង ។

អ្នកខ្លះបាននិយាយពីកំណែទម្រង់ឆ្នាំ១៩៨៩ ថាហាក់ដូចជាគេធ្វើការបោសសម្អាតផ្នែកខាងក្រៅមួយ ដែលគ្រាន់តែជាការដាត់ម្សៅលាបក្រែមប៉ុណ្ណោះ ។ អ្នកខ្លះទៀតចង់ឃើញការដាក់ឲ្យប្រើធម្មនុញ្ញនេះឲ្យសមស្របទៅនឹងការពិតនិងបំណងប្រាថ្នាថ្មីៗ ។ អ្នកខ្លះទៀតយល់ថា រដ្ឋធម្មនុញ្ញនេះគ្រាន់តែជាកាយវិការនយោបាយមួយសំដៅបញ្ឆោតបណ្ដាប្រទេសលោកខាងលិចប៉ុណ្ណោះ ។ ខ្ញុំជឿថាវាមានទាំងអស់ក្នុងសេចក្ដីស្នើការជាហូរហែនៅខែមេសា ឆ្នាំ១៩៨៩ ។ ទោះជាយ៉ាងណាក៏ដោយខ្ញុំបានសង្កេតឃើញថា បេសកកម្មរបស់អង្គការសហប្រជាជាតិដែលទទួលបន្ទុកសិក្សាប្រព័ន្ធនយោបាយ-រដ្ឋបាលនៃរដ្ឋកម្ពុជាបានកត់ត្រានៅក្នុងរបាយការណ៍របស់ខ្លួនថា "វិសោធនកម្មដែលទើបមានថ្មីៗបានធ្វើឲ្យរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១មានការកែប្រែជាដុំកំភួន" ។

## រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

កិច្ចព្រមព្រៀងដើម្បីស្វែងរកដំណោះស្រាយរួមមួយនៃជម្លោះនៅប្រទេសកម្ពុជា ដែលចុះហត្ថលេខានៅទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានបញ្ជាក់នៅក្នុងមាត្រា១២ របស់ខ្លួនថា "ប្រជាជនកម្ពុជាត្រូវមានសិទ្ធិសម្រេចអនាគតនយោបាយរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ដើម្បីជ្រើសរើសសភាធម្មនុញ្ញមួយដែលត្រូវព្រាងនិងអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាមួយថ្មីស្របទៅតាមមាត្រា២៣ រួចនឹងប្រែក្លាយទៅជាសភានីតិបញ្ញត្តិដែលនឹងត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាថ្មី ។ មាត្រា២៣ បញ្ជាក់ថា បណ្ដាគោលការណ៍ជាមូលដ្ឋានដែលបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាថ្មីនោះ គឺមានចែងនៅក្នុងឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀង ។

បណ្ដាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជាដែលចែងនៅក្នុងឧបសម្ព័ន្ធទី៥ មានដូចតទៅ÷

១) រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេស ។ ការកែប្រែរដ្ឋធម្មនុញ្ញនេះអាចធ្វើបានលុះត្រាតែមានរបៀបរបបចាត់តាំងមួយទាក់ទងដល់ការយល់ព្រមពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្ដង ។

២) ប្រវត្តិសាស្ត្រថ្មីៗប្រកបដោយសោកនាដកម្មនៅកម្ពុជាទាមទារឲ្យមានវិធានការពិសេសដើម្បីធានាការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមានសេចក្ដីថ្លែងការណ៍មួយអំពីសិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅសន្តិសុខ សេរីភាពរបស់បុគ្គល សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នានិងការបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវនិងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឲ្យមានការដកហូតកម្មសិទ្ធិដោយវិធីផ្ដាច់ការ ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជំងឺចិត្តដ៏ត្រឹមត្រូវនិងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿសាសនា ឬភេទឡើយ ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល ។ សេចក្ដីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្ដីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវរំលោភបំពាន មានសិទ្ធិប្ដឹងទៅតុលាការដើម្បីកាត់សេចក្ដីនិងធ្វើឲ្យគេគោរពសិទ្ធិទាំងអស់នេះ ។

៣) រដ្ឋធម្មនុញ្ញត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជាជារដ្ឋអធិបតេយ្យ ឯករាជ្យ និងអព្យាក្រឹតមួយ និងអំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា ។

៤) រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរីដោយឈរលើមូលដ្ឋានពហុបក្ស ។ រដ្ឋ

ធម្មនុញ្ញត្រូវកំណត់ឲ្យមានការបោះឆ្នោតដោយត្រឹមត្រូវនិងតាមពេលវេលា ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសម្រាប់បោះឆ្នោតនិងឈរឈ្មោះឲ្យគេបោះឆ្នោតតាមរបៀបបោះឆ្នោតដោយសកលនិងស្មើភាព ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឲ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឲ្យទម្រង់បែបបទនៃការបោះឆ្នោតត្រូវផ្តល់ឱកាសគ្រប់គ្រាន់និងសមរម្យ ដើម្បីរៀបចំនិងចូលរួមក្នុងដំណើរការបោះឆ្នោត ។

៥) ត្រូវបង្កើតអង្គការតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់ឲ្យអនុវត្តនូវបណ្តាសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។

៦) រដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសំឡេងភាគច្រើន ពីរភាគបីនៃសមាជិករបស់សភាធម្មនុញ្ញ ។

ការរំឭកអំពីគោលការណ៍ទាំងនេះ គឺមានប្រយោជន៍ដើម្បីពិនិត្យបញ្ជាក់មិនត្រឹមតែថាវាត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ (តាមការពិតវាត្រូវបានបញ្ចូលមែន) ប៉ុន្តែដើម្បីវាយតម្លៃថា វាត្រូវបានបញ្ចូលដោយរបៀបវះកាត់ ហើយដែលត្រូវបានអនុវត្តសព្វថ្ងៃនេះ ។

មុននឹងចាត់ចែងធ្វើច្បាប់នេះ យើងសូមរំឭកថា សភាធម្មនុញ្ញដែលកើតចេញពីការបោះឆ្នោតដែលរៀបចំឲ្យមានដំណើរឡើងនៅចន្លោះថ្ងៃទី២៣និង២៨ ខែឧសភា ត្រូវបានដាក់ឲ្យចូលកាន់មុខតំណែងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ។ គណៈកម្មាធិការមួយដែលមានសមាជិក២១រូប (គណបក្សហ៊្វុនស៊ិនប៉ិច៦រូប គណបក្សប្រជាជន៥រូប គណបក្សប្រជាធិបតេយ្យ សេរីនិយមព្រះពុទ្ធសាសនា១រូប) អ្នកជំនាញការកម្ពុជាជាច្រើន រូបបានរួបរួមក្នុងកិច្ចការនេះដែរ បានស្ថិតនៅរហូតដល់ថ្ងៃទី១៧ ខែសីហា ជាកាលបរិច្ឆេទដែលគណៈកម្មាធិការបានសម្រេចអំពីច្បាប់រដ្ឋធម្មនុញ្ញមួយ ។ ប៉ុន្តែហាក់ដូចជាថា គណៈកម្មាធិការពុំចង់ ឬពុំអាចសម្រេចចិត្តស្តីអំពីជំពូកទាក់ទងទៅនឹងប្រមុខរដ្ឋទេ ហើយថាត្រូវទុកចំហសម្រាប់ការជ្រើសរើសរវាងសិទ្ធិជ្រើសរើសជាច្រើនៈ សាធារណរដ្ឋជាមួយនឹងប្រព័ន្ធប្រធានាធិបតីនិយមមួយ ឬប្រព័ន្ធសភានិយម ឬរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ឬការបង្កើតឡើងវិញនូវរបបដែលមានមុនថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលត្រូវគ្រោងគិតពីផ្នែកគតិយុត្តិកាន់តែច្រើនថែមទៀត ហើយជាពិសេសដែលគ្រោងគិតដោយលោក សឹង សាន ជាប្រធានធម្មនុញ្ញ ដែលនៅថ្ងៃទី១៤ ខែមិថុនា សភានេះបានអនុម័តជាឯកច្ឆ័ន្ទនូវបញ្ញត្តិមួយលុបចោលការសម្រេច (ទម្លាក់សម្តេចសីហនុ) នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ការបញ្ចេញមតិ (សម្រេចពីបញ្ហានេះ) មិនត្រឹមតែប៉ះពាល់ដល់ភាពគ្មានតម្លៃនៃទង្វើទាំងអស់របស់បណ្តារបបបន្ទាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងបង្កើតឲ្យមាននិរន្តរភាពមួយត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។

៨

គណៈប្រតិភូមួយនៃគណៈកម្មាធិការតាក់តែងរដ្ឋធម្មនុញ្ញបានធ្វើដំណើរជាបន្តបន្ទាប់ទៅកាន់ទីក្រុងព្យុងយ៉ាង ជាទីកន្លែងដែលសម្តេចព្រះ នរោត្តម សីហនុ គង់ប្រថាប់នៅទីនោះ ។ ការចរចាមួយបានបញ្ចប់ដោយការជ្រើសរើសរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលវាច្បាស់លាស់ណាស់ថា ជាការជ្រើសរើសអនាគតព្រះមហាក្សត្រ ។ គេនៅចាំនៅឡើយអំពីសេចក្តីសង្ឃឹមដែលថ្លែងជាមួយនឹងបំណងដ៏ខ្ជាប់ខ្ជួនគួរចាប់អារម្មណ៍មួយ ដែលសម្តេចព្រះ នរោត្តម សីហនុ ចង់ទតឃើញការរៀបចំជាប្រព័ន្ធគ្រប់គ្រងមួយ ដោយយកគំនិតតាមរដ្ឋធម្មនុញ្ញសាធារណរដ្ឋទី៥របស់បារាំងឲ្យបានទូលំទូលាយ ។ គេមិនសូវភ័ន្តច្រឡំប៉ុន្មានទេចំពោះការអះអាងថា របបបច្ចុប្បន្នដែលព្រះមហាក្សត្រគោរពច្បាប់ផ្សេងៗដោយឥតល្អៀង ពុំមែនជារបបដែលព្រះអង្គសព្វព្រះទ័យចង់បាននៅឆ្នាំ១៩៩៣ សម្រាប់ប្រទេសកម្ពុជាឡើយ ។

លទ្ធផលនៃការសម្របសម្រួលនៅក្រុងព្យុងយ៉ាង ត្រូវដាក់ឲ្យសភាធម្មនុញ្ញពិនិត្យនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលបានពិភាក្សាអំពីច្បាប់រដ្ឋធម្មនុញ្ញក្នុងសម័យប្រជុំជាសាធារណៈ ហើយក៏បានសម្រេចធ្វើវិសោធនកម្មលើមាត្រាមួយចំនួន ។ រដ្ឋធម្មនុញ្ញបានត្រូវអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយ១១៣សំឡេងយល់ព្រម ៥សំឡេងជំទាស់ និង២សំឡេងអនុបវាទ ។ រដ្ឋធម្មនុញ្ញត្រូវបានប្រកាសឲ្យប្រើដោយប្រមុខរដ្ឋនៅថ្ងៃទី២៤ ខែកញ្ញា ។ នាថ្ងៃដដែលនោះ សម្តេចព្រះ នរោត្តម សីហនុ ត្រូវបានក្រុមប្រឹក្សារាជបល្ល័ង្កជ្រើសរើស និងសុំឲ្យព្រះអង្គធ្វើសច្ចាប្រណិធានដើម្បីឲ្យក្លាយជាព្រះមហាក្សត្រមួយអង្គអាស្រ័យរដ្ឋធម្មនុញ្ញ ។

រដ្ឋធម្មនុញ្ញរួមមានបុព្វកថាមួយនិង១៣៩មាត្រា ចែកជា ១៤ជំពូក ។ នេះជារដ្ឋធម្មនុញ្ញដែលវែងជាងគេ ។ រដ្ឋធម្មនុញ្ញនេះបានក្លាយទៅជាកម្មវត្ថុនៃការសិក្សាពិនិត្យអំពីលទ្ធិគ្រប់គ្រងតាំងពីពេលនោះមកម៉្លេះ ដែលធ្វើឲ្យលើសតម្រូវការនាំឲ្យស្គាល់មួយ ។ ផ្ទុយទៅវិញ ដូចបានបង្ហាញរួចមកហើយថា វាអាចមានសារសំខាន់ដែលត្រូវពិនិត្យរបៀបអនុវត្តបញ្ញត្តិផ្សេងៗ ដែលបញ្ចូលក្នុងច្បាប់រដ្ឋធម្មនុញ្ញបីឆ្នាំបន្ទាប់ពីចូលជាធរមានយ៉ាងណាខ្លះ ហើយជាពិសេស ពិនិត្យមើលផលវិបាកទាំងឡាយទៅលើប្រព័ន្ធនយោបាយមួយដែលចាប់ផ្តើមកែទម្រង់ដោយល្បឿនយឺតៗ អំណាចជ្រើសរើសខ្លះៗ (រួមទាំងការជ្រើសរើសដែលគ្មានបញ្ចូលក្នុងច្បាប់រដ្ឋធម្មនុញ្ញផង) និងការថ្លែងដោយសម្តីជាក់លាក់មួយចំនួនតូចរបស់សមាជិកសភាធម្មនុញ្ញ ។

រដ្ឋធម្មនុញ្ញគ្មាននិយាយពីប្រព័ន្ធបោះឆ្នោតដែលនឹងត្រូវដាក់ប្រើតាមច្បាប់ដែលរៀបចំមុនដោយមាត្រា៧៦ឡើយ ។ ប៉ុន្តែគេដឹងពីយោបល់ផ្សេងៗដែលសម្រេចក្នុងការជ្រើសរើសប្រព័ន្ធបោះឆ្នោតមួយ(ប្រព័ន្ធបោះឆ្នោតផ្អែកដែលលើមតិភាគច្រើន ប្រព័ន្ធបោះឆ្នោតជុំទី១ឬជុំទី២ និងប្រព័ន្ធសមាមាត្រ) តាមរបៀបគ្រប់គ្រងនយោបាយ ។ រយៈពេល២ឆ្នាំបន្ទាប់ពីការបោះឆ្នោតដែលត្រូវពិនិត្យមើលការបន្តសភាដែលបានជ្រើសតាំងនៅឆ្នាំ១៩៩៣ គឺច្បាប់បោះឆ្នោតនៅតែពុំទាន់បានអនុម័តដោយសារមួយផ្នែកធំមកពីការលំបាកវះកាត់ ការជ្រើសរើសមួយដែលត្រូវពន្យារពេលដោយសមាជិកសភាបញ្ញត្តិច្បាប់ ។

មាត្រា៨៨បានតម្រូវឲ្យមានកូរ៉ុមពីរភាគដប់នៃសមាជិកសភាទាំងមូល ទើបការប្រជុំរបស់រដ្ឋសភាអាចយកជាការបាន ។ ការតម្រូវនេះក្រៅពីឆ្លុះបញ្ចាំងឲ្យឃើញការចាប់បដិសន្ធិរបស់ក្រុមអ្នកតំណាងជាតិ ដែលស្របតិចតួចនឹងបណ្តាគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យតាមរយៈតំណាង វាបានបង្ហាញឲ្យឃើញពីគ្រោះថ្នាក់ធ្ងន់ធ្ងរក្នុងការធ្វើឲ្យស្ថាប័ននេះតាំងដំណើរដូចបានពិនិត្យបញ្ជាក់ឲ្យឃើញយ៉ាងទូលំទូលាយរួចមកហើយ ។ តាមអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិថា រដ្ឋសភាជាតិបានរួមប្រជុំត្រឹមតែពាក់កណ្តាលសម័យកាលដែលគ្រោងទុកជាមុន សម្រាប់សម័យប្រជុំបីខែដែលបានបញ្ចប់នៅថ្ងៃទី២២ ខែកក្កដា ។ គេគោងតែពិនិត្យមើលការប្រព្រឹត្តិរបស់បណ្តាសមាជិកសភានេះនូវមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើននៃភាពទន់ខ្សោយក្នុងការផលិតច្បាប់របស់សភាមួយ ដែលក្នុងរយៈពេលបីឆ្នាំបានអនុម័តច្បាប់តែចំនួន៣០ប៉ុណ្ណោះ ។

ពីមាត្រា១១៧ដល់មាត្រា១២៥ គឺនិយាយអំពីក្រុមប្រឹក្សាធម្មនុញ្ញមួយដែលនៅតែរង់ចាំការអនុម័តច្បាប់ស្តីអំពីការបង្កើតនិងបញ្ជាក់អំពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអង្គការនេះ ដែលបញ្ញត្តិដោយមាត្រា១២៥ ។ កង្វះខាតក្រុមប្រឹក្សាធម្មនុញ្ញ តើវាធ្វើឲ្យលិខិតស្នាមទាំងអស់របស់រដ្ឋាភិបាលបានការដែរឬទេ? ។ ទោះបីជាយ៉ាងណាក៏ដោយ នេះជាយោបល់របស់អតីតនាយករដ្ឋមន្ត្រីនិងជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ គឺឯកឧត្តម ញឹក ជូឡុង ដែលជ្រើសរើសទុកជាមុនដោយព្រះមហាក្សត្រ ដើម្បីធ្វើជាសមាជិកក្នុងក្រុមប្រឹក្សាធម្មនុញ្ញនេះ ។ ម្យ៉ាងទៀត គេអាចកាត់យល់ពីសេចក្តីសម្រេចនេះរបស់ប្រមុខរដ្ឋក្នុងការជ្រើសតាំងពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៣ នូវបុគ្គលបីរូប ដោយសំអាងទៅលើមាត្រា១១៨ សមាជិកបីរូបបានត្រូវតែងតាំងដោយព្រះមហាក្សត្រ ។ នេះជាព្រះរាជកាយវិការមួយបង្ហាញឲ្យឃើញពីព្រះរាជបំណងរបស់ព្រះមហាក្សត្រ ដែលចង់ទតឃើញស្ថាប័ននេះត្រូវបានបង្កើតឡើងដោយឆាប់រហ័សបំផុត ។

អន្តរបញ្ញត្តិត្រង់ជំពូក១៣៨ ដែលនិយាយអំពីការមាននាយករដ្ឋមន្ត្រីពីររូបក្នុងនីតិកាលទី១ គឺសម្បូរដោយពត៌មានអំពីសកម្មភាពនយោបាយរបស់កម្ពុជាសម្រាប់អ្នកសង្កេតការណ៍ ។ ជាបឋម វាបានអះអាងបន្ថែមអំពីការបែងចែកអំណាចរវាងកម្លាំងនយោបាយសំខាន់ពីរ ក្នុងពេលដែលមានការសរសេរច្បាប់រដ្ឋធម្មនុញ្ញ ។ ប្រការនេះសឲ្យឃើញថា សភាដែលផ្តល់រដ្ឋធម្មនុញ្ញត្រូវតែធ្វើសម្បទានចំពោះស្ថានភាពនយោបាយមួយតាមកាលៈទេសៈ ។ លក្ខណៈបណ្តោះអាសន្ននៃអន្តរបញ្ញត្តិនេះគឺជាការបង្ហាញមួយអំពីបំណងដែលមិនចង់ប្រកាន់យកប្រព័ន្ធបោះឆ្នោតដែលតម្រូវឲ្យទទួលដោយកិច្ចព្រមព្រៀងក្រុងប៉ារីសនិងច្បាប់បោះឆ្នោតរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ។ ភាពព្រលំគ្នាដែលចារឹកក្នុងលំដាប់ឋានានុក្រមមួយរវាងនាយករដ្ឋមន្ត្រីពីររូប អាចធ្វើឲ្យជឿថា

គេស្ថិតនៅចំពោះមុខរដ្ឋាភិបាលចម្រុះមួយដែលនៅក្នុងនោះការបែងចែកអំណាចបានធ្វើឡើងលើមូលដ្ឋាននៃលទ្ធផលបោះឆ្នោត ដូចដែលមានប្រើក្នុងបណ្តាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យអាស្រ័យសភាដែរ ។ ពួកអ្នកសង្កេតការណ៍ខ្លះដែលប្រាប់ឲ្យដឹងតិចតួចអំពីប្រព័ន្ធនយោបាយដែលរដ្ឋាភិបាលចម្រុះបំពេញមុខងារបានឆ្ងើងឆ្ងល់ដែលឃើញរដ្ឋមន្ត្រីម្នាក់របស់គណបក្សមួយត្រូវអបអរដោយរដ្ឋលេខាធិការម្នាក់របស់គណបក្សមួយទៀត ទោះបីនេះជាទម្លាប់ធម្មតាក្នុងប្រភេទរដ្ឋាភិបាលនេះក៏ដោយ ។ ផ្ទុយទៅវិញ មនុស្សមួយចំនួនតូចបានសង្កេតឃើញថា ការបែងចែកអំណាចពុំបានធ្វើតាមលទ្ធផលនៃការបោះឆ្នោតទេ ។ រដ្ឋាភិបាលទី១ដែលនៅក្រោមរដ្ឋធម្មនុញ្ញ និងដែលរៀបចំជាដំបូងនៅខែតុលា ឆ្នាំ១៩៩៣ រួមមានសមាជិក៣៨រូប គឺរដ្ឋមន្ត្រី១៨រូប និងរដ្ឋលេខាធិការ១៦រូប ក្នុងនោះមាន១៨រូបខាងគណបក្សប្រជាជនកម្ពុជា ១១រូបខាងគណបក្សហ៊្វុនស៊ិនប៉ិច ៣រូបខាងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា និង៧រូបគ្មានឈ្មោះក្នុងគណបក្សណាទេ ។ គេមិនអាចនិយាយថាការបែងចែកនេះឆ្លុះបញ្ចាំងឲ្យឃើញលទ្ធផលនៃការបោះឆ្នោតឡើយ (កៅអីដែលទទួលបានត្រូវបែងចែកដូចតទៅ÷ គណបក្សហ៊្វុនស៊ិនប៉ិច៥៨ គណបក្សប្រជាជនកម្ពុជា៥១ គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា១០ គណបក្សម៉ូលីណាកា១) ។ ប្រការនេះបានអះអាងបន្ថែមដោយសេចក្តីថ្លែងការណ៍ថ្មីមួយរបស់ព្រះមហាក្សត្រ ដែលតាមរយៈនេះថា ការបោះឆ្នោតឆ្នាំ១៩៩៣ ពុំបានចាត់ចែងបញ្ហានយោបាយនៅកម្ពុជាទេ ហើយរដ្ឋាភិបាលបច្ចុប្បន្នពុំមានផ្អែកលើលទ្ធផលនៃការបោះឆ្នោតឡើយ ប៉ុន្តែគឺផ្អែកលើការព្រមព្រៀងបែងចែកអំណាចរវាងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជនកម្ពុជា ដោយមិនគិតដល់លទ្ធផលនៃការបោះឆ្នោតឡើយ ។

មាត្រា១៣៩ដែលកំណត់គោលបំណងសម្រាប់ធានានិរន្តរភាពរបស់រដ្ឋ និងជៀសវាងភាពចំហផ្នែកគតិយុត្តិ បានធ្វើឲ្យងាយស្រួលដល់ការងាករេមួយ ក្នុងករណីដែលផ្នែកមួយប៉ុន្តែសំខាន់នៃមាត្រានេះពុំត្រូវបានគោរព ។ មាត្រានេះបញ្ជាក់ថា "ច្បាប់និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការការពារដល់ទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គលដែលសមនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ" ។ ផ្អែកលើមូលដ្ឋាននៃមាត្រានេះ ជាឧទាហរណ៍ គេបានប្តឹងនិងផ្តន្ទាទោសពួកកាសែត គេបានរំលោភសិទ្ធិក្នុងការរួមប្រជុំនិងការបង្កើតសមាគម ដោយអាងលើបទបញ្ញត្តិផ្សេងៗ ដែលត្រឹមត្រូវតាមច្បាប់កាលពីមុន ហើយដែលផ្ទុយនឹងស្មារតីសេរីនិយមរបស់រដ្ឋធម្មនុញ្ញយ៉ាងជាក់ស្តែង ។

## កំណត់សម្គាល់ទូទៅចំនួនបីមុននឹងបញ្ចប់

បទបញ្ញត្តិផ្សេងៗនៅជំពូកទី៣ទាក់ទងទៅនឹងសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ (មាត្រា៣១ដល់៥០) មាត្រា៧៦ (និយាយអំពីភាពអាចជ្រើសតាំងបាននៃបណ្តាសមាជិករដ្ឋសភាជាតិ) និងមាត្រា១២៨ (ការចូលរួមសមាជជាតិ) បានតម្រូវសម្រាប់តែ "ប្រជាពលរដ្ឋខ្មែរ"ប៉ុណ្ណោះ ។ ការជ្រើសរើសរូបមន្តនេះដើម្បីសម្គាល់អ្នករស់ក្នុងស្រុក ដោយចាត់ទុកជាសមាជិកពេញសិទ្ធិរបស់សហគមន៍ជាតិ ជាជាងថា "កម្ពុជា" ឬ "ប្រជាពលរដ្ឋ"បានបង្ហាញនូវការរើសអើងមួយចំពោះសមាជិកដទៃៗទៀតនៃប្រជាពលរដ្ឋកម្ពុជាដែលពុំមែនជាសាសន៍ខ្មែរ (ហើយអាចសម្គាល់ឃើញថាខ្លួនត្រូវបញ្ចៀសចេញពីអត្ថប្រយោជន៍?) ដែលត្រូវបានពីសិទ្ធិនិងសេរីភាពសំខាន់ៗ ដែលចារឹកនៅក្នុងរដ្ឋធម្មនុញ្ញៈ ប្រជាជនដើមកំណើតចិនឬថៃ ជនជាតិភាគតិចដែលរស់នៅលើភ្នំ ឬប្រជាជនឥស្លាម ។ ការរើសអើងនេះ (គ្មាននៅក្នុងរដ្ឋធម្មនុញ្ញ២មុន ដែលយកចិត្តទុកដាក់ចំពោះ"ប្រជាពលរដ្ឋកម្ពុជា") បានអនុញ្ញាតឲ្យមានការព្រួយបារម្ភមួយទៀតចំពោះជោគវាសនាដែលបម្រុងទុកចំពោះជនទាំងឡាយដែលត្រូវចាត់ទុកថាជាជនបរទេស ហើយជាពិសេស ប្រជាជនវៀតណាមដែលតាំងពីឆ្នាំ១៩៧០មក បានទទួលរងការបាត់បង់យ៉ាងធ្ងន់ធ្ងរ ដោយសារប្រកាន់ពូជសាសន៍ និងការស្អប់ខ្ពើមជនបរទេសរបស់ប្រជាជនខ្មែរមួយភាគ ។ សមាជិកនៃសភាធម្មនុញ្ញឆ្នាំ១៩៩៣ហាក់ដូចជាមិនដឹងឬធ្វើជាមិនដឹងថា សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ក៏ដូចអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិង

សិទ្ធិនយោបាយ និងអនុសញ្ញាអន្តរជាតិស្តីពីការការពារជនជាតិភាគតិច បានយកចិត្តទុកដាក់ចំពោះជនបរទេសដូចគ្នានឹងប្រជាពលរដ្ឋក្នុងស្រុកដែរ ។ បំណងរបស់សភាធម្មនុញ្ញបានធ្វើឲ្យចុះខ្សោយយ៉ាងខ្លាំង ដល់ភាពគួរឲ្យជឿជាក់នៃការរួបរួមរបស់ប្រទេសកម្ពុជានិងស្ថាប័នអន្តរជាតិទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្សដែលមានបញ្ជាក់នៅជំពូក១ មាត្រា៣១ ដូចគ្នានឹងការយល់ព្រមរបស់ខ្លួនអំពីគោលការណ៍នៃភាពស្មើគ្នាចំពោះមុខច្បាប់ដែរដែលមាននិយាយនៅជំពូក២ មាត្រាដដែលនេះ ។ បើមានតែ"ប្រជាពលរដ្ឋខ្មែរ"ប៉ុណ្ណោះ ដែលមានភាពស្មើគ្នាចំពោះមុខច្បាប់ តើអត្ថន័យនៃកថាខណ្ឌបន្ទាប់នៃមាត្រានេះ ដែលបង្ហាញថាពួកគេមានសិទ្ធិសេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ "ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធានឬស្ថានភាពឯទៀតៗ" វាយ៉ាងណាទៅវិញ? ភាពស្មើមុខគ្នានៃសិទ្ធិនិងករណីយកិច្ចផ្សេងៗត្រូវសម្របទៅតាមមនុស្សខុសៗគ្នា ។

(២) ចំពោះការពិនិត្យមើលស័ព្ទវិទ្យាជាលើកដំបូងនេះ ត្រូវបានគេថែមស័ព្ទមួយទៀតៈ ភាពទន់ខ្សោយទូទៅ ទស្សនៈគតិយុត្តិមួយ ពាក្យដែលប្រើប្រាស់ ។ ពាក្យឬរបៀបថ្លែងទាំងអស់ ដែលប្រើប្រាស់គឺគ្មានន័យណាមួយសោះខាងច្បាប់ ។ អ្វីខ្លះទៅជាទំនៀមទម្លាប់"ល្អ" តើទំហំនៃ "ការដាក់ទណ្ឌកម្មដ៏តឹងរ៉ឹង"មួយមានប៉ុនណា? តើ"ប្រជាពលរដ្ឋល្អ"ម្នាក់មានលក្ខណៈដូចម្តេច?

ឃ្លាឃ្លាខ្លះៗដែលប្រើក្នុងនោះ មានលក្ខណៈមិនជាក់លាក់ ធ្វើឲ្យមានការបកស្រាយផ្សេងៗដែលផ្ទុយគ្នាយ៉ាងខ្លាំង ហើយដែលធ្វើឲ្យចុះខ្សោយ ជួនកាលថែមទាំងធ្វើឲ្យការទាក់ទងគ្នានៃបញ្ញត្តិមួយរលាយបាត់បង់ទៀតផង ។

រូបមន្តខុសៗគ្នាត្រូវបានប្រើប្រាស់ក្នុងមាត្រាជាច្រើនដើម្បីសម្គាល់បញ្ហាមួយដូចគ្នា ។ ឧទាហរណ៍មាត្រា២២ មាត្រា៧៨ និងមាត្រា៨៦ និយាយអំពី "ប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់" "ពេលមានសង្គ្រាម" "កាលៈទេសៈពិសេស" "ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" ដោយគ្មានកំណត់ច្បាស់លាស់អំពីសញ្ញាណទាំងនេះឡើយ ទោះបីជាវាឆ្លើយតបទាំងស្រុងចំពោះការប្រាប់លក្ខណៈនូវអ្វីដែលនីតិសាធារណៈហៅថា "កាលៈទេសៈពិសេស" ក៏ដោយ ។

ពាក្យច្បាប់ទាំងឡាយត្រូវបានប្រើដោយគ្មានរវល់ការពារភាពទាក់ទងគ្នានៃច្បាប់រដ្ឋធម្មនុញ្ញទាំងមូលឡើយ ។ ឧទាហរណ៍ការបញ្ជាក់លក្ខណៈនៃពាក្យ"អធិបតេយ្យ" បានផ្អែកទៅលើមូលដ្ឋានផ្សេងៗដែលផ្ទុយគ្នានឹងការប្រគល់អំណាច ។ មាត្រា៥០ និយាយអំពីការគោរពអធិបតេយ្យភាព ចំណែកមាត្រា៥១ និយាយអំពីអធិបតេយ្យប្រជាពលរដ្ឋដោយកំណត់ថាជាប្រភពនៃអំណាច ។ នៅមាត្រា៧៧ គេបានលុបចោលអាណត្តិអាជ្ញាបញ្ជា ប៉ុន្តែមាត្រា៨៨ បានតម្រូវឲ្យមានកូរ៉ុមប្រាំពីរភាគដប់ ទើបការប្រជុំសភាអាចយកជាការបាន ។ ដោយសារប្រភេទនៃភាពផ្ទុយគ្នានេះហើយ ដែលគេអាចដកហូតអ្នកដែលត្រូវបានជ្រើសតាំងពីអំណាចដែលប្រគល់ឲ្យដោយបំពានច្បាប់នោះ ។

ភាសាខ្មែរគឺជាភាសាវិភាគី (ដែលវិនិច្ឆ័យដោយប្រើការវែកញែក) ។ ការសម្បូណ៌ពាក្យឥតប្រយោជន៍បានធ្វើឲ្យឃ្លាកាន់តែធ្ងន់គ្មានបានការបង្កើតភាពមិនច្បាស់លាស់ និងការសង្ស័យអំពីចេតនារបស់សភាធម្មនុញ្ញនិងន័យដែលសភានេះកំណត់ឲ្យពាក្យពេចន៍ទាំងឡាយដែលខ្លួនប្រើប្រាស់ ។ មាត្រា៥៣ មានលក្ខណៈប្រកបដោយសំនួនវោហារយ៉ាងចម្លែកចំពោះទស្សនៈនេះៈ ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ ។ ការពោលអះអាងនៃច្បាប់រដ្ឋធម្មនុញ្ញមួយសម្តែងចេញឲ្យដឹងនូវបំណងមួយដែលមិនប្រែប្រួលអ្វីចឹងឬ? តើគេអាចគ្រោងប្រតិបត្តិជានិច្ចនូវនយោបាយអព្យាក្រឹតមួយដែលមានឡើងដោយកាលៈទេសៈដែរឬទេ? ឧទាហរណ៍មួយទៀត សិទ្ធិ"ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ" (មាត្រា៣៥) ។ តើការចូលរួមអកម្ម (ដែលគ្មានធ្វើអ្វីសោះ) នឹងត្រូវហាមឃាត់ឬ? តាមការពិត សិទ្ធិនេះដែលលេចឡើង ហាក់ដូចជាករណីយកិច្ចមួយនៅក្នុងរដ្ឋធម្មនុញ្ញពីមុន តើមានរួមបញ្ចូលនូវលទ្ធភាពផ្សេងៗទៀត ដូចជាលទ្ធភាពដែលបង្ហាញក្នុងបទបញ្ញត្តិផ្សេងៗទាក់ទងទៅនឹងសេរីភាពក្នុងការសម្តែងមតិ ការប្រជុំ និងការបង្កើតសមាគមដែរទេ?

បើប្រៀបធៀបនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ឆ្នាំ១៩៥៦

ឬឆ្នាំ១៩៧២ រដ្ឋធម្មនុញ្ញ១៩៩៣ បានឆ្លុះបញ្ចាំងឲ្យឃើញភាពថយក្រោយមួយយ៉ាងច្បាស់ក្នុងការធ្វើជាម្ចាស់គំនិតផ្សេងៗស្តីពីសិទ្ធិពលរដ្ឋនិងសេចក្តីទៀងទាត់ឥតល្អៀងផ្នែកគតិយុត្តិ ។

៣) ចំនួន៣៣លើក អត្ថបទទាំងស្រុងនៃច្បាប់គ្រឹះបានប្រគល់ឲ្យរដ្ឋសភាមើលខុសត្រូវធ្វើច្បាប់ដោយប្រើបទបញ្ញត្តិមួយត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។ ភាពទន់ខ្សោយនៃច្បាប់រដ្ឋធម្មនុញ្ញដែលមានតាំងពីការកកើតមក ត្រូវបានអះអាងបន្ថែមដោយភាពយឺតយ៉ាវ ដោយសារច្បាប់ទាំងនោះត្រូវដាក់ឲ្យពិនិត្យនិងអនុម័ត ។ នៅថ្ងៃនេះ ក្នុងចំនួនច្បាប់៣៣ដែលប្រកាសឲ្យធ្វើដោយរដ្ឋធម្មនុញ្ញ គឺមានតែច្បាប់ចំនួន៩ប៉ុណ្ណោះដែលត្រូវបានអនុម័ត ។ គេអាចពោលអះអាងដោយសមហេតុសមផលថានៅចំពោះមុខយើងមានរដ្ឋធម្មនុញ្ញមួយដែលខ្វះការអនុវត្តន៍យ៉ាងខ្លាំង ។

វាក្លាយទៅជារឿងសាមញ្ញមួយទៅហើយដែលគេសម្គាល់ឃើញថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មានលក្ខណៈប្លែកជាទីបំផុតដោយសារកាលៈទេសៈនៃការតាក់តែងខ្លឹមសាររបស់វា ។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញបានត្រឹមតែបង្កើតដោយផ្អែកនូវរបបមួយដែលបីឆ្នាំក្រោយមកនៅតែស្វែងរកលក្ខណៈពិសេសនៃស្ថិរភាពរបស់ខ្លួននៅឡើយ ។ ដោយហេតុនេះ រដ្ឋធម្មនុញ្ញមុខជានឹងមានភាពឃ្លាតពីគ្នាយ៉ាងឆាប់រហ័ស បើប្រៀបធៀបនឹងលក្ខណៈពិសេសផ្សេងៗនៃប្រព័ន្ធនយោបាយដែលខំប្រឹងកែទម្រង់របស់ខ្លួន ។ តាមការមើលឃើញនេះ គេនឹងមិនអាចបន្ទោសថា អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិបានកំណត់លក្ខណៈរដ្ឋធម្មនុញ្ញរបស់កម្ពុជាទៅតាមលក្ខណៈរបស់ខ្លួនឡើយ ។ ក៏ប៉ុន្តែការពោលអះអាងនេះត្រូវតែកុំឲ្យជ្រុលដោយការបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនូវសេរីភាពសំខាន់ៗ ច្បាប់ផ្សេងៗខាងសេដ្ឋកិច្ច និងសង្គមកិច្ច ដែលជួយឲ្យមានការពង្រីកសង្គមស៊ីវិលមួយ ដែលនៅយឺតយាវនៅឡើយ ប៉ុន្តែក្នុងជំហានពិតប្រាកដ ទោះបីជាមានការបណ្តែតបណ្តោយជាច្រើនដែលគេអាចសង្កេតឃើញនៅពេលសព្វថ្ងៃក៏ដោយ ។ ប្រសិនបើ ជារដ្ឋធម្មនុញ្ញអាចប្លែកពីគ្នាពង្រីងការចាក់ឫសនិងស្វ័យភាពរបស់ខ្លួន សង្គមស៊ីវិលនេះគឺជាតំណាងអ្វីៗដែលឲ្យសម្រេចផលច្រើនប្រការសម្រាប់អនាគតប្រព័ន្ធប្រជាធិបតេយ្យដែលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ប្រកាសឲ្យដឹងជាសាធារណៈ ។ ជាមួយភាពទាក់ទងគ្នាហូរហែមួយដែលកំពុងតែរីកលូតលាស់ជាមួយនឹងសារពត៌មានដ៏សម្បូរ ទោះបីជាសេចក្តីខាងក្នុងរបស់វាមានលក្ខណៈជាការធ្វើឫនិយាយដោយប្រុងប្រយ័ត្ន (មិននិយាយឲ្យអស់រឿង) យ៉ាងណាក៏ដោយ [កាសែតជាច្រើនដែលកំពុងផ្សាយនៅប្រទេសកម្ពុជានឹងត្រូវហាមឃាត់ទាំងស្រុងនៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ហើយមានកាសែតយ៉ាងច្រើននឹងត្រូវប្តឹងនិងផ្តន្ទាទោសនៅក្នុងបណ្តាប្រទេសលោកខាងលិចដែលប្រកាន់លិទ្ធិប្រជាធិបតេយ្យសេរីជាងគេ ។ សេរីភាពក្នុងការសម្តែងមតិពុំមែនបង្ហាញភ័ស្តុតាងពីការប៉ិនប្រសប់ដែលធ្វើឡើងជាក្បួនតាមការជេរប្រមាថ ការមួលបង្កាច់ ការបរិហារកេរ្តិ៍ ការធ្វើឲ្យប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស ការអុជអាលឲ្យមានការស្អប់ខ្ពើមនិងអំពើហិង្សា ភាពចំអេសចំអាសនោះទេ ។ សូមអានរឿងនេះ នៅក្នុងរបាយការណ៍របស់យើងស្តីពីសារពត៌មានរបស់កម្ពុជា ដែលបោះពុម្ពផ្សាយដោយ រីព័កទ័រ សង់ហ្វ្រង់ដែ (បោះពុម្ពផ្សាយនៅទីក្រុងប៉ារីសចុងឆ្នាំ១៩៩៦)] ។ ជាមួយនឹងពហុនិយមមួយខាងនយោបាយដែលដាក់ឲ្យគេព្រមទទួល (ដោយសេចក្តីគោរព) ក្នុងហេតុការណ៍ផ្សេងៗ ទោះបីជាវាពើបប្រទះនឹងការប្រឆាំងជំទាស់ដ៏ខ្លាំងក្លាក៏ដោយ ក៏ប្រទេសកម្ពុជាមានអ្វីៗដែលឲ្យសម្រេចលទ្ធផលច្រើនប្រការ ដើម្បីដើរទៅមុខតាមបែបផែនរបស់ខ្លួន ហើយទំនងជាប្រកបដោយភាពយឺតយ៉ាវប្រាកដមួយនិងដំណើរផ្លាស់ប្តូរដែលមិនបានគិតទុកជាមុនច្រើនឥតគណនា ឆ្ពោះទៅរកសង្គមពហុនិយមដែលប្រកាសដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មិនខាន ។

## ១) ការបន្ត និង ការលុបចោល

ឆ្លងកាត់តាមច្បាប់គ្រឹះចំនួន៧ដែលទើបនឹងពិនិត្យមើលជាបន្តបន្ទាប់គ្នា លក្ខណៈរដ្ឋធម្មនុញ្ញរបស់កម្ពុជាបានបង្ហាញឲ្យឃើញនូវភាពបន្តដ៏ជាក់លាក់មួយចំនួន ប៉ុន្តែក៏មានការលុបចោលមួយចំនួនផងដែរ ។ គេអាចដកស្រង់ខ្លះៗដោយពិនិត្យមើលយ៉ាងល្អិតល្អន់អំពីមូលបទសំខាន់ៗនៃសកម្មភាពសាធារណៈដែលគេដឹងព្រួគ្រប់ៗគ្នារបស់ប្រទេសនេះ ។

### ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាគឺជាធាតុមួយដែលមានសារជាតិតែមួយ ដូចពាក្យ“ស្រុកខ្មែរ”ដែរ ។ តាមការពិត បើគ្មានព្រះពុទ្ធសាសនា គេពិបាកនឹងស្វែងយល់ពីវប្បធម៌និងទំនៀមទម្លាប់ប្រពៃណីខ្មែរណាស់ ។ នៅប្រទេសកម្ពុជា ព្រះពុទ្ធសាសនាត្រូវបានដាក់ឲ្យត្រួតត្រាដោយព្រះសង្ឃមួយក្រុមដែលបង្កើតជាអង្គការមានទម្រង់ត្រឹមត្រូវមួយ ហើយដែលរចនាសម្ព័ន្ធត្រូវបានរៀបចំតាមឋានានុក្រមច្រើនជាន់ថ្នាក់ ។ ព្រះពុទ្ធសាសនាមានលក្ខណៈឯករាជ្យទាំងស្រុង ហើយគ្មានចំណងទាក់ទងណាមួយ ទាំងសម្ភារទាំងនយោបាយ ជាមួយបណ្តាព្រះសង្ឃនៃប្រទេសផ្សេងៗទៀត ដែលកាន់ព្រះពុទ្ធសាសនាថេរវាទឡើយ ។ លោក ប្រេសស្លេ បានគូសបញ្ជាក់ពីរឿងនេះថា “សង្ឃ (ពាក្យនេះ តាមវចនានុក្រមខ្មែរ ឲ្យន័យថា ពួកប្រជុំបន ហ្វូង ហើយតាមលទ្ធិពុទ្ធសាសនាសំដៅចំពោះក្រុមភិក្ខុចាប់ពី៤រូបឡើងទៅ) របស់កម្ពុជា គឺជាគណៈសង្ឃមួយរបស់ជាតិ” ។ ក្រៅពីមានអំណាចគ្រប់យ៉ាង ព្រះសង្ឃបានបំពេញតួនាទីសង្គមកិច្ចអប់រំមួយដែលមានសារសំខាន់បំផុត ។ ព្រះសង្ឃរួមបង្កជាកម្លាំងសង្គមដ៏សំខាន់មួយ ។

ឋានៈជាព្រះពុទ្ធសាសនានៅក្នុងសង្គមរបស់កម្ពុជាគឺថាត្រូវបានទទួលស្គាល់ ជួនកាលត្រូវលុបចោល ប៉ុន្តែនៅតែត្រូវយកចិត្តទុកដាក់ជានិច្ចដោយរដ្ឋធម្មនុញ្ញដែលមានជាបន្តបន្ទាប់ ។ ដោយអនុម័តព្រះពុទ្ធសាសនាជា“សាសនារបស់រដ្ឋ”ក្នុងរដ្ឋធម្មនុញ្ញចំនួនប្រាំ (១៩៤៧, ១៩៥៦, ១៩៧២, ១៩៨៩, ១៩៩៣) ក្នុងចំណោមរដ្ឋធម្មនុញ្ញទាំងប្រាំពីរ ព្រះពុទ្ធសាសនាបានត្រូវហាមឃាត់ដោយគ្មានចែងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងដែលគាំពារដោយគ្រាន់តែមានលំនាំក្រៅក្នុងរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានោះ ព្រះពុទ្ធសាសនាត្រូវបានធ្វើឲ្យទៅជាឧបករណ៍ដោយរដ្ឋអំណាច ដែលជួនកាលល្បងប្រើសាសនា ដើម្បីធ្វើឲ្យមានលក្ខណៈពេញច្បាប់ផ្ទាល់របស់ខ្លួន ជួនកាលចាត់ទុកសាសនាជាគ្រោះថ្នាក់ថែមទៀត (កម្ពុជាប្រជាធិបតេយ្យ) ។

នយោបាយរបស់គណបក្សសង្គមរាស្ត្រនិយមពឹងផ្អែកលើគោលសីលធម៌សំខាន់ៗរបស់ព្រះពុទ្ធសាសនា ។ សាធារណរដ្ឋខ្មែររបស់ លន់ ណុល បានប្រើវិធីធ្វើកំណែនព្រះពុទ្ធសាសនា និងព្រះសង្ឃក្នុងការប្រយុទ្ធប្រឆាំងទាំងស្រុងទល់នឹងលទ្ធិកុម្មុយនិស្ត ។ តាមការប្រឆាំងតបវិញ ប៉ុន្តែអាស្រ័យដោយភាពប្រាកដក្នុងចិត្តមិនជឿសាសនាអ្វីទាំងអស់ ដែលជាប់ទាក់ទាមយ៉ាងស្អិតនឹងមនោគមវិជ្ជារបស់គេ ពួកខ្មែរក្រហមបានចាត់ទុកព្រះពុទ្ធសាសនាជា“អាភៀនដែលធ្វើឲ្យទេពកោសល្យនិងកម្លាំងប្រាជ្ញានិងកម្លាំងកាយរបស់ប្រជាជនចុះអន់ថយ” ។ ព្រះសង្ឃទាំងឡាយត្រូវបានចាត់ទុកជា“ពូនសត្វកម” ដែល“ចេះតែស៊ីគ្មានចេះផលិត” ។ ក្រោមសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រះពុទ្ធសាសនាបានលូតលាស់ឡើងវិញពីផេះផង់របស់ខ្លួន ប៉ុន្តែតាមនីតិក្រមយ៉ាងតឹងរ៉ឹងមួយដែលឃ្លាំមើលដោយអាជ្ញាធរមានសមត្ថកិច្ច ។ ជាមួយរដ្ឋកម្ពុជា គឺដំណើរប្រែត្រឡប់ទៅរកស្ថានភាពជាសាសនារបស់រដ្ឋវិញ ហើយជាមួយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣គឺការទទួលស្គាល់និកាយទាំងពីររបស់ព្រះពុទ្ធសាសនា (ធម្មយុត្តិកនិកាយនិងមហានិកាយ) ដែលសម្តេចសង្ឃទាំងពីរនិកាយមានសិទ្ធិចូលរួមក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មី ។

## រាជាធិបតេយ្យ

មួយចំណែក យើងពិនិត្យមើលឋានៈកណ្តាលដែលកាន់កាប់ដោយព្រះមហាក្សត្រក្នុងវប្បធម៌ពុទ្ធសាសនាថេរវាទ ។ ម្យ៉ាងទៀតអង្គព្រះមហាក្សត្រដែលតាមគោលការណ៍នៃរាជាធិបតេយ្យ គឺជាកម្មវត្ថុនៃការគោរពបូជា ស្វាមីភក្តិ និងការស្តាប់ឱវាទរបស់ប្រជារាស្ត្រ គឺមានភាពស្របគ្នាទាំងស្រុងនឹងទស្សនៈនៃចំណងទាក់ទងផ្ទាល់ខ្លួនមួយរវាង“ចៅកែ”និង“អតិថិជន”របស់ខ្លួន នេះជាទស្សនៈដែលថ្លែងដោយសម្តេចព្រះ នរោត្តម សីហនុ “សម្តេចឪ” ទៅកាន់“កូនចៅ” របស់ព្រះអង្គក្នុងន័យស្និទ្ធស្នាល ប្រៀបដូចជាសមាជិកគ្រួសារមួយ ។ ឋានៈនេះត្រូវបានការពារក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងត្រូវបានលើកតម្កើងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ទៀត ។ ឋានៈនេះត្រូវរលាយបាត់ជាមួយនឹងរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋខ្មែរ ។ ជាធម្មតា ទស្សនៈស្តីពីរបបរាជាធិបតេយ្យពុំមានឃើញនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជារដ្ឋធម្មនុញ្ញសាធារណរដ្ឋនិយមរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជាឡើយ ។ ដូចដែលគេបានដឹងរួចមកហើយថារដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើតរាជាធិបតេយ្យឡើងវិញ ប៉ុន្តែ

ដោយរឹតត្បិតអំណាចរបស់ព្រះមហាក្សត្រយ៉ាងតឹងរ៉ឹង ។

យើងក៏សម្គាល់ដែរ អំពីយន្តការនៃការឡើងស្នងរាជ្យជាបន្តបន្ទាប់ដែលប្រែភាពប្លែកដាច់ពីគ្នា រវាងឆ្នាំ១៩៨៧និងឆ្នាំ១៩៩៣ ។ នៅឆ្នាំ១៩៨៧ បើសិនជារាជាធិបតេយ្យនៅតែត្រូវជ្រើសតាំង ព្រះមហាក្សត្រអាចជ្រើសរើសអ្នកស្នងរាជសម្បត្តិទុកជាមុន ។ អំណាចនេះបានរក្សាទុកសម្រាប់ព្រះអង្គក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ ប៉ុន្តែបានត្រូវបំបាត់ចោលដោយពាក្យច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញដែលកំពុងប្រើសព្វថ្ងៃ ។ មួយចំណែកទៀត យើងពិនិត្យមើលថា ក្នុងរយៈពេល៤៣ឆ្នាំនៃឯករាជ្យភាពរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន គឺកម្ពុជាស្គាល់របបរាជាធិបតេយ្យ ២០ឆ្នាំនិងរបបសាធារណរដ្ឋនិយម២៣ឆ្នាំ ។ ការសម្គាល់ឃើញនេះប្រហែលជានៅតែដក់ជាប់នៅក្នុងគំនិតអ្នកទាំងឡាយដែលនឹងឃ្លាំមើលសកម្មភាពនយោបាយនៅក្នុងអំឡុងបណ្តាឆ្នាំដែលនឹងមកដល់ខាងមុខ ។ ភាគច្រើនបំផុតនៃប្រជាពលរដ្ឋបច្ចុប្បន្នរបស់កម្ពុជា ទើបតែបានស្គាល់របបរាជាធិបតេយ្យចំនួនបីឆ្នាំកន្លងទៅប៉ុណ្ណោះ ។ សម្រាប់ហេតុផលដែលទាក់ទងជាសំខាន់នឹងព្រះរាជសុខភាព ព្រះមហាក្សត្រពុំសូវមានព្រះរាជវត្តមាននៅក្នុងប្រទេសទេសម្រាប់រយៈពេលបីឆ្នាំនេះ ។ ការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយដែលគ្រោងទុកដោយរដ្ឋធម្មនុញ្ញដើម្បីជ្រើសរើសព្រះមហាក្សត្រឲ្យឡើងសោយរាជ្យបន្ត នៅតែពុំទាន់អនុម័តសម្រេចនៅឡើយ ។ ប្រសិនបើពុំត្រូវបានគាំទ្រដោយអ្នកមានអំណាចខ្លាំងម្នាក់ដែលគ្រាន់តែព្រមព្រៀង គេអាចដណ្តឹងសួរដោយសមហេតុផលអំពីស្ថិរភាពនៃគោលការណ៍របបរាជាធិបតេយ្យ និងអំពីសមត្ថភាពនៅគង់វង្សចំពោះការសាកល្បងមើលផ្សេងៗនៅពេលខាងមុខ ។

## អធិបតេយ្យ (អំណាចធំបំផុត)

ពីឆ្នាំ១៩៥៦ដល់ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញទាំងអស់បានឆ្លើយតបនឹងបំណងរបស់អ្នកទាំងឡាយដែលកាន់កាប់អំណាច គឺពុំមែនឆ្លើយតបនឹងបំណងអ្នកទាំងឡាយជាអ្នកតំណាងជាតិទេ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ឆ្លើយតបនឹងបំណងព្រះប្រមុខរដ្ឋនរោត្តម សីហនុ, រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២អនុលោមទៅតាមបំណងប្រាថ្នារបស់ លន់ ណុល, រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦, ១៩៨១ និង ១៩៨៩ បានបង្ហាញពីបំណងរបស់គណបក្សតែមួយដែលជាអ្នកកាន់កាប់អំណាច ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៧ និង១៩៩៣ ត្រូវលើកលែងដោយសារវាចេញពីសភាធម្មនុញ្ញមួយ ។ ប៉ុន្តែរដ្ឋធម្មនុញ្ញដែលរៀបចំដោយសភាធម្មនុញ្ញត្រូវបានវាយតម្លៃដោយសម្មតិកម្មជាលើកចុងក្រោយ ហើយមុននឹងអនុម័តតែងតែមានការសម្រុះសម្រួលជាមួយសម្តេចព្រះ នរោត្តម សីហនុ រៀងរាល់លើក ។

តើប្រភពអំណាចចេញមកពីណា? ព្រះមហាក្សត្រ? ប្រជាជាតិ? ពលរដ្ឋ? បក្ស? ។ ប្រភពនៃអធិបតេយ្យខុសគ្នាទាំងពីរនេះនឹងមានទាំងអស់ក្នុងរដ្ឋធម្មនុញ្ញទាំងឡាយរបស់កម្ពុជាដោយឆ្លាស់គ្នាមួយដងមួយពេល ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ដែលយកតម្រាប់តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧បញ្ជាក់ថាព្រះមហាក្សត្រគឺជាប្រភពនៃអំណាចទាំងអស់ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២បានអះអាងថា អំណាចទាំងអស់ចេញមកពីប្រជារាស្ត្រ ដោយប្រើប្រាស់គោលការណ៍ស្តីអំពីអធិបតេយ្យប្រជារាស្ត្រ ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យអះអាងថា រដ្ឋជាកម្មសិទ្ធិរបស់ប្រជាជន កម្មករ កសិករ និងពលករផ្សេងទៀតទាំងអស់ ប៉ុន្តែតាមពិតគេដឹងថា ប្រភពនៃអំណាចគឺអង្គការដែលជាឡប់ឡែមួយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏ដូចជារដ្ឋកម្ពុជាការអះអាងដែលថាអំណាចទាំងអស់ជារបស់ប្រជាជន គឺមានភាពជាឧបសគ្គដោយការប្រកាសពីតួនាទីដឹកនាំរបស់បក្សប្រជាជនបដិវត្តកម្ពុជា ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ប្រកាសថា អំណាចទាំងអស់ចេញមកពីប្រជារាស្ត្រដែលប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ដោយប្រើប្រាស់គោលការណ៍នៃអធិបតេយ្យជាតិ ហើយដែលនិយាយច្រំដែលនៅមាត្រា៥០យ៉ាងជាក់លាក់ ។

គ្មានពេលណាមួយនៃប្រវត្តិសាស្ត្របច្ចុប្បន្នរបស់ខ្លួនដែលអធិបតេយ្យប្រជារាស្ត្រត្រូវបានសម្តែងចេញដូច្នេះទេ ទោះបីជាមានការប្រឹងប្រែងពិតប្រាកដធ្លាប់ត្រូវបានសាកល្បងដើម្បីបង្កើតឲ្យមានប្រភេទប្រជាធិបតេយ្យដោយផ្ទាល់មួយ នៅសម័យសង្គមរាស្ត្រនិយមក៏ដោយ ។ ចំពោះរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

ភាពមិនច្បាស់លាស់របស់ខ្លួនអំពីចំណុចនេះ ត្រូវបានសម្រេចនៅពេលដែលរដ្ឋសភាបានលើកតម្លៃអំណាចរបស់ខ្លួនក្នុងការបញ្ឈប់សមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងអស់នៃអាណត្តិរបស់ខ្លួន ។

### ការបែងចែកអំណាច

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានបង្កើតឲ្យមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទទួលបន្ទុកឃ្លាំមើលឯករាជ្យភាពរបស់តុលាការ ប៉ុន្តែស្ថាប័ននេះគឺដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលធ្វើឲ្យឯករាជ្យភាពនិងភាពគួរឲ្យទុកចិត្តនៃឧបករណ៍ទទួលបន្ទុកធានាដោយជាក់លាក់នូវឯករាជ្យភាពនៃអំណាចតុលាការថយដល់កម្រិតសូន្យ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៦ បានប្រគល់តំណែងប្រធានក្រុមប្រឹក្សានេះដល់ចៅក្រមម្នាក់នៅពេលដែលប្រមុខរដ្ឋមិនធ្វើជាអធិបតីដោយផ្ទាល់ព្រះអង្គ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានបញ្ចេញឲ្យដឹងនូវការសាកល្បងបញ្ឈប់ជាស្ថាពរ ដោយសារចំណុះរបស់អង្គការតុលាការដោយប្រៀបធៀបនឹងអង្គការនីតិប្រតិបត្តិនិងអង្គការនីតិបញ្ញត្តិ ។ រដ្ឋធម្មនុញ្ញនានា ដែលនឹងមានក្រោយមកទៀត នឹងរៀបចំប្រព័ន្ធយុត្តិធម៌ទាំងអស់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកនយោបាយមួយ រួមទាំងរដ្ឋធម្មនុញ្ញបច្ចុប្បន្នដែលនៅក្នុងធរមានបញ្ញត្តិ(ចំពោះច្បាប់ដែលនៅប្រើ)ផង ។

អំពីរឿងនីតិបញ្ញត្តិ គោលការណ៍ដ៏មានតម្លៃរបស់លោកម៉ុងតេសគីយើ ដែលថា «តាមប្រភេទនៃរឿងរ៉ាវ អំណាចអាចបញ្ឈប់អំណាចបាន» មិនសូវត្រូវបានអនុវត្តទៅតាមគោលការណ៍នៅប្រទេសកម្ពុជាទេ ។ ដើម្បីជៀសវាងលិទ្ធិផ្តាច់ការ អំណាចនីតិបញ្ញត្តិគោងតែអាចបញ្ឈប់អំណាចនីតិប្រតិបត្តិនិងទៅវិញទៅមក ។ តែថាដូចលោកសាស្ត្រាចារ្យ ហ្គួ បានកត់សម្គាល់ពីរឿងនេះនៅឆ្នាំ១៩៦៥ថា «ប្រទេសកម្ពុជាមិនបានអនុម័តគោលការណ៍នៃការបែងចែកអំណាចទេ ហើយបានច្រានចោលទស្សនៈស្តីអំពីអំណាចនៃប្រព័ន្ធតុលាការ ។ ការបែងចែកអំណាច គឺគ្មានទាក់ទងនឹងទម្លាប់ជាប្រពៃណីរបស់កម្ពុជាឡើយ ។ វាក៏ជាច្បាប់វិជ្ជមានរបស់ខ្មែរនាបច្ចុប្បន្នដែរ» ។ គេពុំអាចប្រកែកបានថា រដ្ឋធម្មនុញ្ញដែលមានអានុភាពគតិយុត្តិក្រោមរបបសង្គមរាស្ត្រនិយមបានប្រគល់មុខងារផ្នែកនីតិប្រតិបត្តិនិងតុលាការឲ្យព្រះមហាក្សត្ររដ្ឋាភិបាល រដ្ឋសភា និងរាស្ត្រ ព្រមគ្នាដោយបង្កើតឲ្យមានភាពច្របូកច្របល់ពិតប្រាកដមួយនៃអំណាច ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ក៏ដូចរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានអនុញ្ញាតឲ្យមានរដ្ឋសភាជាតិតែមួយប៉ុណ្ណោះ ដើម្បីធ្វើការអនុម័តច្បាប់ ។ រដ្ឋសភាជាតិគឺជាកន្លែងទីតាំងតែមួយគត់នៃអំណាចនីតិបញ្ញត្តិ ដែលបញ្ជាក់ព្រមគ្នាដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ និង ១៩៨៩ ចំណែករដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ បានកំណត់ឲ្យសហសភា (រដ្ឋសភានិងព្រឹទ្ធសភា) នូវសិទ្ធិអនុម័តច្បាប់ ហើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ បានផ្តល់ដូចគ្នាចំពោះសភាតំណាងប្រជាជន ។ ការមូលមតិគ្នាដ៏ល្អនេះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវភាពមិនចុះសម្រុងមួយដែលកំពុងមានអត្ថិភាពរវាងច្បាប់ដែលប្រកាសឲ្យប្រើនិងការអនុវត្តន៍ដែលសង្កេតឃើញ ។ ភាពឃ្លាតគ្នាមួយបែបនោះ បានធ្វើឲ្យអាជ្ញាយុកាលនៃរដ្ឋធម្មនុញ្ញទៅជាការសម្គាល់លក្ខណៈដូចគ្នានៃទម្រង់និយមមួយ ដែលត្រូវបានធ្វើឲ្យទៅជាឧបករណ៍ដោយប្រភពពិតប្រាកដនៃអំណាច ពោលគឺកាលពីមុនព្រះមហាក្សត្រថ្មីៗនេះបក្សតែមួយ ហើយសព្វថ្ងៃនេះរដ្ឋាភិបាលចម្រុះ ។

### ច្បាប់

អ្វីទៅជាសារសំខាន់នៃច្បាប់ក្នុងច្បាប់ទាំងមូលរបស់កម្ពុជា? ច្បាប់គឺជាវិញ្ញត្តិ (ការជម្រាបការសម្តែង)នៃ «ឆន្ទៈរបស់ជាតិ» ដែលអះអាងដោយពាក្យពេចន៍ដូចគ្នាក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ១៩៥៦ និង ១៩៧២ ខណៈដែលរដ្ឋធម្មនុញ្ញចំនួនបួនដែលមានជាបន្តបន្ទាប់មកទៀតគឺគ្មាននិយាយតែម្តង ។ តើអ្វីដែលបង្ហាញឲ្យដឹងពីឆន្ទៈជាតិ? ក្នុងប្រព័ន្ធមួយដែលប្រើអធិបតេយ្យជាតិគឺស្ថាប័នរដ្ឋសភាដោយមិនអាចប្រកែកបានឲ្យតែឯករាជ្យភាពរបស់ខ្លួនត្រូវបានការពារ ។ ក្នុងប្រព័ន្ធផ្សេងៗទៀត ច្បាប់គឺជាវិញ្ញត្តិរបស់អ្នកបង្កើតជាច្រើនដែលធ្វើឲ្យប៉ះពាល់ព្រមគ្នាដល់ភាពពេញច្បាប់របស់ខ្លួន ហើយក្នុងករណីខ្លះប៉ះពាល់ដល់ភាពគតិយុត្តិរបស់ខ្លួន ។

ដើម្បីឲ្យច្បាប់អាចឲ្យគេព្រមទទួលទុកដូចជាវិធានរួមដែលកើតចេញពីឆន្ទៈជាតិ ច្បាប់ត្រូវតែមានដើមកំណើតមកពីក្រុមអ្នកតំណាងជាតិដោយអាជ្ញាបញ្ញាដែលត្រូវសម្តែងឲ្យដឹងដោយ

ចំពោះមុខៗ ភាពច្របូកច្របល់នៃអំណាចដែលនៅស្ថិតស្ថេរ ក្នុងរយៈពេល៥៥ឆ្នាំនៃការអនុវត្ត ច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជា បានចូលរួមមួយចំណែកក្នុងការបកស្រាយពីសារសំខាន់តិចតួច នៃច្បាប់នៅចំពោះមុខប្រជាពលរដ្ឋទាំងឡាយ ។

ក្នុងរយៈពេលយូរមកហើយ ច្បាប់ធ្លាប់ត្រូវបានបញ្ចូល មកប្រទេសកម្ពុជារបៀបដូចការចម្លងពីសេចក្តីបង្គាប់នៃលោក ធាតុតាមរយៈការប្រគល់អំណាចដែលប្រកាសថាដូចគ្នាដោយ លោកទស្សនៈព្រាហ្មណ៍និយមផង និងដោយលោកទស្សនៈពុទ្ធ និយមផង ។ ច្បាប់ពុំមែនចេញពីប្រជារាស្ត្រទេ ហើយក៏ពុំមែន សម្តែងឲ្យឃើញឆន្ទៈរបស់ប្រជារាស្ត្រភាគច្រើនដែរ ។ ច្បាប់គឺជា ឧបករណ៍ ដែលតាមរយៈនេះ បានបញ្ញត្តិនូវរបៀបរបបនយោបាយ មួយដែលចេញឲ្យឃើញឡើងដោយរបៀបម៉្យាងដូចជាព្រំដែន រួមនៃសេចក្តីបង្គាប់នៃលោកធាតុ ។ ការរៀបចំតម្រូវគ្នាតាមរយៈ ច្បាប់នូវរបៀបរៀបរយនយោបាយនេះគឺជាស្នាដៃរដ្ឋាភិបាល ។ ច្បាប់ថែទាំសេចក្តីរៀបរយសកល ដោយធ្វើឲ្យមានភាពស្របគ្នា រវាងសេចក្តីបង្គាប់នៃលោកធាតុនិងរបៀបរបបនយោបាយ ។ តាមពិត ភាពច្របូកច្របល់នៃសាសនានិងនយោបាយ គឺសំដៅ ធ្វើឲ្យនយោបាយរឹងមាំជាងមុន ដោយការសំអាងលើសាសនា ។ ច្បាប់គឺជារបៀបធ្វើឲ្យសាសនាជាឧបករណ៍បម្រើឲ្យរដ្ឋាភិបាល ។ កាលណារដ្ឋាភិបាលធ្វើឲ្យបាត់បង់សេចក្តីរាប់អានពីអ្នកផ្សេង ទៀត ការបាត់បង់ជំនឿទុកចិត្តនេះច្បាស់ជាបង្ហាញឲ្យឃើញមុន អ្វីៗទាំងអស់នូវការបាត់បង់តម្លៃនៃច្បាប់និងការសម្តែងចេញនូវ ការមិនសប្បាយចិត្តចំពោះរដ្ឋាភិបាលដែលនឹងស្តែងចេញដោយ ការមើលងាយមួយចំពោះច្បាប់ ។

រដ្ឋធម្មនុញ្ញផ្សេងៗបានបញ្ចូលដោយរបៀបមួយឬរបៀប មួយទៀតនូវគោលការណ៍នៃឧត្តមភាពរបស់រដ្ឋធម្មនុញ្ញលើច្បាប់ ឯទៀតៗទាំងអស់ និងបញ្ជាក់ពីកាតព្វកិច្ចធ្វើឲ្យច្បាប់ត្រូវស្រប នឹងរដ្ឋធម្មនុញ្ញដាច់ខាតលើកលែងតែរដ្ឋធម្មនុញ្ញដ៏ខ្លីរបស់កម្ពុជា ប្រជាធិបតេយ្យប៉ុណ្ណោះ ។ នេះជាការធ្វើឲ្យមានរូបរាងនូវគោល ការណ៍នៃលំដាប់លំដោយរបស់ច្បាប់ទាំងឡាយ ដែលត្រូវតែ ធានាភាពស្អិតល្មួតនៃនីតិរដ្ឋ ។ ប៉ុន្តែការត្រួតពិនិត្យភាពត្រឹម ត្រូវតាមរដ្ឋធម្មនុញ្ញនេះគឺត្រូវបានប្រគល់លើស្ថាប័នផ្សេងៗ ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ឆ្នាំ១៩៥៦ ឆ្នាំ១៩៨១ និងឆ្នាំ ១៩៨៩ បានបម្រុងទុកតួនាទីនេះឲ្យរដ្ឋសភា ចំណែកឯរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧២ និង១៩៩៣ បានប្រគល់តួនាទីនេះឲ្យក្រុមប្រឹក្សា ធម្មនុញ្ញ ។

គ) តើរដ្ឋធម្មនុញ្ញរបស់កម្ពុជាមានលក្ខណៈយ៉ាងដូចម្តេច?

ក្បួនទ្រឹស្តីនៃអ្នកធ្វើរដ្ឋធម្មនុញ្ញគឺធ្វើឲ្យមាននីតិរដ្ឋ ។ ទម្លាប់ ជាប្រពៃណីរបស់កម្ពុជា បានឲ្យអត្ថប្រយោជន៍ដល់របៀបគ្រប់ គ្រងមួយដែលនិយមពង្រីកបក្សពួក ។ តើភាពចូលគ្នាចុះស្ថិត នៅត្រង់ណា?

ពីឆ្នាំ១៩៤៦ដល់ឆ្នាំ១៩៥២ គណបក្សប្រជាធិបតេយ្យ បានល្បងបញ្ចូលរបបសភានិយម (របៀបគ្រប់គ្រងអាស្រ័យ សភាគឺគណៈរដ្ឋមន្ត្រីទទួលខុសត្រូវចំពោះរដ្ឋសភា) ពីព្រោះវាជា វិធីទំនើបក្នុងការគ្រប់គ្រងកិច្ចការសាធារណៈ ។ បទពិសោធន៍នេះ បានទទួលបរាជ័យព្រោះតែហេតុផលផ្សេងៗដែលនៅខាងក្រៅ កម្មវត្ថុគម្រោងនេះ ។ វាមានភាពស័ក្តិសមនឹងត្រូវសិក្សាដោយ ល្អិតល្អន់ ដើម្បីដកស្រង់មេរៀនផ្សេងៗសម្រាប់អនាគត ។

គណបក្សសង្គមរាស្ត្រនិយមបានធ្វើការសាកល្បងមួយ ទៀតដែលទុកតម្លៃនៃការប្រតិបត្តិជាធំដើម្បីរកការខិតចូលជិត គ្នាមួយរវាងការគ្រប់គ្រងកិច្ចការរដ្ឋប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធនិយមបក្ខពួកជាអចិន្ត្រៃយ៍មួយ ។ គេអាចអះអាងថា នេះជាការសាកល្បងការរួមបញ្ចូលការដឹកនាំផ្សេងៗដែលជាការ ផ្ទុយពីនីតិរដ្ឋក្នុងប្រព័ន្ធដែលរដ្ឋគ្រប់គ្រង ។ គេប្រហែលជាពុំបាន សិក្សាឲ្យបានគ្រប់គ្រាន់អំពីបទពិសោធន៍នេះ ដូចគ្នាអំពីទស្សនៈ នៃច្បាប់ដែលអាស្រ័យរដ្ឋធម្មនុញ្ញឡើយ ដោយបណ្តោយឲ្យបឺត ស្រូបខ្លាំងពេកដោយដំណើរប្រែប្រួលនយោបាយដែលមិនបាន គិតទុកជាមុន ។

នៅប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញអាចតម្រូវឲ្យមានការពិតថ្មី មួយ ដទៃពីការប្រព្រឹត្តិផ្សេងៗដែលលេចឡើងខ្លាំងជាងគេ ដោយក្រឹត្យដែរឬទេ? ខ្ញុំមិនយល់ឃើញដូច្នេះទេ ។ ឬមួយ រដ្ឋធម្មនុញ្ញបង្ហាញជាថ្មីអំពីការពិតទាំងឡាយដែលនៅមានតែ ក្នុងគ្រាបច្ចុប្បន្ន ឬមួយសម្តែងឲ្យឃើញបំណងមួយ? ។ ចំពោះ ស្ថានភាពបច្ចុប្បន្ននៃច្បាប់ផ្សេងៗ គេសម្គាល់ឃើញថា ច្បាប់

រដ្ឋធម្មនុញ្ញរបស់កម្ពុជាបានដាក់ឲ្យពិនិត្យថែមទៀតអំពីលក្ខណៈរដ្ឋធម្មនុញ្ញមួយដែលអាចកើតមាន ឬលក្ខណៈរដ្ឋធម្មនុញ្ញមួយដែលទាក់ទងនឹងការសិក្សាពីភាពវត្តដែលមានទីបញ្ចប់ ប្រសិនបើគេចង់ឲ្យវាមានលក្ខណៈវិជ្ជមានជាងមុន ។

ប្រពៃណីរបស់កម្ពុជាបានចាក់ឫសរបស់ខ្លួននៅក្នុងព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាបានបង្រៀនអំពីតម្លៃផ្សេងៗដែលមានលក្ខណៈរួមចំពោះអ្នកទាំងអស់ណាដែលសម្រេចចិត្តប្រតិបត្តិធម៌នៅទីនេះក៏ដូចជានៅទីដទៃទៀត ព្រមជាមួយគ្នានឹងសេចក្តីថ្លៃថ្នូររបស់មនុស្សនិងផលប្រយោជន៍រួមគ្នា ។ ដោយស្រង់ចេញពីក្នុងអ្វីដែលពួកគេមាន ពីក្នុងអ្វីដែលពួកគេធ្លាប់ពិសោធន៍ ហើយដោយសម្របខ្លួនទៅតាមអ្វីដែលពួកគេប្រាថ្នា ប្រជាជនកម្ពុជានឹងរកឃើញតែខ្លួនឯងនិងដោយខ្លួនឯង នូវពាក្យពេចន៍ត្រឹមត្រូវដែលប្រើប្រាស់ដើម្បីសម្តែងពីគំនិតរបស់ខ្លួនក្នុងគោលបំណងរស់នៅរួមជាមួយគ្នាទាំងអស់ ។

**រ៉ាអ៊ូល ម៉ៃន័រ**

មតិណែនាំទៅ៩២០

ទូរលេខ៣៧ ចុះថ្ងៃទី២៥-៧-៧៦

## ជំរាបសមមិត្ត ឈិន ជាធីរស្នេហា

១) បានទទួលទូរលេខសមមិត្ត ថ្ងៃ២២-៧ ហើយ ។

២) ចំពោះពួកអាយួនដែលវាវាយយើងកន្លងមក យើងត្រូវដកពិសោធន៍ ហើយមានវិធានការរៀបចំកំលាំងឱយស្ទាត់និង ឱយស្រាល ។ ប្រយ័ត្នវាទៅវាយកន្លែងធំទៀត ។ ដើម្បីការពារកន្លែងធំ ត្រូវមានកំលាំងពង្រាយតូចៗ ឆ្ងាយៗ និងល្បាតឱយជាប់ ។

៣) ត្រូវមានវិធានការវាយសំរុកវាវិញ ។ ត្រូវរៀបចំស៊ើបពិនិត្យ តាមដាន វាយកន្លែងដែលវាមកបោះទីតាំងថ្មីដែលយើងបានពិភាក្សាថ្ងៃមុននោះ ។ បញ្ហានេះសុំពិនិត្យឱយឯកភាពជាមួយមូលដ្ឋានខាងតំបន់ ហើយមានវិធានការវាយកំទេចវា ។ សំខាន់ត្រូវការពារកំលាំងយើងឱយបាន ។ ត្រូវរកវិធីវាយឱយសក្តិសិទ្ធឱយមែនទែន ។ ត្រូវសំងាត់អំពីផែនការឱយមែនទែន ។ ត្រូវប្រើកំលាំងតូចកំទេចកំលាំងធំរបស់ខ្មាំង ។

ឧទាហរណ៍ៈ ប្រើកាំភ្លើងធំជាដើម ។ បើវាយពិសេស ត្រូវប្រយ័ត្នឱយមែនទែន ។ បើឯកភាពជាមួយសមមិត្ត ឡាំង ហើយស្នើរាយការណ៍ជូនសមមិត្ត យ៉ា ។ សុំជំរាបសមមិត្ត យ៉ា ផងថា បញ្ហានេះ ខ្ញុំឯកភាពជាមួយអង្គការហើយ អំពីគោលការណ៍ការពារកន្លែងដែលវាមកបោះថ្មី និងគោលការណ៍វាយសំរុកដើម្បីការពារ ព្រោះវាមកបោះខុសកិច្ចព្រមព្រៀងថា អ្នកនៅកន្លែងណា នៅកន្លែងនោះសិន មិនតែប៉ុណ្ណោះ វាចូលមកវាយយើងក្នុងដីយើងទៀត ដូចកាលពីថ្ងៃ២២-៧-៧៦ នេះស្រាប់ ។ បើយើងមិនវាយសំរុកវា មុខជាវាឆ្លក់វាយសំរុកយើងតទៀត ។

៤) បញ្ហាលើកទំនប់និងជីកប្រឡាយ ខ្ញុំសុំយល់ស្របនិងមានសេចក្តីរីករាយ ។

ភាតរភាពបដិវត្តកក់ក្តៅបំផុត

៨៩

**ចម្លងជូនៈ** បង៨១ បងណាត បងសោម ឯកសារ

# អតីតកាលមិនជ្រះស្រឡះ ប៉ះពាល់ដល់នីតិរដ្ឋកម្ពុជា

សង្គ្រាមត្រជាក់បានផុតរលត់ទៅ ។ សហភាពសូវៀតត្រូវដួលរលំនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ហើយមុននេះបន្តិចគឺការចូលមកដល់ប្រទេសកម្ពុជារបស់កងទ័ពវៀតណាមដែលរុញច្រានអង្គការចាត់តាំងនយោបាយខ្មែរក្រហមទៅដល់ព្រំដែនខ្មែរ-ថៃ ។ រដ្ឋនានាក្រោមចំណុះអតីតសហភាពសូវៀតបានបំបែកគ្នាដោយទទួលឯករាជ្យរៀងៗខ្លួន ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពដែលប្រទេសកុម្មុយនិស្តធំៗត្រូវដួលរលំយ៉ាងណាក៏ដោយ ក៏ប្រទេសចិនដែលជាមហាអំណាចដ៏ធំនៅក្នុងប្លុកកុម្មុយនិស្ត នៅតែខិតខំក្រាញនៀលឱបក្រសោបនិងខបត្តម្ភយ៉ាងសម្បើមដល់អតីតក្រុមកុម្មុយនិស្តរួមលទ្ធិដដែល ។ ប្រទេសចិនបានផ្តល់ឲ្យក្រុមខ្មែរក្រហមនូវអាវុធយុទ្ធភណ្ឌគិតជាទឹកប្រាក់ចំនួន១០០លាន ជារៀងរាល់ឆ្នាំពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។

ទោះបីជានៅពេលដែលបដិវត្តន៍និងអង្គការចាត់តាំងនយោបាយរបស់ខ្មែរក្រហមរលាយសាបសូន្យនៅចន្លោះឆ្នាំ១៩៩៦-១៩៩៨ គឺពេលដែលមេដឹកនាំកំពូលៗរបស់ខ្មែរក្រហមចុះចូលជាមួយរដ្ឋាភិបាលកម្ពុជាច្រើនសន្ទឹកសន្ធាប់យ៉ាងណាក៏ដោយ ក៏សាធារណរដ្ឋប្រជាមានិតចិននៅតែសម្តែងនូវការមិនពេញចិត្តចំពោះរាល់ការផ្តួចផ្តើមគំនិតបង្កើតតុលាការកាត់


ខៀវ សំផន

ទោសខ្មែរក្រហមជានិច្ច ។ តើអនាគត "នីតិរដ្ឋ" របស់ប្រទេសកម្ពុជានឹងក្លាយជាយ៉ាងណា ក្នុងខណៈដែលអតីតកាលរបស់កម្ពុជានៅតែមិនជ្រះស្រឡះនោះ?

គិតមកត្រឹមសតវត្សរ៍ទី២១នេះ មានប្រទេសមិនតិចជាង១២ទេ ដែលបានបង្កើតគណៈកម្មការស្វែងរកការពិត ឬគណៈកម្មការដោះស្រាយការរំលោភសិទ្ធិមនុស្សពីអតីតកាល ឬគណៈកម្មការដែលមានដែនសមត្ថកិច្ចប្រហាក់ប្រហែលគ្នានេះ ទោះជាលក្ខណៈរដ្ឋឬលក្ខណៈអង្គការក្រៅរដ្ឋាភិបាលក្តី ។ ទង្វើបែបនេះ វាជាការប្រពៃណាស់ក្នុងការរំលត់កំហឹងចងពៀរព្យាបាទ មិនចេះចប់មិនចេះហើយ អារម្មណ៍មិនអស់ចិត្ត និងស្រពេចស្រពិលចំពោះអ្វីដែលកើតឡើងចំពោះជាតិនិងប្រជាជនរបស់ប្រទេសមួយដែលទទួលរងនូវការរំលោភសិទ្ធិមនុស្ស ។ ប្រទេសទាំងនោះរួមមាន ប្រទេសអាហ្សង់ទីន ប្រទេសប៊ុលហ្គារី ប្រទេសឆាដ ប្រទេសឈីលី ប្រទេសអែលសាវ៉ាឌ័រ ប្រទេសអេត្យូពី ប្រទេសហុងគ្រី ប្រទេសម៉ិកស៊ិក ប្រទេសរ៉្វាន់ដា ប្រទេសអាហ្វ្រិកខាងត្បូង ប្រទេសអ៊ូរ៉ាហ្គាយ ជាពិសេសប្រទេសយូហ្គោស្លាវីដែលកំពុងតែដំណើររឿងក្តីប្រឆាំងនឹងលោក មីឡូសេវីក ។ ប្រទេសយូហ្គោស្លាវីត្រូវបានសន្យាផ្តល់នូវជំនួយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ជាថ្នូរនឹងការយកជនជាប់ចោទ មីឡូសេវីក មកកាត់ទោសនៅមុខតុលាការអន្តរជាតិពីបទឧក្រិដ្ឋសង្គ្រាម ។

ចំពោះករណីប្រទេសកម្ពុជាវិញ តុលាការប្រជាជនបដិវត្តកម្ពុជាបានចាប់ផ្តើមវិនិច្ឆ័យទោស ប៉ុល ពត, អៀង សារី ដោយត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងៗទៀតដែលមានចរិតអន្តរជាតិផ្សេងៗទៀត ។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩សវនាការតុលាការនេះបានប្រព្រឹត្តទៅនៅអតីតសាលសន្និសីទចតុមុខ ដោយមានតំណាងគ្រប់ខេត្ត ក្រសួង មន្ទីរ អង្គការមហាជន ព្រះសង្ឃ ព្រមទាំងពលរដ្ឋសាមញ្ញ សរុបជាង៦០០

នាក់ចូលរួម ។ ការណ៍ដែលគួរឲ្យកត់សម្គាល់សម្រាប់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺការចូលរួមពីសំណាក់អ្នកច្បាប់អន្តរជាតិមួយចំនួនដូចជា ស៊ុយ ស៊ូមីអូសាគី (ជនជាតិជប៉ុន) វីតន់ជ្រា សាម៉ា (ជនជាតិឥណ្ឌា) លោក ហ្វ្រង់ស៊ីស្កូ រ៉ាំរ៉ូណាខូក អេស្ត្រាដា (ជនជាតិគុយបា) លោក ចន ប៊ែរណា គ្វីកលី (ជនជាតិអាមេរិក) អ្នកស្រី ង្វី វក់ថាញ់ (ជនជាតិវៀតណាម) រួមទាំងអង្គការអ្នកសារពត៌មានអន្តរជាតិជាច្រើនទៀត ។

ទោះបីជាមានការចូលរួមពីសំណាក់ "ភ្ញៀវអន្តរជាតិ" ដូចរៀបរាប់ខាងលើនេះក៏ដោយ ក៏ដំណើរការជំនុំជម្រះក្តីនេះទទួលការរិះគន់យ៉ាងច្រើនពីមតិអន្តរជាតិផ្សេងទៀត រហូតដល់ថាមិនអាចទទួលយកបានទៀតផង ជាពិសេសអង្គការសហប្រជាជាតិផ្ទាល់តែម្តង ដែលស្តែងចេញតាមរយៈការបន្តទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យ (និងរដ្ឋាភិបាលត្រីភាគី) រហូតមកដល់ឆ្នាំ១៩៩២ ។ មានចម្ងល់ជាច្រើនទាក់ទងនឹងទោសវនាការដែលរៀបចំឡើងដោយតុលាការប្រជាជនបដិវត្តកម្ពុជាទាក់ទងទៅនឹងច្បាប់សារធាតុ ដូចជាទំនាក់ទំនងរវាងក្រឹត្យច្បាប់លេខ០១ និងអនុសញ្ញាប្រល័យពូជសាសន៍ បញ្ហានីតិវិធីត្រឹមត្រូវទៅតាមច្បាប់ ដូចជាប្រការដែលថា តើមេធាវីការពារក្តីជនជាប់ចោទ ប៉ុល ពត និង អៀង សារី បានផ្តល់នូវការការពារក្តីប្រកបដោយប្រសិទ្ធភាពនិងអស់ពីលទ្ធភាពដែរឬទេ ហើយថាតើជនជាប់ចោទអាចមានលទ្ធភាពប្តឹងឧទ្ធរណ៍បានដែរឬទេ បញ្ហាបន្ទុកនៃភ័ស្តុតាងនិងបញ្ហាទាក់ទងមួយចំនួនធំទៀត ។

ចំណែកប្រវត្តិវិទូមួយចំនួនទាញហេតុផលថា នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អ្នកដែលស្លាប់ភាគច្រើនគឺដោយសារកង្វះជីវជាតិ ធ្វើការបាក់កម្លាំង និងជំងឺ ហើយថា ការស្លាប់នេះគឺជាលទ្ធផលប្រយោលបណ្តាលមកពីនយោបាយសេដ្ឋកិច្ចសង្គមដែលកម្ពុជាប្រជាធិបតេយ្យបានអនុវត្ត ពោលគឺមិនមែនជាការសម្លាប់ដោយចេតនាទេ ។ តើដល់ពេលណាទើបការទាញហេតុផលរបស់អ្នកច្បាប់និងប្រវត្តិវិទូអំពីប្រវត្តិសាស្ត្រនិងធម្មាធិបតេយ្យនៅកម្ពុជាត្រូវបានបញ្ចប់ ហើយការពិភាក្សាផុលផុសអំពីការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារត្រូវធ្វើឲ្យជក់នៅក្នុងគំនិតប្រជាជនខ្មែរក៏ដូចជាគំនិតរបស់ប្រមុខដឹកនាំកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិដែលមានសន្តានចិត្តចំពោះការស្តាបនានីតិរដ្ឋនិងសេដ្ឋកិច្ចនៅកម្ពុជា?

រហូតមកដល់ឆ្នាំ២០០២នេះទៀតសោត បញ្ហាយុត្តិធម៌ "តើអ្នកណាសម្លាប់អ្នកណា ហើយអ្នកណាជាអ្នកបញ្ជានិងសមគំនិតប្រព្រឹត្តអំពើឃោរឃៅអមនុស្សធម៌នៅក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩" នៅតែមិនជ្រះស្រឡះ ជនរងគ្រោះនិងជនដែលថ្នាក់ក្រោម មានអារម្មណ៍មិនស្រណុកក្នុងចិត្ត ចង់បានអ្វីដែលខ្លួនសមនឹងទទួលបាន ។ ប៉ុន្តែរឿងរ៉ាវជាប្រវត្តិសាស្ត្រក៏ដូចជាតាមផ្លូវច្បាប់នៅតែមិនទាន់ចប់សព្វគ្រប់ ដើម្បីឲ្យប្រទេសកម្ពុជាដែលកំពុងតែកសាងគ្រឹះនីតិរដ្ឋធ្វើដំណើរឆ្ពោះទៅអនាគតប្រកបដោយអតីតកាលជ្រះស្រឡះទេ ។ មានន័យថា ការកសាងគ្រឹះនីតិរដ្ឋមានលក្ខណៈចាំបាច់ខានមិនបានសម្រាប់កសាងសេដ្ឋកិច្ចជាតិនៃប្រទេសមួយ ។ ប្រទេសកម្ពុជាមិនសូវខុសគ្នានឹងប្រទេសមួយចំនួនធំដែលមានការរំលោភសិទ្ធិមនុស្សកាលពីអតីតកាលប៉ុន្មានទេ ។ លុះកណាតែ អតីតកាលត្រូវមេដឹកនាំព្រងើយកន្តើយធម្មាធិបតេយ្យរបស់ប្រទេសនោះក៏នឹងទ្រុឌទ្រោមទៅតាមនោះដែរ ហើយកាលបើការគោរពច្បាប់ចេះតែចុះខ្សោយទៅហើយនោះ ទោះជាខំប្រឹងអនុម័តច្បាប់"ល្អដូចមាស"រាប់ពាន់ទៀតក៏ដោយ ក៏មិនអាចកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋ អ្នកវិនិយោគទុនមកបោះទុនរកស៊ី និងភ្ញៀវទេសចរមកដើរកម្សាន្តចាយលុយ ចរិកាចូលរដ្ឋដែរ ។ ការមិនដោះស្រាយវិបត្តិដ៏ធ្ងន់ធ្ងរពីអតីតកាលជាសញ្ញាណបញ្ជាក់ថា ការមិនគោរពច្បាប់បច្ចុប្បន្នក៏មិនសូវជាមានបញ្ហាប៉ុន្មានដែរ ។

ហេតុដូច្នេះ ការគិតគូរដោះស្រាយវិបត្តិ ជាអាយុជីវិតនិងការប៉ះពាល់ដល់សតិអារម្មណ៍ប្រជាជនកម្ពុជាពីអតីតកាលនិងមានឥទ្ធិពលដល់បច្ចុប្បន្នកាល គឺពិតជាអាចជួយស្តាបនានិងពង្រឹងថែមនូវនីតិរដ្ឋក្មេងខ្ចីរបស់កម្ពុជា ។ ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋកម្ពុជា ពិតជាធ្វើឲ្យអ្នកដឹកនាំប្រទេសកម្ពុជាមានឱកាសកាន់តែច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសន្តិភាពនៅក្នុងប្រទេស និងរួមចំណែកដល់ការពង្រឹងនីតិរដ្ឋ សន្តិសុខ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងភូមិភាគអាស៊ី-អាគ្នេយ៍ទៀតផង ។

**សូ ប៊ុនស៊ូ**

# យុត្តិធម៌អន្តរកាលនៅកម្ពុជា

ខ្ញុំបានអានរបាយការណ៍ចុងក្រោយបំផុតរបស់តំណាងពិសេសអគ្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដាក់ជូនមហាសន្និបាតអគ្គការសហប្រជាជាតិចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០២ ។ នៅក្នុងរបាយការណ៍នោះខ្ញុំបានសង្កេតឃើញថា ភាសាដែលប្រើសម្រាប់យុត្តិធម៌អន្តរកាលហាក់ដូចជាបានវិលវិលគើមៗមកហើយ ។ ឃើញទេ! ខ្ញុំគិតថាគេចង់ឲ្យកម្ពុជាមានគណៈកម្មការស្វែងរកការពិតមួយ ។ ដូចនេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ក្នុងការអានសរុបឲ្យឆាប់ចប់ក្រោយពីប្រធានាធិបតីអាហ្វ្រិកខាងត្បូង បូថា បេគី ចូលរួមគំនិតជាមួយកម្ពុជាអំពីរូបមន្តរបស់ប្រទេសលោក សម្រាប់ប្រទេសនានាដែលមានអាថ៌កំបាំងដ៏ខ្មៅងងឹត ពោលគឺគណៈកម្មការស្វែងរកការពិតមួយ ។

ប្រការនេះបង្កើបជាតម្រុយសំខាន់ថ្មីមួយសម្រាប់ប្រទេសកម្ពុជា ។ សំណួរសួរថា តើត្រូវធ្វើយ៉ាងដូចម្តេចទៅ បើជម្រើសដ៏គួរឲ្យប៉ងប្រាថ្នារបស់សង្គមនិងច្បាប់សម្រាប់យុត្តិធម៌និងការទទួលខុសត្រូវតាមរយៈប្រព័ន្ធយុត្តិធម៌(តុលាការអន្តរជាតិ) មិនបានសម្រេច ហើយជម្រើសទីពីរទៀតសោត (តុលាការចម្រុះដោយមានការចូលរួមពីសំណាក់អគ្គការសហប្រជាជាតិ) មិនទទួលបានផ្លែផ្កានោះ? តើមានអ្វីកើតឡើងប្រសិនបើគ្មានទាំងជម្រើសទីបី(តុលាការចម្រុះដែលគ្មានការចូលរួមពីសំណាក់អគ្គការសហប្រជាជាតិ ប៉ុន្តែចូលរួមពីបុគ្គលិកដែលតែងតាំងដោយរដ្ឋនានា) និងជម្រើសទីបួន(តុលាការក្នុងស្រុកសុទ្ធសាធ) មិនចេញជារូបរាងនោះ? តើត្រូវដេកសុបិនតែរហូតទៅឬចេះតែសន្យាមិនចេះចប់មិនចេះហើយទៅឬ? នៅពេលណាទើបចាប់ផ្តើមរកជម្រើសថ្មី?

យុត្តិធម៌អន្តរកាល គឺជាគំរូយុត្តិធម៌អន្តរកាលថ្មីមួយដែលផ្តោតសំខាន់ទៅលើប្រទេសនានា ដែលរើបម្រះខ្លួនផុតពីមត៌កនៃការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរក្រោមរបបផ្តាច់ការ និងផ្តោតសំខាន់ទៅលើវិធីក្នុងការទប់ទល់ដោះស្រាយជាមួយនឹងផលវិបាកចេញពីយុត្តិធម៌នេះ ។ យុត្តិធម៌អន្តរកាលសន្មតជាការពិតថា ប្រជាជាតិដែលស្ថិតនៅក្នុងស្ថានភាពបែបនេះមានជនរងគ្រោះរាប់ពាន់និងជនដៃដល់រាប់ពាន់នាក់ ។ ប្រទេសទាំងនេះ ជាទូទៅច្រើនតែមានប្រព័ន្ធយុត្តិធម៌ខ្សោយ គ្មានស្ថិរភាព និងពោរពេញទៅដោយគំនាបសង្កត់ផ្សេងៗទៀត ដែលតម្រូវឲ្យរិះរកមធ្យោបាយនិងជម្រើសផ្សេងទៀតក្រៅពីយុត្តិធម៌បទអាជ្ញាតាមផ្លូវតុលាការដើម្បីសម្រេចបាននូវលំនឹងនៅក្នុងសង្គម ។ ដូច្នេះយុត្តិធម៌អន្តរកាលជួនកាល ត្រូវគេនិយាយថាជាបញ្ហា "នយោបាយអន្តរកាល" ។

គណៈកម្មការស្វែងរកការពិតត្រូវបានផ្សព្វផ្សាយកាន់តែខ្លាំងឡើងៗជុំវិញពិភពលោកថា ជាយន្តការដ៏ល្អបំផុតសម្រាប់ដោះស្រាយបញ្ហាយុត្តិធម៌នៅក្នុងសម័យអន្តរកាល ។ គណៈកម្មការស្វែងរកការពិតគឺជាគណៈកម្មការស្វែងរកអង្គហេតុដោយមានគោលបំណងបម្រើឲ្យនយោបាយសង្គម ។ គណៈកម្មការប្រភេទនេះគឺបានយកគំរូតាមប្រទេសអ៊ូហ្គង់ដា នៅឆ្នាំ១៩៧៤ ។ មធ្យោបាយនេះកាន់តែមានប្រជាប្រិយភាពថែមទៀតនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ នៅអាមេរិកខាងត្បូង ជាពិសេសក្រោយពេលប្រទេសអាហ្សង់ទីនបង្កើតគណៈកម្មការជាតិសម្រាប់ជនបាត់ខ្លួន ដើម្បីស៊ើបអង្កេតពីជោគវាសនារបស់បុគ្គលរាប់ពាន់នាក់ដែលបានបាត់ខ្លួននៅក្នុងអំឡុងពេលនៃការកាន់កាប់អំណាចបែបផ្តាច់ការយោធា ។ មកទល់នឹងពេលនេះ មានគណៈកម្មការប្រមាណជាង៣០ហើយ ។ សូមជម្រាបជូនដោយសង្ខេបថា ភាសា"ការពិត" និង "ផ្សះផ្សា" បានចូលខ្លួនមកហើយ ដោយសារអត្ថិភាពនៃគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាជាតិអាហ្វ្រិកខាងត្បូង ឥឡូវនេះការពិភាក្សាវែកញែកគ្នាផ្តោតសំខាន់

អំពីកត្តាដែលត្រូវបញ្ចូលទៅក្នុងការធ្វើវិនិច្ឆ័យមានដូចជា “ការអត់ឱន” “ការផ្សះរបួស” “ការជាសះស្បើយ” “ការធ្វើឲ្យប្រសើរឡើងវិញ” ជាដើម ។ ប្រជុំស័ព្ទបច្ចេកទេសទាំងនេះ បង្ហាញពីជំហានមួយឃ្លាតចាកពីប្រព័ន្ធច្បាប់ និងជាការទាញយកបទពិសោធន៍ដែលផ្តោតសំខាន់ទៅលើជនរងគ្រោះនៅអាហ្វ្រិកខាងត្បូង មានដូចជា ការពិគ្រោះឲ្យដំបូន្មានអំពីការប៉ះទង្គិចអារម្មណ៍ខ្លាំងនិងសាសនាជាដើម ។

ការពិភាក្សាវែកញែកទៅលើអ្វីដែលនឹងត្រូវធ្វើនៅប្រទេសកម្ពុជាចាំបាច់ត្រូវតែមានតុល្យភាពជាមួយនឹងពត៌មាន ។ មានសំណេរជាលក្ខណៈសិក្សាស្រាវជ្រាវជាច្រើនស្តីអំពីយុត្តិធម៌អន្តរកាល ។ គណៈកម្មការស្វែងរកការពិតគឺគ្រាន់តែជាជម្រើសមួយក្នុងបណ្តាជម្រើសដ៏ច្រើនផ្សេងទៀត ។ ជម្រើសទាំងនោះមានអ្នកគាំទ្រនិងអ្នកមិនគាំទ្រ ។ មានការនិយាយនិងសរសេរជាច្រើនទៅលើតួនាទីដ៏សំខាន់ដែលជនរងគ្រោះទទួលបាននៅក្នុងវេទិកានេះនិងស្តីអំពីវិធីធ្វើយ៉ាងដូចម្តេច ដើម្បីបញ្ចប់ដោយមានការផ្តល់“ការពិត”ផង ។ អ្នកខ្លះមានអំណះអំណាងថា ប្រការនេះបង្កើតជាក្របខណ្ឌមួយសម្រាប់ស្ថាបនាឡើងវិញនូវរដ្ឋ សហគមន៍ គ្រួសារ និងបុគ្គលដែលបាក់បែកប្រេះឆា ។ មានការកត់សម្គាល់ថា គណៈកម្មការស្វែងរកការពិតអាចបញ្ចៀសការគាបសង្កត់កុំឲ្យធ្លាក់មកលើប្រព័ន្ធយុត្តិធម៌ដែលមានលក្ខណៈផុយស្រួយ ។ ផ្ទុយទៅវិញ មនុស្សជាច្រើនមានការព្រួយបារម្ភថា ការរំពឹងទុកដែលបង្កើតដោយភាសាប្រើនៅក្នុងដំណើរការរបស់គណៈកម្មការស្វែងរកការពិតគឺមានលក្ខណៈមិនប្រាកដប្រជា ហើយការប្រើពាក្យ “ការពិត” និង “ផ្សះផ្សា” មិនចេញពីប្រព័ន្ធយុត្តិធម៌នៃបទអាជ្ញាឡើយ ។ មានការព្រួយបារម្ភអំពីការឲ្យយោបល់ទាំងស្រុងថា តុលាការដែលវិនិច្ឆ័យតែទៅលើអង្គច្បាប់មិនផ្តល់នូវផ្លូវសម្រាប់ឲ្យជនរងគ្រោះសម្តែងចេញនូវអារម្មណ៍ខ្លួនឯង ឬផ្លូវសម្រាប់ផ្តល់នូវយុត្តិធម៌ដ៏គួរឲ្យពេញចិត្តឡើយ ។ ការអះអាងដែលថា គណៈកម្មការស្វែងរកការពិត គឺជាទម្រង់មួយនៃការទទួលខុសត្រូវនោះត្រូវបានមនុស្សមួយចំនួនយល់ឃើញដោយមិនជឿទៅតាមមតិទូទៅទាល់តែសោះ ។ អ្នកខ្លះទៀតជំទាស់យ៉ាងដាច់ណាត់ទៅនឹងវិធាននៃច្បាប់ទន់ជ្រាយ ហើយមើលឃើញថាជាជំហានមួយប្រាសចាកពីគោលការណ៍ជាសារវន្តនៃការជំនុំជម្រះក្តីនៅតុលាការនូរីមប៊ឹក ដែលក្នុងពេលនោះ ចារីជាបុគ្គលប្រព្រឹត្តអំពើឃោរឃៅ ចាំបាច់ត្រូវតែទទួលខុសត្រូវដាច់ខាតចំពោះទង្វើរបស់ផងខ្លួន ។ ចលនាសិទ្ធិមនុស្សពិភពលោកបានផ្តោតការយកចិត្តទុកដាក់អស់ច្រើនទសវត្សរ៍មកហើយ ទៅលើការប្រើការទទួលខុសត្រូវលើបទអាជ្ញាជាបុគ្គល ដើម្បីផ្តល់នូវការការពារជាអតិបរមាដល់សិទ្ធិរបស់បុគ្គល ហើយមានមនុស្សជាច្រើនទាក់មានចំណាប់អារម្មណ៍ ថាតើគំរូថ្មីនេះនឹងដឹកនាំទៅតាមផ្លូវណា ។

គណៈកម្មការស្វែងរកការពិតរបស់អាហ្វ្រិកខាងត្បូង ដែលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងនោះ គឺគួរឲ្យចាប់អារម្មណ៍មែនទែន ។ បទពិសោធន៍ដ៏កម្ររបស់អាហ្វ្រិកខាងត្បូងកើតចេញពីការសម្របសម្រួលខាងនយោបាយ ។ គណៈកម្មការស្វែងរកការពិត និងការលើកលែងទោស គឺជាតម្លៃនៃការឆ្លងកាត់ប្រកបដោយសន្តិវិធីចេញពីរបបអាប៉ាថេត ។ ប្រទេសនេះស្ទើរតែធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលទៅហើយ ។ តាមបទដ្ឋាននៃច្បាប់អន្តរជាតិ ការលើកលែងទោសចំពោះចារីដែលប្រព្រឹត្តបទល្មើសរើសអើង ដែលជាសញ្ញាដ៏ច្បាស់ក្រឡែតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះអ្នកប្រព្រឹត្តិអំពើឃាតកម្មជាទ្រង់ទ្រាយធំ និងឧក្រិដ្ឋជនមានកម្រិតអាជ្ញាប្រហាក់ប្រហែលនេះ គឺជាការរំលោភដល់កាតព្វកិច្ចជាអន្តរជាតិ ។ ក៏ប៉ុន្តែសហគមន៍អន្តរជាតិបានសម្រេចចិត្តមើលរំលងបញ្ហានេះ ដោយសារមានការទទួលស្គាល់អំពីជម្រើសដ៏ពិបាកគេចបំផុតថា រឿងក្តីនោះគឺមានតែមួយគត់សម្រាប់ដោះស្រាយស្ថានការណ៍រាំងស្ទះរបស់អាហ្វ្រិកខាងត្បូង ហើយគឺជាកិច្ចប្រឹងប្រែងពិតៗក្នុងការដោះស្រាយជាមួយនឹងមត៌កនៃអំពើឃោរឃៅមួយ ។ ការផ្តល់នូវការលើកលែងទោសជាពិសេស ត្រូវបានមនុស្សជាច្រើនចាត់ទុកថាជាការដោះស្រាយប្រកបដោយការគិតគូរជ្រៅជ្រះ និងមានការទទួលខុសត្រូវ ។ ការអនុវត្តការលើកលែងទោសចំពោះបុគ្គលម្នាក់ៗ សុទ្ធតែមានលក្ខខណ្ឌច្បាស់លាស់ មិនមែនលើកលែងទោសទទេៗនោះទេ ពោលគឺដើម្បីប្តូរមកវិញនូវការបញ្ចប់រឿងរ៉ាវឲ្យបានជ្រះស្រឡះ ។ ប៉ុន្តែមិនមែនគ្រប់គ្នា(រួមទាំងនៅអាហ្វ្រិកខាងត្បូងផង) សុទ្ធតែ

ចាត់ទុកថានេះជាជោគជ័យនោះទេ ។ មានអ្នកខ្លះយល់ឃើញថា វាគ្រាន់តែជាការកែរោគក្នុងការនិយាយចេញជាសាធារណៈនូវការឈឺចាប់និងទុក្ខវេទនារបស់ខ្លួន ។ ប៉ុន្តែមានមនុស្សច្រើនទៀតដែលមិនបានគិតដូច្នេះទេ ។ តាមការពិត មានមនុស្សច្រើននាក់នៅអាហ្វ្រិកខាងត្បូងមានកំហឹងនិងឈឺចាប់ដោយសារតែមេដឹកនាំរបស់ខ្លួនសម្រេចចិត្តធ្វើការតថ្លៃជាមួយជនដែលប្រព្រឹត្តអំពើឃោរឃៅ សូម្បីតែផ្តល់នូវការលើកលែងទោសជាថ្នូរនឹង«ការពិត» ដែលគេជឿថាជាកម្មសិទ្ធិដាច់មុខរបស់ខ្លួន ជាជាងកាត់បន្ថយតម្លៃតាមប្រពៃណីនៃការផ្តល់នូវ«ការពិត» នៅចំពោះមុខតុលាការ ។ មានអ្នកខ្លះបានលើកឡើងអំពីការដែលគណៈកម្មការនេះខកខានមិនបានធានាឲ្យមានការគាំទ្រដល់ជនជាតិអាហ្វ្រិកខាងត្បូងដែលបានប្រឡូកប្រឡាក់ជាមួយនឹងរបបអាប៉ាថេតនោះដែរ ។ ដោយសារថា ភាគច្រើននៃបុគ្គលដែលស្វះស្វែងផ្តល់នូវពត៌មានជាថ្នូរនឹងការលើកលែងទោសនោះ តាមពិត គឺជាជនជាតិអាហ្វ្រិកខាងត្បូងស្បែកខ្មៅ ។ មានមនុស្សមួយចំនួនទៀត បានចោទសួរអំពីតួនាទីដ៏សកម្មរបស់ព្រះវិហារគ្រិស្ត ថាតើជនរងគ្រោះជាច្រើនត្រូវបានគាបសង្កត់សុខចិត្ត «អត់ឱន» និង «ផ្សះផ្សា» ជាមួយជនដៃដល់មុនពេលត្រូវរៀបចំខ្លួនមែនឬ? ។

ការសិក្សានានាបានសឲ្យឃើញថា គណៈកម្មការស្វែងរកការពិតជាច្រើន យ៉ាងហោចណាស់មានគោលបំណងសំខាន់បួនគឺ÷ បង្កើតនូវឯកសារប្រវត្តិសាស្ត្រសុក្រឹត រកយុត្តិធម៌ឲ្យជនរងគ្រោះ សម្រួលដល់ការផ្សះផ្សានិងបង្ការមិនឲ្យមានការរំលោភបំពាននិងទុក្ខទោសជាថ្មីទៀត ។ កិច្ចការជាច្រើនអំពីបញ្ហាទាំងនេះត្រូវបានធ្វើរួចទៅហើយនៅប្រទេសកម្ពុជា ឧទាហរណ៍ជាក់ស្តែងគឺមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទាល់តែម្តង ។ គោលបំណងរបស់មជ្ឈមណ្ឌលនេះគឺចងក្រង និងអភិរក្សប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមសម្រាប់យុវវ័យជំនាន់ក្រោយៗ ហើយប្រមូលផ្តុំ និងរៀបចំពត៌មានដែលអាចយកមកប្រើជាភស្តុតាងប្រកបដោយសក្តានុពលនៅក្នុងការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់នូវឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ របាយការណ៍ការងារប្រចាំឆ្នាំ២០០១ របស់មជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា «គោលដៅទាំងនេះបង្ហាញពីការលើកតម្កើងនូវការចងចាំនិងយុត្តិធម៌ ដែលប្រការទាំងពីរនេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់នីតិរដ្ឋ និងការបង្រួបបង្រួមផ្សះផ្សាជាតិនៅកម្ពុជា» ។ ជាមួយនឹងទិន្នន័យដ៏ច្រើនសន្ធឹកសន្ធាប់ «ការពិត»ច្បាស់ជាមាននៅក្នុងនោះមិនខាន ។ ក៏ប៉ុន្តែកិច្ចការនេះ ដំណើរការទៅបានល្អជាងការកសាងសំណុំរឿងនិងការប្រមូលភស្តុតាងសម្រាប់ប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះក្តីទៅទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយដល់ការស្វែងរកគ្រួសារសាច់ញាតិ មិត្តភក្តិ ធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅ និងអភិវឌ្ឍការយល់ដឹងអំពីរបបខ្មែរក្រហម ហើយបានបណ្តុះបណ្តាលជនជាតិខ្មែរឲ្យមានជំនាញឯកទេសជាច្រើនដែលមានផលប្រយោជន៍ ។ កិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានអានុភាពយ៉ាងប្រសើរចំពោះយុត្តិធម៌សង្គមនិងការបង្កើតសង្គមមួយឲ្យមានលក្ខណៈកាន់តែប្រសើរជាងមុន តាមរយៈការយល់ដឹងពីអតីតកាល ។ នៅក្នុងការបោះផ្សាយថ្មីៗនេះ សឲ្យឃើញថា «ឥទ្ធិពលមកពីការរំសាយអារម្មណ៍ជួយនាំមកនូវការផ្លាស់ប្តូរនៅក្នុងប្រទេសកម្ពុជាម្តងម្នាក់ៗ បន្តិចម្តងៗ យូរៗទៅនឹងជះឥទ្ធិពលដល់ការសម្រួលដល់ការផ្សះផ្សាជាតិនៅគ្រប់ទីស្ថានទូទាំងប្រទេសកម្ពុជា» ។

ពេលអានទៅឃើញថា មានគណៈប្រតិភូកម្ពុជាមួយក្រុមបានធ្វើដំណើរទៅប្រទេសអាហ្វ្រិកខាងត្បូងរៀនសូត្រអំពីគណៈកម្មការស្វែងរកការពិតរបស់ប្រទេសនេះ នាងខ្ញុំសង្ឃឹមដោយស្មោះថា គណៈប្រតិភូនេះក៏នឹងធ្វើដំណើរទៅ ឆើឈីលបេ្ងន១ នៅទីក្រុងឡាអេ ដែលជាកន្លែងតាំងនៅរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដើម្បីទៅមើលយុត្តិធម៌ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់សម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា ។ គណៈប្រតិភូក៏គួរតែមើលនូវកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសរ្វ៉ាន់ដាដែលចុះក្រ ពោលគឺក្នុងខណៈដែលមានជនសង្ស័យថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលកំពុងតែស្រពាប់ស្រពោននៅក្នុងគុក ប្រទេសរ្វ៉ាន់ដាកំពុងតែព្យាយាមជំនុំជម្រះក្តីជាច្រើនតាមរយៈការប្រើប្រាស់ប្រកបដោយប្រឌិតញាណ នូវយន្តការដោះស្រាយជម្លោះជាលក្ខណៈប្រពៃណីដែលមានឈ្មោះថា «ហ្កាចាចា» ។ មានការព្រួយបារម្ភស្រប

ច្បាប់ទៅលើដំណើរការរឿងក្តីនេះ ប៉ុន្តែទោះបីជាល្អក្តី អាក្រក់ក្តី វ៉ាន់ដាគឺជាការបង្ហាញនូវការប៉ុនប៉ងជាលក្ខណៈរដ្ឋក្នុងការប្រើប្រាស់វិធាននៃច្បាប់ ដើម្បីបង្កើតនូវអនាគតកាលក្រោយជម្លោះទៅតាមវិធីមួយដែលមានគោលការណ៍ច្បាស់លាស់ ។ កិច្ចការរបស់គណៈកម្មការជាច្រើនផ្សេងទៀតគួរតែយកមកគិតពិចារណាដែរ ។ បន្ទាប់មកចូរមើលកិច្ចខិតខំប្រឹងប្រែងថ្មីៗនេះនៅទីម័រខាងកើត មានក្រុមអ្នកច្បាប់ចម្រុះដែលមានចៅក្រមជំនុំជម្រះបទឧក្រិដ្ឋអន្តរជាតិ និងគណៈកម្មការស្វែងរកការពិត ។ គណៈកម្មការនេះគឺជាគំរូទំនើបមួយដែលស្ថិតក្រោមទម្រង់ប្រព័ន្ធយុត្តិធម៌នៃបទអាជ្ញាគ្មានការលើកលែងទោស ចំពោះអំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ។ល ។ ការលើកលែងទោសទាំងឡាយត្រូវតែមានការអនុម័តយល់ព្រម (តាមផ្លូវតុលាការ) និងការប្រើយន្តការយុត្តិធម៌អន្តរកាល ។ បន្ទាប់មកទៀតចូរពិនិត្យមើលប្រទេសឥណ្ឌូនេស៊ីដែលនៅជិតខាង ។ ប្រទេសឥណ្ឌូនេស៊ីមានបញ្ហាទៅលើចំណុចដែលត្រូវដោះស្រាយជាមួយនឹងមត៌កដ៏ធំធេង បន្សល់ទុកដោយការគាបសង្កត់ជាង៣៤ឆ្នាំក្រោមរបបដែលគេឲ្យឈ្មោះថា «របៀបរៀបរយថ្មី» ។ បញ្ហានេះមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ ចំណែកឯសេចក្តីព្រាងច្បាប់ ស្តីអំពីគណៈកម្មការស្វែងរកការពិតដែលមានឥទ្ធិពលយ៉ាងធ្ងន់ពីគំរូរបស់អាហ្វ្រិកខាងត្បូងនោះត្រូវទទួលការរិះគន់យ៉ាងចាស់ដៃថា មានលក្ខណៈមិនសមស្របទៅនឹងប្រទេសនេះ ។ បន្ទាប់មកទៀត គឺនិយាយអំពីប្រទេសសេរ៉ាឡេអូនម្តង ដែលតុលាការពិសេសនិងគណៈកម្មការបានចាប់ផ្តើមដំណើរការទើបតែថ្មីៗនេះ ។ ប្រទេសនេះកំពុងតែពិសោធន៍ជាមួយនឹងការប្រើយន្តការយុត្តិធម៌ជាលក្ខណៈប្រពៃណី និងជាមធ្យោបាយឈានទៅរកការបង្រួបបង្រួមផ្សះផ្សាជាតិ ។

មានមេរៀនមួយដែលមានតម្លៃមិនអាចកាត់ថ្លៃបានមកពីអាហ្វ្រិកខាងត្បូង ។ គឺមេរៀននេះហើយ (រួមផ្សំជាមួយនឹងឆន្ទៈនយោបាយ សេចក្តីស្មោះត្រង់ និងការគិតប្រកបដោយភាពច្នៃប្រឌិត) ដែលប្រទេសមួយអាចកែខៃយ៉ាងប៉ិនប្រសប់នូវវិធីក្នុងការដោះស្រាយជាមួយនឹងមត៌កនៃការរំលោភសិទ្ធិមនុស្ស ហើយធ្វើដូច្នេះតាមវិធីដែលប្រកបដោយការទទួលខុសត្រូវ និងមានខ្លឹមសារ ។ កម្ពុជាគួរតែក្រឡេកមើលប្រទេសនានាជុំវិញខ្លួន ថាគេកំពុងធ្វើអ្វី ប៉ុន្តែចាំបាច់មិនត្រូវចូលរួមជាមួយនឹងវិធីដោះស្រាយតាមរយៈយុត្តិធម៌អន្តរកាលនោះទេ ។ ពីព្រោះថាវិធីមួយដែលប្រើហើយមានជោគជ័យខ្លះៗនៅប្រទេសមួយដែលមានស្ថានការណ៍ខុសពីគេឯង ឬដែលបង្ហាញជូនតាមរយៈម្ចាស់ជំនួយសំខាន់ៗថាជាយន្តការសមស្រប មិនមានន័យថាវាសមស្របសម្រាប់ប្រទេសកម្ពុជានោះទេ ។ កម្ពុជាមានតម្រូវការចាំបាច់របស់ខ្លួនផ្ទាល់ ដែលតម្រូវការមួយក្នុងចំណោមតម្រូវការទាំងនោះគឺការកែទម្រង់ដ៏ជុំកំភួន និងពង្រឹងដល់ផ្នែកយុត្តិធម៌របស់ខ្លួន ព្រមទាំងការពារនីតិរដ្ឋក្នុងការដាក់ឲ្យបុគ្គលទាំងឡាយទោះបីជាមានឋានៈ និងឥទ្ធិពលប៉ុនណាក៏ដោយ ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ។ ភាពរួចទោសមិនចេះតែបន្តទៅមុខឥតឈប់នោះឡើយ បើបណ្តោយឲ្យធ្វើដូច្នេះ វានឹងបំពុលជីវិតរស់នៅរាល់ថ្ងៃ និងបំផ្លាញយុវវ័យជំនាន់ក្រោយមិនខានឡើយ ។

សូមបងចាំឲ្យច្បាស់ថា កាតព្វកិច្ចរបស់រដ្ឋគឺត្រូវស៊ើបអង្កេតវិនិច្ឆ័យទោស និងផ្តន្ទាទោសចារីដែលប្រព្រឹត្តអំពើឃោរឃៅ ហើយប្រសិនបើធ្វើដូច្នេះមិនបាន ត្រូវបញ្ជូនខ្លួនទៅដល់ប្រទេសទីបីដែលមានសុឆន្ទៈចង់អនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនក្នុងការវិនិច្ឆ័យទោសឧក្រិដ្ឋជនទាំងនោះ ។ ប្រហែលជាដល់ពេលដែលរដ្ឋនានាដែលគាំទ្រដល់យុត្តិធម៌ចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តដោយខ្មែរក្រហម គិតគូរពិចារណាអនុវត្តដែនសមត្ថកិច្ចសកលរបស់ផងខ្លួនតាមរយៈតុលាការរបស់ខ្លួនផ្ទាល់ហើយ ។ ទន្ទឹមនឹងនេះដែរ ប្រហែលជាថាគ្រាប់ពូជបណ្តុះឲ្យបាននូវដំណោះស្រាយពិសេស គឺស្ថិតនៅលើការពិភាក្សាទូទាំងប្រទេសទៅលើវិធីធ្វើយ៉ាងណាប្រើធនធានដែលមានស្រាប់ឲ្យអស់លទ្ធភាព និងដោះស្រាយការលំបាកដែលកំពុងតែបន្តកើតមានក្នុងការដោះស្រាយឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម ។

**ស៊ូហ្សាណា លីនគុន**

> **◆ ធ្វើការច្រើន ទទួលផលច្រើន តែចំណាយទុនតិច។**
>
> *(យុវជន-យុវនារីបដិវត្ត លេខ D ២១៣៨៨)*

# ពាក្យបណ្តឹង

## (បញ្ជូនមកពីអង្គការសិទ្ធិមនុស្សសហប្រជាជាតិប្រចាំនៅកម្ពុជា)

*ខ្ញុំបាទឈ្មោះ សុខ សាន់ដេ ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិចំការហ្លួង ឃុំរាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។*

**សូមគោរពចូលមក**

*លោក-លោកស្រីប្រធានអង្គការសិទ្ធិមនុស្សសហប្រជាជាតិប្រចាំនៅកម្ពុជា និងស្ថានទូតប្រទេសនានាប្រចាំនៅកម្ពុជា ជាទីគោរព ។*

*ត្បិតខ្ញុំបាទកើតទុក្ខមិនសុខចិត្តនឹងឈ្មោះ អៀង សារី, ខៀវ សំផន, នួន ជា, ចាន់ យូរ៉ាន់, តាម៉ុក, ឌុច, ម៉ក់ បេន និងអតីតមេដឹកនាំខ្មែរក្រហមដទៃទៀត ពីបទសម្លាប់ប៉ា ពូ៣នាក់ ប្អូន តា និងយាយធំរបស់ខ្ញុំម្នាក់ សរុប៧នាក់ និងប្រជាពលរដ្ឋខ្មែរស្លូតត្រង់គ្មានកំហុសរាប់លាននាក់ទៀតដែលបានស្លាប់ក្នុងរបបខ្មែរក្រហមកាន់កាប់អំណាច៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។*

*ឯដំណើររឿងហេតុការស្លាប់របស់សមាជិកក្នុងគ្រួសារខ្ញុំទាំង៧នាក់នោះមានដូចតទៅ៖*

*ក្រោយថ្ងៃដែលខ្មែរក្រហមទទួលបានជ័យជម្នះលើរបបលោក លន់ ណុល ១៧ មេសា ១៩៧៥ ពួកខ្មែរក្រហមបានបណ្តេញប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញនិងស្រុកនានាដែលនៅជិតទីក្រុង ឲ្យទៅរស់នៅភូមិតាមជនបទស្រុកស្រែចម្ការ ក្នុងនោះក៏មានក្រុមគ្រួសារខ្ញុំដងដែរ ។ ភូមិដែលខ្ញុំរស់នៅនោះគឺជ្រោយចង្វារ នៅជិតទីក្រុងភ្នំពេញ ។ ផ្ទះរបស់ខ្ញុំនៅជិតម៉ាស៊ីនទឹកជាប់នឹងមាត់ទន្លេ ។ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំបានត្រូវពួកខ្មែរក្រហមបណ្តេញចេញពីផ្ទះដោយធ្វើដំណើរតាមទូកផ្ទាល់ខ្លួនចេញពីជ្រោយចង្វារទៅឈប់សម្រាកនៅវត្តរកាកោង បន្ទាប់មកក៏បន្តដំណើរទៅឈប់នៅព្រែកពោធិ៍ ទុកទូកនៅទីនោះ រួចបន្តដំណើរតាមរទេះគោទៅកាត់តាមព្រៃឫស្សីទឹកព្រែកទាំងថ្ងៃទាំងយប់ សម្រាកខ្លះពេលហូបបាយ រួចបន្តដំណើររហូតដល់ភូមិដែលពួកខ្មែរក្រហមឲ្យរស់នៅ ។ ទៅដល់ដំបូង គេឲ្យក្រុមគ្រួសាររបស់ខ្ញុំស្នាក់នៅក្នុងព្រះវិហារក្នុងវត្តព្រៃសុវណ្ណហៅព្រៃស្វា ។ ស្នាក់នៅក្នុងព្រះវិហារបានមួយយប់ ពួកប្រធានភូមិបានហៅក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅស្នាក់នៅក្រោមផ្ទះអ្នកភូមិ គ្មានជញ្ជាំងបិទបាំងទេ ភូមិនោះឈ្មោះភូមិព្រៃស្វា ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ។*

*ស្នាក់នៅក្រោមផ្ទះនោះបានប្រហែល៥ថ្ងៃ ប្អូនរបស់ខ្ញុំអាយុ៣ឆ្នាំបានផឹកទឹកឆៅដែលគ្មានទសដាំនោះ ក៏កើតជំងឺរាកផងក្អួតផង ប៉ានិងម៉ាក់របស់ខ្ញុំបានដឹកប្អូនខ្ញុំទៅមន្ទីរពេទ្យឃុំ តែដោយមន្ទីរពេទ្យនោះគ្មានថ្នាំព្យាបាល ប្អូនរបស់ខ្ញុំក៏ស្លាប់នៅពេលដឹកត្រឡប់មកផ្ទះវិញ ។*

*គួរឲ្យឈឺចាប់បំផុត បន្ទាប់ពីប្អូនខ្ញុំស្លាប់បាន២-៣ថ្ងៃ ប្រធានភូមិហៅប៉ារបស់ខ្ញុំនិងអ្នកដែលជម្លៀសទៅនៅភូមិនោះដែរដែលមានអាយុប្រហែលប៉ាខ្ញុំទៅសួរប្រវត្តិរូបពីមុនធ្វើអ្វី? ប៉ារបស់ខ្ញុំក៏ប្រាប់ប្រធានភូមិនោះតាមត្រង់ថា គាត់ធ្វើទាហានជើងទឹកពាក់ស័ក្តិ៣នៅជ្រោយចង្វារ និងអ្នកដទៃទៀតក៏គេនិយាយត្រង់ពីមុខងាររផ្សេងៗដែលគេធ្វើពីមុនមកគ្រប់ៗគ្នា ។*

*ក្រោយពីសួរប្រវត្តិរូបរួចហើយ ប្រធានភូមិបានឲ្យពួកគាត់ទៅធ្វើការជាធម្មតាតាមដែលពួកវាបញ្ជា ។ ធ្វើការបាន៤-៥ថ្ងៃ ប្រធានភូមិក៏បានមកហៅប៉ាខ្ញុំដែលកំពុងត្រង់ទឹកភ្លៀង និងអ្នកដែលពួកវាសួរប្រវត្តិរូបពីថ្ងៃមុនទាំងយប់ ដោយភរថាទៅរៀនសូត្រ ពេលនោះម្តាយខ្ញុំបានរៀបចំខោអាវដាក់ក្នុងស្បោងសមួយដើម្បីឲ្យប៉ាខ្ញុំផ្លាស់ប្តូរ តែប៉ាខ្ញុំគាត់និយាយថាមិនបាច់ដាក់អ្វីទៅទេ គេហៅទៅសម្លាប់ មិនមែនទៅរៀនទេ ។ ប៉ារបស់ខ្ញុំដឹងថាគេយកទៅសម្លាប់ គាត់មិនបានរត់ទៅណាទេ ដោយខ្លាចគេធ្វើបាបម្តាយខ្ញុំ និងអ្នកដទៃទៀតនៅក្នុងគ្រួសារខ្ញុំ ។ ថ្ងៃដែលគេហៅយកប៉ាខ្ញុំទៅសម្លាប់ គាត់ស្លៀកពាក់តែមួយកំប្លេទៅប៉ុណ្ណោះ ។*

*បន្ទាប់ពីយកប៉ាខ្ញុំទៅសម្លាប់រួច ពួកប្រធានភូមិខ្មែរក្រហមបានប្រមូលយកសម្ភារដែលដាក់ទៅជាមួយសម្រាប់ប្រើប្រាស់*

ទាំងអស់ មានម៉ូតូពីរគ្រឿង ចាន ឆ្នាំង និងរបស់ផ្សេងៗជាច្រើនទៀត ប្រមូលចូលសហករណ៍ទាំងអស់ ។ រស់នៅក្នុងភូមិនោះបានរយៈពេល៣ខែ ជីតារបស់ខ្ញុំក៏មានជំងឺតែមិនធ្ងន់ប៉ុន្មានទេ តែរបបព្រៃផ្សៃនោះគ្មានថ្នាំព្យាបាល គាត់ក៏បានស្លាប់ទៅគួរឲ្យអាសូរ ។ ស្លាប់ភ្លាម ពួកប្រធានភូមិបានហៅឲ្យកូនៗរបស់គាត់យកសាកសពទៅបញ្ចុះ ។ ពេលយកសពទៅបញ្ចុះគ្មានក្តារមឈូសទេ គ្រាន់តែរុំកន្ទេលប៉ុណ្ណោះ ។ គ្រាន់តែក្នុងរយៈពេល៤ខែ សមាជិកក្នុងគ្រួសាររបស់ខ្ញុំស្លាប់ចំនួន៣នាក់ ។ ក្រោយមក ពួកវាបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅខេត្តបាត់ដំបង ដោយជិះកាណូតមកឈប់សម្រាកនៅវត្តពញាឮបាន២-៣ថ្ងៃ មានរថយន្ត២-៣គ្រឿងបានមកដឹកអ្នកជម្លៀសជាច្រើនគ្រួសារដែលនៅរង់ចាំក្នុងវត្តនោះ ឲ្យទៅជិះរថភ្លើងដើម្បីបន្តដំណើរទៅខេត្តបាត់ដំបងទៀត ។ តែដោយក្នុងក្រុមគ្រួសាររបស់ខ្ញុំមានពូខ្ញុំម្នាក់ខ្វិន ពួកវាមិនឲ្យទៅទេ ដោយពួកវានិយាយថាជិះឡានហើយជិះរថភ្លើង ចុះពីរថភ្លើងត្រូវដើរជាច្រើនគីឡូទៀតទើបដល់កន្លែងនៅមិនអាចអៀវដើរឆ្ងាយបានទេ ត្រូវរើអីវ៉ាន់ចុះពីឡានវិញ មិនឲ្យទៅទេ ។ ក្រុមគ្រួសារខ្ញុំក៏សម្រាកនៅក្នុងវត្តពញាឮនោះជាច្រើនថ្ងៃបន្តទៀត រង់ចាំកាណូតមកដឹកទៅភូមិដែលក្រុមគ្រួសាររបស់ខ្ញុំស្នាក់នៅពីមុន ។ នៅក្នុងវត្តពញាឮ ពួកវាឲ្យក្រុមគ្រួសាររបស់ខ្ញុំស្នាក់នៅក្នុងរោងដាក់មឈូសមួយដែលទុកចោលគ្មានជញ្ជាំង គ្មានគ្រែទេ ដេកផ្ទាល់ដីពេលដេកម្តងៗ ខ្ញុំសម្លឹងទៅដំបូលឃើញសុទ្ធតែមឈូសដែលគេដាក់នៅលើធ្នើរគួរឲ្យខ្លាច ។

ស្នាក់នៅក្នុងវត្តនោះជាច្រើនថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំគ្មានអ្វីហូបទេ ដើរបេះផ្ទីដែលដុះក្នុងវត្តនោះមកស្ងោរជាមួយអំបិលហូបជាមួយបបរតែប៉ុណ្ណោះ ។ ពេលកាណូតមកដឹកក្រុមគ្រួសាររបស់ខ្ញុំត្រឡប់ទៅភូមិនោះវិញ សមាជិកក្នុងក្រុមគ្រួសាររបស់ខ្ញុំឈឺទាំងអស់គ្នាងើបពីកន្ទេលលែងរួច នៅសល់តែយាយខ្ញុំម្នាក់ប៉ុណ្ណោះ ដើរទៅយកបបរពីរោងបាយសហករណ៍មកឲ្យអ្នកដែលកំពុងឈឺនោះហូប ពូខ្ញុំខ្វិននិងយាយធំរបស់ខ្ញុំឈឺជាទម្ងន់ដោយជំងឺរាកមិនឈប់ គ្មានថ្នាំព្យាបាលក៏ស្លាប់ទាំងពីរនាក់គួរឲ្យឈឺចាប់បំផុត ។

ក្រោយពីឈឺមិនទាន់ជាស្រួលបួលផង ពួកប្រធានកងចល័តបានមកហៅម្តាយខ្ញុំនិងពូខ្ញុំបីនាក់ឲ្យទៅជីកប្រឡាយ និងរែកទឹកឲ្យអ្នកនៅកងចល័តដែលកំពុងជីកប្រឡាយផឹក ដែលនៅឆ្ងាយពីភូមិប្រហែល៧គីឡូពីភូមិ រែកទឹកជារៀងរាល់ថ្ងៃ ។ លុះដល់ពាក់កណ្តាលឆ្នាំ៧៨ ពូខ្ញុំពីរនាក់ក៏ធ្លាក់ខ្លួនឈឺ គឺឈឺក្បាលជន្លក់ ហើយក៏សម្រាកនៅកន្លែងកងចល័តជាមួយអ្នកជីកប្រឡាយដែលឈឺ៤-៥នាក់ ក៏ត្រូវពួកខ្មែរក្រហមហៅយកទៅសម្លាប់នៅក្នុងវត្តព្រៃសុវណ្ណ ហៅព្រៃស្វាទាំងអស់គ្នាទៅ ដោយចោទថា ធ្វើពុតជាឈឺគេចពីការងារអង្គការ ។ សូមបញ្ជាក់ថា វត្តនោះជាទីពិឃាតមួយយ៉ាងធំ ដែលមានមនុស្សស្រីប្រុស ចាស់ក្មេង ជាច្រើននាក់ត្រូវខ្មែរក្រហមប្រមូលពីភូមិស្រុកខេត្តនានាយកមកសម្លាប់យ៉ាងសាហាវ ដោយកាប់នឹងកាំបិតផ្គាក់ ត្បូងចប គល់ឫស្សី ដែលពួកវានិយាយថា ជាប្រជាជនថ្មី ដែលមានរណ្តៅសាកសពពី៣០ទៅ៤០រណ្តៅ ដែលក្នុងមួយរណ្តៅកប់សាកសពពី២០ទៅ៣០នាក់ ។ នៅក្នុងអំឡុងខែ៩ ឆ្នាំ១៩៧៨ ទឹកឡើងធំលិចចូលវត្តនោះ សាកសពហើមឡើងប្រេះផ្ទុះ សត្វឆ្កែកាយទាញស៊ីគួរឲ្យខ្លាចផ្សារបំផុត ។

ចំណែករូបខ្ញុំដែលទើបតែមានអាយុ៧ឆ្នាំ ត្រូវពួកវាបំបែកចេញពីបងនិងម្តាយ បង្ខំឲ្យធ្វើការជាទម្ងន់ ដោយពួកវាដាស់ឲ្យក្រោកពីដេកនៅម៉ោង៤ព្រឹក លើកអាចម៍គោដាក់ស្រែដែលនៅឆ្ងាយពីភូមិ៣-៤គីឡូ រួចឲ្យទៅជីកដីលើកផ្លូវ១ម៉ែត្រគូបក្នុងមួយព្រឹកៗ រួចពេលថ្ងៃ ដឹកគោ៤ឲ្យស៊ីស្មៅតាមភ្លឺស្រែដែលមានសន្ទូងនៅអមសងខាង ត្រូវគោទាញដួលជាច្រើនដងក្នុងមួយថ្ងៃៗ ។

ល្ងាចថ្ងៃមួយ មេឃភ្លៀងរលឹមស្រិចៗ មេឃងងឹតបន្តិចទៅហើយ គោដែលខ្ញុំឃ្វាលទាំង៤ ដោយស៊ីស្មៅមិនឆ្អែត វាក៏ទាញខ្សែដែលដឹកវាមុខ២ក្រោយ២ទៅស៊ីសន្ទូងដែលនៅក្នុងស្រែ ធ្វើឲ្យខ្ញុំឈឺដៃយ៉ាងខ្លាំងក៏លែងខ្សែឲ្យវាស៊ីសន្ទូងតាមចិត្តវាទៅ ។ ដោយរងារផង ខ្លាចខ្មោចផង ព្រោះកន្លែងដែលខ្ញុំឃ្វាលគោនេះជិតកន្លែងគេដុតខ្មោច និងនៅមិនឆ្ងាយពីវត្តដែលខ្មែរក្រហមសម្លាប់មនុស្សផងខ្ញុំក៏រត់ចោលគោទាំង៤នោះទៅពួននៅក្នុងបន្ទន់មួយ នៅជិតក្រោលគោ រង់ចាំលួចមើលតើនរណាដឹកគោមកចងក្នុងក្រោល ។ នៅក្នុងបន្ទន់នោះលួចមើលមួយសន្ទុះធំទើបឃើញយាយខ្ញុំដឹកគោទាំង៤មកចងក្នុងក្រោល ។ ពេលយាយខ្ញុំចងរួច គាត់ក៏ដើរទៅផ្ទះវិញបាត់ទៅ ។ ដោយខ្ញុំឃ្លានបាយ ពេកក៏ដាច់ចិត្តចេញពីបន្ទន់នោះដើម្បីទៅរកបាយហូបនៅផ្ទះ ក៏ត្រូវប្រធានកងកុមារចាប់

ក្របួចកអាវជាប់រួចនិយាយថា អ្នែងលែងគោឲ្យស៊ីសន្ទូង អញត្រូវយកអ្អែងដាក់ក្នុងចេតិយក្នុងវត្ត ។ ពេលនោះខ្ញុំភ័យញ័រចំប្រប់ដូចជាកូនចៀមនៅក្នុងក្រញាំចចក ត្រូវប្រធានកងកុមារចាប់អូសកអាវទៅរោងបាយសហករណ៍ ។ ដើរបណ្តើរ ខ្ញុំលើកដៃសំពះបណ្តើរ ដោយនិយាយថា ខ្ញុំខ្យល់ចាប់បានជាលែងគោឲ្យស៊ីសន្ទូងដូច្នេះ អាណិតខ្ញុំផង កុំយកខ្ញុំទៅដាក់ក្នុងចេតិយអី ថ្ងៃក្រោយខ្ញុំឈប់ធ្វើអីចឹងទៀតហើយ ។ បណ្តើរខ្ញុំដល់រោងបាយ ប្រធានកងកុមារបានហៅមីងពីរនាក់នៅរោងបាយកោសខ្យល់ឲ្យខ្ញុំ ។ ម្នាក់ចាប់ដៃជើង ម្នាក់កោសខ្ញុំដូចគេកោសជ្រូក ឡើងក្រហមពេញខ្លួនដូចគេយកខ្សែតីមកវាយលើខ្លួនខ្ញុំអីចឹង ។ កោសខ្យល់រួច ប្រធានកងកុមារនោះបានសួរខ្ញុំថា អ្អែងឃ្លានបាយទេ? ខ្ញុំឆ្លើយថា ឃ្លានណាស់បង ។ ពេលនោះ វាបានយកបាយមួយចានឲ្យខ្ញុំហូបជាមួយអំបិលតែប៉ុណ្ណោះ ។ ពេលខ្ញុំហូបបាយ ប្រធានកងកុមារនោះបានយកជើងដាក់លើកៅអីដែលខ្ញុំអង្គុយ ហើយនិយាយថា ស៊ីបាយជាមួយអំបិលឆ្ងាញ់ទេអា? ខ្ញុំមិននិយាយអ្វីទេ ដោយថាឆ្ងាញ់ណាស់ហើយផ្អែមទៀតផង ។ ថ្ងៃក្រោយមក គេឲ្យខ្ញុំឃ្វាលតែគោពីរទេ ដោយខ្លាចគោស៊ីសន្ទូងដូចលើកមុនទៀត ។ ខ្ញុំមិនហ៊ានដឹកគោឲ្យស៊ីស្មៅតាមភ្លឺស្រែទៀតឡើយ ដោយដឹកវាឲ្យស៊ីស្មៅនៅលើទីទួល មិនហ៊ានលែងខ្សែឡើយ ។ ជួនជាថ្ងៃមួយ គោផ្អើលគ្នាវាទាញដៃខ្ញុំទាំងពីរយះត្រង់ប្រឡោះមេដៃជិតដល់ថ្លើមដៃ ឈាមហូររហាម ។ ខ្ញុំស្រែកយំតែម្នាក់ឯងគ្មាននរណាជួយឡើយ គ្មានថ្នាំអ្វីដាក់ទេ មានតែខ្ញុំនោមដាក់មុខរបួសដៃទាំងពីរតែប៉ុណ្ណោះដើម្បីកុំឲ្យក្លាយ ។ ខ្ញុំយកខ្សែគោចងរុំនៅកដៃ ដឹកគោទាំងពីរមកភូមិវិញទាំងឈឺផ្សាបំផុត ។

រឿងរ៉ាវសង្ខេបខាងលើគឺជារឿងពិតទាំងស្រុងដែលសមាជិកក្រុមគ្រួសាររបស់ខ្ញុំបានស្លាប់និងរូបខ្ញុំផ្ទាល់បានទទួលទារុណកម្មយ៉ាងធ្ងន់ធ្ងរដែលខ្ញុំមិនអាចបំភ្លេចបាន ជាពិសេសរឿងរ៉ាវរបស់ខ្ញុំដែលជាក្មេងម្នាក់រងទារុណកម្មជាងក្មេងដទៃដែលរស់នៅក្នុងភូមិនោះជាមួយគ្នា ។

អាស្រ័យហេតុដូចជម្រាបខាងលើ សូមលោក-លោកស្រីប្រធានអង្គការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងប្រទេសស្នេហាយុត្តិធម៌ មានសហរដ្ឋអាមេរិក អង់គ្លេស អូស្ត្រាលី បារាំង និងប្រទេសដទៃទៀត សូមមេត្តាជំរុញឲ្យអង្គការសហប្រជាជាតិចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ ដើម្បីឲ្យតុលាការអន្តរជាតិដែលទើបបង្កើតកាលពីដើមខែកក្កដា ឆ្នាំ២០០២ យកឧក្រិដ្ឋជនដ៏សាហាវឃោរឃៅនៅរស់ទាំងអស់នោះឡើងតុលាការអន្តរជាតិ រកយុត្តិធម៌ឲ្យសមាជិកក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាពលរដ្ឋខ្មែរស្លូតត្រង់ដែលគ្មានកំហុសជាច្រើនលាននាក់ដែលពួកវាបានសម្លាប់ ។

ប្តឹងសុំឲ្យតុលាការអន្តរជាតិ៖

កោះហៅមេឧក្រិដ្ឋជនដែលមានឈ្មោះដូចខាងលើ និងជនជាប់ពាក់ព័ន្ធក្នុងរបបដ៏ឃោរឃៅនោះ ឲ្យឡើងតុលាការអន្តរជាតិឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន ព្រោះមេឧក្រិដ្ឋជនទាំងអស់នោះចាស់ៗហើយស្លាប់អស់ទៅដោយគ្មានការកាត់ទោស ។ ដាក់ទោសឲ្យបានធ្ងន់ធ្ងរមេឧក្រិដ្ឋជនដ៏សាហាវឃោរឃៅជាងពួកហ៊ីត្លែរនេះ ឲ្យស័ក្តិសមទៅអំពើដែលពួកនេះបានប្រព្រឹត្ត ។

ក្រែងពុំប្រាកដ សូមផ្តិតមេដៃស្តាំនិងរូបថតសមាជិកក្រុមគ្រួសាររបស់ខ្ញុំដែលបានស្លាប់ និងរូបថតរបស់ខ្ញុំមួយសន្លឹកទុកជាភស្តុតាង ។

ខដុង្គ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០២

ស្នាមមេដៃ

ចម្លងជូនៈ

- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅប្រទេសកម្ពុជា
- ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា
- ស្ថានទូតកាណាដាប្រចាំនៅកម្ពុជា

**សុខ សាន់ដេ**

**សម្តេចព្រះសង្ឃរាជ**

**គណៈធម្មយុត្តិកនិកាយនៃកម្ពុជា**

# សូមចម្រើនពរ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លោកបណ្ឌិត ឆាំង យុ ជាទីស្រលាញ់រាប់អាន!

អាត្មាភាពសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកបណ្ឌិត ដែលបានថ្វាយនូវទស្សនាវដ្តី«ស្វែងរកការពិត» លេខ៣៨ ចំនួន២០ច្បាប់និងសៀវភៅ«មុនដំបូងខ្មែរក្រហមសម្លាប់ប៉ាខ្ញុំ» ចំនួនមួយក្បាល ដើម្បីតម្កល់ទុកក្នុងបណ្ណាល័យនិងចែកជូនពុទ្ធបរិស័ទ ។

អាត្មាភាពសូមថ្លែងជូននូវការកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះវិរិយៈព្យាយាម ដែលលោកបណ្ឌិតបានខិតខំស្វែងរកការពិត ជូនដល់ជនរួមជាតិខ្មែរយើងនិងជនរួមលោកទាំងមូលដែលត្រូវការចង់ដឹងនិងចង់យល់អំពីសកម្មភាពរបស់ពួកខ្មែរនិយមលទ្ធិកុម្មុយនិស្ត«ខ្មែរក្រហមនាសម័យកាលមួយនោះ» ដើម្បីជាការឆ្លុះបង្ហាញនូវការពិតមួយ ដែលមិនអាចបដិសេធបានចំពោះមុខប្រវត្តិសាស្ត្រនៃមនុស្សលោក ហើយក៏ដើម្បីនាំគ្នាគេចវៀសឲ្យផុត ឬក៏ថានាំគ្នាបណ្តេញឲ្យឃ្លាតឆ្ងាយចេញទៅនូវអ្វីៗដែលជាអពមង្គលដល់ជីវិតរបស់គេ យើងគ្រប់គ្នាដែលប្រាថ្នានូវសុភមង្គលក្នុងលោកមនុស្សដ៏ល្អបំផុតដែលមិនមានអ្វីប្រៀបបានឡើយនោះ ។

សូមលោកបណ្ឌិតទទួលនូវសេចក្តីរាប់អានក្នុងធម៌ដ៏ខ្ពង់ខ្ពស់អំពីអាត្មាភាព ។

វត្តបទុមវតី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០២

**សម្តេចព្រះសង្ឃរាជ បួរ គ្រី**

# ពីភូមិបងប្អូនចាមឥស្លាម

យើងខ្ញុំ អ៊ីមាំម៉ាស្ថិត ភូឈួយ តួន ព្រមទាំងប្រជាពលរដ្ឋទាំងអស់នៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក ឆាំង យុ នាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជានិងលោកស្រី វេនី ខាវហៀល ដែលលោកនិងលោកស្រីបានចាប់អារម្មណ៍និងយកចិត្តទុកដាក់ស្វែងរកជំនួយសម្រាប់កសាងព្រះវិហារក្នុងភូមិយើងខ្ញុំ ។ នេះគឺជាការយកចិត្តទុកដាក់មួយដ៏ថ្លៃថ្លារបស់លោកនិងលោកស្រី ដែលធ្វើឲ្យយើងខ្ញុំទាំងអស់មានក្តីរីករាយនិងត្រេកអរជាខ្លាំងចំពោះទឹកចិត្តអាណិតស្រឡាញ់



របស់លោកនិងលោកស្រីចំពោះភូមិដ្ឋានយើងខ្ញុំដែលតែងតែទទួលនូវការរងគ្រោះគ្រប់បែបយ៉ាងតាំងពីរបបខ្មែរក្រហមមកនោះ ។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរឲ្យលោក ឆាំង យុ ព្រមទាំងក្រុមគ្រួសារ លោកស្រី វេនី ខាវហៀល ព្រមទាំងលោក អ៊ីសា ឧស្មាន សូមឲ្យអ្នកទាំងអស់ទទួលបាននូវសេចក្តីសុខសប្បាយនិងជ័យជម្នះគ្រប់ពេលវេលា ។

ធ្វើនៅភូមិទី៥ , ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២

**ស៊ុះ ពន់យ៉ាមីន**




«មេដឹកនាំខ្មែរក្រហមរួមមាន អៀង សារី, ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធិ មិនគួរទទួលបានការសន្តោសប្រណីទោសពីគណៈកម្មការស្វែងរកការពិតណាមួយឡើយ ។ គណៈកម្មការស្វែងរកការពិតដែលរៀបចំឡើងនៅបណ្តាប្រទេសនានាគឺសម្រាប់ធ្វើកិច្ចការជាមួយនឹងកម្មាភិបាលថ្នាក់ក្រោមតែប៉ុណ្ណោះ ។ កម្មាភិបាលថ្នាក់កណ្តាលនិងថ្នាក់ក្រោមដែលមានចំនួនរហូតដល់ទៅរាប់ពាន់នាក់ គឺមិនអាចនិងមិនគួរត្រូវបានយកមកវិនិច្ឆ័យទោសទេ ដោយហេតុថា ការដាក់ទោសអ្នកទាំងអស់នេះនឹងនាំមកនូវការបែកបាក់ប្រេះឆានៅក្នុងសង្គម» ។ ឆាំង យុ

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃ ដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 36, December 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government,Embassy of Switzerland and the Royal Netherlands Government, *The Hague*.